# មាតិកាធម៌

ល.រ. ទំព័រ


**១_ដែនក្សរ កម្មាសធម្មនិគម** .................... ១
_សតិប្បដ្ឋានសូត្រ .................................. ១
**២_នគរសង្កស្ស** ................................. ៤
_រំលឹកព្រះអភិធម្ម .................................. ៥
**៣_កោសម្ពី ឃោសិតារាម** .................... ២២
**៤_ពារាណសី_ សារនាថ** ..................... ២៤
_ព្រះធម្មចក្កប្បវត្តនសូត្រ .......................... ៣០
_អនត្តលក្ខណសូត្រ ................................. ៥១
_ព្រះនាមព្រះពុទ្ធ ២៨ ព្រះអង្គ ...................... ៦៦
**៥_ពុទ្ធគយា ឧរុវេលាសេនានិគម** ............. ៧១
_ជយបរិត្តគាថា ....................................... ៧១
_ពុទ្ធោ នាគលំពោធិព្រឹក្ស ........................... ៧៤
_សម្ពុទ្ធេ ............................................. ៧៨
_ពុទ្ធជយមង្គល ...................................... ៨០
_បច្ចយាការ ........................................... ៨៨
_ព្រះពុទ្ធឧទានក្នុងសប្តាហ៍ទី ៥ ...................... ៩៦
_អាយាចនសូត្រ ...................................... ៩៧
_នមស្ការ បូជាសត្តមហាថាន ...................... ១០៦
_អាទិត្តបរិយាយសូត្រ ............................... ១០៩
_ប្រវត្តិសង្ខេបបងប្អូន ៣ នាក់ ....................... ១២២
_មហាកស្សបត្ថេរគាថា .............................. ១២៨
_ប្រវត្តិសង្ខេបព្រះមហាកស្សបត្ថេរ ................ ១៣៧
**៦_មហានគររមគធៈ** ............................. ១៤១
_នគរមគធៈ ក្រុងរាជគ្រឹះ .......................... ១៤១
_ហេតុការណ៍សំខាន់ៗ ............................. ១៥៣
_គាថាព្រះអានន្ទត្ថេរ ................................ ១៦៤
_ទីឃនខសូត្រ ........................................ ១៧២
_ប្រវត្តិសង្ខេបរបស់ពេទ្យជីវកៈ ..................... ១៧៨
_ភាសិតោវាទសង្ខេប ............................... ១៨៨
_រឿងធាតុវិវណ្ណប្រេត .............................. ១៩៧
_តិរោកុឌ្ឌសូត្រ ....................................... ២០០

-គាថានៃព្រះសារីបុត្ត ............................ ២០៦
-គាថាព្រះមហាមោគ្គល្លាន ....................... ២១៦
**៧-នគរវេសាលី** ................................ ២៣១
-ក្រុងវេសាលី ...................................... ២៣១
-រតនសូត្រ ........................................ ២៣២
**៨-បាវា-កុសិនារា** ............................ ២៥០
-ព្រះគាថាកន្លែងផ្សេងៗ .......................... ២៦២
-ធាតុចេតិយនមស្ការ ............................. ២៦៩
**៩-កបិលពស្តុនិងរាមគ្រាម** ..................... ២៧៦
-ធម្មនិយាម ........................................ ២៧៦
**១០-ក្រុងសាវត្ថី** ................................ ២៨៥
-មង្គលសូត្រ ....................................... ២៨៥
-ឯតទគ្គបុគ្គល ...................................... ២៩១
-ធម្មនិយាម ៣០ របស់ព្រះពុទ្ធគ្រប់ព្រះអង្គ ........ ៣១៣





សៀវភៅ **ធម្មយាត្រាទៅកាន់ដែនពុទ្ធភូមិ** នេះ សម្រេចឡើងដោយមនោសញ្ចេតនាដ៏ជ្រាលជ្រៅដែលខ្ញុំព្រះករុណា ខ្ញុំបាទធ្លាប់បានទៅដល់ទីនោះ ហើយនឹករលឹកឃើញដល់សម័យពុទ្ធកាលដែលកន្លងផុតទៅ នៅសល់តែស្ថានទីជាទីនឹករលឹក ។

ព្រះពុទ្ធសាសនា មានអាយុវែងឆ្ងាយមកដល់សព្វថ្ងៃនេះ ចាប់តាំងពីព្រះពុទ្ធអង្គទ្រង់បរិនិព្វានទៅ ដោយមនុស្សជំនាន់ក្រោយៗ មានការរក្សាទ្រទ្រង់បន្តជាប់មកមិនដាច់ ។ ដោយសទ្ធាជឿមាំក្នុងពាក្យទូន្មានរបស់ព្រះអង្គ យ៉ាងនេះហើយ ទើបធ្វើឱ្យព្រះពុទ្ធសាសនាឋិតនៅជាទីពឹងទីរលឹកដ៏ប្រសើរ សម្រាប់ពុទ្ធសាសនិកជន និងដើម្បីបង្ហាននាំយកមកជាគោលក្នុងការរៀបចំដំណើរជីវិត ប្រព្រឹត្តទៅបានយ៉ាងល្អបំផុត រហូតមក ។

**ជីវិតដែលគ្រប់គ្រងដោយព្រះធម៌ ជាជីវិតសុខស្ងប់**

សូមឱ្យព្រះធម៌ស្ថិតក្នុងចិត្តរបស់ពុទ្ធបរិស័ទជានិច្ចនិរន្តរ៍
សូមចិត្តនៃពុទ្ធបរិស័ទ មានព្រះធម៌ជាអាហារប្រចាំថ្ងៃ ។

ថ្ងៃសៅរ៍ ៥ កើត ខែអាសាឍ ព.ស.២៥៥៣

**ខ្ញុំព្រះករុណា ខ្ញុំបាទ**

**ប៊ុត សាវង្ស**

## ដែនកុរុ កម្មាសធម្មនិគម

# សតិប្បដ្ឋានសូត្រ

### ឧទ្ទេសវារកថា

**ឯវម្មេ សុតំ** សូត្រនេះឈ្មោះ សតិប្បដ្ឋានសូត្រ ដែលខ្ញុំអានន្ទ បានស្ដាប់មកយ៉ាងនេះថា :

**ឯកំ សមយំ ភគវា កុរូសុ វិហរតិ កម្មាសធម្មំ នាម កុរូនំ និគមោ** សម័យមួយ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់គង់នៅក្នុងដែនកុរុ ទ្រង់អាស្រ័យនៅកម្មាសធម្មនិគម នៃអ្នកដែនកុរុទាំងឡាយ ជាទីគោចរ ។

**តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ** ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយអើយ

**ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ** ភិក្ខុទាំងឡាយនោះ ទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស ។





**ភគវា ឯតទវោច ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ ចត្តារោ សតិប្បដ្ឋានា** ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ព្រះពុទ្ធដីកានេះថា ម្នាលភិក្ខុទាំងឡាយ ផ្លូវគឺសតិប្បដ្ឋានទាំងឡាយ ៤ នេះ ជាផ្លូវមូលតែមួយ ( ប្រព្រឹត្តទៅ ) ដើម្បីសេចក្ដីស្អាតវិសេសដល់សត្វទាំងឡាយ ដើម្បីកន្លងបង់នូវសោកនិងខ្សឹកខ្សួលរំជួលចិត្តទាំងឡាយ ដើម្បីអស្ដង្គតរលត់ទៅនៃទុក្ខនិងទោមនស្សទាំងឡាយ ដើម្បីដល់នូវអរិយមគ្គ ជាធម៌ស្រោចស្រង់សត្វ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ។

**កតមេ ចត្តារោ** សតិប្បដ្ឋានទាំងឡាយ ៤ គឺអ្វីខ្លះ ?

**ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេសប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់បណ្ដេញបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

**វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី**

**សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** ពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់បណ្តេញបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។

**ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** ពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្ត មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេសប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់បណ្តេញបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

**ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេសប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់បណ្តេញបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

**( ឧទ្ទេសវារកថា និដ្ឋិតា )**

*-**វត្តខ្មែរក្សេត្ររដ្ឋខេមរារាម** ជាទីរីករាយនៃពុទ្ធបរិស័ទ ។





# នគរសង្កស្សជាទីដែលព្រះពុទ្ធទ្រង់យាងចុះពីឋានតាវត្តិង្ស

ព្រះបរមសាស្តា ទ្រង់ត្រាស់នឹងព្រះមហាមោគ្គល្លាន ដូច្នេះថា ៖ ម្នាលមោគ្គល្លាន ក្នុងថ្ងៃទី ៧ បន្តពីថ្ងៃនេះទៅ តថាគតនឹងចុះនៅត្រង់ទ្វារនគរសង្កស្ស ក្នុងថ្ងៃមហាបវារណា អ្នកណាប្រាថ្នានឹងជួបតថាគត ក៏ចូលទៅកាន់ទីនោះចុះ ។

(អដ្ឋកថា ធម្មបទ)

*-នគរសង្កស្ស នៅទិសនិរតីនៃនគរសាវត្ថី ប្រមាណ ៣០ យោជន៍ពីសាវត្ថី ។

*-ជណ្តើរមាសនៅខាងស្តាំ សម្រាប់ពួកទេវតា ជណ្តើរប្រាក់នៅខាងឆ្វេង សម្រាប់មហាព្រហ្មទាំងឡាយ ជណ្តើរកែវនៅកណ្តាល សម្រាប់ព្រះតថាគត ។

*-ទីដែលព្រះបាទខាងស្តាំទ្រង់ប្រតិស្ឋាននោះ ឈ្មោះថា **អចលចេតិយស្ថាន** ជាទីតែមួយដែលព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គទ្រង់យាងចុះជាន់ ។

*-ធម្មាភិសម័យ (មគ្គផល) កើតមានដល់សត្វប្រមាណ

៣០ កោដិ ។ ភិក្ខុ ៥០០ អង្គជាសទ្ធិវិហារិក របស់ព្រះសារីបុត្ត តាំងនៅហើយ ក្នុងព្រះអរហត្ត ។

(អដ្ឋកថា ធម្មបទ)

*-ព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គទ្រង់មិនលះបង់នូវស្ថាន ៤ កន្លែងគឺ

១-ពោធិបល្ល័ង្ក កន្លែងទ្រង់ត្រាស់ដឹង ។

២-ទីសម្តែងព្រះធម្មចក្កប្បវត្តនសូត្រ ។

៣-ទីជាន់ព្រះបាទជាដំបូង ដែលទ្រង់យាងចុះអំពីឋានត្រ័យត្រិង្ស ។

៤-ជើងគ្រែទាំង ៤ ក្នុងព្រះគន្ធកុដិ នាវត្តជេតពន ។

(អដ្ឋកថា ពុទ្ធវង្ស)

## រំលឹកព្រះធម៌អភិធម្ម

## ធម្មសង្គណី

(បិដកលេខ ៧៨ , ទំព័រ ១-៣)

កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា សុខាយ វេទនាយ សម្បយុត្តា ធម្មា ទុក្ខាយ វេទនាយ





សម្បយុត្តា ធម្មា អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ធម្មា វិបាកា ធម្មា វិបាកធម្មធម្មា នេវ វិបាកនវិបាក-ធម្មធម្មា ឧបាទិន្នុបាទានិយា ធម្មា អនុបាទិន្នុបាទានិយា ធម្មា អនុបាទិន្នានុបាទានិយា ធម្មា សង្កិលិដ្ឋសង្កិលេសិកា ធម្មា អសង្កិលិដ្ឋសង្កិលេសិកា ធម្មា អសង្កិលិដ្ឋាសង្កិលេសិកា ធម្មា សវិតក្កសវិចារា ធម្មា អវិតក្កវិចារមត្តា ធម្មា អវិតក្កាវិចារា ធម្មា បីតិសហគតា ធម្មា សុខសហគតា ធម្មា ឧបេក្ខាសហគតា ធម្មា ទស្សនេន បហាតព្វា ធម្មា ភាវនាយ បហាតព្វា ធម្មា នេវ ទស្សនេន ន ភាវនាយ បហាតព្វា ធម្មា ទស្សនេន បហាតព្វហេតុកា ធម្មា ភាវនាយ បហាតព្វហេតុកា ធម្មា នេវ ទស្សនេន ន ភាវនាយ បហាតព្វហេតុកា ធម្មា អាចយគាមិនោ ធម្មា អបចយគាមិនោ ធម្មា នេវាចយគាមិនោ នាបចយគា-មិនោ ធម្មា សេក្ខា ធម្មា អសេក្ខា ធម្មា នេវសេក្ខានាសេក្ខា ធម្មា បរិត្តា ធម្មា មហគ្គតា ធម្មា អប្បមាណា ធម្មា បរិត្តារម្មណា ធម្មា មហគ្គតារម្មណា ធម្មា អប្បមា-ណារម្មណា ធម្មា ហីនា ធម្មា មជ្ឈិមា ធម្មា បណីតា

ធម្មា មិច្ឆត្តនិយតា ធម្មា សម្មត្តនិយតា ធម្មា អនិយតា ធម្មា មគ្គារម្មណា ធម្មា មគ្គហេតុកា ធម្មា មគ្គាធិបតិនោ ធម្មា ឧប្បន្នា ធម្មា អនុប្បន្នា ធម្មា ឧប្បាទិនោ ធម្មា អតីតា ធម្មា អនាគតា ធម្មា បច្ចុប្បន្នា ធម្មា អតីតា-រម្មណា ធម្មា អនាគតារម្មណា ធម្មា បច្ចុប្បន្នារម្មណា ធម្មា អជ្ឈត្តា ធម្មា ពហិទ្ធា ធម្មា អជ្ឈត្តពហិទ្ធា ធម្មា អជ្ឈត្តារម្មណា ធម្មា ពហិទ្ធារម្មណា ធម្មា អជ្ឈត្តពហិទ្ធា-រម្មណា ធម្មា សនិទស្សនសប្បដិឃា ធម្មា អនិទស្សន-សប្បដិឃា ធម្មា អនិទស្សនាប្បដិឃា ធម្មា ។

ពាវីសតិ តិកមាតិកា

ធម្មសង្គណិប្បករណំ នាម សមត្តំ ១

## វិភង្គ

ក្នុងអដ្ឋកថា

( តទនន្តរំ វិភង្គប្បករណំ នាមេតំ )

ខន្ធវិភង្គោ អាយតនវិភង្គោ ធាតុវិភង្គោ សច្ចវិ-ភង្គោ ឥន្ទ្រិយវិភង្គោ បច្ចយាការវិភង្គោ សតិប្បដ្ឋានវិភង្គោ





សម្មប្បធានវិភង្គោ ឥទ្ធិបាទវិភង្គោ ពោជ្ឈង្គវិភង្គោ មគ្គ-វិភង្គោ ឈានវិភង្គោ អប្បមញ្ញាវិភង្គោ សិក្ខាបទវិភង្គោ បដិសម្ភិទាវិភង្គោ ញាណវិភង្គោ ខុទ្ទកវត្ថុវិភង្គោ ធម្ម-ហទយវិភង្គោតិ ។

អដ្ឋារសវិធេន វិភត្តំ វិភង្គប្បករណំ នាម សមត្តំ។

## ធាតុកថា

ក្នុងអដ្ឋកថា

( តទនន្តរំ ធាតុកថាបករណំ នាមេតំ )

សង្គហោ អសង្គហោ សង្គហិតេន អសង្គហិតំ អ-សង្គហិតេន សង្គហិតំ សង្គហិតេន សង្គហិតំ អសង្គហិតេន អសង្គហិតំ សម្បយោគោ វិប្បយោគោ សម្បយុត្តេន វិប្បយុត្តំ វិប្បយុត្តេន សម្បយុត្តំ សម្បយុត្តេន សម្បយុត្តំ វិប្បយុត្តេន វិប្បយុត្តំ សង្គហិតេន សម្បយុត្តំ វិប្បយុត្តំ សម្បយុត្តេន សង្គហិតំ អសង្គហិតំ អសង្គហិតេន សម្បយុត្តំ វិប្បយុត្តំ វិប្បយុត្តេន សង្គហិតំ អសង្គហិតន្តិ ។

ចុទ្ទសវិធេន វិភត្តំ ធាតុកថាបករណំ នាម សមត្តំ។

# បុគ្គលប្បញ្ញត្តិ

ក្នុងអដ្ឋកថា

( តទនន្តរំ បុគ្គលប្បញ្ញត្តិប្បករណំ នាមេសា )

ខន្ធប្បញ្ញត្តិ អាយតនប្បញ្ញត្តិ ធាតុប្បញ្ញត្តិ សច្ចប្បញ្ញត្តិ ឥន្ទ្រិយប្បញ្ញត្តិ បុគ្គលប្បញ្ញត្តីតិ ។

ឆវិធេន វិភត្តំ បុគ្គលប្បញ្ញត្តិប្បករណំ នាម សមត្តំ។

# កថាវត្ថុ

ក្នុងអដ្ឋកថា

( តទនន្តរំ កថាវត្ថុប្បករណំ នាមេតំ )

សកវាទិបញ្ចសុត្តសតានិ បរិវាទិបញ្ចសុត្តសតានីតិ សុត្តសហស្សំ សមោធានេត្វាន វិភត្តំ កថាវត្ថុប្បករណំ នាម សមត្តំ ។

# យមក

ក្នុងអដ្ឋកថា

( តទនន្តរំ យមកប្បករណំ នាមេតំ )

មូលយមកំ ខន្ធយមកំ អាយតនយមកំ ធាតុយមកំ





សច្ចយមកំ សង្ខារយមកំ អនុសយយមកំ ចិត្តយមកំ ធម្មយមកំ ឥន្ទ្រិយយមកន្តិ ។

ទសវិធេន វិភត្តំ យមកប្បករណំ នាម សមត្តំ ។

# បដ្ឋាន

ក្នុងអដ្ឋកថា

( តទនន្តរំ មហាបដ្ឋានប្បករណំ នាមេតំ )

ហេតុប្បច្ចយោ អារម្មណប្បច្ចយោ អធិបតិប្បច្ចយោ អនន្តរប្បច្ចយោ សមនន្តរប្បច្ចយោ សហជាតប្បច្ចយោ អញ្ញមញ្ញប្បច្ចយោ និស្សយប្បច្ចយោ ឧបនិស្សយប្បច្ចយោ បុរេជាតប្បច្ចយោ បច្ឆាជាតប្បច្ចយោ អាសេវនប្បច្ចយោ កម្មប្បច្ចយោ វិបាកប្បច្ចយោ អាហារប្បច្ចយោ ឥន្ទ្រិយប្បច្ចយោ ឈានប្បច្ចយោ មគ្គប្បច្ចយោ សម្បយុត្តប្បច្ចយោ វិប្បយុត្តប្បច្ចយោ អត្ថិប្បច្ចយោ នត្ថិប្បច្ចយោ វិគតប្បច្ចយោ អវិគតប្បច្ចយោតិ ។

បច្ចយវសេន តា ចតុវីសតិវិធេន វិភត្តំ មហាបដ្ឋានប្បករណំ នាម សមត្តំ ។

# ខន្ធវិភង្គ

(បិដកលេខ ៨០ , ទំព័រ ១...)

## ( តទនន្តរំ វិភង្គប្បករណំ នាមេតំ )

បញ្ចក្ខន្ធា រូបក្ខន្ធោ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ។ តត្ថ កតមោ រូបក្ខន្ធោ ។ យំ កិញ្ចិ រូបំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ រូបក្ខន្ធោ ។ តត្ថ កតមោ វេទនាខន្ធោ ។ យា កាចិ វេទនា អតីតានាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ វេទនាខន្ធោ ។ តត្ថ កតមោ សញ្ញាខន្ធោ ។ យា កាចិ សញ្ញា អតីតានាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ



វុច្ចតិ សញ្ញាខន្ធោ ។ តត្ថ កតមោ សង្ខារក្ខន្ធោ ។ យេ កេចិ សង្ខារា អតីតានាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យេ ទូរេ សន្តិកេ វា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ សង្ខារក្ខន្ធោ ។ តត្ថ កតមោ វិញ្ញាណក្ខន្ធោ ។ យំ កិញ្ចិ វិញ្ញាណំ អតីតានា-គតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ វិញ្ញាណក្ខន្ធោ។ (អយំ ខន្ធវិភង្គោតិ អដ្ឋារសវិធេន វិភត្តំ វិភង្គប្បករណំ នាម សមត្តំ) ។

# ធាតុកថា

(បិដកលេខ ៨៣ , ទំព័រ ១-២)

## ( តទនន្តរំ ធាតុកថាបករណំ នាមេតំ )

សង្គហោ អសង្គហោ សង្គហិតេន អសង្គហិតំ អសង្គហិតេន សង្គហិតំ សង្គហិតេន សង្គហិតំ អសង្គហិតេន

អសង្គហិតំ សម្បយោគោ វិប្បយោគោ សម្បយុត្តេន វិប្បយុត្តំ វិប្បយុត្តេន សម្បយុត្តំ សម្បយុត្តេន សម្បយុត្តំ វិប្បយុត្តេន វិប្បយុត្តំ សង្គហិតេន សម្បយុត្តំ វិប្បយុត្តំ សម្បយុត្តេន សង្គហិតំ អសង្គហិតំ អសង្គហិតេន សម្បយុត្តំ វិប្បយុត្តំ វិប្បយុត្តេន សង្គហិតំ អសង្គហិតន្តិ បញ្ចក្ខន្ធា ទ្វាទសាយតនានិ អដ្ឋារស ធាតុយោ ចត្តារិ សច្ចានិ ពាវីសតិន្ទ្រិយានិ បដិច្ចសមុប្បាទោ ចត្តារោ សតិប្បដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា ចត្តារិ ឈានានិ ចតស្សោ អប្បមញ្ញាយោ បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ ។ ផស្សោ វេទនា សញ្ញា ចេតនា ចិត្តំ អធិមោក្ខោ មនសិការោ ។ តីហិ សង្គហោ តីហិ អសង្គហោ ចតូហិ សម្បយោគោ ចតូហិ វិប្បយោគោ សភាគោ វិសភាគោ សព្វាបិ ធម្មសង្គណិ ធាតុកថាយ មាតិកា ។

( នយមាតិកាតិ បញ្ចវិធេន វិភត្តំ ធាតុកថាបករណំ នាម សមត្តំ ) ។



# បុគ្គលប្បញ្ញត្តិ

(បិដកលេខ ៨៣ ,ទំព័រ ២១១_២១៦)

( តទនន្តរំ បុគ្គលប្បញ្ញត្តិប្បករណំ នាមេសា )

ខន្ធប្បញ្ញត្តិ អាយតនប្បញ្ញត្តិ ធាតុប្បញ្ញត្តិ សច្ចប្បញ្ញត្តិ ឥន្ទ្រិយប្បញ្ញត្តិ បុគ្គលប្បញ្ញត្តីតិ ។

កិត្តាវតា ( ខន្ធានំ ) ខន្ធប្បញ្ញត្តិ ។ យាវតា បញ្ចក្ខន្ធា រូបក្ខន្ធោ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ឯត្តាវតា ខន្ធានំ ខន្ធប្បញ្ញត្តិ ។

កិត្តាវតា ( អាយតនានំ ) អាយតនប្បញ្ញត្តិ ។ យាវតា ទ្វាទសាយតនានិ ចក្ខាយតនំ រូបាយតនំ សោតាយតនំ សទ្ទាយតនំ ឃានាយតនំ គន្ធាយតនំ ជិវ្ហាយតនំ រសាយតនំ កាយាយតនំ ផោដ្ឋព្វាយតនំ មនាយតនំ ធម្មាយតនំ ឯត្តាវតា អាយតនានំ អាយតនប្បញ្ញត្តិ ។

កិត្តាវតា ( ធាតូនំ ) ធាតុប្បញ្ញត្តិ ។ យាវតា អដ្ឋារស ធាតុយោ ចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណធាតុ សោតធាតុ សទ្ទធាតុ សោតវិញ្ញាណធាតុ ឃានធាតុ

គន្ធធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាធាតុ រសធាតុ ជិវ្ហាវិញ្ញាណធាតុ កាយធាតុ ផោដ្ឋព្វធាតុ កាយវិញ្ញាណធាតុ មនោធាតុ ធម្មធាតុ មនោវិញ្ញាណធាតុ ឯត្តាវតា ធាតូនំ ធាតុប្បញ្ញត្តិ ។

កិត្តាវតា (សច្ចានំ) សច្ចប្បញ្ញត្តិ ។ យាវតា ចត្តារិ សច្ចានិ ទុក្ខសច្ចំ សមុទយសច្ចំ និរោធសច្ចំ មគ្គសច្ចំ ឯត្តាវតា សច្ចានំ សច្ចប្បញ្ញត្តិ ។

កិត្តាវតា ( ឥន្ទ្រិយានំ ) ឥន្ទ្រិយប្បញ្ញត្តិ ។ យាវតា ពាវីសតិន្ទ្រិយានិ ចក្ខុន្ទ្រិយំ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ មនិន្ទ្រិយំ ឥត្ថិន្ទ្រិយំ បុរិសិន្ទ្រិយំ ជីវិតិន្ទ្រិយំ សុខិន្ទ្រិយំ ទុក្ខិន្ទ្រិយំ សោមនស្សិន្ទ្រិយំ ទោមនស្សិន្ទ្រិយំ ឧបេក្ខិន្ទ្រិយំ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ អនញ្ញតញ្ញស្សាមីតិន្ទ្រិយំ អញ្ញិន្ទ្រិយំ អញ្ញាតាវិន្ទ្រិយំ ឯត្តាវតា ឥន្ទ្រិយានំ ឥន្ទ្រិយប្បញ្ញត្តិ ។

កិត្តាវតា ( បុគ្គលានំ ) បុគ្គលប្បញ្ញត្តិ ។ សមយវិមុត្តោ អសមយវិមុត្តោ កុប្បធម្មោ អកុប្បធម្មោ បរិ-





ហានធម្មោ អបរិហានធម្មោ ចេតនាភព្វោ អនុរក្ខនាភព្វោ បុថុជ្ជនោ គោត្រភូ ភយូបរតោ អភយូបរតោ ភព្វាគមនោ អភព្វាគមនោ និយតោ អនិយតោ បដិបន្នកោ ផលេដ្ឋិតោ សមសីសី ឋិតកប្បី អរិយោ អនរិយោ សេក្ខោ អសេក្ខោ នេវ សេក្ខោ នាសេក្ខោ តេវិជ្ជោ ឆឡភិញ្ញោ សម្មាសម្ពុទ្ធោ បច្ចេកសម្ពុទ្ធោ ឧភតោភាគវិមុត្តោ បញ្ញាវិមុត្តោ កាយសក្ខី ទិដ្ឋិប្បត្តោ សទ្ធាវិមុត្តោ ធម្មានុសារី សទ្ធានុសារី សត្តក្ខត្តុំបរមោ កោលំកោលោ ឯកពីជី សកទាគាមី អនាគាមី អន្តរាបរិនិព្វាយី ឧបហច្ចបរិនិព្វាយី អសង្ខារបរិនិព្វាយី សសង្ខារបរិនិព្វាយី ឧទ្ធំសោតោ អកនិដ្ឋគាមី សោតាបន្នោ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ សកទាគាមី សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ អនាគាមី អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ អរហា អរហត្តផលសច្ឆិកិរិយាយ បដិបន្នោតិ ។

អយំ ខន្ធប្បញ្ញត្តាតិ ឆវិធេន វិភត្តំ បុគ្គលប្បញ្ញត្តិប្បករណំ នាម សមត្តំ ។

# កថាវត្ថុ

(បិដកលេខ ៨៤ , ទំព័រ ១_២ )

## ( តទនន្តរំ កថាវត្ថុប្បករណំ នាមេតំ )

បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមដ្ឋេនាតិ។ អាមន្តា។ យោ សច្ចិកដ្ឋោ បរមដ្ឋោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមដ្ឋេនាតិ ។

ន ហេវំ វត្តព្វេ ។ អាជានាហិ និគ្គហំ ហញ្ចិ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមដ្ឋេន តេន វត រេ វត្តព្វេ យោ សច្ចិកដ្ឋោ បរមដ្ឋោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមដ្ឋេនាតិ ។ យំ តត្ថ វទេសិ វត្តព្វេ ខោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមដ្ឋេន នោ ច វត្តព្វេ យោ សច្ចិកដ្ឋោ បរមដ្ឋោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមដ្ឋេនាតិ មិច្ឆា ។ នោ ចេ បន វត្តព្វេ យោ សច្ចិកដ្ឋោ បរមដ្ឋោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមដ្ឋេនាតិ នោ វត រេ វត្តព្វេ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមដ្ឋេនាតិ ។ យំ តត្ថ





វទេសិ វត្តព្វេ ខោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមដ្ឋេន នោ ច វត្តព្វេ យោ សច្ចិកដ្ឋោ បរមដ្ឋោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមដ្ឋេនាតិ មិច្ឆា ។

### អនុលោមបញ្ចកំ

សកវាទិបញ្ចសុត្តសតានិ បរវាទិបញ្ចសុត្តសតានីតិ សុត្តសហស្សំ សមោធានេត្វាន វិភត្តំ កថាវត្ថុប្បករណំ នាម សមត្តំ ។

# យមក

(បិដកលេខ ៨៧ , ទំព័រ ១_៣ )

## ( តទនន្តរំ យមកប្បករណំ នាមេតំ )

យេកេចិ កុសលា ធម្មា សព្វេ តេ កុសលមូលា យេ វា បន កុសលមូលា សព្វេ តេ ធម្មា កុសលា ។ យេកេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលា យេ វា បន កុសលមូលេន ឯកមូលា សព្វេ តេ ធម្មា កុសលា ។ យេកេចិ កុសលមូលេន ឯកមូលា ធម្មា សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលា យេ វា បន កុសលមូលេន អញ្ញមញ្ញមូលា សព្វេ តេ ធម្មា

កុសលា ។ យេកេចិ កុសលា ធម្មា សព្វេ តេ កុសលមូលមូលា យេ វា បន កុសលមូលមូលា សព្វេ តេ ធម្មា កុសលា ។ យេកេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលមូលា យេ វា បន កុសលមូលេន ឯកមូលមូលា សព្វេ តេ ធម្មា កុសលា ។ យេកេចិ កុសលមូលេន ឯកមូលមូលា ធម្មា សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលមូលា យេ វា បន កុសលមូលេន អញ្ញមញ្ញមូលមូលា សព្វេ តេ ធម្មា កុសលា ។ យេកេចិ កុសលា ធម្មា សព្វេ តេ កុសលមូលកា យេ វា បន កុសលមូលកា សព្វេ តេ ធម្មា កុសលា ។ យេកេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលកា យេ វា បន កុសលមូលេន ឯកមូលកា សព្វេ តេ ធម្មា កុសលា ។ យេកេចិ កុសលមូលេន ឯកមូលកា ធម្មា សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលកា យេ វា បន កុសលមូលេន អញ្ញមញ្ញមូលកា សព្វេ តេ ធម្មា កុសលា ។ យេកេចិ កុសលា ធម្មា សព្វេ តេ កុសលមូលមូលកា យេ វា បន កុសលមូលមូលកា សព្វេ តេ ធម្មា





កុសលា ។ យេកេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលមូលកា យេ វា បន កុសលមូលេន ឯកមូលមូលកា សព្វេ តេ ធម្មា កុសលា ។ យេកេចិ កុសលមូលេន ឯកមូលមូលកា ធម្មា សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលមូលកា យេ វា បន កុសលមូលេន អញ្ញមញ្ញមូលមូលកា សព្វេ តេ ធម្មា កុសលាតិ ។

មូលំ ហេតុនិទានញ្ច សម្ភវោ បភវេន ន ច សមុដ្ឋានាហារារម្មណា បច្ចយោ សមុទយេន ចាតិ ។

មូលយមកាទិ ទសយមកប្បដិមណ្ឌិតំ យមកប្បករណំ នាម សមត្តំ ។

## បដ្ឋាន

(បិដកលេខ ៩៤ , ទំព័រ ១...)

### ( តទនន្តរំ មហាបដ្ឋានប្បករណំ នាមេតំ )

ហេតុប្បច្ចយោ អារម្មណប្បច្ចយោ អធិបតិប្បច្ចយោ អនន្តរប្បច្ចយោ សមនន្តរប្បច្ចយោ សហជាតប្បច្ចយោ អញ្ញមញ្ញប្បច្ចយោ និស្សយប្បច្ចយោ ឧបនិស្សយប្បច្ចយោ

បុរេជាតប្បច្ចយោ បច្ឆាជាតប្បច្ចយោ អាសេវនប្បច្ចយោ កម្មប្បច្ចយោ វិបាកប្បច្ចយោ អាហារប្បច្ចយោ ឥន្ទ្រិយប្បច្ចយោ ឈានប្បច្ចយោ មគ្គប្បច្ចយោ សម្បយុត្តប្បច្ចយោ វិប្បយុត្តប្បច្ចយោ អត្ថិប្បច្ចយោ នត្ថិប្បច្ចយោ វិគតប្បច្ចយោ អវិគតប្បច្ចយោ ។

តិកញ្ច បដ្ឋានវរំ ទុកុត្តមំ ទុកត្តិកញ្ចេវ តិកទុកញ្ច តិកត្តិកញ្ចេវ ទុកទុកញ្ច ឆ អនុលោមម្ហិ នយា សុគម្ភិរា។ តិកញ្ច បដ្ឋានវរំ ទុកុត្តមំ ទុកត្តិកញ្ចេវ តិកទុកញ្ច តិកត្តិកញ្ចេវ ទុកទុកញ្ច ឆ បច្ចនីយម្ហិ នយា សុគម្ភិរា ។ តិកញ្ច បដ្ឋានវរំ ទុកុត្តមំ ទុកត្តិកញ្ចេវ តិកទុកញ្ច តិកត្តិកញ្ចេវ ទុកទុកញ្ច ឆ អនុលោមបច្ចនីយម្ហិ នយា សុគម្ភិរា ។ តិកញ្ច បដ្ឋានវរំ ទុកុត្តមំ ទុកត្តិកញ្ចេវ តិកទុកញ្ច តិកត្តិកញ្ចេវ ទុកទុកញ្ច ឆ បច្ចនីយានុលោមម្ហិ នយា សុគម្ភិរាតិ ។

ចតុវីសតិប្បច្ចយវសេន អយំ សមន្តប្បដ្ឋានប្បករណវណ្ណនា និដ្ឋិតា ។





# កោសម្ពីឃោសិតារាម

ព្រះបរមសាស្តា កាលដែលទ្រង់អាស្រ័យនៅក្រុងកោសម្ពី ព្រះអង្គទ្រង់គង់ប្រថាប់នៅឃោសិតារាម បានប្រារព្ធនូវសេចក្តីស្លាប់នៃស្ត្រីទាំង ៥០០ មានព្រះនាងសាមាវតីជាប្រធាន និងការស្លាប់របស់នាងមាគន្ទិយាព្រមទាំងញាតិ ។ ព្រះអង្គបានត្រាស់នូវព្រះធម៌ទេសនានេះ ដែលជាព្រះគាថាធម្មបទ :

អប្បមាទោ អមតំ បទំ　　បមាទោ មច្ចុនោ បទំ
អប្បមត្តា ន មីយន្តិ　　យេ បមត្តា យថា មតា
ឯតំ វិសេសតោ ញត្វា　　អប្បមាទម្ហិ បណ្ឌិតា
អប្បមាទេ បមោទន្តិ　　អរិយានំ គោចរេ រតា
តេ ឈាយិនោ សាតតិកា និច្ចំ ទឡ្ហបរក្កមា
ផុសន្តិ ធីរា និព្វានំ　　យោគក្ខេមំ អនុត្តរំ ។

សេចក្តីមិនប្រមាទ[១] ជាផ្លូវនៃសេចក្តីមិនស្លាប់[២] សេចក្តីប្រមាទជាផ្លូវនៃសេចក្តីស្លាប់ ជនទាំងឡាយ ដែលមិនប្រមាទហើយ ឈ្មោះថា មិនស្លាប់ ជនទាំងឡាយដែលប្រមាទហើយ[៣]

---

១-បានដល់ការប្រុងប្រយ័ត្ន ពាក្យនេះជាឈ្មោះស្មារតីដែលបានតាំងប្រុងជានិច្ច ។ ២-ពាក្យថាមិនស្លាប់នេះជាឈ្មោះព្រះនិព្វាន ព្រោះព្រះនិព្វានមិនមានចាស់ មិនមានស្លាប់ ។ ៣-បានដល់ការមិនប្រុងប្រយ័ត្ន ពាក្យនេះជាឈ្មោះនៃការលះបង់ស្មារតី ។

ទុកដូចជាមនុស្សស្លាប់ទៅហើយ ។ ពួកបណ្ឌិត បានជ្រាបនូវដំណើរនេះ ដោយប្លែកគ្នា ( ទើបឋិតនៅ ) ក្នុងសេចក្តីមិនប្រមាទ រីករាយ ក្នុងសេចក្តីមិនប្រមាទ បណ្ឌិតទាំងនោះ ជាអ្នកត្រេកអរក្នុងធម៌ជាទីគោចរ[១] នៃព្រះអរិយបុគ្គលទាំងឡាយ ។ បណ្ឌិតអ្នកមិនប្រមាទទាំងនោះ មានការពិនិត្យជាប្រក្រតី មានព្យាយាមជាប់តគ្នា មានសេចក្តីប្រឹងប្រែងមាំមួនជានិច្ច ជាអ្នកមានប្រាជ្ញា តែងពាល់ត្រូវនូវព្រះនិព្វានជាទីក្សេមក្សាន្តចាកយោគៈ ជាធម្មគុណដ៏ប្រសើរបំផុត ។ ( បិដកលេខ ៥២ , ទំព័រ ២៥-២៦ )

✳-ប្រវត្តិរឿង ឃោសកសេដ្ឋី ។

✳-ប្រវត្តិរឿង មាគន្ទិយព្រាហ្មណ៍ ។

✳-ឧបាសិកា ខុជ្ជុត្តរា សម្តែងធម៌ក្នុងគម្ពីរឥតិវុត្តកៈ ១១០ សូត្រ បិដកខ្មែរលេខ ៥៣ ។

✳-ព្រះពាកុលត្ថេរ កើតនៅកោសម្ពីបាន ៥ ថ្ងៃគេនាំទៅធ្វើពិធីនាកំពង់ទឹកទន្លេយមុនា ត្រូវត្រីលេប ហើយគេចាប់ត្រីនោះបាននៅក្រុងពារាណសី ។

✳-ក្រុងកោសម្ពីនៅទិសបស្ចិម នៃក្រុងពារាណសី ៣០ យោជន៍ ។

---

១-ពោធិបក្ខិយធម៌ ៣៧ និងលោកុត្តរធម៌ ៩ ហៅថាទីគោចរនៃព្រះអរិយៈ ។





# ពារាណសី-សារនាថ

✳-ក្រុងពារាណសី មានឈ្មោះមកយូរហើយ នៅក្នុងព្រះជាតកយ៉ាងច្រើន បានពោលពីក្រុងពារាណសី ។

✳-ស្តូបដែលព្រះបរមសាស្តា ទ្រង់ជួបបញ្ចវគ្គិយតាបស នៅពេលដែលព្រះអង្គទើបតែយាងមកដល់ ។

✳-សារនាថ គឺជាព្រៃឥសិបតនមិគទាយវ័ន ជាទីអាស្រ័យនៅនៃបញ្ចវគ្គិយ ទាំងជាកន្លែងដូចតទៅ :

-កន្លែងសម្តែងបឋមទេសនាដោយព្រះសម្មាសម្ពុទ្ធ ។

-កន្លែងដែលចាប់ផ្តើមមានព្រះសង្ឃ ដែលធ្វើឱ្យគ្រប់ព្រះ-រតនត្រ័យនៅទីនេះឯង ។

-កន្លែងដែលចាប់ផ្តើមបានសម្រេចអមតធម៌នៃសត្វលោក។

-កន្លែងគង់ក្នុងវស្សាទី ១ នៃព្រះសម្មាសម្ពុទ្ធ ។

-កន្លែងកើតមានព្រះអរហន្តសាវ័កមុនគេ ។

-កន្លែងដែលព្រះសង្ឃ ៦០ អង្គ សុទ្ធតែជាព្រះអរហន្តចេញទៅផ្សព្វផ្សាយព្រះពុទ្ធសាសនា មុនដំបូងបំផុត ។

✳-ប្រវត្តិព្រះនាឡកត្ថេរដោយសង្ខេប មានដូចតទៅ :

ព្រះនាឡកៈកើតក្នុងវណ្ណៈព្រាហ្មណ៍ ក្នុងនគរកបិលពស្តុ មាតារបស់លោក គឺជាប្អូនស្រីរបស់អសិតតាបស ដែលក្នុងកាលមុន អសិតតាបសជាបុរោហិតនៃព្រះបិតារបស់ព្រះបាទស្រីសុទ្ធោទនៈ តមកដល់រជ្ជកាលនៃព្រះបាទស្រីសុទ្ធោទនៈទៀតផង ។ ព្រះនាឡកៈចេញបួសជាតាបសតាំងតែពីក្មេង តាមការណែនាំរបស់អសិតតាបស ដើម្បីរង់ចាំការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ ។

បន្ទាប់ពីព្រះសម្មាសម្ពុទ្ធ ត្រាស់សម្តែងនូវព្រះធម្មចក្កប្បវត្តនសូត្រ បាន ៧ ថ្ងៃ ទើបព្រះនាឡកៈបានចូលគាល់ព្រះអង្គនៅព្រៃឥសិបតនមិគទាយវ័ន បានទូលសួរព្រះធម៌ និងបានស្តាប់នូវ **មោនេយ្យប្បដិបទា** គឺការប្រព្រឹត្តរបស់អ្នកប្រាជ្ញ ដែលមានទាំងស្រុងក្នុងបិដកលេខ ៥៤, ទំព័រ ២៤១-២៤៦ ។

( ព្រះដ៏មានព្រះភាគ ) ទ្រង់ត្រាស់ថា តថាគតនឹងបញ្ញត្តមោនេយ្យប្បដិបទា ដែលជាវត្តធ្វើបានដោយកម្រ អត់ធន់បានដោយកម្រដល់អ្នក បើដូច្នោះ តថាគតនឹងសម្តែងមោនេយ្យប្បដិបទានោះដល់អ្នក ត្រូវអ្នកផ្គងព្យាយាមឱ្យមាំមួនចុះ ។

បុគ្គល ត្រូវធ្វើខ្លួនឱ្យមានភាពស្មើ ចំពោះបុគ្គលអ្នកជេរ និងអ្នកថ្វាយបង្គំក្នុងស្រុក បុគ្គល (បើគេជេរ) ត្រូវរក្សាសេចក្តី





ប្រទូស្តក្នុងចិត្ត (បើគេថ្វាយបង្គំ) ត្រូវស្ងប់កុំប៉ោងតាមអារម្មណ៍ ។

អារម្មណ៍ខ្ពស់និងទាបទាំងឡាយ (អារម្មណ៍ល្អនិងអាក្រក់) តែងផ្សាយចេញមក ( កាន់វង់ចក្ខុជាដើម ) ឧបមាដូចជាអណ្តាតភ្លើងដែលឆេះក្នុងព្រៃ នារីទាំងឡាយតែងប្រលោមនូវអ្នកប្រាជ្ញ នារីទាំងឡាយនោះ កុំគប្បីប្រលោមអ្នកបានឡើយ ។

បុគ្គលវៀរហើយចាកមេថុនធម្ម លះកាមដែលល្អ និងអាក្រក់ទាំងឡាយ កុំទោមនស្ស កុំត្រេកអរចំពោះសត្វដែលតក់ស្លុតនិងសត្វដែលមាំមួន (មិនតក់ស្លុត) ក្នុងសត្វទាំងឡាយ ។

គប្បីប្រៀបខ្លួនឯងថា អាត្មាអញយ៉ាងណា សត្វទាំងឡាយនោះ ក៏យ៉ាងនោះដែរ សត្វទាំងឡាយនោះយ៉ាងណា អាត្មាអញក៏យ៉ាងនោះដែរ ហើយមិនត្រូវសម្លាប់ មិនត្រូវប្រើគេឱ្យសម្លាប់ឡើយ ។

បុថុជ្ជនជាប់ជំពាក់ក្នុងបច្ច័យណា បុរសអ្នកមានបញ្ញាចក្ខុត្រូវតែលះចោលនូវសេចក្តីប្រាថ្នាផង នូវសេចក្តីលោភផង (ក្នុងបច្ច័យនោះ) ហើយប្រតិបត្តិនូវមោនេយ្យប្បដិបទា ត្រូវតែប្រឆាំងនូវតណ្ហាដែលបំពេញបានដោយកម្រនេះ ។

បុគ្គល គួរមានពោះធូរ មានអាហារកំណត់ មានប្រាថ្នាតិចមិនល្មោភ បុគ្គលមិនឃ្លានដោយសេចក្តីប្រាថ្នាសព្វៗកាល ជាអ្នក

មិនមានសេចក្តីប្រាថ្នា រមែងរលត់សេចក្តីក្តៅក្រហាយ ព្រោះកិលេស ( ដោយមិនមានសេចក្តីប្រាថ្នា ) ។

ភិក្ខុអ្នកប្រតិបត្តិមោនេយ្យប្បដិបទានោះ ប្រព្រឹត្តនូវបិណ្ឌ-បាតចារិកវត្តរួចហើយ គប្បីប្រញាប់ចូលទៅកាន់ព្រៃហើយចូរឋិតនៅក្រោមម្លប់ឈើ រួចចូលទៅកាន់អាសនៈ ។

អ្នកប្រាជ្ញនោះ គួរខ្វល់ខ្វាយក្នុងឈាន គួរត្រេកអរក្នុងព្រៃ គួរត្រេកអរនឹងអប់រំចិត្ត ហើយគប្បីចម្រើនឈានក្រោមម្លប់ឈើ។

តអំពីនោះ លុះកន្លងរាត្រីទៅ គប្បីចូលទៅកាន់ស្រុក មិនគួរត្រេកអរនឹងការនិមន្តផង មិនគួរទទួលនូវភោជនដែលគេនាំចេញអំពីស្រុកផង ។

មុនីចូលទៅកាន់ស្រុក មិនគួរត្រាច់ទៅដោយការរួសរាន់ក្នុងត្រកូលទាំងឡាយឡើយ គួរជាអ្នកកាត់បង់នូវកថា ( ពាក្យពោល ) មិនគួរពោលពាក្យផ្សែផ្សំ ស្វែងរកស៊ីឡើយ ។ មុនីនោះជាតាទិបុគ្គល ដោយហេតុទាំងពីរប្រការ គឺអាត្មាអញបាននេះ ជាការប្រពៃ អាត្មាអញមិនបានក៏ជាការល្អ ហើយក៏ចូលទៅកាន់ត្រកូលដូចអ្នករកផ្លែឈើ ចូលទៅកាន់ដើមឈើ ។

មុនីមានបាត្រក្នុងដៃត្រាច់ទៅ មិនគ សន្មតថា ដូចគ មិនគួរពេបជ្រាយនឹងទានដែលមានប្រមាណតិច មិនគួរមើលងាយនូវ





បុគ្គលអ្នកឱ្យទាន ។

ឯបដិបទាដែលខ្ពស់និងទាប សមណៈបានប្រកាសហើយ ធម្មតាព្រះអរិយបុគ្គលមិនដែលទៅកាន់ត្រើយខាងនាយ គឺព្រះ-និព្វានដល់ពីរដងឡើយ ព្រះនិព្វាននោះ មិនគួរបានដោយគុណតែមួយទេ ( មិនអាចលះកិលេសទាំងអស់ដោយមគ្គតែមួយ ) ។

ភិក្ខុណាមិនមានតណ្ហា សេចក្តីក្រហល់ក្រហាយ នឹងមិនមានដល់ភិក្ខុនោះ ជាអ្នកមានខ្សែកិលេសកាត់ហើយ អ្នកលះចោលនូវកិច្ចតូចនិងកិច្ចធំហើយ ។

( ព្រះមានព្រះភាគ ) ទ្រង់ត្រាស់ថា តថាគតនឹងបញ្ញត្តនូវមោនេយ្យប្បដិបទាដល់អ្នក ភិក្ខុអ្នកប្រព្រឹត្តនូវមោនេយ្យប្បដិបទា គប្បីមានមុខកាំបិតកោរ ជាគ្រឿងប្រៀបធៀប គប្បីទល់ពិតានដោយអណ្តាត ហើយសង្រួមផ្ទៃ ( ដោយការមិនសេពបច្ច័យដែលកើតឡើងដោយផ្លូវសៅហ្មង ) ។

ភិក្ខុនោះមិនមានចិត្តខ្ជិលផង មិនគិតច្រើនផង ជាអ្នកមិនមានកិលេសផង មិនអាស្រ័យតណ្ហាផង មានសាសនព្រហ្មចរិយៈជាខាងមុខផង គួរសិក្សាបម្រុងនិងសេពនូវអាសនៈស្ងាត់ម្នាក់ឯងផង បម្រុងសេពអារម្មណ៍ដែលសមណៈគប្បីចូលទៅជិតផង អ្នកជាបុគ្គលម្នាក់ឯង ទាំងត្រេកអរនូវមោនេយ្យប្បដិបទាជាចំណែក

មួយ ដែលតថាគតសម្តែងហើយដោយពិត ។

( អ្នកនឹងល្បីឮខ្ចរខ្ចាយទៅក្នុងទិសទាំង ១០ ក្នុងកាលជាខាងក្រោយ ) អ្នកឮសំឡេងល្បី (អំពីសំណាក់) អ្នកប្រាជ្ញទាំងឡាយជាអ្នកមានឈាន លះបង់កាម គប្បីធ្វើដោយក្រៃលែងនូវហិរិផងនូវសទ្ធាផង ក្នុងកាលនោះ ទើបឈ្មោះថាជាសាវ័ករបស់តថាគត។

អ្នកត្រូវដឹងបរិយាយនោះ ដោយសេចក្តីឧបមា ដោយទន្លេទាំងឡាយ ( ត្រូវដឹងបរិយាយផ្សេងទៀត ) ចំពោះបឹងនិងស្ទឹងទាំងឡាយថា ស្ទឹងតូចទាំងឡាយ តែងធ្វើសំឡេងហូរទៅ ឯស្ទឹងធំតែងហូរទៅស្ងៀមៗ ។

ទឹកណាដែលកន្លះ ទឹកនោះតែងឮសូរ ទឹកណាដែលពេញទឹកនោះតែងស្ងប់ ជនពាលមានឧបមាដូចទឹកកន្លះក្អម ជនបណ្ឌិតមានឧបមាដូចអន្លង់ទឹកដ៏ពេញ ។ សមណៈគឺព្រះពុទ្ធ តែងសម្តែងនូវធម៌ដែលប្រកបដោយប្រយោជន៍ដ៏ច្រើន សមណៈនោះជ្រាបប្រាកដ ទើបសម្តែងនូវធម៌ សមណៈនោះជ្រាបប្រាកដ ទើបសម្តែងដោយច្រើន ។

មួយទៀត មុនីណា ជ្រាបប្រាកដនូវធម៌ មានចិត្តសង្រួម ហើយ ជ្រាបប្រាកដនូវធម៌មិននិយាយច្រើន មុនីនោះ គួរដល់មោនេយ្យប្បដិបទា មុនីនោះបានដល់នូវអរហត្តមគ្គញ្ញាណ ។





*-ព្រះស្តូបឈ្មោះ **ធម្មេក្ខស្តូប** ជាព្រះចេតិយសាងក្នុងសម័យព្រះបាទធម្មាសោក ។ ព្រះចេតិយធំមូលខ្ពស់នេះ បានបង្ហាញពីការឃើញធម៌ (ធម្មេក្ខៈ) ក្នុងទីនេះ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងព្រះធម៌ប្រោសបញ្ចវគ្គិយ គឺតាបសមានគ្នា ៥ នាក់ មានព្រះអញ្ញាកោណ្ឌញ្ញៈជាដើម ។ ព្រះអញ្ញាកោណ្ឌញ្ញៈបាននូវធម្មចក្ខុក្នុងទីនេះឯង ព្រោះបានស្តាប់នូវព្រះធម្មចក្កប្បវត្តនសូត្របឋមទេសនា ។

# ព្រះធម្មចក្កប្បវត្តនសូត្រ

(បិដកលេខ ៦ , ទំព័រ ២៨-៣៦)

**ឯវម្មេ សុតំ** សូត្រនេះ (ឈ្មោះធម្មចក្កប្បវត្តនសូត្រ) គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្តាប់មកហើយយ៉ាងនេះថា

**ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ** សម័យមួយព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី

**តត្រ ខោ ភគវា បញ្ចវគ្គិយេ ភិក្ខូ អាមន្តេសិ** ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅនូវបញ្ចវគ្គិយភិក្ខុទាំងឡាយក្នុងទីនោះឯង ឱ្យតាំងចិត្តស្តាប់នូវភាសិតនេះថា

**ទ្វេមេ ភិក្ខវេ អន្តា បព្វជិតេន ន សេវិតព្វា** ម្នាលភិក្ខុទាំងឡាយ អន្តធម៌គឺធម៌ជាផ្លូវប្រតិបត្តិអមខាងដ៏លាមកអាក្រក់ទាំងឡាយ ពីរប្រការនេះ បព្វជិតមិនគួរសេពគប់ គឺថាមិនគួរប្រព្រឹត្តឡើយ ។

**កតមេ ទ្វេ** អន្តធម៌ទាំងឡាយពីរយ៉ាងនោះដូចម្តេច ?

**យោ ចាយំ កាមេសុ កាមសុខល្លិកានុយោគោ** ធម៌ណាដែលប្រកបខ្លួន ឱ្យជាប់ជំពាក់ដោយកាម ក្នុងកាមទាំងឡាយ

**ហីនោ** ជាធម៌ថោកទាប

**គម្មោ** ជាធម៌របស់អ្នកស្រុក

**បោថុជ្ជនិកោ** ជាធម៌របស់បុថុជ្ជន

**អនរិយោ** មិនមែនជារបស់អរិយបុគ្គលទេ

**អនត្ថសញ្ហិតោ** មិនប្រកបដោយប្រយោជន៍ឡើយ។

**យោ ចាយំ អត្តកិលមថានុយោគោ** ធម៌ណាដែលប្រកបសេចក្តីលំបាកដល់ខ្លួន





**ទុក្ខោ** ជាហេតុនាំឱ្យលំបាកកាយទទេៗ

**អនរិយោ** មិនមែនជារបស់អរិយបុគ្គលទេ

**អនត្ថសញ្ហិតោ** មិនប្រកបដោយប្រយោជន៍ឡើយ។

**ឯតេ តេ ខោ ភិក្ខវេ ឧភោ អន្តេ អនុបគម្ម មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ** ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រតិបត្តិជាកណ្តាល មិនលាយច្រឡំដោយអន្តធម៌ទាំងឡាយពីរយ៉ាងនោះឯង ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឱ្យកើតបញ្ញាចក្ខុ ( ភ្នែកគឺប្រាជ្ញា ) ធ្វើឱ្យកើតសេចក្តីដឹងច្បាស់ប្រាកដ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងចំពោះ ដើម្បីសេចក្តីដឹងដោយប្រពៃ ដើម្បីសេចក្តីរំលត់ទុក្ខ ។

**កតមា ច សា ភិក្ខវេ មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ** ម្នាលភិក្ខុទាំងឡាយ ក៏សេចក្តីប្រតិបត្តិជាកណ្តាលដែលតថាគត បានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឱ្យកើតបញ្ញាចក្ខុ ធ្វើឱ្យកើតសេចក្តីដឹងច្បាស់ប្រាកដ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បី

សេចក្តីដឹងចំពោះ ដើម្បីសេចក្តីដឹងដោយប្រពៃ ដើម្បីសេចក្តីរំលត់ទុក្ខនោះ តើដូចម្តេច ?

**អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ** អដ្ឋង្គិកមគ្គ គឺធម៌ជាផ្លូវមានអង្គប្រាំបីដ៏ប្រសើរនេះឯង ( ហៅថា សេចក្តីប្រតិបត្តិជាកណ្តាល )

**សេយ្យថីទំ** អដ្ឋង្គិកមគ្គនោះដូចម្តេចខ្លះ ?

**សម្មាទិដ្ឋិ** ប្រាជ្ញាយល់ឃើញត្រូវ

**សម្មាសង្កប្បោ** សេចក្តីត្រិះរិះត្រូវ

**សម្មាវាចា** សម្តីត្រូវ

**សម្មាកម្មន្តោ** ការងារត្រូវ

**សម្មាអាជីវោ** កិរិយាចិញ្ចឹមជីវិតត្រូវ

**សម្មាវាយាមោ** ព្យាយាមត្រូវ

**សម្មាសតិ** សេចក្តីរលឹកត្រូវ

**សម្មាសមាធិ** កិរិយាតម្កល់ចិត្តឱ្យនឹងត្រូវ

**អយំ ខោ សា ភិក្ខវេ មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ** ម្នាលភិក្ខុ





ទាំងឡាយ អដ្ឋង្គិកមគ្គនេះឯងដែលហៅថា សេចក្តីប្រតិបត្តិជាកណ្តាល ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឱ្យកើតបញ្ញាចក្ខុ ធ្វើឱ្យកើតសេចក្តីដឹងច្បាស់ប្រាកដ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងចំពោះ ដើម្បីសេចក្តីដឹងដោយប្រពៃ ដើម្បីសេចក្តីរំលត់ទុក្ខ ។

**ឥទំ ខោ បន ភិក្ខវេ ទុក្ខំ អរិយសច្ចំ ជាតិបិ ទុក្ខា ជរាបិ ទុក្ខា ( ព្យាធិបិ ទុក្ខោ ) មរណម្បិ ទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសាបិ ទុក្ខា អប្បិយេហិ សម្បយោគោ ទុក្ខោ បិយេហិ វិប្បយោគោ ទុក្ខោ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា** ម្នាលភិក្ខុទាំងឡាយ ជាតិ គឺកិរិយាកកើតនៃខន្ធ ជាហេតុនាំមកនូវទុក្ខ ជរា គឺកិរិយាចាស់គ្រាំគ្រានៃខន្ធ ក៏ជាហេតុនាំមកនូវទុក្ខ ( ព្យាធិ គឺជំងឺតម្កាត់ទាំងឡាយ ក៏ជាហេតុនាំមកនូវទុក្ខ ) មរណៈ គឺកិរិយាបែកធ្លាយនៃខន្ធ ក៏ជាហេតុនាំមកនូវទុក្ខ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏ជាហេតុនាំមកនូវទុក្ខ កិរិយាប្រកបដោយសត្វនិងសង្ខារទាំងឡាយ ដែលមិនជាទីស្រឡាញ់ពេញចិត្ត ក៏ជាហេតុនាំមកនូវទុក្ខ កិរិយាព្រាត់ប្រាសចាកសត្វ និងសង្ខារទាំងឡាយដែល

ជាទីស្រឡាញ់ពេញចិត្ត ក៏ជាហេតុនាំមកនូវទុក្ខ កាលបើចង់បាននូវវត្ថុណាមួយហើយ មិនបាននូវវត្ថុនោះ កិរិយាមិនបាននោះក៏ជាហេតុនាំមកនូវទុក្ខ ឧបាទានក្ខន្ធទាំងឡាយប្រាំ ដែលតថាគតសម្តែងហើយដោយបំប្រួញ ក៏ជាហេតុនាំមកនូវទុក្ខ កងទុក្ខមានជាតិជាដើមនេះ ឈ្មោះថា ទុក្ខអរិយសច្ច ។

**ឥទំ ខោ បន ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ យាយំ តណ្ហា បោនោព្ភវិកា នន្ទិរាគសហគតា តត្រ តត្រាភិនន្ទិនី សេយ្យថីទំ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា** ម្នាលភិក្ខុទាំងឡាយ តណ្ហាឯណា ដែលរមែងតាក់តែងនូវភពថ្មី ប្រកបដោយតម្រេក ដោយអំណាចនៃសេចក្តីត្រេកត្រអាល មានកិរិយារីករាយក្នុងអារម្មណ៍នោះៗ ជាប្រក្រតី តណ្ហានោះដូចម្តេចខ្លះ ? ( តណ្ហានោះ ) គឺ កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ តណ្ហាទាំង ៣ នេះ ឈ្មោះថា ទុក្ខសមុទយអរិយសច្ច ។

**ឥទំ ខោ បន ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ យោ តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ** ម្នាលភិក្ខុទាំងឡាយ កិរិយារំលត់បង់នូវតណ្ហានោះ ដោយអរិយមគ្គ មិនឱ្យមានសេសសល់



កិរិយាលះបង់នូវតណ្ហានោះ កិរិយារលាស់ចោលនូវតណ្ហានោះ កិរិយារួចផុតចាកតណ្ហានោះ កិរិយាមិនមានអាល័យក្នុងតណ្ហានោះឯណា កិរិយារំលត់បង់នូវតណ្ហាដោយអរិយមគ្គមិនឱ្យមានសេសសល់ជាដើមនេះឯង ឈ្មោះថា ទុក្ខនិរោធអរិយសច្ច ។

**ឥទំ ខោ បន ភិក្ខវេ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ** ម្នាលភិក្ខុទាំងឡាយ អដ្ឋង្គិកមគ្គដ៏ប្រសើរនេះឯងដូចម្តេចខ្លះ ? គឺ ប្រាជ្ញាយល់ឃើញត្រូវ សេចក្តីត្រិះរិះត្រូវ សម្តីត្រូវ ការងារត្រូវ កិរិយាចិញ្ចឹមជីវិតត្រូវ ព្យាយាមត្រូវ សេចក្តីរលឹកត្រូវ កិរិយាតម្កល់ចិត្តឱ្យនឹងត្រូវ អដ្ឋង្គិកមគ្គដ៏ប្រសើរនេះឯង ឈ្មោះថា ទុក្ខនិរោធ-គាមិនីបដិបទាអរិយសច្ច ។

( កាលត្រាស់ទេសនានូវលក្ខណៈនៃអរិយសច្ច ៤ ប្រការដូច្នេះហើយ ទើបត្រាស់ទេសនានូវញាណទាំង ៣ ប្រការ គឺ សច្ចញ្ញាណ កិច្ចញ្ញាណ និងកតញ្ញាណ ឱ្យទូទៅក្នុងអរិយសច្ច ៤ តទៅទៀតថា )

**ឥទំ ទុក្ខំ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ**

**អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ** ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលពីដើម តថាគតមិនធ្លាប់បានឮបានស្តាប់ថា នេះជាទុក្ខអរិយសច្ច ដូច្នេះឡើយ ។

**តំ ខោ បនិទំ ទុក្ខំ អរិយសច្ចំ បរិញ្ញេយ្យន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ** ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយដែលពីដើម តថាគតមិនធ្លាប់បានឮបានស្តាប់ថា ទុក្ខអរិយសច្ចនេះឯង គួរតែកំណត់ដឹងដោយបញ្ញា ដូច្នេះឡើយ ។

**តំ ខោ បនិទំ ទុក្ខំ អរិយសច្ចំ បរិញ្ញាតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ** ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ





ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយដែលពីដើម តថាគតមិនធ្លាប់បានឮបានស្តាប់ថា ទុក្ខអរិយសច្ចនេះឯង តថាគតកំណត់ដឹងបានហើយ ដូច្នេះឡើយ ។

**ឥទំ ទុក្ខសមុទយោ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ** ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលពីដើម តថាគតមិនធ្លាប់បានឮបានស្តាប់ថា នេះជាទុក្ខសមុទយអរិយសច្ច ដូច្នេះឡើយ ។

**តំ ខោ បនិទំ ទុក្ខសមុទយោ អរិយសច្ចំ បហាតព្វន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ** ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលពីដើម តថាគតមិនធ្លាប់បានឮបានស្តាប់ថា ទុក្ខ-

សមុទយអរិយសច្ចនេះឯង គួរតែលះបង់ ដូច្នេះឡើយ ។

**តំ ខោ បនិទំ ទុក្ខសមុទយោ អរិយសច្ចំ បហីនន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ** ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយដែលពីដើម តថាគតមិនធ្លាប់បានឮបានស្តាប់ថា ទុក្ខសមុទយអរិយសច្ចនេះឯង តថាគតលះបង់បានហើយ ដូច្នេះឡើយ ។

**ឥទំ ទុក្ខនិរោធោ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ** ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលពីដើម តថាគតមិនធ្លាប់បានឮបានស្តាប់ថា នេះជាទុក្ខនិរោធអរិយសច្ច ដូច្នេះឡើយ ។

**តំ ខោ បនិទំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកាតព្វន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ**





**ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ** ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយដែលពីដើម តថាគតមិនធ្លាប់បានឮបានស្តាប់ថា ទុក្ខនិរោធអរិយសច្ចនេះឯង គួរតែធ្វើឱ្យជាក់ច្បាស់ ដូច្នេះឡើយ ។

**តំ ខោ បនិទំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ** ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយដែលពីដើម តថាគតមិនធ្លាប់បានឮបានស្តាប់ថា ទុក្ខនិរោធអរិយសច្ចនេះឯង តថាគត ធ្វើឱ្យជាក់ច្បាស់បានហើយ ដូច្នេះឡើយ ។

**ឥទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ** ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ

ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលពីដើម តថាគតមិនធ្លាប់បានឮបានស្តាប់ថា នេះជាទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ដូច្នេះឡើយ ។

**តំ ខោ បនិទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ភាវេតព្វន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ** ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮបានស្តាប់ថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចនេះឯង គួរតែចម្រើនឱ្យកើតឡើង ដូច្នេះឡើយ ។

**តំ ខោ បនិទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ភាវិតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ** ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើង



ហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយ ដែលពីដើម តថាគតមិនធ្លាប់បានឮបានស្តាប់ថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចនេះឯង តថាគតចម្រើនឱ្យកើតបានហើយ ដូច្នេះឡើយ ។

**យាវកីវញ្ច មេ ភិក្ខវេ ឥមេសុ ចតូសុ អរិយសច្ចេសុ ឯវន្តិបរិវដ្តំ ទ្វាទសាការំ យថាភូតំ ញាណទស្សនំ ន សុវិសុទ្ធំ អហោសិ** ម្នាលភិក្ខុទាំងឡាយ ប្រាជ្ញាដែលដឹងច្បាស់ឃើញច្បាស់តាមពិត មានបរិវដ្តៈ ៣ មានអាការៈ ១២ យ៉ាងនេះ ( ប្រព្រឹត្តទៅ ) ក្នុងអរិយសច្ចទាំងឡាយ ៤ នៅមិនទាន់បរិសុទ្ធល្អមានដល់តថាគត អស់កាលត្រឹមណា ។

**នេវ តាវាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវ-មនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ** ម្នាលភិក្ខុទាំងឡាយ តថាគតក៏មិនទាន់ប្តេជ្ញាខ្លួនថា ជាអ្នកត្រាស់-ដឹងនូវសម្មាសម្ពោធិញ្ញាណ ឥតមានសេចក្តីដឹងឯទៀតក្រៃលែងជាងក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិ-ទេព និងមនុស្សដ៏សេស អស់កាលត្រឹមណោះ នៅឡើយទេ ។

**យតោ ច ខោ មេ ភិក្ខវេ ឥមេសុ ចតូសុ អរិយសច្ចេសុ ឯវន្តិបរិវដ្ដំ ទ្វាទសាការំ យថាភូតំ ញាណទស្សនំ សុវិសុទ្ធំ អហោសិ** ម្នាលភិក្ខុទាំងឡាយ ក៏បញ្ញាដែលដឹងច្បាស់ ឃើញច្បាស់តាមពិត មានបរិវដ្ដៈ ៣ មានអាការ ១២ យ៉ាងនេះ (ប្រព្រឹត្តទៅ) ក្នុងអរិយសច្ចទាំងឡាយ ៤ នេះ បរិសុទ្ធល្អ មានដល់តថាគត ក្នុងកាលឯណា ។

**អថាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ** ម្នាលភិក្ខុទាំងឡាយ តថាគតប្ដេជ្ញាខ្លួនថា ជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ឥតមានសេចក្ដីដឹងឯទៀតក្រៃលែងជាងក្នុងលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្ស ជាសម្មតិទេព និងមនុស្សដ៏សេស ក្នុងកាលណោះឯង ។

**ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ វិមុត្តិ អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ** ក៏បញ្ញាដែលដឹងច្បាស់ ឃើញច្បាស់ កើតឡើងហើយ ដល់តថាគតដូច្នេះថា សេចក្ដីរួចផុតវិសេស របស់តថាគត មិនប្រែត្រឡប់កម្រើកទៀត





ឡើយ ជាតិនេះ ក៏ជាទីបំផុតត្រឹមនេះហើយ ឥឡូវនេះ ភពថ្មីគឺការត្រឡប់កើតទៀត ក៏មិនមានឡើយ ។

**ឥទមវោច ភគវា** ព្រះដ៏មានព្រះភាគ បានត្រាស់ទេសនា ព្រះធម្មចក្កប្បវត្តនសូត្រនេះ (ចប់ហើយ) ។

**អត្តមនា បញ្ចវគ្គិយា ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ** បញ្ចវគ្គិយភិក្ខុទាំងឡាយ ក៏មានចិត្តត្រេកអររីករាយនឹងភាសិតរបស់ព្រះដ៏មានព្រះភាគដោយក្រៃពេក ។

**ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញមានេ អាយស្មតោ កោណ្ឌញ្ញស្ស វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ** នាកាលវេយ្យាករណ៍ គឺព្រះសូត្រដែលឥតមានគាថានេះ ដែលព្រះដ៏មានព្រះភាគ កំពុងត្រាស់ទេសនា ធម្មចក្ខុគឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី គឺរាគៈ ប្រាសចាកមន្ទិលគឺអកុសលកើតឡើងហើយដល់ព្រះកោណ្ឌញ្ញៈដ៏មានអាយុថា

**យំកិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ** ធម្មជាតិណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតិនោះទាំងអស់មានកិរិយារលត់ទៅជាធម្មតា ។

**បវត្តិតេ ច ភគវតា ធម្មចក្កេ** ក៏នាកាលព្រះធម្មចក្កប្បវត្តនសូត្រ គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទេសនាចប់

ហើយ ។

**ភុម្មា ទេវា សទ្ទមនុស្សាវេសុំ ឯតម្ភគវតា ពារាណសិយំ ឥសិបតនេ មិគទាយេ អនុត្តរំ ធម្មចក្កំ បវត្តិតំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មិន្តិ** ភុម្មទេវតាទាំងឡាយ ក៏ញ៉ាំងសំឡេងឱ្យលាន់ឮឡើង ដូច្នេះថា ចក្រគឺធម៌នេះ ឥតមានចក្រឯណាមួយក្រៃលែងជាង គឺសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកឯណានីមួយក្តីក្នុងលោកសម្តែងពុំបានឡើយ មានតែព្រះដ៏មានព្រះភាគព្រះអង្គត្រាស់សម្តែងហើយ ក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។

**ភុម្មានំ ទេវានំ សទ្ទំ សុត្វា ចាតុម្មហារាជិកា ទេវា សទ្ទមនុស្សាវេសុំ** ទេវតាទាំងឡាយក្នុងជាន់ចាតុម្មហា-រាជ បានឮសំឡេងនៃភុម្មទេវតាទាំងឡាយហើយក៏ញ៉ាំងសំឡេងឱ្យលាន់ឮឡើង ( ដោយសេចក្តីសរសើរដូចគ្នា ) ។

**ចាតុម្មហារាជិកានំ ទេវានំ សទ្ទំ សុត្វា តាវត្តឹសា ទេវា សទ្ទមនុស្សាវេសុំ** ទេវតាទាំងឡាយក្នុងជាន់តាវត្តិង្ស បានឮសំឡេងនៃទេវតា ក្នុងជាន់ចាតុម្មហារាជហើយ ក៏ញ៉ាំង





សំឡេងឱ្យលាន់ឮឡើង ( ដោយសេចក្តីសរសើរដូចគ្នា )។

**តាវត្តឹសានំ ទេវានំ សទ្ទំ សុត្វា យាមា ទេវា សទ្ទមនុស្សាវេសុំ** ទេវតាទាំងឡាយក្នុងជាន់យាមា បានឮសំឡេងនៃទេវតាក្នុងជាន់តាវត្តិង្សហើយ ក៏ញ៉ាំងសំឡេង ឱ្យលាន់ឮឡើង (ដោយសេចក្តីសរសើរដូចគ្នា ) ។

**យាមានំ ទេវានំ សទ្ទំ សុត្វា តុសិតា ទេវា សទ្ទមនុស្សាវេសុំ** ទេវតាទាំងឡាយ ក្នុងជាន់តុសិត បានឮសំឡេងនៃទេវតាក្នុងជាន់យាមាហើយ ក៏ញ៉ាំងសំឡេងឱ្យលាន់ឮឡើង ( ដោយសេចក្តីសរសើរដូចគ្នា )។

**តុសិតានំ ទេវានំ សទ្ទំ សុត្វា និម្មានរតី ទេវា សទ្ទមនុស្សាវេសុំ** ទេវតាទាំងឡាយក្នុងជាន់និម្មានរតី បានឮសំឡេងនៃទេវតាក្នុងជាន់តុសិតហើយ ក៏ញ៉ាំងសំឡេងឱ្យលាន់ឮឡើង ( ដោយសេចក្តីសរសើរដូចគ្នា ) ។

**និម្មានរតីនំ ទេវានំ សទ្ទំ សុត្វា បរនិម្មិតវសវត្តី ទេវា សទ្ទមនុស្សាវេសុំ** ទេវតាទាំងឡាយក្នុងជាន់បរនិម្មិត-វសវត្តី បានឮសំឡេងនៃទេវតាក្នុងជាន់និម្មានរតីហើយ ក៏ញ៉ាំងសំឡេងឱ្យលាន់ឮឡើង ( ដោយសេចក្តីសរសើរដូចគ្នា ) ។

**បរនិម្មិតវសវត្តីនំ ទេវានំ សទ្ទំ សុត្វា ព្រហ្មកា-**

**យិកា ទេវា សទ្ទមនុស្សាវេសុំ ឯតម្ភគវតា ពារាណសិយំ ឥសិបតនេ មិគទាយេ អនុត្តរំ ធម្មចក្កំ បវត្តិតំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មិន្តិ** ទេវតាទាំងឡាយក្នុងពួកព្រហ្ម បានឮសំឡេងនៃទេវតាក្នុងជាន់បរនិម្មិត-វសវត្តីហើយ ក៏ញុំាងសំឡេងឱ្យលាន់ឮឡើងដូច្នេះថា ចក្រគឺធម៌នេះ ឥតមានចក្រឯណាមួយក្រៃលែងជាង គឺសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកឯណានីមួយក្តីក្នុងលោក សម្តែងពុំបានឡើយ មានតែព្រះដ៏មានព្រះភាគ ព្រះអង្គត្រាស់សម្តែងហើយ ក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។

**ឥតិហ តេន ខណេន តេន មុហុត្តេន យាវ ព្រហ្មលោកា សទ្ទោ អព្ភុគ្គច្ឆិ** សំឡេងសាធុការលាន់ឮឡើងទៅដរាបដល់ព្រហ្មលោក ក្នុងខណៈនោះ ក្នុងមួយរំពេចនោះ ដោយអាការលាន់ឮត ៗ គ្នាដូច្នេះ ។

**អយញ្ច ទសសហស្សី លោកធាតុ សង្កម្បិ សម្បកម្បិ សម្បវេធិ** ទាំងម៉ឺនលោកធាតុនេះក៏កក្រើក ញាប់ញ័រ ទាំងខាងលើទាំងខាងក្រោម និងញាប់ញ័រក្នុងទិសទាំងពួង ។



**អប្បមាណោ ច ឧឡារោ ឱភាសោ លោកេ បាតុរហោសិ អតិក្កម្ម ទេវានំ ទេវានុភាវន្តិ** ទាំងរស្មីដ៏រុងរឿងក្រៃពេក និងប្រមាណមិនបាន កន្លងលើសទេវានុភាពនៃទេវតាទាំងឡាយ ក៏កើតឡើងប្រាកដក្នុងលោក ។

**អថខោ ភគវា ឧទានំ ឧទានេសិ អញ្ញាសិ វត ភោ កោណ្ឌញ្ញោ អញ្ញាសិ វត ភោ កោណ្ឌញ្ញោតិ** លំដាប់នោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បន្លឺនូវឧទានវាចាថា ឱ ! កោណ្ឌញ្ញៈ បានចេះដឹងហើយហ្ន៎ ឱ ! កោណ្ឌញ្ញៈ បានចេះដឹងហើយហ្ន៎ ។

**ឥតិហិទំ អាយស្មតោ កោណ្ឌញ្ញស្ស អញ្ញាកោណ្ឌញ្ញោត្វេវ នាមំ អហោសីតិ** ព្រោះហេតុនោះ ពាក្យថា អញ្ញាកោណ្ឌញ្ញៈនេះឯង បានមកជាឈ្មោះនៃព្រះកោណ្ឌញ្ញៈដ៏មានអាយុ ។

(របៀបសូត្រតាមភាណវារៈ)

**(ព្រះធម្មចក្កប្បវត្តនសូត្រ ចប់)**

*-បញ្ចវគ្គិយទាំង ៥ អង្គគឺ ១-ព្រះអញ្ញាកោណ្ឌញ្ញៈ , ២-ព្រះវប្បៈ, ៣-ព្រះភទ្ទិយៈ, ៤-ព្រះមហានាម, ៥-ព្រះអស្សជិ ។

*-និគ្រោធជាតក ប្រវត្តិមិគទាយវ័ន ឈ្មោះសារនាថ ។

*-ប្រវត្តិរឿងព្រះយសពីរោះស្តាប់ ។

*-បិតាព្រះយសជាឧបាសកដល់ព្រះរតនត្រ័យមុនគេ ។

*-សម្លាញ់ព្រះយស ៤ អង្គគឺ ១-ព្រះវិមល , ២-ព្រះសុពាហុ , ៣-ព្រះបុណ្ណជិ , ៤-ព្រះគវម្បតិ រួមដោយ ៥០ អង្គផ្សេងទៀត ។

*-ព្រះសម្មាសម្ពុទ្ធ ត្រាស់បង្គាប់មិនឱ្យនិមន្តទៅក្នុងផ្លូវតែមួយ សម្រាប់ភិក្ខុ ៦០ អង្គ ទ្រង់ត្រាស់ឱ្យនិមន្តទៅផ្លូវមួយតែមួយអង្គប៉ុណ្ណោះ ក្នុងការផ្សព្វផ្សាយព្រះពុទ្ធសាសនា ដែលមានសេចក្តីដ៏ពីរោះថា :

ម្នាលភិក្ខុទាំងឡាយ តថាគតរួចហើយអំពីអន្ទាក់ទាំងអស់ ទោះបីជារបស់ទេវតាក្តី ទោះបីជារបស់មនុស្សក្តី ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសោត ក៏បានរួចហើយអំពីអន្ទាក់ទាំងអស់ដែរ ទោះបីជារបស់ទេវតាក្តី ទោះបីជារបស់មនុស្សក្តី ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរត្រាច់ទៅកាន់ចារិក ( គឺស្រុកនិងនិគមទាំងរាជធានី ហើយសម្តែងនូវព្រះធម៌ ) ដើម្បីជាប្រយោជន៍ និងសេចក្តីសុខ ដល់ជនជាច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីជាប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្តីសុខ



ដល់ទេវតានិងមនុស្សទាំងឡាយ ។ អ្នកទាំងឡាយកុំទៅពីរនាក់តាមផ្លូវមួយជាមួយគ្នាឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរសម្តែងធម៌ឱ្យពីរោះបទដើម បទកណ្តាល និងបទចុង ។ អ្នកទាំងឡាយចូរប្រកាសនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ប្រកបដោយអត្ថនិងព្យញ្ជនៈដ៏ពេញបរិបូណ៌ទាំងអស់ ។ សត្វទាំងឡាយដែលមានធូលី គឺរាគាទិក្កិលេសតិចក្នុងភ្នែកក៏មាន សត្វទាំងនោះ នឹងសាបសូន្យចាកមគ្គផល ព្រោះមិនបានស្តាប់នូវព្រះធម៌។ សត្វទាំងឡាយអ្នកបម្រុងត្រាស់ដឹងធម៌គង់នឹងមាន។ ម្នាលភិក្ខុទាំងឡាយ ចំណែកតថាគត ក៏នឹងចូលទៅកាន់សេនានិគម ក្នុងឧរុវេលាប្រទេសដើម្បីសម្តែងនូវព្រះធម៌ដែរ ។ (វិនយបិដកលេខ ៦ , ទំព័រ ៦៦-៦៧ )

*-ព្រៃឥសិបតនមិគទាយវ័ននេះ ជាសំវេជនីយដ្ឋាន ១ កន្លែងដ៏សំខាន់ក្រៃលែង ។ សាសនធម៌ សច្ចធម៌ និងបរមធម៌របស់ព្រះសម្មាសម្ពុទ្ធជាបរមសាស្តា បានវិលទៅ ដូចជាកងចក្រប្រព្រឹត្តទៅក្នុងចិត្តសន្តានរបស់វេនេយ្យសត្វ ដែលមានកិលេសស្រាលស្តើង មានតណ្ហាមានះទិដ្ឋិជាធូលីតិចក្នុងភ្នែក ក៏បាននូវធម្មចក្ខុភ្នែកឃើញធម៌ បានចាក់ធ្លុះនូវធម៌ដែលព្រះពុទ្ធអង្គ ទ្រង់ត្រាស់សម្តែង ។

*-ថ្វាយបង្គំព្រះចេតិយប្រោសព្រះយស អនុបុព្វីកថាលើក

ទី ១ ។ ព្រះយសសម្រេចព្រះអរហត្ត និងជាឯហិភិក្ខុនៅទីនេះ ។

*-ថ្វាយបង្គំមូលព្រះគន្ធកុដិនៃព្រះសម្មាសម្ពុទ្ធក្នុងវស្សាទី១ របស់ព្រះអង្គ ទាំងដែលព្រះអង្គទ្រង់គង់ប្រថាប់ថ្ងៃក្រោយៗ មកទៀត ។

*-ថ្វាយបង្គំសសរថ្មរបស់ព្រះបាទធម្មាសោក តាំងចិត្តនឹកដល់ព្រះចេតិយបញ្ចុះព្រះបរមសារីរិកធាតុ ៨៤.០០០ ព្រះចេតិយ ។

*-ថ្វាយបង្គំបរិភោគចេតិយ (ធម្មរាជិកស្តូប) កន្លែងព្រះ-អង្គទ្រង់ត្រាស់សម្តែងនូវអនត្តលក្ខណសូត្រ ។

# អនត្តលក្ខណសូត្រ

(បិដកលេខ ៦ , ទំព័រ ៤០-៤៧)

**ឯវម្មេ សុតំ** ( សូត្រនេះឈ្មោះអនត្តលក្ខណសូត្រ ) គឺខ្ញុំ ( ឈ្មោះ អានន្ទ ) បានស្តាប់មកហើយ យ៉ាងនេះថា

**ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ** សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងទីព្រៃឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។

**តត្រ ខោ ភគវា បញ្ចវគ្គិយេ ភិក្ខូ អាមន្តេសិ**



ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅនូវបញ្ចវគ្គិយភិក្ខុទាំងឡាយក្នុងទីនោះ ( ឱ្យនាំគ្នាតាំងចិត្តស្តាប់នូវភាសិតនេះ ) ថា

**រូបំ ភិក្ខវេ អនត្តា** ម្នាលភិក្ខុទាំងឡាយ រូបគឺរាងកាយជាអនត្តា មិនមែនជារបស់ខ្លួនឡើយ ។

**រូបញ្ច ហិទំ ភិក្ខវេ អត្តា អភវិស្ស** ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើរូបនេះជារបស់ខ្លួនពិតមែន

**ន យិទំ រូបំ អាពាធាយ សំវត្តេយ្យ** រូបនេះក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធ គឺជំងឺតម្កាត់ឡើយ ។

**លព្ភេថ ច រូបេ ឯវំ មេ រូបំ ហោតុ ឯវំ មេ រូបំ មា អហោសីតិ** ម្យ៉ាងទៀត បុគ្គលគប្បីបាន ( នូវអំណាច ) ក្នុងរូបថា សូមឱ្យរូបរបស់អញយ៉ាងនេះទៅ សូមកុំឱ្យរូបរបស់អញយ៉ាងនេះឡើយ ។

**យស្មា ច ខោ ភិក្ខវេ រូបំ អនត្តា តស្មា រូបំ អាពាធាយ សំវត្តតិ** ម្នាលភិក្ខុទាំងឡាយ រូបជាអនត្តាពិតមែន ព្រោះហេតុនោះ បានជារូបចេះតែប្រព្រឹត្តទៅដើម្បីអាពាធ ។

**ន ច លព្ភតិ រូបេ ឯវំ មេ រូបំ ហោតុ ឯវំ មេ រូបំ មា អហោសីតិ** ម្យ៉ាងទៀត បុគ្គលមិនបាន (នូវអំណាច) ក្នុងរូបថា សូមឱ្យរូបរបស់អញយ៉ាងនេះទៅ សូមកុំឱ្យរូបរបស់អញ

យ៉ាងនេះឡើយ ។

**វេទនា អនត្តា** វេទនាមិនមែនជារបស់ខ្លួនឡើយ ។

**វេទនា ច ហិទំ ភិក្ខវេ អត្តា អភវិស្ស** ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើវេទនានេះជារបស់ខ្លួនពិតមែន

**ន យិទំ វេទនា អាពាធាយ សំវត្តេយ្យ** វេទនានេះក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធឡើយ ។

**លព្ភេថ ច វេទនាយ ឯវំ មេ វេទនា ហោតុ ឯវំ មេ វេទនា មា អហោសីតិ** ម្យ៉ាងទៀត បុគ្គលគប្បីបាន ( នូវអំណាច ) ក្នុងវេទនាថា សូមឱ្យវេទនារបស់អញយ៉ាងនេះទៅ សូមកុំឱ្យវេទនារបស់អញយ៉ាងនេះឡើយ ។

**យស្មា ច ខោ ភិក្ខវេ វេទនា អនត្តា តស្មា វេទនា អាពាធាយ សំវត្តតិ** ម្នាលភិក្ខុទាំងឡាយ វេទនាជាអនត្តាពិតមែន ព្រោះហេតុនោះ បានជាវេទនា ចេះតែប្រព្រឹត្តទៅដើម្បីអាពាធ ។

**ន ច លព្ភតិ វេទនាយ ឯវំ មេ វេទនា ហោតុ ឯវំ មេ វេទនា មា អហោសីតិ** ម្យ៉ាងទៀត បុគ្គលមិនបាន ( នូវអំណាច ) ក្នុងវេទនាថា សូមឱ្យវេទនារបស់អញយ៉ាងនេះទៅ សូមកុំឱ្យវេទនារបស់អញយ៉ាងនេះឡើយ ។



**សញ្ញា អនត្តា** សញ្ញាមិនមែនជារបស់ខ្លួនឡើយ ។

**សញ្ញា ច ហិទំ ភិក្ខវេ អត្តា អភវិស្ស** ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើសញ្ញានេះជារបស់ខ្លួនពិតមែន

**ន យិទំ សញ្ញា អាពាធាយ សំវត្តេយ្យ** សញ្ញានេះក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធឡើយ ។

**លព្ភេថ ច សញ្ញាយ ឯវំ មេ សញ្ញា ហោតុ ឯវំ មេ សញ្ញា មា អហោសីតិ** ម្យ៉ាងទៀត បុគ្គលគប្បីបាន ( នូវអំណាច ) ក្នុងសញ្ញាថា សូមឱ្យសញ្ញារបស់អញយ៉ាងនេះទៅ សូមកុំឱ្យសញ្ញារបស់អញយ៉ាងនេះឡើយ ។

**យស្មា ច ខោ ភិក្ខវេ សញ្ញា អនត្តា តស្មា សញ្ញា អាពាធាយ សំវត្តតិ** ម្នាលភិក្ខុទាំងឡាយ សញ្ញាជាអនត្តាពិតមែន ព្រោះហេតុនោះបានជាសញ្ញាចេះតែប្រព្រឹត្តទៅដើម្បីអាពាធ ។

**ន ច លព្ភតិ សញ្ញាយ ឯវំ មេ សញ្ញា ហោតុ ឯវំ មេ សញ្ញា មា អហោសីតិ** ម្យ៉ាងទៀត បុគ្គលមិនបាន ( នូវអំណាច ) ក្នុងសញ្ញាថា សូមឱ្យសញ្ញារបស់អញយ៉ាងនេះទៅ សូមកុំឱ្យសញ្ញារបស់អញយ៉ាងនេះឡើយ ។

**សង្ខារា អនត្តា** សង្ខារទាំងឡាយ មិនមែនជារបស់ខ្លួន

ឡើយ ។

**សង្ខារា ច ហិទំ ភិក្ខវេ អត្តា អភវិស្សំសុ** ម្នាលភិក្ខុទាំងឡាយប្រសិនណាបើសង្ខារទាំងឡាយនេះជារបស់ខ្លួនពិតមែន

**ន យិទំ សង្ខារា អាពាធាយ សំវត្តេយ្យុំ** សង្ខារទាំងឡាយនេះ ក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធឡើយ ។

**លព្ភេថ ច សង្ខារេសុ ឯវំ មេ សង្ខារា ហោន្តុ ឯវំ មេ សង្ខារា មា អហេសុន្តិ** ម្យ៉ាងទៀត បុគ្គលគប្បីបាន ( នូវអំណាច ) ក្នុងសង្ខារទាំងឡាយថា សូមឱ្យសង្ខារទាំងឡាយរបស់អញយ៉ាងនេះទៅ សូមកុំឱ្យសង្ខារទាំងឡាយរបស់អញយ៉ាងនេះឡើយ ។

**យស្មា ច ខោ ភិក្ខវេ សង្ខារា អនត្តា តស្មា សង្ខារា អាពាធាយ សំវត្តន្តិ** ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយជាអនត្តាពិតមែន ព្រោះហេតុនោះ បានជាសង្ខារទាំងឡាយចេះតែប្រព្រឹត្តទៅដើម្បីអាពាធ ។

**ន ច លព្ភតិ សង្ខារេសុ ឯវំ មេ សង្ខារា ហោន្តុ ឯវំ មេ សង្ខារា មា អហេសុន្តិ** ម្យ៉ាងទៀត បុគ្គលមិនបាន ( នូវអំណាច ) ក្នុងសង្ខារទាំងឡាយថា សូមឱ្យសង្ខារទាំងឡាយរបស់អញយ៉ាងនេះទៅ សូមកុំឱ្យសង្ខារទាំងឡាយរបស់អញយ៉ាង





នេះឡើយ ។

**វិញ្ញាណំ អនត្តា** វិញ្ញាណមិនមែនជារបស់ខ្លួនឡើយ ។

**វិញ្ញាណញ្ច ហិទំ ភិក្ខវេ អត្តា អភវិស្ស** ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើវិញ្ញាណនេះជារបស់ខ្លួនពិតមែន

**ន យិទំ វិញ្ញាណំ អាពាធាយ សំវត្តេយ្យ** វិញ្ញាណនេះ ក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធឡើយ ។

**លព្ភេថ ច វិញ្ញាណេ ឯវំ មេ វិញ្ញាណំ ហោតុ ឯវំ មេ វិញ្ញាណំ មា អហោសីតិ** ម្យ៉ាងទៀត បុគ្គលគប្បីបាន ( នូវអំណាច ) ក្នុងវិញ្ញាណថា សូមឱ្យវិញ្ញាណរបស់អញយ៉ាងនេះទៅ សូមកុំឱ្យវិញ្ញាណរបស់អញយ៉ាងនេះឡើយ ។

**យស្មា ច ខោ ភិក្ខវេ វិញ្ញាណំ អនត្តា តស្មា វិញ្ញាណំ អាពាធាយ សំវត្តតិ** ម្នាលភិក្ខុទាំងឡាយ វិញ្ញាណជាអនត្តាពិតមែន ព្រោះហេតុនោះ បានជាវិញ្ញាណចេះតែប្រព្រឹត្តទៅដើម្បីអាពាធ ។

**ន ច លព្ភតិ វិញ្ញាណេ ឯវំ មេ វិញ្ញាណំ ហោតុ ឯវំ មេ វិញ្ញាណំ មា អហោសីតិ** ម្យ៉ាងទៀត បុគ្គលមិនបាន ( នូវអំណាច ) ក្នុងវិញ្ញាណថា សូមឱ្យវិញ្ញាណរបស់អញយ៉ាងនេះទៅ សូមកុំឱ្យវិញ្ញាណរបស់អញយ៉ាងនេះឡើយ ។

**តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់នូវសេចក្តីនោះថា ដូចម្តេច រូបទៀង ឬមិនទៀង ?

**អនិច្ចំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន រូបមិនទៀងទេ ។

**យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ** របស់ឯណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ?

**ទុក្ខំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ ។

**យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ** ក៏របស់ឯណាដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឬ ដើម្បីនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ?

**នោ ហេតំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនុ៎ះទេ ។

**តំ កឹ មញ្ញថ ភិក្ខវេ វេទនា និច្ចា វា អនិច្ចា វាតិ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវសេចក្តីនោះថាដូចម្តេច វេទនាទៀង ឬមិនទៀង ?

**អនិច្ចា ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន វេទនាមិនទៀងទេ។



**យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ** របស់ឯណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ?

**ទុក្ខំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ ។

**យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ** ក៏របស់ឯណាដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឬ ដើម្បីនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ?

**នោ ហេតំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនុ៎ះទេ ។

**តំ កឹ មញ្ញថ ភិក្ខវេ សញ្ញា និច្ចា វា អនិច្ចា វាតិ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវសេចក្តីនោះថាដូចម្តេច សញ្ញាទៀង ឬមិនទៀង ?

**អនិច្ចា ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន សញ្ញាមិនទៀងទេ។

**យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ** របស់ឯណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ?

**ទុក្ខំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ ។

**យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ** ក៏របស់ឯណាដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឬ ដើម្បីនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ?

**នោ ហេតំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនុ៎ះទេ ។

**តំ កឹ មញ្ញថ ភិក្ខវេ សង្ខារា និច្ចា វា អនិច្ចា វាតិ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវសេចក្តីនោះថាដូចម្តេច សង្ខារទាំងឡាយទៀង ឬមិនទៀង ?

**អនិច្ចា ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន សង្ខារទាំងឡាយមិនទៀងទេ ។

**យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ** របស់ឯណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ?

**ទុក្ខំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ ។

**យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ** ក៏របស់ឯណាដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជា





ធម្មតា គួរឬ ដើម្បីនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ?

**នោ ហេតំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនុ៎ះទេ ។

**តំ កឹ មញ្ញថ ភិក្ខវេ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវសេចក្តីនោះថាដូចម្តេច វិញ្ញាណទៀង ឬមិនទៀង ?

**អនិច្ចំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន វិញ្ញាណមិនទៀងទេ។

**យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ** របស់ឯណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ?

**ទុក្ខំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ ។

**យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ** ក៏របស់ឯណាដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឬ ដើម្បីនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ?

**នោ ហេតំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនុ៎ះទេ ។

**តស្មាតិហ ភិក្ខវេ យំ កិញ្ចិ រូបំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យន្ទូរេ សន្តិកេ វា សព្វំ រូបំ** ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ រូបឯណាមួយ ដែលជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី រូបឯណាដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី រូបទាំងអស់នោះ ក៏គ្រាន់តែជារូប ( ប៉ុណ្ណោះឯង ) ។

**នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ** អ្នកទាំងឡាយគួរឃើញនូវសេចក្តីនុ៎ះដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិត យ៉ាងនេះ ដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។

**យា កាចិ វេទនា អតីតានាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា សព្វា វេទនា** វេទនាឯណាមួយដែលជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី





វេទនាឯណាដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី វេទនាទាំងអស់នោះ ក៏គ្រាន់តែជាវេទនា (ប៉ុណ្ណោះឯង ) ។

**នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ** អ្នកទាំងឡាយគួរឃើញនូវសេចក្តីនុ៎ះដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិតយ៉ាងនេះ ដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។

**យា កាចិ សញ្ញា អតីតានាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា សព្វា សញ្ញា** សញ្ញាឯណាមួយដែលជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី សញ្ញាឯណាដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី សញ្ញាទាំងអស់នោះ ក៏គ្រាន់តែជាសញ្ញា ( ប៉ុណ្ណោះឯង ) ។

**នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ** អ្នកទាំងឡាយគួរឃើញនូវសេចក្តីនុ៎ះដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិត យ៉ាងនេះ ដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែន

ជាខ្លួនរបស់អញឡើយ ។

**យេ កេចិ សង្ខារា អតីតានាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យេ ទូរេ សន្តិកេ វា សព្វេ សង្ខារា** សង្ខារទាំងឡាយឯណាមួយដែលជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី សង្ខារទាំងឡាយឯណាដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី សង្ខារទាំងឡាយទាំងអស់នោះ ក៏គ្រាន់តែជាសង្ខារ (ប៉ុណ្ណោះឯង) ។

**នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ** អ្នកទាំងឡាយគួរឃើញនូវសេចក្តីនុ៎ះដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិត យ៉ាងនេះ ដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។

**យំ កិញ្ចិ វិញ្ញាណំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យន្ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ** វិញ្ញាណឯណាមួយដែលជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី



វិញ្ញាណឯណាដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី វិញ្ញាណទាំងអស់នោះ ក៏គ្រាន់តែជាវិញ្ញាណ (ប៉ុណ្ណោះឯង) ។

**នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ** អ្នកទាំងឡាយគួរឃើញនូវសេចក្តីនុ៎ះដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិត យ៉ាងនេះ ដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។

**ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ រូបស្មឹបិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ សញ្ញាយបិ និព្វិន្ទតិ សង្ខារេសុបិ និព្វិន្ទតិ វិញ្ញាណស្មឹបិ និព្វិន្ទតិ** ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កបានស្តាប់ហើយ យល់ឃើញយ៉ាងនេះ ក៏នឿយណាយក្នុងរូបផង នឿយណាយក្នុងវេទនាផង នឿយណាយក្នុងសញ្ញាផង នឿយណាយក្នុងសង្ខារទាំងឡាយផង នឿយណាយក្នុងវិញ្ញាណផង ។

**និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ** កាលបើនឿយណាយ (យ៉ាងនេះហើយ) ក៏ប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះ (ចាកអាសវៈ) ព្រោះកិរិយាប្រាសចាកតម្រេក ។

**វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ** កាលដែលចិត្ត

ផុតស្រឡះ ( ចាកអាសវៈ ) ហើយ ញាណ ( របស់អរិយសាវក័នោះ ) ក៏កើតឡើងប្រាកដថា ចិត្ត ( របស់អញ ) ផុតស្រឡះ (ចាកអាសវៈ) ហើយ ។

**ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ** ( អរិយសាវក័នោះ ) ក៏ដឹងច្បាស់ដូច្នេះថា ជាតិ ( របស់អញ ) អស់ហើយ មគ្គព្រហ្មចរិយធម៌អញបាននៅរួចហើយ កិច្ចដែលគួរធ្វើ អញក៏បានធ្វើរួចហើយ កិច្ចឯទៀតក្រៅពីនេះ មិនមាន (ដល់អញ ) ឡើយ ។

**ឥទមវោច ភគវា** ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បានត្រាស់សម្តែងនូវសូត្រនេះចប់ហើយ ។

**អត្តមនា បញ្ចវគ្គិយា ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុំ** បញ្ចវគ្គិយភិក្ខុទាំងឡាយ ក៏មានចិត្តត្រេកអររីករាយចំពោះភាសិត នៃព្រះដ៏មានព្រះភាគជាម្ចាស់ ។

**ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញមានេ បញ្ចវគ្គិយានំ ភិក្ខូនំ អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចឹសូតិ** ក៏កាលដែលព្រះដ៏មានព្រះភាគជាម្ចាស់ កំពុងត្រាស់សម្តែងនូវវេយ្យាករណ៍នេះ ចិត្តរបស់ភិក្ខុទាំង ៥ រូប បានរួចស្រឡះហើយចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ (ថាអញ





ថាយើងទៀតឡើយ ) ។

(របៀបសូត្រតាមភាណវារៈ)

**( អនត្តលក្ខណសូត្រ ចប់)**

*-ថ្វាយបង្គំព្រះពោធិព្រឹក្ស ព្រះពុទ្ធប្បដិមា ២៨ ព្រះអង្គ។

## ព្រះនាមព្រះពុទ្ធ ២៨ ព្រះអង្គ

**នមោ មេ សព្វពុទ្ធានំ ឧប្បន្នានំ មហេសិនំ**

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំចំពោះព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គដែលបានត្រាស់រួចមកហើយ ព្រះអង្គស្វែងរកគុណដ៏ធំ (ព្រះសម្ពុទ្ធទាំងនោះគឺ )

១-**តណ្ហង្ករោ មហាវីរោ** = ព្រះតណ្ហង្ករ ព្រះអង្គមានព្យាយាមធំ

២-**មេធង្ករោ មហាយសោ** = ព្រះមេធង្ករ ព្រះអង្គមានយសធំ

៣-**សរណង្ករោ លោកហិតោ** = ព្រះសរណង្ករ ព្រះអង្គធ្វើឱ្យជាប្រយោជន៍ដល់សត្វលោក

៤.**ទីបង្ករោ ជុតិន្ធរោ** ៖ ព្រះទីបង្ករ ព្រះអង្គទ្រទ្រង់នូវបញ្ញាដ៏រុងរឿង

៥.**កោណ្ឌញ្ញោ ជនបាមោក្ខោ** ៖ ព្រះកោណ្ឌញ្ញៈ ព្រះអង្គជាប្រធាននៃពពួកជន

៦.**មង្គលោ បុរិសាសភោ** ៖ ព្រះមង្គលៈ ព្រះអង្គជាបុរសដ៏ប្រសើរ

៧.**សុមនោ សុមនោ ធីរោ** ៖ ព្រះសុមនៈ ព្រះអង្គជាអ្នកប្រាជ្ញមានព្រះហឫទ័យដ៏ល្អ

៨.**រេវតោ រតិវឌ្ឍនោ** ៖ ព្រះរេវតៈ ព្រះអង្គញ៉ាំងសេចក្តីត្រេកអរឱ្យចម្រើន

៩.**សោភិតោ គុណសម្បន្នោ** ៖ ព្រះសោភិតៈ ព្រះអង្គបរិបូណ៌ដោយព្រះគុណ

១០.**អនោមទស្សី ជនុត្តមោ** ៖ ព្រះអនោមទស្សី ព្រះអង្គឧត្តមជាងពពួកជន

១១.**បទុមោ លោកបជ្ជោតោ** ៖ ព្រះបទុមៈ ព្រះអង្គញ៉ាំងលោកឱ្យភ្លឺស្វាង

១២.**នារទោ វរសារថី** ៖ ព្រះនារទៈ ព្រះអង្គដូចជាសារថីដ៏ប្រសើរ



១៣.**បទុមុត្តរោ សត្តសារោ** ៖ ព្រះបទុមុត្តរៈ ព្រះអង្គជាខ្លឹមសារនៃពួកសត្វ

១៤.**សុមេធោ អប្បដិបុគ្គលោ** ៖ ព្រះសុមេធៈ ព្រះអង្គរកបុគ្គលប្រៀបដូចគ្មាន

១៥.**សុជាតោ សព្វលោកគ្គោ** ៖ ព្រះសុជាតៈ ព្រះអង្គប្រសើរលើសជាងសត្វលោកទាំងពួង

១៦.**បិយទស្សី នរាសភោ** ៖ ព្រះបិយទស្សី ព្រះអង្គប្រសើរជាងនរជន

១៧.**អត្ថទស្សី ការុណិកោ** ៖ ព្រះអត្ថទស្សី ព្រះអង្គប្រកបដោយករុណា

១៨.**ធម្មទស្សី តមោនុទោ** ៖ ព្រះធម្មទស្សី ព្រះអង្គបន្ទោបង់នូវងងឹត

១៩.**សិទ្ធត្ថោ អសមោ លោកេ** ៖ ព្រះសិទ្ធត្ថ ព្រះអង្គឥតមានអ្នកណាស្មើក្នុងលោក

២០.**តិស្សោ ច វទតំ វរោ** ៖ ព្រះតិស្សៈ ព្រះអង្គប្រសើរជាងអ្នកប្រាជ្ញខាងសម្តីទាំងឡាយ

២១.**ផុស្សោ ច វរទោ ពុទ្ធោ** ៖ ព្រះពុទ្ធទ្រង់ព្រះនាមផុស្សៈ ព្រះអង្គប្រទាននូវធម៌ដ៏ប្រសើរ

**២២.វិបស្សី ច អនូបមោ** = ព្រះវិបស្សី ព្រះអង្គឥតមានអ្នកណាប្រៀបផ្ទឹមបានឡើយ

**២៣.សិខី សព្វហិតោ សត្ថា** = ព្រះសិខី ព្រះអង្គជាគ្រូប្រៀនប្រដៅធ្វើឱ្យជាប្រយោជន៍ដល់សត្វទាំងពួង

**២៤.វេស្សភូ សុខទាយកោ** = ព្រះវេស្សភូ ព្រះអង្គប្រទាននូវសេចក្តីសុខ

**២៥.កកុសន្ធោ សត្ថវាហោ** = ព្រះកកុសន្ធៈ ព្រះអង្គនាំសត្វចេញចាកផ្លូវឆ្ងាយដាច់ស្រយាល គឺកិលេស

**២៦.កោនាគមនោ រណញ្ជហោ** = ព្រះកោនាគមនៈ ព្រះអង្គបំបាត់បង់នូវសត្រូវ គឺកិលេស

**២៧.កស្សបោ សិរិសម្បន្នោ** = ព្រះកស្សបៈ ព្រះអង្គបរិបូណ៌ដោយសិរី

**២៨.គោតមោ សក្យបុង្គវោ** = ព្រះគោតម ព្រះអង្គប្រសើរចម្បងជាងពួកសក្យរាជ ។

✳.សូត្រព្រះធម្មចក្កប្បវត្តនសូត្រ មុខសិលាចារឹកអក្សរខ្មែរក្បែរព្រះពោធិព្រឹក្ស ។

✳.ចូលក្នុងព្រះវិហារថ្វាយបង្គំព្រះបរមសារីរិកធាតុ ។



✳.**វត្តខ្មែរពារាណសី** ជាទីរីករាយនៃពុទ្ធបរិស័ទ ។

✳.ទស្សនាទន្លេគង្គា សូត្រធម៌ផ្សាយមេត្តា ឧទ្ទិសបុណ្យ ។

## ឋានត្រៃរតនៈ

ក្រុងពារាណសីទឹកដីពោធិសត្វ    ក្នុងសង្សារវដ្តបំពេញបារមី
ព្រះបាទព្រហ្មទត្តគ្រងដែនកាសី    ព្រះពោធិសត្វថ្លៃបួសជាតាបស ។
ឥសិបតនៈព្រៃមិគទាយា    ឋានព្រះភគវាគ្រប់អង្គទាំងអស់
សម្តែងធម្មចក្កប្រោសពួកតាបស    អរិយមគ្គខ្ពង់ខ្ពស់បឋមទេសនា ។
អាសាឍបុណ្ណមីថ្ងៃកំណើតធម៌    ទេសនាបវរមជ្ឈិមាយាត្រា
ថ្ងៃខួបកំណើតព្រះធម៌ទេសនា    បរិស័ទជ្រះថ្លាថ្វាយផ្កាចេតិយ ។
អាសាឍបុណ្ណមីថ្ងៃកំណើតសង្ឃ    សរណៈពេញអង្គសង្ឃគម្រប់បី
ឋានត្រៃរតនៈក្នុងដែនកាសី    អាសាឍបុណ្ណមីអាសាឡ្ហបូជា ។
ចេតិយព្រះយសខ្ពស់ព្រោះសសរ    យសបានស្តាប់ធម៌តលំដាប់គ្នា
ឯហិភិក្ខុដោយព្រះភគវា    ព្រះយសបានជាសង្ឃព្រះអរហន្ត ។
ហាសិបបួនអង្គសម្លាញ់ព្រះយស    មកបួសទាំងអស់ព្រៃមិគទាយវ័ន
ឋានត្រៃរតនៈឋានព្រះភគវន្ត    ត្រាស់ប្រាប់អរហន្តចេញផ្សាយសាសនា ។
ខ្ញុំថ្វាយបង្គំឋានត្រៃរតនៈ    ដោយចិត្តស្មោះស្ម័គ្រនឹកព្រះសាស្តា
នឹកព្រះអរហន្តនឹកធម៌ទេសនា    ខ្ញុំសូមប្រាថ្នាផុតកាមលោកីយ៍ ។

ដោយ **ប.ស.វ.**

## ពុទ្ធគយា ឧរុវេលាសេនានិគម

*-ពុទ្ធគយា មហាសង្ឃារាម ព្រះពុទ្ធឃោសាចារ្យបួស នៅវត្តនេះ ។

*-បល្ល័ង្កខាងកើតគល់ព្រះពោធិព្រឹក្ស ជាទីត្រាស់ដឹងនៃ ព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គ ។

## ជយបរិត្តគាថា

**មហាការុណិកោ នាថោ ហិតាយ សព្វបាណិនំ**
**បូរេត្វា បារមី សព្វា បត្តោ សម្ពោធិមុត្តមំ ។**

ព្រះសម្មាសម្ពុទ្ធ ជាទីពឹងនៃសត្វលោក ទ្រង់ប្រកបដោយ មហាករុណា ព្រះអង្គបំពេញនូវបារមីទាំងឡាយទាំងពួងដើម្បីប្រ-យោជន៍ដល់សត្វទាំងអស់ ហើយទ្រង់បានដល់នូវសម្ពោធិញ្ញាណ ដ៏ឧត្តមហើយ ។

**ឯតេន សច្ចវជ្ជេន ហោតុ តេ ជយមង្គលំ**

ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមជយមង្គលកើត មានដល់អ្នក ។





**ជយន្តោ ពោធិយា មូលេ សក្យានំ នន្ទិវឌ្ឍនោ**
**ឯវំ ត្វំ វិជយោ ហោហិ ជយស្សុ ជយមង្គលេ**
**អបរាជិតបល្លង្កេ សីសេ បឋវិបោក្ខរេ**
**អភិសេកេ សព្វពុទ្ធានំ អគ្គប្បត្តោ បមោទតិ ។**

ព្រះសម្មាសម្ពុទ្ធ ទ្រង់ញុាំងសេចក្ដីត្រេកអរនៃសក្យ ទាំងឡាយឱ្យចម្រើន ព្រះអង្គឈ្នះមារហើយ បានដល់នូវភាពជា បុគ្គលប្រសើរបំផុត ទ្រង់រីករាយ ( ចំពោះធម៌ដែលព្រះអង្គត្រាស់-ដឹង )លើអបរាជិតបល្ល័ង្ក ជាជយមង្គល ទៀបគល់ពោធិព្រឹក្សត្រង់ ផ្ចិតផែនដីដូចជាស្លឹកឈូក ជាទីអភិសេកនៃព្រះពុទ្ធគ្រប់ព្រះអង្គ (យ៉ាងណាមិញ ) សូមឱ្យអ្នកជាបុគ្គលមានជម្នះឈ្នះ (អស់សត្រូវ ) យ៉ាងនោះឯង ។

**សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ**
**សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ ។**

( ពេលណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ពេលនោះ ) ឈ្មោះថាជានក្ខត្តឫក្សល្អ ជាមង្គលល្អ ជាពេលភ្លឺស្វាងល្អ ជាពេលនៃអរុណរះល្អ ជាខណៈល្អ ជាយាម ល្អ ( ទានដែលបុគ្គលបានបូជាហើយ ) ដល់ព្រហ្មចារីបុគ្គល ទាំងឡាយ ( ក្នុងពេលនោះ ) ឈ្មោះថាជាគ្រឿងបូជាល្អ ។

**បទក្ខិណំ កាយកម្មំ      វាចាកម្មំ បទក្ខិណំ**

**បទក្ខិណំ មនោកម្មំ      បណិធី តេ បទក្ខិណា ។**

( ក្នុងថ្ងៃនោះ ) កាយកម្ម ក៏ឈ្មោះថានាំឱ្យមានសេចក្តីចម្រើន វចីកម្ម ក៏ឈ្មោះថានាំឱ្យមានសេចក្តីចម្រើន មនោកម្ម ក៏ឈ្មោះថានាំឱ្យមានសេចក្តីចម្រើន សេចក្តីប្រាថ្នាទាំងឡាយរបស់អ្នកទាំងនោះ ក៏ឈ្មោះថានាំឱ្យមានសេចក្តីចម្រើន ។

**បទក្ខិណានិ កត្វាន      លភន្តត្ថេ បទក្ខិណេ**

បុគ្គលដែលបានធ្វើនូវកាយកម្ម វចីកម្ម មនោកម្ម គួរដល់សេចក្តីចម្រើន ( យ៉ាងនេះ ) ហើយ ក៏រមែងបាននូវប្រយោជន៍ដ៏ចម្រើនទាំងឡាយ ។

**តេ អត្ថលទ្ធា សុខិតា      វិរូឡ្ហា ពុទ្ធសាសនេ**

**អរោគា សុខិតា ហោថ      សហ សព្វេហិ ញាតិភិ ។**

អ្នកទាំងឡាយ ( ទាំងបុរសទាំងស្ត្រី ) នោះ ចូរបាននូវប្រយោជន៍ បាននូវសេចក្តីសុខ ចូរចម្រើនក្នុងព្រះពុទ្ធសាសនា ចូរកុំឱ្យមានរោគ ឱ្យបាននូវសេចក្តីសុខ ព្រមទាំងញាតិទាំងឡាយគ្រប់គ្នា ។ (របៀបសូត្រតាមភាណវារៈ)

**(ជយបរិត្តគាថា ចប់)**





# ពុទ្ធោ នាគល់ព្រះពោធិព្រឹក្ស

(បិដកលេខ ៦៦ , ទំព័រ ២៣៧-២៣៩)

**ពុទ្ធោតិ យោ សោ ភគវា សយម្ភូ អនាចរិយកោ បុព្វេ អននុស្សុតេសុ ធម្មេសុ សាមំ សច្ចានិ អភិសម្ពុជ្ឈិ តត្ថ ច សព្វញ្ញុតំ បត្តោ ពលេសុ ច វសីភាវំ បត្តោ ។**

ពាក្យថា **ពុទ្ធោ** គឺព្រះដ៏មានព្រះភាគអង្គណា ព្រះដ៏មានព្រះភាគអង្គនោះជាព្រះសយម្ភូ ទ្រង់ត្រាស់ដឹងដោយព្រះអង្គឯង មិនមាននូវគ្រូអាចារ្យឡើយ ទ្រង់ត្រាស់ដឹងដោយប្រពៃក្រៃលែងនូវសច្ចៈក្នុងធម៌ទាំងនោះដោយព្រះអង្គឯង ពុំបានស្តាប់ពីមុនមកឡើយ ព្រះអង្គទ្រង់ដល់នូវសព្វញ្ញុតញ្ញាណក្នុងធម៌ទាំងឡាយផង ទ្រង់ដល់នូវភាពជំនាញក្នុងពលៈទាំងឡាយផង ។

**ពុទ្ធោតិ កេនត្ថេន ពុទ្ធោ** ពាក្យថា **ពុទ្ធោ** តើ **ពុទ្ធោ** ដោយអត្ថដូចម្តេច ?

១-**ពុជ្ឈិតា សច្ចានីតិ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវសច្ចៈទាំងឡាយ ។

២-**ពោធេតា បជាយាតិ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គញ៉ាំងពពួកជនឱ្យត្រាស់ដឹងផង ។

៣-**សព្វញ្ញុតាយ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវធម៌ទាំងពួង ។

៤-**សព្វទស្សាវិតាយ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គឃើញនូវធម៌ទាំងពួងដោយញាណចក្ខុ ។

៥-**អនិញ្ញេយ្យតាយ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គមិនមានអ្នកដទៃណាដឹកនាំព្រះអង្គឡើយ ។

៦-**វិកសិតាយ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គមាននូវស្មារតីដ៏វិសេស ។

៧-**ខីណាសវសង្ខាតេន ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គដល់នូវការរាប់ថាអស់ទៅនូវអាសវៈ ។

៨-**និរុបក្កិលេសសង្ខាតេន ពុទ្ធោ** - ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គដល់នូវការរាប់ថាមិនមានឧបក្កិលេស ។

៩-**ឯកន្តវីតរាគោតិ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គប្រាសចាកនូវរាគៈដោយដាច់ខាត ។



១០-**ឯកន្តវីតទោសោតិ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គប្រាសចាកនូវទោសៈដោយដាច់ខាត ។

១១-**ឯកន្តវីតមោហោតិ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គប្រាសចាកនូវមោហៈដោយដាច់ខាត ។

១២-**ឯកន្តនិក្កិលេសោតិ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គមិនមាននូវកិលេសដោយដាច់ខាត ។

១៣-**ឯកាយនមគ្គំ គតោតិ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គយាងទៅក្នុងផ្លូវតែមួយ ជាផ្លូវទៅកាន់ព្រះនិព្វាន បានដល់សតិប្បដ្ឋាន ៤ ។

១៤-**ឯកោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណដ៏ប្រសើរមួយព្រះអង្គឯង ។

១៥-**អពុទ្ធិវិហតត្តា ពុទ្ធិប្បដិលាភត្តា ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គកម្ចាត់បង់នូវការមិនមានបញ្ញាដោយការបាននូវបញ្ញា ។

**ពុទ្ធោតិ នេតំ នាមំ មាតរា កតំ ន បិតរា កតំ ន ភាតរា កតំ ន ភគិនិយា កតំ ន មិត្តាមច្ចេហិ កតំ ន**

**ញាតិសាលោហិតេហិ កតំ ន សមណព្រាហ្មណេហិ កតំ ន ទេវតាហិ កតំ វិមោក្ខន្តិកមេតំ ពុទ្ធានំ ភគវន្តានំ ពោធិយា មូលេ សហ សព្វញ្ញុតញ្ញាណស្ស បដិលាភា សច្ឆិកា បញ្ញត្តិ យទិទំ ពុទ្ធោតិ ។**

ព្រះនាម **ពុទ្ធោ** នេះ មិនមែនជាព្រះនាមដែលព្រះមាតាថ្វាយទេ មិនមែនព្រះបិតាថ្វាយទេ មិនមែនបងប្អូនប្រុសថ្វាយទេ មិនមែនបងប្អូនស្រីថ្វាយទេ មិនមែនមិត្តអាមាត្យថ្វាយទេ មិនមែនញាតិសាលោហិតថ្វាយទេ មិនមែនសមណព្រាហ្មណ៍ថ្វាយទេ មិនមែនទេវតាថ្វាយទេ ទ្រង់ព្រះនាម **ពុទ្ធោ** នេះជាវិមោក្ខន្តិកនាម គឺព្រះនាមដែលមានក្នុងទីបំផុត នៃអរហត្តផល របស់ព្រះពុទ្ធទាំងឡាយ ទ្រង់មានព្រះភាគ ជាសច្ឆិកាបញ្ញត្តិ គឺបញ្ញត្តិព្រោះការជាក់ច្បាស់ក្នុងធម៌ទាំងពួង ដែលបានកើតព្រមគ្នាជាមួយនឹងសព្វញ្ញុតញ្ញាណ នៅគល់ព្រះពោធិព្រឹក្ស ។

**( ពុទ្ធោ នាគល់ព្រះពោធិព្រឹក្ស ចប់ )**





## សម្ពុទ្ធេ

**សម្ពុទ្ធេ អដ្ឋវីសញ្ច ទ្វាទសញ្ច សហស្សកេ**
**បញ្ចសតសហស្សានិ នមាមិ សិរសា អហំ**

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំងឡាយ ២៨ ព្រះអង្គផង ១ ម៉ឺន ២ ពាន់ព្រះអង្គផង ៥ សែនព្រះអង្គផង ដោយត្បូង ( របស់ខ្ញុំព្រះករុណា )

**តេសំ ធម្មញ្ច សង្ឃញ្ច អាទរេន នមាមិហំ**

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះធម៌ផង នូវព្រះ-សង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ដោយគោរព ។

**នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ**
**អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ**

ដោយអានុភាពនៃកិរិយានមស្ការថ្វាយបង្គំ សូមឱ្យកម្ចាត់-បង់នូវឧបទ្រពទាំងឡាយទាំងពួង ទាំងសេចក្តីអន្តរាយទាំងឡាយជាអនេកក៏ចូរឱ្យវិនាសទៅកុំបីមានសេសសល់ឡើយ ។

**សម្ពុទ្ធេ បញ្ចបញ្ញាសញ្ច ចតុវីសតិសហស្សកេ**
**ទសសតសហស្សានិ នមាមិ សិរសា អហំ**

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធ

ទាំងឡាយ ៥៥ ព្រះអង្គផង ២ ម៉ឺន ៤ ពាន់ព្រះអង្គផង ១ លាន ព្រះអង្គផង ដោយត្បូង ( របស់ខ្ញុំព្រះករុណា )

**តេសំ ធម្មញ្ច សង្ឃញ្ច អាទរេន នមាមិហំ**

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះធម៌ផង នូវព្រះ-សង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ដោយគោរព ។

**នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ**
**អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ**

ដោយអានុភាពនៃកិរិយានមស្ការថ្វាយបង្គំ សូមឱ្យកម្ចាត់-បង់នូវឧបទ្រពទាំងឡាយទាំងពួង ទាំងសេចក្ដីអន្តរាយទាំងឡាយ ជាអនេកក៏ចូរឱ្យវិនាសទៅកុំបីមានសេសសល់ឡើយ ។

**សម្ពុទ្ធេ នវុត្តរសតេ អដ្ឋចត្តាឡីសសហស្សកេ**
**វីសតិសតសហស្សានិ នមាមិ សិរសា អហំ**

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធ ទាំងឡាយ ១០៩ ព្រះអង្គផង ៤ ម៉ឺន ៨ ពាន់ព្រះអង្គផង ២ លាន ព្រះអង្គផង ដោយត្បូង ( របស់ខ្ញុំព្រះករុណា )

**តេសំ ធម្មញ្ច សង្ឃញ្ច អាទរេន នមាមិហំ**

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះធម៌ផង នូវព្រះ-សង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ដោយគោរព ។



**នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ**
**អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ**

ដោយអានុភាពនៃកិរិយានមស្ការថ្វាយបង្គំ សូមឱ្យកម្ចាត់-បង់នូវឧបទ្រពទាំងឡាយទាំងពួង ទាំងសេចក្ដីអន្តរាយទាំងឡាយ ជាអនេកក៏ចូរឱ្យវិនាសទៅកុំបីមានសេសសល់ឡើយ ។

**(សម្ពុទ្ធេ ចប់ )**

## ពុទ្ធជយមង្គល

**១- ពាហុំ សហស្សមភិនិម្មិតសាវុធន្តំ**
**គ្រីមេខលំ ឧទិតឃោរសសេន មារំ**
**ទានាទិធម្មវិធិនា ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ**

ព្រះមុនិន្ទលោកាចារ្យ ផ្ចាញ់ក្រុងមារចិត្តមោហន្ធ និម្មិតដៃ មួយពាន់ កាន់សស្ត្រាវុធនានា ។ ជិះគ្រីមេខលជាតិ គោពព្ទនាទខ្ទរ ពសុធា ព្រមដោយមារសេនា ពន្លឹកលន់កងសព្ទស៊ាន ។ ដោយ ធម្មពិធី ទានបារមីជាប្រធាន ក្រុងមារចាញ់ទ្រង់ញាណ ប្រណម្យ

កាយថ្វាយវន្ទា ។ វីជយមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជះជយា ព្រះឈ្មះមារគ្រានោះហោង ។

**២~ មារាតិរេកមភិយុជ្ឈិតសព្វរត្តឹ**
**ឃោរម្បនាឡវកមក្ខមថទ្ធយក្ខំ**
**ខន្តី សុទន្តវិធិនា ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ**

ព្រះមុនិន្ទ្រពិននាយកៈ ផ្ចាញ់អាឡវកយក្ខឃោរឃៅ រឹងរូស មិនតាំងនៅ ក្នុងខន្តីគុណសត្យា។ រហូតដល់រាត្រី ព្រះជិនស្រីទ្រង់យុទ្ធនា ក្រៃលែងក្រុងមារា ក្នុងបឋមសម្ពោធី ។ ដោយព្រះពិធីញាណ ទ្រង់ទូន្មានដោយខន្តី ញុំាងចិត្តអសុរីឱ្យបង់ព្យសន៍ចុះវន្ទា។ វីជយមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជះជយា ព្រះឈ្មះអាឡវកយក្ខហោង ។

**៣~ នាឡាគិរឹ គជវរំ អតិមត្តភូតំ**
**ទាវគ្គិចក្កមសនីវ សុទារុណន្តំ**
**មេត្តម្ពុសេកវិធិនា ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ**

ព្រះមុនិន្ទ្រពិនជិនស្រី ផ្ចាញ់ដំរីឈ្មោះនាឡា គីរីវរគជា ដ៏ហានក្លាចុះប្រេងព្រេច ។ សាហាវឆាវឆេះក្រៃ ដូចភ្លើងព្រៃឆេះកម្ទេច មុតដូចចក្រក្រុតពេជ្រ ខ្លាំងដូចកម្ទអសនី ។ ដោយព្រះ-ពិធីស្រព ស្រោចទឹកអប់គឺបារមី មេត្តាព្រះជិនស្រី ញុំាងដំរីឱ្យជ្រះថ្លា ។ វីជយមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជះជយា ព្រះឈ្មះនាឡាគីរី ។





**៤~ ឧក្ខិត្តខគ្គមតិហត្ថសុទារុណន្តំ**
**ធាវន្តិ យោជនបថង្គុលិមាលវន្តំ**
**ឥទ្ធីភិសង្ខតមនោ ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ**

ព្រះមុនិន្ទ្រពិនលោកត្រៃ មានព្រះទ័យធ្វើបាដិហារ្យ ផ្ចាញ់ចោរអង្គុលីមាល មានកម្រងគឺម្រាមដៃ នៃមនុស្សដែលគាត់កាត់មកដោតចាត់ជាមាល័យ អង់អាចអំណាចក្រៃ ដ៏មានដៃស្ទាត់ប្រ-ហារ ។ កាន់ដាវងាគ្រវី ដេញព្រះមុនីសាស្តាចារ្យ ចម្ងាយផ្លូវកន្តារ កណ្តាលព្រៃបីយោជនា ។ វីជយមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជះជយា ព្រះឈ្មះអង្គុលីមាល ។

**៥~ កត្វាន កដ្ឋមុទរំ ឥវ គព្ភិនីយា**
**ចិញ្ចាយ ទុដ្ឋវចនំ ជនកាយមជ្ឈេ**
**សន្តេន សោមវិធិនា ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ**

ព្រះមុនិន្ទមានព្រះភាគ ផ្ចាញ់ទ្រុស្តពាក្យនាងចិញ្ចា អំពើធ្វើដូចជា ស្រីមានគភ៌ចាស់ចើសពោះ ។ យកឈើធ្វើជាកូន ព័ទ្ធពោះខ្លួនពោលទ្រគោះ ព្រះពុទ្ធឈ្នះកាលនោះ ដោយសមាចារពិធី ។ រម្ងាប់ពាក្យចណ្ឌាល នាកណ្តាលជនប្រុសស្រី ចិញ្ចាចាញ់បារមី គឺសច្ចំពាក្យសត្យា ។ វីជយមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជះជយា ព្រះសាស្តាឈ្នះចិញ្ចា ។

**៦. សច្ចំ វិហាយមតិសច្ចកវាទកេតុំ**
**វាទាភិរោបិតមនំ អតិអន្ធភូតំ**
**បញ្ញាបទីបជលិតោ ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ**

ព្រះមុនិន្ទពិនអ្នកប្រាជ្ញ រុងរឿងស្វាចដោយបញ្ញា ផ្ចាញ់សច្ចកៈជា និគ្រន្ថក្រៅពុទ្ធវិន័យ ។ អធ្យាស្រ័យលះបង់ ពាក្យសត្យត្រង់តាមគាប់ចៃ សរសើរខ្លួនឯងក្រៃ លើកកម្ពស់ដូចដងទង់ បង្កើតមួងងឹត ដោយពោលឥតពាក្យទៀងត្រង់ ព្រះទ្រង់កម្ចាត់បង់ ដោយប្រទីបគឺបញ្ញា ។ វីជយមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជះជយា ឈ្នះសច្ចកនិគ្រន្ថ ។

**៧. នន្ទោបនន្ទភុជគំ វិពុធំ មហិទ្ធឹ**
**បុត្តេន ថេរភុជគេន ទមាបយន្តោ**



**ឥទ្ធូបទេសវិធិនា ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ**

ព្រះមុនិន្ទពិនទ្រង់ញាណ ញុំាងមោគ្គល្លានមានអំណាច ឱ្យប្លែងជានាគរាជ ទៅទូន្មានព្យសន៍ភុជង្គ ។ ឈ្មោះនន្ទោបនន្ទ ចិត្តមោហន្ធ រឿងឫទ្ធិរុង ទិដ្ឋិកាចទ្រនង់ ទ្រង់ផ្ចាញ់ដោយពិធីឈាន ។ គឺឱ្យឧបទេស ឫទ្ធិវិសេសដល់មោគ្គល្លាន ឫទ្ធិនាគអន្តរធាន ឱនចុះចាញ់ព្រះចេស្តា ។ វីជយមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជះជយា ព្រះភគវាឈ្នះនាគហោង ។

**៨. ទុគ្គាហទិដ្ឋិភុជគេន សុទដ្ឋហត្ថំ**
**ព្រហ្មំ វិសុទ្ធិជុតិមិទ្ធិពកាភិធានំ**
**ញាណាគទេន វិធិនា ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ**

ព្រះមុនិន្ទពិនគោតម ផ្ចាញ់មហាព្រហ្មឈ្មោះពកា សម្គាល់ថាអាត្មា រុងរឿងដោយគុណវិសុទ្ធ ។ ដៃកាន់អាសិរ្វិស គឺចិត្តទ្រឹស្តិដ៏មោះមុត កាន់ខុសផ្លូវសម្ពុទ្ធ មិនលើកលាកលះបង់ប្រាណ ។ ទ្រង់ឈ្នះដោយពិធី ឱសថវិសេសសម្រាន្ត ផ្សំត្រូវគាប់សន្តាន គឺព្រះញាណប្រោសទេសនា ។ វីជយមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជះជយា ឈ្នះព្រហ្មាឥតមានហ្មង ។

**ឯតាបិ ពុទ្ធជយមង្គលអដ្ឋគាថា**

**យោ វាចនោ ទិនទិនេ សរតេ មតន្ទី**

**ហិត្វាន នេកវិវិធានិ ចុបទ្ទវានិ**

**មោក្ខំ សុខំ អធិគមេយ្យ នរោ សបញ្ញោ**

**យោ នរោ** ជនឯណា កបបញ្ញាប្រាសក្តីខ្ជិល ឧស្សាហ៍សាងទានសីល សូត្ររំឭកព្រះធម៌ថ្ងៃ ។ គាថាប្រាំបីបទ នេះកំណត់ឈ្មោះពុទ្ធជ័យ ខំសូត្រសព្វៗ ថ្ងៃ កើតមង្គលជានិរន្តរ៍ ។

**សោ នរោ** វីជននោះ បានរដោះរោគអាសន្ន ឧបទ្រពអនេកលន់ មានប្រការផ្សេងៗ ផង ។ នឹងដល់ធម៌ក្សេមក្សាន្ត គឺនិព្វានសុខកន្លង លែងទុក្ខទាំងបួនកង ដោយពុទ្ធជ័យមង្គលនេះ ។

**(ពុទ្ធជយមង្គល ចប់ )**

## ទ្រង់ត្រាស់ដឹង

កាលព្រះសិទ្ធត្ថដ៏មានបុណ្យ ព្រះជន្មដប់ប្រាំមួយវស្សា
ទ្រង់សោយរាជ្យជួសព្រះបិតា គ្រប់គ្រងរដ្ឋាកបិលពស្តុ ។
ជាមួយព្រះនាងយសោធរា ពិម្ពាក្សត្រីស្រីល្អស្រស់
ប្រសើរលើសស្រីស្នំទាំងអស់ ប្រកបដោយយសថ្កើងណាស់ណា ។





លុះដល់ព្រះជន្មបានគ្រប់ធួន ម្ភៃប្រាំបួនព្រះវស្សា
ទ្រង់បានឱរសមួយថ្លៃថ្លា នាមថារាហុលល្អប្រិមប្រិយ ។
ក្នុងថ្ងៃរាហុលកើតនោះមិញ ទ្រង់ចេញបព្វជ្ជាដោយឃ្លាតខ្វី
បច្ឆិមបដិបត្តិតឹងពេកក្រៃ ដើម្បីឱ្យឆាប់បានត្រាស់ដឹង ។
ក្រោយពេលទ្រង់លះព្រះកិរិយា ទុក្ករៈនោះណាទ្រង់រំពឹង
មជ្ឈិមបដិបត្តិបានត្រាស់ដឹង ធម៌ថ្លៃតតថ្លឹងដ៏ក្សេមក្សាន្ត ។
នៅនាថ្ងៃពុធពេញបូណ៌មី ពិសាខរង្សីរកាបាន
ជាសព្វញ្ញុពុទ្ធថ្កើងថ្កាន ព្រះញាណប្រាជ្ញប្រសើរផុតលោកា ។
នៅក្រោមដើមពោធិ៍មានមង្គល នៅត្រង់មណ្ឌលឈ្មោះគយា
កៀរនេរញ្ជរាទីនេរញ្ជរា បានជាគ្រូគ្រប់សព្វភពបី ។
ទីទ្រង់ត្រាស់ដឹងនោះព្រះបាទ អសោកនាថស្តេចផែនដី
ទ្រង់សាងព្រះស្តូបល្អប្រិមប្រិយ សម្គាល់ទីដីទ្រង់ត្រាស់ដឹង ។
ខ្ញុំសូមក្រាបថ្វាយបង្គំវន្ទា ឆ្ពោះព្រះភគវាជាទីពឹង
ព្រះអង្គឈ្នះមារហើយត្រាស់ដឹង សម្លឹងត្រើយនាយនិព្វានពិត ។
សូមបុណ្យដែលយើងរួបរួមគ្នា ព្យាយាមពុះពារទាំងឆ្ងាយជិត
ទោះក្តៅ រងា យប់ងងឹត ប្រឹងអស់កាយចិត្តដ្បិតជ្រះថ្លា ។
សូមបុណ្យទាំងនេះជួយនាំមុខ ឱ្យឆ្លងផុតទុក្ខដូចប្រាថ្នា
សូមឱ្យបានកើតជាតិណាៗ ជួបទាន់សាសនាព្រះទ្រង់ញាណ ។

សូមកុំឱ្យជួបភយន្តរាយ        រោគាទាំងឡាយកុំឱ្យមាន
សូមកុំឱ្យជួបការអត់ឃ្លាន        រហូតនិព្វានកុំខានឡើយ ។

**សូមអនុមោទនា !!!**

-កំណាព្យនេះខ្ញុំព្រះករុណា ខ្ញុំបាទ **គុយ សុធន** បានចេះចាំមាត់តាំងពី ព.ស.២៥២៣ ( ពេលចេញពីសម័យ ប៉ុល ពត ឆ្នាំ១៩៧៩ ) ។ មិនដឹងថាជាស្នាដៃរបស់អ្នកនិពន្ធណាទេ ក្រោយមកខ្ញុំភ្លេចខ្លះ ខ្ញុំខំព្យាយាមរកកំណាព្យនេះវិញ តែរកមិនជួបសោះ ខ្ញុំក៏បន្ថែមពាក្យដែលភ្លេចដោយពាក្យខ្លួនឯង ដូច្នេះបើមានខុសពីកំណាព្យដើម សូមលោកអ្នកនិពន្ធមេត្តា អភ័យទោសដល់ខ្ញុំព្រះករុណា ខ្ញុំបាទដោយអនុគ្រោះផងចុះ ។

*-ព្រះសម្មាសម្ពុទ្ធ ទ្រង់គង់ប្រថាប់នៅគល់ព្រះពោធិព្រឹក្ស កាលដែលព្រះអាទិត្យនៅមិនទាន់អស្តង្គត ព្រះអង្គទ្រង់បានកម្ចាត់បង់នូវមារព្រមទាំងសេនាហើយ ។ ក្នុងបឋមយាម ព្រះអង្គបានទម្លាយនូវភាពងងឹតដែលបិទបាំងបុព្វេនិវាសានុស្សតិញ្ញាណ ក្នុងមជ្ឈិមយាមទ្រង់ជម្រះនូវទិព្វចក្ខុឱ្យហ្មត់ចត់ លុះដល់បច្ឆិមយាម ទ្រង់អាស្រ័យព្រះមហាករុណាក្នុងពពួកសត្វ ទ្រង់បានញុាំងនូវព្រះញាណឱ្យចុះក្នុងបច្ចយាការ ទ្រង់ពិចារណានូវបច្ចយាការនោះដោយអំណាចនៃអនុលោម និងបដិលោម ។

( ធម្មបទដ្ឋកថា ជរាវគ្គ បឋមពោធិកាល )



# បច្ចយាការ

## អនុលោម និង បដិលោម

**អវិជ្ជាបច្ចយា សង្ខារា** សង្ខារទាំងឡាយ ( កើតមាន ) ព្រោះបច្ច័យ គឺអវិជ្ជា ពោលគឺសេចក្តីល្ងង់ ។

**សង្ខារប្បច្ចយា វិញ្ញាណំ** វិញ្ញាណ ( កើតមាន ) ព្រោះបច្ច័យគឺ សង្ខារ ។

**វិញ្ញាណប្បច្ចយា នាមរូបំ** នាមនិងរូប ( កើតមាន ) ព្រោះបច្ច័យ គឺវិញ្ញាណ ។

**នាមរូបប្បច្ចយា សឡាយតនំ** អាយតនៈ៦ ( កើតមាន ) ព្រោះបច្ច័យ គឺនាមនិងរូប ។

**សឡាយតនប្បច្ចយា ផស្សោ** សម្ផស្ស ( កើតមាន ) ព្រោះបច្ច័យ គឺអាយតនៈ ៦ ។

**ផស្សប្បច្ចយា វេទនា** វេទនា ( កើតមាន ) ព្រោះបច្ច័យគឺ សម្ផស្ស ។

**វេទនាបច្ចយា តណ្ហា** តណ្ហា ( កើតមាន ) ព្រោះបច្ច័យគឺ វេទនា ។

**តណ្ហាបច្ចយា ឧបាទានំ** ឧបាទាន ( កើតមាន ) ព្រោះ

បច្ច័យគឺ តណ្ហា ។

**ឧបាទានប្បច្ចយា ភវោ** ភព (កើតមាន ) ព្រោះបច្ច័យគឺ ឧបាទាន ។

**ភវប្បច្ចយា ជាតិ** ជាតិ (កើតមាន) ព្រោះបច្ច័យគឺ ភព។

**ជាតិប្បច្ចយា ជរាមរណំ** ជរានិងមរណៈ ( កើតមាន ) ព្រោះបច្ច័យគឺ ជាតិ ។

**សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ** សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីព្រួយ សេចក្ដីតូចចិត្ត និងសេចក្ដីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏រមែងកើតមាន ( ព្រោះជាតិជាបច្ច័យដែរ ) ។

**ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ** កិរិយាកើតមាន នៃកងទុក្ខទាំងអស់នេះ មានដោយប្រការដូច្នេះ ។

**អវិជ្ជាយត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ** កិរិយារលត់នៃសង្ខារ ព្រោះកិរិយារលត់ដោយអរិយមគ្គឥតមានសេសសល់ នៃអវិជ្ជាមែនពិត ។

**សង្ខារនិរោធា វិញ្ញាណនិរោធោ** កិរិយារលត់នៃវិញ្ញាណ ព្រោះរលត់នៃសង្ខារ ។



**វិញ្ញាណនិរោធា នាមរូបនិរោធោ** កិរិយារលត់នៃនាមនិងរូប ព្រោះរលត់នៃវិញ្ញាណ ។

**នាមរូបនិរោធា សឡាយតននិរោធោ** កិរិយារលត់នៃអាយតនៈ ៦ ព្រោះរលត់នៃនាមនិងរូប ។

**សឡាយតននិរោធា ផស្សនិរោធោ** កិរិយារលត់នៃសម្ផស្ស ព្រោះរលត់នៃអាយតនៈ ៦ ។

**ផស្សនិរោធា វេទនានិរោធោ** កិរិយារលត់នៃ វេទនា ព្រោះរលត់នៃសម្ផស្ស ។

**វេទនានិរោធា តណ្ហានិរោធោ** កិរិយារលត់នៃ តណ្ហា ព្រោះរលត់នៃវេទនា ។

**តណ្ហានិរោធា ឧបាទាននិរោធោ** កិរិយារលត់នៃឧបាទាន ព្រោះរលត់នៃតណ្ហា ។

**ឧបាទាននិរោធា ភវនិរោធោ** កិរិយារលត់នៃភព ព្រោះរលត់នៃឧបាទាន ។

**ភវនិរោធា ជាតិនិរោធោ** កិរិយារលត់នៃ ជាតិ ព្រោះរលត់នៃភព ។

**ជាតិនិរោធា ជរាមរណំ** ជរានិងមរណៈ (រលត់ ) ព្រោះកិរិយារលត់នៃជាតិ ។

**សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ** សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីព្រួយ សេចក្តីតូចចិត្ត និង សេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏រមែងរលត់ទៅ ( ព្រោះកិរិយារលត់ទៅនៃជាតិដែរ ) ។

**ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ** កិរិយារលត់ទៅនៃកងទុក្ខទាំងអស់នេះ មានដោយប្រការដូច្នេះ ។

(តាមភាណវារៈ)

**( បដិច្ចសមុប្បាទ ចប់ )**

*-ក្នុងវេលាបច្ចូសសម័យ ទ្រង់បានសម្រេចនូវព្រះសម្មាសម្ពោធិញ្ញាណ ព្រមដោយសេចក្តីអស្ចារ្យច្រើនយ៉ាង កាលដែលព្រះអង្គទ្រង់ឧទាន ដែលព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គឧទាន ទើបទ្រង់បន្លឺនូវឧទាននេះ ក្នុងវេលានោះថា :

**អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ**
**គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ ។**
**គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ**
**សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ**
**វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។**





កាលតថាគតកំពុងតែស្វះស្វែងរកជាងធ្វើផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះគឺអត្តភាព មិនទាន់បានជួបប្រទះនៅឡើយ (តថាគត ) ក៏អន្ទោលទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន សេចក្តីកើតជាទុក្ខរឿយៗ ។

នែជាងផ្ទះ អ្នកធ្វើផ្ទះគឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ (របស់តថាគត ) ទៀតមិនបានឡើយ ឆ្អឹងជំនីរគឺកិលេសរបស់អ្នកទាំងអស់តថាគតកាច់បំបាក់អស់ហើយ ដំបូលផ្ទះគឺអវិជ្ជា តថាគតកម្ចាត់ចោលហើយ ចិត្តរបស់តថាគត ដល់ព្រះនិព្វានដែលប្រាសចាកសង្ខារហើយ តថាគត បានដល់ធម៌ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ។

(ធម្មបទ បិដកលេខ ៥២ , ទំព័រ ៥៤)

*-ព្រះសម្មាសម្ពុទ្ធ ទ្រង់គង់សោយវិមុត្តិសុខ នៅគល់ព្រះពោធិព្រឹក្សពុទ្ធគយា អស់វេលា ១ សប្តាហ៍ រួចហើយព្រះអង្គទ្រង់បន្លឺនូវឧទាននេះក្នុងវេលានោះថា :

**យទា ហវេ បាតុភវន្តិ ធម្មា**
**អាតាបិនោ ឈាយតោ ព្រាហ្មណស្ស**
**អថស្ស កង្ខា វបយន្តិ សព្វា**
**យតោ បជានាតិ សហេតុធម្មន្តិ ។**

ធម៌ទាំងឡាយ រមែងប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យា-យាមញុំាងកិលេសឱ្យក្តៅ ជាអ្នកដុតបង់នូវកិលេស ក្នុងកាលណា សេចក្តីសង្ស័យទាំងឡាយរបស់ព្រាហ្មណ៍នោះ រមែងអស់ទៅក្នុងកាលនោះឯង ព្រោះដឹងច្បាស់នូវធម៌ព្រមទាំងហេតុ ។

(បិដកលេខ ៥២ , ទំព័រ ១១៤ )

**យទា ហវេ បាតុភវន្តិ ធម្មា**
**អាតាបិនោ ឈាយតោ ព្រាហ្មណស្ស**
**អថស្ស កង្ខា វបយន្តិ សព្វា**
**យតោ ខយំ បច្ចយានំ អវេទីតិ ។**

ធម៌ទាំងឡាយ រមែងប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យា-យាមញុំាងកិលេសឱ្យក្តៅ ជាអ្នកដុតបង់នូវកិលេស ក្នុងកាលណា សេចក្តីសង្ស័យទាំងឡាយរបស់ព្រាហ្មណ៍នោះ រមែងអស់ទៅក្នុងកាលនោះឯង ព្រោះដឹងច្បាស់នូវព្រះនិព្វាន ជាទីអស់ទៅនៃបច្ច័យទាំងឡាយ ។ (បិដកលេខ ៥២ , ទំព័រ ១១៥ )

**យទា ហវេ បាតុភវន្តិ ធម្មា**
**អាតាបិនោ ឈាយតោ ព្រាហ្មណស្ស**
**វិធូបយំ តិដ្ឋតិ មារសេនំ**
**សុរិយោវ ឱភាសយមន្តលិក្ខន្តិ ។**



ធម៌ទាំងឡាយ រមែងប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យា-យាមញុំាងកិលេសឱ្យក្តៅ ជាអ្នកដុតបង់នូវកិលេស ក្នុងកាលណា ព្រាហ្មណ៍នោះ រមែងកម្ចាត់បង់នូវមារ ព្រមទាំងសេនាមារ ឋិតនៅ ក្នុងកាលនោះ បីដូចព្រះអាទិត្យរះឡើងធ្វើអាកាសឱ្យរុងរឿងដោយរស្មីរបស់ខ្លួន កម្ចាត់បង់នូវងងឹតឋិតនៅ ដូច្នោះឯង ។

(បិដកលេខ ៥២ , ទំព័រ ១១៧ )

*-**ព្រះមហាចេតិយពុទ្ធគយា** ចាប់ផ្តើមកសាងដោយព្រះបាទធម្មាសោក ក្រោយមកព្រះរាជាដែនមគធៈ បានសាងឱ្យធំឡើងដូច្នេះឯង ។

*-**ពោធិបល្ល័ង្ក** ឋិតនៅរវាងព្រះពោធិព្រឹក្សនិងព្រះមហាចេតិយ ជាទីត្រាស់ដឹងនៃព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គ ទ្រង់សម្រេចនូវព្រះគុណប្រមាណមិនបាន ។

*-**ព្រះពុទ្ធមេត្តា** គឺ ព្រះពុទ្ធប្បដិមាក្នុងព្រះមហាចេតិយ ជាទីចម្រើនចិត្ត ដូរផ្លាស់ត្រៃចីវររាល់ថ្ងៃ ហាក់បីដូចព្រះអង្គទ្រង់ជីវិតិន្ទ្រិយ ។ ព្រះពុទ្ធមេត្តា មានប្រវត្តិគួរឱ្យអស្ចារ្យ តាំងពីជំនាន់នៃព្រះពោធិព្រឹក្ស ដើមទី ២ មកម្ល៉េះ ។

*.**អនិមិសចេតិយ** ( **អនិមិស** =មិនពព្រិចព្រះនេត្រា ) ជាទីដែលព្រះអង្គទ្រង់ប្រថាប់ឈរ សម្លឹងព្រះពោធិព្រឹក្ស និង រតនបល្ល័ង្ក ។ រតនបល្ល័ង្កនៅខាងកើតគល់ព្រះពោធិព្រឹក្ស ជាទីសម្រេចផលនៃព្រះបារមីទាំងឡាយ ។ ព្រះអង្គទ្រង់សម្លឹងមើល មិនពព្រិចព្រះនេត្រា អស់ ៧ ថ្ងៃក្នុងសប្តាហ៍ទី ២ ។

*.**រតនចង្រ្កម** ទីដែលព្រះអង្គទ្រង់យាងចង្រ្កមទៅមក ពីអនិមិសចេតិយទៅព្រះពោធិព្រឹក្ស ។ រតនចង្រ្កមចេតិយ គេបានសាងនៅទិសខាងជើងព្រះមហាចេតិយ មានថ្មផ្កាឈូក ១៩ ដុំ បិតនៅលើនោះ ពុទ្ធបរិស័ទទាំងអស់គប្បីវន្ទា សូត្រធម៌ ។

*.**រតនឃរចេតិយ** អដ្ឋកថាប្រាប់ថា ទេវតាទាំងឡាយនិម្មិតផ្ទះកែវ ថ្វាយព្រះសម្មាសម្ពុទ្ធ ។ ព្រះសុគតសាស្តាទ្រង់ពិចារណានូវព្រះអភិធម្ម រហូតដល់មហាបដ្ឋាន ដ៏មានន័យមិនមានទីបំផុត (អនន្តន័យ) ។

*.**អជបាលនិគ្រោធ** នៅខាងកើតស្ទឹងនេរញ្ជរា ជាកន្លែងសំខាន់ច្រើនមុខគឺ ១.ទទួលមធុបាយាស ចង្ហាន់នាងសុជាតា , ២.ព្រះអង្គគង់សោយវិមុត្តិសុខក្នុងសប្តាហ៍ទី ៥, ៣.ព្រហ្មអារាធនាសូមព្រះភគវាទ្រង់ត្រាស់សម្តែង ព្រះធម៌ទេសនា វិស័យស្វែងស្វែង ទ្រង់ព្រមសម្តែងដោយព្រហ្មវិហារ (ក្នុងសប្តាហ៍ទី ៨)។



## ព្រះពុទ្ធឧទានក្នុងសប្តាហ៍ទី ៥

**យោ ព្រាហ្មណោ ពាហិតបាបធម្មោ**
**និហុំហុំកោ និក្កសាវោ យតត្តោ**
**វេទន្តគូ វុសិតព្រហ្មចរិយោ**
**ធម្មេន សោ (ព្រាហ្មណោ) ព្រហ្មវាទំ វទេយ្យ**
**យស្សុស្សទា នត្ថិ កុហិញ្ចិ លោកេតិ ។**

ព្រាហ្មណ៍ណា មានបាបធម៌បណ្តែតចោលហើយ មានសំឡេងគំរាមថា **ហុំហុំ** លះចោលហើយ មានទឹកចត់ គឺរាគាទិក្កិលេសលះចោលហើយ មានចិត្តសង្រួមហើយ ចេះចប់នូវវេទ គឺមគ្គញ្ញាណទាំង ៤ មានមគ្គព្រហ្មចរិយធម៌អប់រំហើយម្យ៉ាងទៀត ព្រាហ្មណ៍ណា មិនមានគំនរ គឺរាគាទិក្កិលេសក្នុងអារម្មណ៍បន្តិចបន្តួច ក្នុងលោកសន្និវាស ព្រាហ្មណ៍នោះ ទើបគួរនឹងហៅខ្លួនថាជាព្រាហ្មណ៍ ដោយធម៌បាន ។

(បិដកលេខ ៥២ , ទំព័រ ១១៨)

# អាយាចនសូត្រ

(បិដកលេខ ៣០ ទំព័រ ២៤)

ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ទើបនឹងបានត្រាស់ដឹងជាដំបូង ទ្រង់គង់នៅក្រោមដើមអជ-បាលនិគ្រោធ ប្របមាត់ស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ស្តេចទៅគង់ក្នុងទីស្ងាត់សំងំនៅ មានព្រះទ័យត្រិះរិះកើតឡើង យ៉ាងនេះថា ធម៌[១] នេះអាត្មាអញបានត្រាស់ដឹងហើយ ជាធម៌ដ៏ជ្រាលជ្រៅ ជាធម៌ដែលសត្វឃើញបានដោយកម្រ ជាធម៌ដែលសត្វត្រាស់ដឹងបានដោយកម្រ ជាធម៌ស្ងប់រម្ងាប់ ជាធម៌ថ្លៃថ្លា ជាធម៌ដែលសត្វមិនគប្បីស្ទង់មើល ដោយសេចក្តីត្រិះរិះបាន ជាធម៌ដ៏ល្អិត ជាធម៌មានតែអ្នកប្រាជ្ញ ទើបត្រាស់ដឹងបាន ឯពួកសត្វនេះ ជាអ្នកត្រេកត្រអាលដោយសេចក្តីអាល័យ[២] ត្រេកអរក្នុងសេចក្តីអាល័យ រីករាយក្នុងសេចក្តីអាល័យ មួយទៀត បដិច្ចសមុប្បាទធម៌ គឺធម៌ជាបច្ច័យនៃគ្នានិងគ្នាណា បដិច្ចសមុប្បាទធម៌នេះ ពួកសត្វជាអ្នកត្រេកត្រអាលដោយសេចក្តីអាល័យ ត្រេកអរក្នុងសេចក្តីអាល័យ រីករាយក្នុងសេចក្តីអាល័យ ឃើញបានដោយក្រ មួយទៀត ធម៌ណា សម្រាប់រម្ងាប់សង្ខារទាំងពួង សម្រាប់លះបង់ឧបធិទាំងពួង ជាទីអស់ទៅនៃតណ្ហា ជាទីនឿយណាយចាករាគៈ ជាទីរំលត់សេចក្តីទុក្ខ គឺព្រះនិព្វាន ធម៌នេះ ពួកសត្វឃើញបានដោយក្រដូចគ្នា ប្រសិនបើអាត្មាអញសម្តែងធម៌ទៅ ក៏សត្វទាំងឡាយដទៃ មិនគប្បីត្រាស់ដឹងធម៌របស់អាត្មាអញបានទេ អាត្មាអញនឹងមានតែសេចក្តីលំបាកនោះ អាត្មាអញ នឹងមានតែសេចក្តីនឿយព្រួយនោះ (ឥតអំពើ) ។ បានឮថា ព្រះគាថាជាអស្ចារ្យទាំងឡាយនេះ ដែលមិនធ្លាប់បានស្តាប់មកអំពីកាលមុន ក៏ប្រាកដដល់ព្រះមានព្រះភាគថា :

> **កិច្ឆេន មេ អធិគតំ ហលន្ទានិ បកាសិតុំ**
> **រាគទោសបរេតេហិ នាយំ ធម្មោ សុសម្ពុធោ ។**

ឥឡូវនេះ អាត្មាអញ មិនគួរប្រកាសធម៌ ដែលអាត្មាអញបានត្រាស់ដឹងហើយ ដោយលំបាកទេ ព្រោះថា ធម៌នេះ សត្វទាំងឡាយដែលត្រូវរាគៈ ទោសៈ គ្របសង្កត់ហើយ មិនងាយត្រាស់ដឹងបានឡើយ ។

---

[១] សំដៅយកអរិយសច្ចទាំង ៤ ។ [២] បានដល់តណ្ហាវិចរិតទាំង ១០៨ ។

**បដិសោតគាមឹ និបុណំ គម្ភីរំ ទុទ្ទសំ អណុំ**
**រាគរត្តា ន ទក្ខន្តិ តមោខន្ធេន អាវុតាតិ ។**

សត្វទាំងឡាយត្រេកអរ ដោយរាគៈ មានគំនរងងឹត គឺអវិជ្ជាបិទបាំង រមែងមិនឃើញនូវធម៌ដែលប្រព្រឹត្តច្រាសខ្សែទឹក[១] ជាធម៌ល្អិត ជ្រាលជ្រៅ សត្វឃើញបានដោយកម្រ ជាធម៌ដ៏តូចឆ្មារ ។

កាលព្រះមានព្រះភាគ ពិចារណាដូច្នេះហើយ ព្រះទ័យក៏បង្អោនទៅដើម្បីសេចក្តីខ្វល់ខ្វាយតិច មិនបង្អោនទៅដើម្បីនឹងសម្តែងធម៌ឡើយ ។

គ្រានោះ សហម្បតិព្រហ្ម ដឹងនូវសេចក្តីត្រិះរិះក្នុងព្រះហឫទ័យរបស់ព្រះមានព្រះភាគ ដោយចិត្តហើយ ទើបរំពឹងគិតដូច្នេះថា ឱហ្ន៎ សត្វលោកសាបសូន្យមិនខាន ឱហ្ន៎ សត្វលោកវិនាសមិនខាន ដ្បិតថាព្រះហឫទ័យរបស់ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ បង្អោនទៅដើម្បីសេចក្តីខ្វល់ខ្វាយតិច មិនបង្អោនទៅដើម្បីសម្តែងធម៌ឡើយ ។

គ្រានោះ សហម្បតិព្រហ្ម ក៏បាត់អំពីព្រហ្មលោកមកប្រាកដក្នុងទីចំពោះព្រះភក្ត្រព្រះមានព្រះភាគ ដោយឆាប់រហ័ស ដូចបុរស

១-បានដល់ចតុសច្ចធម៌ ។





មានកម្លាំងលាចេញនូវដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ ។ លំដាប់នោះ សហម្បតិព្រហ្ម ធ្វើនូវសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង លុតចុះនូវមណ្ឌល នៃជង្គង់ខាងស្តាំ លើផែនដីប្រណម្យអញ្ជលី ចំពោះទៅរកព្រះមានព្រះភាគ ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ សូមព្រះសុគតទ្រង់សម្តែងធម៌ សត្វទាំងឡាយ ដែលមានធូលី[១] ស្រាលស្តើងក្នុងភ្នែក[២] ក៏មានខ្លះដែរ សត្វទាំងនោះ នឹងសាបសូន្យ ព្រោះមិនបានស្តាប់ធម៌ សត្វទាំងឡាយជាអ្នកត្រាស់ដឹងនូវធម៌គង់មាន ។ សហម្បតិព្រហ្ម បានពោលពាក្យនេះ លុះពោលពាក្យនេះរួចហើយ ទើបពោលពាក្យនេះតទៅទៀតថា

**បាតុរហោសិ មគធេសុ បុព្វេ**
**ធម្មោ អសុទ្ធោ សមលេហិ ចិន្តិតោ**
**អបាបុរេតំ អមតស្ស ទ្វារំ**
**សុណន្តុ ធម្មំ វិមលេនានុពុទ្ធំ ។**

ពីមុនរៀងមក ធម៌ដែលជនទាំងឡាយ អ្នកប្រកបដោយមន្ទិល[៣] តែងគិត ជាធម៌មិនបរិសុទ្ធ កើតប្រាកដក្នុងដែនមគធៈ

១-បានខាងកិលេសមានរាគៈជាដើម ។ ២-បានខាងបញ្ញាចក្ខុ ។ ៣-សំដៅយកគ្រូទាំង ៦

សូមព្រះអង្គបើកនូវទ្វារ [១] នៃព្រះនិព្វាន សត្វទាំងឡាយនឹងស្តាប់នូវធម៌ដែលព្រះពុទ្ធជាអ្នកប្រាសចាកមន្ទិលទ្រង់ត្រាស់ដឹងហើយ ។

**សេលេ យថា បព្វតមុទ្ធនិដ្ឋិតោ**
**យថាបិ បស្សេ ជនតំ សមន្តតោ**
**តថូបមំ ធម្មមយំ សុមេធសោ**
**បាសាទមារុយ្ហ សមន្តចក្ខុ**
**សោកាវតិណ្ណំ ជនតមបេតសោកោ**
**អវេក្ខស្សុ ជាតិជរាភិភូតន្តិ ។**

បុរសឈរនៅលើកំពូលភ្នំសុទ្ធសឹងថ្ម គប្បីឃើញប្រជុំជនដោយជុំវិញ យ៉ាងណាមិញ បពិត្រព្រះអង្គមានបញ្ញាល្អ មានចក្ខុជុំវិញ ប្រាសចាកសេចក្តីសោក សូមព្រះអង្គឡើងកាន់ប្រាសាទដែលសម្រេចដោយធម៌ គឺបញ្ញាដូចជាភ្នំនោះ ហើយពិចារណាមើលនូវប្រជុំជន ដែលលិចចុះក្នុងសេចក្តីសោក ត្រូវជាតិ ជរាគ្របសង្កត់ ។

**ឧដ្ឋេហិ វីរ វិជិតសង្គាម**
**សត្ថវាហ អនណ វិចរ លោកេ**

១.បានខាងអរិយមគ្គ ។





**ទេសេតុ ភគវា ធម្មំ**
**អញ្ញាតារោ ភវិស្សន្តីតិ ។**

បពិត្រព្រះអង្គមានព្យាយាម ទ្រង់ឈ្នះនូវសង្គ្រាម សូមព្រះអង្គក្រោកឡើង បពិត្រព្រះអង្គ ជាអ្នកនាំទៅនូវពពួកសត្វ ព្រះអង្គមិនមានបំណុល សូមទ្រង់ស្តេចទៅក្នុងលោក សូមព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ សត្វទាំងឡាយជាអ្នកត្រាស់ដឹងគង់នឹងមាន ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីអារាធនារបស់ព្រហ្មផង ទ្រង់អាស្រ័យនូវសេចក្តីករុណាចំពោះសត្វទាំងឡាយផង ទើបទ្រង់រមិលមើលនូវសត្វលោក ដោយពុទ្ធចក្ខុ ។ កាលដែលព្រះមានព្រះភាគ ទ្រង់រមិលមើលនូវសត្វលោក ដោយពុទ្ធចក្ខុ ទ្រង់បានឃើញសត្វទាំងឡាយ មានភ្នែកប្រកបដោយធូលីតិចខ្លះ មានភ្នែកប្រកបដោយធូលីច្រើនខ្លះ មានឥន្ទ្រិយក្លាខ្លះ មានឥន្ទ្រិយទន់ខ្លះ មានអាការល្អខ្លះ មានអាការអាក្រក់ខ្លះ ជាសត្វដែលឱ្យត្រាស់ដឹងបានដោយងាយខ្លះ ជាសត្វដែលឱ្យត្រាស់ដឹងបានដោយក្រខ្លះ ជាអ្នកឃើញនូវទោសនិងភ័យក្នុងបរលោកខ្លះ ។ ប្រៀបដូចជលជាតិពួកខ្លះ គឺផ្កាព្រលិតក្តី ឈូក

ក្រហមក្តី ឈូកសក្តី ក្នុងគុម្ពព្រលិតក្តី គុម្ពឈូកក្រហមក្តី គុម្ពឈូកសក្តី ដុះឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក លូតលាស់តាមទឹក លិចនៅក្នុងទឹក មានជលជាតិពួកខ្លះ គឺផ្កាព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី ដុះឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក ឋិតនៅត្រឹមស្មើនឹងទឹក មានជលជាតិពួកខ្លះ គឺផ្កាព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី ដុះឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក លូតផុតអំពីទឹក មិនទទឹកដោយទឹក មានឧបមាយ៉ាងណាមិញ កាលដែលព្រះមានព្រះភាគ ទ្រង់រមិលមើលនូវសត្វលោក ដោយពុទ្ធចក្ខុ ទ្រង់ឃើញសត្វទាំងឡាយ មានភ្នែកប្រកបដោយធូលីតិចខ្លះ មានភ្នែកប្រកបដោយធូលីច្រើនខ្លះ មានឥន្ទ្រិយក្លាខ្លះ មានឥន្ទ្រិយទន់ខ្លះ មានអាការល្អខ្លះ មានអាការអាក្រក់ខ្លះ ជាសត្វដែលឱ្យត្រាស់ដឹងបានដោយងាយខ្លះ ជាសត្វដែលឱ្យត្រាស់ដឹងបានដោយក្រខ្លះ ជាអ្នកឃើញនូវទោសនិងភ័យ ក្នុងបរលោកខ្លះ លុះទ្រង់ឃើញហើយ បានពោលគាថា តបនឹងសហម្បតិព្រហ្មថា

**អបារុតា តេ អមតស្ស ទ្វារា**
**យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ ។**

ទ្វារនៃព្រះនិព្វាននោះតថាគតបានបើកហើយ សត្វទាំង-ឡាយណា មានសោតប្បសាទ ចូរបញ្ចេញនូវសទ្ធាចុះ ។



**វិហឹសសញ្ញី បគុណំ ន ភាសឹ**
**ធម្មំ បណីតំ មនុជេសុ ព្រហ្មេតិ ។**

ម្នាលព្រហ្ម តថាគតសម្គាល់នូវសេចក្តីលំបាក បានជាមិនសម្តែងធម៌ដែលស្ងាត់ ជាធម៌ដ៏ឧត្តម ដល់ពួកមនុស្សទាំងឡាយ ។

គ្រានោះ សហម្បតិព្រហ្មគិតថា អាត្មាអញជាបុគ្គលដែលព្រះមានព្រះភាគ ទ្រង់ធ្វើឱកាសដើម្បីនឹងសម្តែងធម៌ហើយ (លុះគិតដូច្នេះហើយ ) ក៏ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយបាត់អំពីទីនោះទៅ ។

*-**មាត់ស្រះមុច្ចលិន្ទ** ព្រះអង្គទ្រង់សោយវិមុត្តិសុខ ៧ ថ្ងៃហើយ ទ្រង់ឧទាន ២ គាថា :

**សុខោ វិវេកោ តុដ្ឋស្ស សុតធម្មស្ស បស្សតោ**
**អព្យាបជ្ឈំ សុខំ លោកេ បាណភូតេសុ សញ្ញមោ ។**

សេចក្តីស្ងប់ស្ងាត់ របស់អ្នកដែលត្រេកអរក្នុងទីស្ងាត់ ជាអ្នកមានធម៌បានស្តាប់ហើយ ពិចារណាឃើញនូវធម៌ នាំមកនូវសេចក្តីសុខ កិរិយាមិនបៀតបៀន គឺកិរិយាសង្រួមចំពោះសត្វទាំងឡាយ នាំមកនូវសេចក្តីសុខក្នុងលោក ។

សុខា វិរាគតា លោកេ  កាមានំ សមតិក្កមោ
អស្មិមានស្ស វិនយោ  ឯតំ វេ បរមំ សុខំ ។

ភាវៈប្រាសចាករាគៈ គឺកិរិយាកន្លងនូវកាមទាំងឡាយ នាំមកនូវសេចក្ដីសុខក្នុងលោក កិរិយាធ្វើឱ្យវិនាសនូវអស្មិមានះនេះឯង នាំមកនូវសេចក្ដីសុខដ៏ឧត្ដម ។ (បិដកលេខ ៥២ , ទំព័រ ១៣៤)

*-**រាជាយតនព្រឹក្ស** ជាទីកន្លែងគួរជ្រះថ្លាដូចតទៅ :

-ព្រះអង្គទ្រង់គង់សោយវិមុត្តិសុខ ៧ ថ្ងៃក្នុងសប្ដាហ៍ទី ៧។

-តបុស្សៈ និងភល្លិកៈ ពីរនាក់បងប្អូន ថ្វាយចង្ហាន់ដល់ព្រះអង្គ ។

-ស្ដេចទេវតាទាំង ៤ អង្គ នាំបាត្រមកថ្វាយដល់ព្រះអង្គ ។

-ព្រះឥន្ទនាំយកទឹកខ្ពុរព្រះឱស ដុសព្រះទន្ត និងផ្លែសម៉ សម្រាប់បញ្ចុះ មកថ្វាយដល់ព្រះអង្គដែរ ។

-៧ សប្ដាហ៍ ព្រះអង្គពុំបានប្រព្រឹត្តនូវសិរីរកិច្ចអ្វីទាំងអស់ មានតែពិចារណាធម៌ សោយនូវវិមុត្តិសុខ និងឧទានតែប៉ុណ្ណោះ ទីនេះគឺកន្លែងរាជាយតនព្រឹក្ស ទ្រង់សោយចង្ហាន់មុនដំបូងបំផុត បន្ទាប់ពីបានត្រាស់ដឹង កន្លងទៅ ៤៩ ថ្ងៃ ។

-តបុស្សៈ និងភល្លិកៈ បានដល់ព្រះពុទ្ធនិងព្រះធម៌ជាទីពឹង





ទីរលឹក ហើយបានទទួលនូវព្រះកេសចេតិយអំពីព្រះសម្មាសម្ពុទ្ធ ។ ក្រោយមកទាំងពីរនាក់បងប្អូននេះ បានស្ដាប់ព្រះធម៌នៅរាជគ្រឹះ សម្រេចនូវសោតាបត្តិផល ហើយភល្លិកៈបានបួសសម្រេចនូវព្រះ-អរហត្ត អស់កង្វល់ក្នុងរឿងលោកិយ ។

-ព្រះសម្មាសម្ពុទ្ធ ស្ដេចទ្រង់យាងពីដើមរាជាយតនៈ ទៅកាន់ដើមអជបាលនិគ្រោធម្ដងទៀត ទើបព្រះឥន្ទព្រមទាំងទេវតា និងសហម្បតិព្រហ្មព្រមទាំងព្រហ្មម៉ឺនចក្កវាឡ ចុះមកអារាធនាព្រះអង្គ សូមឱ្យទ្រង់ត្រាស់សម្ដែងព្រះធម៌ទេសនា ។

## បាលីនមស្ការបូជាសត្តមហាឋាន

(ចាកឃ្លាំងបរិយត្តិ)

**បឋមំ ពោធិបល្លង្កំ  ទុតិយំ អនិមិសកំ**
**តតិយំ ចង្កមំ សេដ្ឋំ  ចតុត្ថំ រតនឃរំ**
**បញ្ចមំ អជបាលញ្ច  មុចលិន្ទេនឆដ្ឋមំ**
**សត្តមំ រាជាយតនំ  សត្តាហំ មុនិសេវិតំ**
**ឯតេ សត្តមហាឋានេ  ជម្ពូទីបេ បតិដ្ឋិតា**
**បូជិតា នរទេវេហិ  អហំ វន្ទាមិ ទូរតោ ។**

## កំណាព្យនមស្ការសត្តមហាឋាន

ខ្ញុំសូមបង្គំប្រណម្យវន្ទា ឋានព្រះភគវ៉ាននានាឆ្ងាយជិត
ឋានធំប្រាំពីរព្រះមុនីនៃបនិត្យ ឋានមួយទ្រង់ឋិតពិតមួយសប្តាហ៍ ។
សត្តមហាឋានមហាចេតិយ ពួកជនប្រុសស្រីគប្បីជ្រះថ្លា
ជាឋានបូជានៃមនុស្សទេវតា ឋិតនៅអស្ចារ្យក្នុងជម្ពូទ្វីប ។
**បឋមំ ពោធិបល្លង្កំ** ទ្រង់តាំងបធានគ្មានស្តាយជន្មជីព
ត្រាស់ជាព្រះពុទ្ធដុតភ្លើងប្រទីប មនុស្សជម្ពូទ្វីបមានលាភថ្លៃថ្លា ។
**ទុតិយំ អនិមិសកំ** ទ្រង់តាំងកាយឈរទិសបូពិឧត្តរា
នៃព្រះពោធិព្រឹក្សមិនព្រិចនេត្រា ទ្រង់ទតវិចារណ៍មហាឋានពុទ្ធោ ។
**តតិយំ ចង្កមំ សេដ្ឋំ** ទ្រង់តាំងហប្បទ័យក្នុងព្រៃព្រះពោធិ៍
ទ្រង់យាងទៅមកពីទីទ្រង់ឈរ និងគល់ព្រះពោធិ៍ប្រពៃអស្ចារ្យ ។
**ចតុត្ថំ រតនឃរំ** ទ្រង់តាំងពលំកម្លាំងប្រាជ្ញា
ពុះជ្រែកអភិធម្មក្នុងផ្ទះរតនា ពាយព្យទិសានៃទីត្រាស់ដឹង ។
**បញ្ចមំ អជបាលញ្ច** ទ្រង់តាំងទ្រង់ដាក់ហប្បទ័យនឹងធឹង
នៅទីទទួលបាយាសត្រាស់ដឹង ខាងកើតដងស្ទឹងនេរញ្ជរា ។
**មុច្ចលិន្ទេនឆដ្ឋមំ** ទ្រង់តាំងបល្ល័ង្កគង់ក្នុងធម្មា
ខាងត្បូងព្រះពោធិ៍មាននាគរាជា បាំងព្រះភគវាការពារពិរុណ ។





**សត្តមំ រាជាយតនំ** ទ្រង់តាំងធម្មំខ្លាំងក្លាដោយគុណ
ខាងត្បូងមុច្ចលិន្ទព្រះឥន្ទចុះមុន បូជាព្រះគុណគង់ក្រោមដើមកែស ។
សត្តមហាឋានមហាចេតិយ សូត្ររៀងរាល់ថ្ងៃចម្រើនចំណេះ
ចម្រើនចិត្តស្ងប់រស់មិនប្រហែស កាត់បង់កិលេសមានះឫស្យា ។
ព្រះពុទ្ធត្រាស់ដឹងទីពឹងក្នុងលោក ផុតពីទុក្ខសោករាគរោគតណ្ហា
គង់ក្នុងឋានស្ងាត់ប្រាំពីរសប្តាហ៍ ចេតិយសម្មាសម្ពុទ្ធគ្រប់អង្គ ។

**សាធុ ! សាធុ ! សាធុ !** ដោយ ច.ស.ទ.

*-**ផ្ទះនាងសុជាតា** សោតាបន្នាដល់ព្រះរតនត្រ័យមុនឧបាសិកាទាំងឡាយ ។ ផ្ទះនាងនៅខាងកើតស្ទឹងនេរញ្ជរាដែលមើលពីផ្ទះនាងទៅទិសខាងកើត ឆៀងត្បូងបន្តិច ឃើញដើមអជបាលនិគ្រោធ កន្លែងដែលនាងថ្វាយមធុបាយាស ។

*-កន្លែងដែលព្រះអង្គ ទ្រង់យាងទៅជួបឧរុវេលកស្សបៈមុនដំបូង ។ ព្រះអង្គទ្រង់គ្របសង្កត់នូវតេជះរបស់នាគរាជ និងទ្រង់សម្តែងបាដិហារ្យច្រើនយ៉ាងដែលធ្វើឱ្យពួកជដិលមានឧរុវេល-កស្សបៈជាដើម លះបង់នូវមានះរបស់ខ្លួន ហើយសូមព្រះដ៏មាន-ព្រះភាគបួស ស្តាប់អាទិត្តបរិយាយសូត្រ សម្រេចព្រះអរហត្ត ។

*-**គយាសីសប្រទេស** កន្លែងសម្តែងអាទិត្តបរិយាយសូត្រ

និងជាកន្លែងដែលភិក្ខុទេវទត្តបំបែកសង្ឃពីរាជគ្រឹះ មកគង់នៅទីនេះ ។ ព្រះសារីបុត្ត និងព្រះមហាមោគ្គល្លាន បានទទួលព្រះពុទ្ធដីកាមកសម្តែងធម៌ នាំយកភិក្ខុ ៥០០ អង្គត្រឡប់ទៅថ្វាយបង្គំព្រះសម្មាសម្ពុទ្ធវិញ ។

# អាទិត្តបរិយាយសូត្រ

(បិដកលេខ ៦ , ទំព័រ ១០៤-១០៦)

**ឯវម្មេ សុតំ** ( សូត្រនេះឈ្មោះ អាទិត្តបរិយាយសូត្រ ) គឺខ្ញុំ ( ឈ្មោះអានន្ទ ) បានស្តាប់មកហើយយ៉ាងនេះថា

**ឯកំ សមយំ ភគវា គយាយំ វិហរតិ គយាសីសេ សទ្ធឹ ភិក្ខុសហស្សេន** សម័យមួយ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់គង់នៅក្នុងគយាសីសប្រទេសជិតស្ទឹងឈ្មោះគយា ជាមួយនឹងភិក្ខុ ១ ពាន់អង្គ ។

**តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ** ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ ក្នុងគយាសីសប្រទេសនោះ ( ឱ្យនាំគ្នាតាំងចិត្តស្តាប់នូវភាសិតដូច្នេះថា )

**សព្វំ ភិក្ខវេ អាទិត្តំ** ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងជារបស់ក្តៅ ។



**កិញ្ច ភិក្ខវេ សព្វំ អាទិត្តំ** ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងជារបស់ក្តៅ គឺអ្វីខ្លះ ?

**ចក្ខុំ ភិក្ខវេ អាទិត្តំ** ម្នាលភិក្ខុទាំងឡាយ ភ្នែកជារបស់ក្តៅ

**រូបា អាទិត្តា** រូបទាំងឡាយ ជារបស់ក្តៅ

**ចក្ខុវិញ្ញាណំ អាទិត្តំ** វិញ្ញាណអាស្រ័យនឹងភ្នែក ជារបស់ក្តៅ

**ចក្ខុសម្ផស្សោ អាទិត្តោ** សម្ផស្សអាស្រ័យនឹងភ្នែក ជារបស់ក្តៅ

**យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា** សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យឯណា

**តម្បិ អាទិត្តំ** សេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ ក៏ជារបស់ក្តៅ ។

**កេន អាទិត្តំ** ក្តៅដោយអ្វី ?

**អាទិត្តំ រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អាទិត្តន្តិ វទាមិ** តថាគត

ពោលថា ក្តៅដោយភ្លើងគឺរាគៈ ដោយភ្លើងគឺទោសៈ ដោយភ្លើងគឺមោហៈ ក្តៅដោយសេចក្តីកើត ដោយសេចក្តីចាស់គ្រាំគ្រា និងសេចក្តីស្លាប់ ក្តៅដោយសេចក្តីសោក ដោយសេចក្តីខ្សឹកខ្សួល ដោយសេចក្តីទុក្ខក្នុងកាយ ដោយសេចក្តីទុក្ខក្នុងចិត្ត ដោយសេចក្តីចង្អៀតចង្អល់ក្នុងចិត្តទាំងឡាយ ។

**សោតំ អាទិត្តំ** ត្រចៀកជារបស់ក្តៅ

**សទ្ទា អាទិត្តា** សំឡេងទាំងឡាយ ជារបស់ក្តៅ

**សោតវិញ្ញាណំ អាទិត្តំ** វិញ្ញាណអាស្រ័យនឹងត្រចៀក ជារបស់ក្តៅ

**សោតសម្ផស្សោ អាទិត្តោ** សម្ផស្សអាស្រ័យនឹងត្រចៀក ជារបស់ក្តៅ

**យម្បិទំ សោតសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា** សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខ មិនមែនសុខក្តី កើតឡើងព្រោះសោតសម្ផស្ស ជាបច្ច័យឯណា

**តម្បិ អាទិត្តំ** សេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ ក៏ជារបស់ក្តៅ ។

**កេន អាទិត្តំ** ក្តៅដោយអ្វី ?



**អាទិត្តំ រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អាទិត្តន្តិ វទាមិ** តថាគតពោលថា ក្តៅដោយភ្លើងគឺរាគៈ ដោយភ្លើងគឺទោសៈ ដោយភ្លើងគឺមោហៈ ក្តៅដោយសេចក្តីកើត ដោយសេចក្តីចាស់គ្រាំគ្រា និងសេចក្តីស្លាប់ ក្តៅដោយសេចក្តីសោក ដោយសេចក្តីខ្សឹកខ្សួល ដោយសេចក្តីទុក្ខក្នុងកាយ ដោយសេចក្តីទុក្ខក្នុងចិត្ត ដោយសេចក្តីចង្អៀតចង្អល់ក្នុងចិត្តទាំងឡាយ ។

**ឃានំ អាទិត្តំ** ច្រមុះជារបស់ក្តៅ

**គន្ធា អាទិត្តា** ក្លិនទាំងឡាយ ជារបស់ក្តៅ

**ឃានវិញ្ញាណំ អាទិត្តំ** វិញ្ញាណអាស្រ័យនឹងច្រមុះ ជារបស់ក្តៅ

**ឃានសម្ផស្សោ អាទិត្តោ** សម្ផស្សអាស្រ័យនឹងច្រមុះជារបស់ក្តៅ

**យម្បិទំ ឃានសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា** សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះឃានសម្ផស្ស ជាបច្ច័យឯណា

**តម្បិ អាទិត្តំ** សេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ ក៏ជារបស់ក្តៅ ។

**កេន អាទិត្តំ** ក្តៅដោយអ្វី ?

**អាទិត្តំ រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អាទិត្តន្តិ វទាមិ** តថាគតពោលថា ក្តៅដោយភ្លើងគឺរាគៈ ដោយភ្លើងគឺទោសៈ ដោយភ្លើងគឺមោហៈ ក្តៅដោយសេចក្តីកើត ដោយសេចក្តីចាស់គ្រាំគ្រា និងសេចក្តីស្លាប់ ក្តៅដោយសេចក្តីសោក ដោយសេចក្តីខ្សឹកខ្សួល ដោយសេចក្តីទុក្ខក្នុងកាយ ដោយសេចក្តីទុក្ខក្នុងចិត្ត ដោយសេចក្តីចង្អៀតចង្អល់ក្នុងចិត្តទាំងឡាយ ។

**ជិវ្ហា អាទិត្តា** អណ្តាតជារបស់ក្តៅ

**រសា អាទិត្តា** រសទាំងឡាយ ជារបស់ក្តៅ

**ជិវ្ហាវិញ្ញាណំ អាទិត្តំ** វិញ្ញាណអាស្រ័យនឹងអណ្តាត ជារបស់ក្តៅ

**ជិវ្ហាសម្ផស្សោ អាទិត្តោ** សម្ផស្សអាស្រ័យនឹងអណ្តាត ជារបស់ក្តៅ

**យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ**





**សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា** សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះជិវ្ហាសម្ផស្ស ជាបច្ច័យឯណា

**តម្បិ អាទិត្តំ** សេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ ក៏ជារបស់ក្តៅ ។

**កេន អាទិត្តំ** ក្តៅដោយអ្វី ?

**អាទិត្តំ រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អាទិត្តន្តិ វទាមិ** តថាគតពោលថា ក្តៅដោយភ្លើងគឺរាគៈ ដោយភ្លើងគឺទោសៈ ដោយភ្លើងគឺមោហៈ ក្តៅដោយសេចក្តីកើត ដោយសេចក្តីចាស់គ្រាំគ្រា និងសេចក្តីស្លាប់ ក្តៅដោយសេចក្តីសោក ដោយសេចក្តីខ្សឹកខ្សួល ដោយសេចក្តីទុក្ខក្នុងកាយ ដោយសេចក្តីទុក្ខក្នុងចិត្ត ដោយសេចក្តីចង្អៀតចង្អល់ក្នុងចិត្តទាំងឡាយ ។

**កាយោ អាទិត្តោ** កាយជារបស់ក្តៅ

**ផោដ្ឋព្វា អាទិត្តា** ផោដ្ឋព្វៈ គឺអារម្មណ៍ ដែលប៉ះពាល់ត្រូវដោយកាយទាំងឡាយ ជារបស់ក្តៅ

**កាយវិញ្ញាណំ អាទិត្តំ** វិញ្ញាណអាស្រ័យនឹងកាយ ជា

របស់ក្តៅ

**កាយសម្ផស្សោ អាទិត្តោ** សម្ផស្សអាស្រ័យនឹងកាយ ជារបស់ក្តៅ

**យម្បិទំ កាយសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា** សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះកាយសម្ផស្ស ជាបច្ច័យឯណា

**តម្បិ អាទិត្តំ** សេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ ក៏ជារបស់ក្តៅ ។

**កេន អាទិត្តំ** ក្តៅដោយអ្វី ?

**អាទិត្តំ រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អាទិត្តន្តិ វទាមិ** តថាគតពោលថា ក្តៅដោយភ្លើងគឺរាគៈ ដោយភ្លើងគឺទោសៈ ដោយភ្លើងគឺមោហៈ ក្តៅដោយសេចក្តីកើត ដោយសេចក្តីចាស់គ្រាំគ្រា និងសេចក្តីស្លាប់ ក្តៅដោយសេចក្តីសោក ដោយសេចក្តីខ្សឹកខ្សួល ដោយសេចក្តីទុក្ខក្នុងកាយ ដោយសេចក្តីទុក្ខក្នុងចិត្ត ដោយសេចក្តីចង្អៀតចង្អល់ក្នុងចិត្តទាំងឡាយ ។





**មនោ អាទិត្តោ** ចិត្តជារបស់ក្តៅ

**ធម្មា អាទិត្តា** ធម៌ទាំងឡាយគឺអារម្មណ៍ ដែលកើតក្នុងចិត្ត ជារបស់ក្តៅ

**មនោវិញ្ញាណំ អាទិត្តំ** វិញ្ញាណអាស្រ័យនឹងចិត្ត ជារបស់ក្តៅ

**មនោសម្ផស្សោ អាទិត្តោ** សម្ផស្សអាស្រ័យនឹងចិត្ត ជារបស់ក្តៅ

**យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា** សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះមនោសម្ផស្ស ជាបច្ច័យឯណា

**តម្បិ អាទិត្តំ** សេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ ក៏ជារបស់ក្តៅ ។

**កេន អាទិត្តំ** ក្តៅដោយអ្វី ?

**អាទិត្តំ រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អាទិត្តន្តិ វទាមិ** តថាគតពោលថា ក្តៅដោយភ្លើងគឺរាគៈ ដោយភ្លើងគឺទោសៈ ដោយភ្លើង

គឺមោហៈ ក្តៅដោយសេចក្តីកើត ដោយសេចក្តីចាស់គ្រាំគ្រា និងសេចក្តីស្លាប់ ក្តៅដោយសេចក្តីសោក ដោយសេចក្តីខ្សឹកខ្សួល ដោយសេចក្តីទុក្ខក្នុងកាយ ដោយសេចក្តីទុក្ខក្នុងចិត្ត ដោយសេចក្តីចង្អៀតចង្អល់ក្នុងចិត្តទាំងឡាយ ។

**ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ ចក្ខុស្មឹបិ និព្វិន្ទតិ រូបេសុបិ និព្វិន្ទតិ ចក្ខុវិញ្ញាណេបិ និព្វិន្ទតិ ចក្ខុសម្ផស្សេបិ និព្វិន្ទតិ** ម្នាលភិក្ខុទាំងឡាយ អរិយសាវកកាល បើបានស្តាប់ហើយ យល់ឃើញយ៉ាងនេះ ក៏នឿយណាយក្នុងភ្នែកផង នឿយណាយក្នុងរូបទាំងឡាយផង នឿយណាយក្នុងវិញ្ញាណអាស្រ័យនឹងភ្នែកផង នឿយណាយក្នុងសម្ផស្សអាស្រ័យនឹងភ្នែកផង

**យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ** សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យឯណា ក៏នឿយណាយក្នុងសេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ ។

**សោតស្មឹបិ និព្វិន្ទតិ សទ្ទេសុបិ និព្វិន្ទតិ សោតវិញ្ញាណេបិ និព្វិន្ទតិ សោតសម្ផស្សេបិ និព្វិន្ទតិ** នឿយណាយក្នុងត្រចៀកផង នឿយណាយក្នុងសំឡេងទាំងឡាយផង





នឿយណាយក្នុងវិញ្ញាណអាស្រ័យនឹងត្រចៀកផង នឿយណាយក្នុងសម្ផស្ស អាស្រ័យនឹងត្រចៀកផង

**យម្បិទំ សោតសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ** សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះសោតសម្ផស្សជាបច្ច័យឯណា ក៏នឿយណាយក្នុងសេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ ។

**ឃានស្មឹបិ និព្វិន្ទតិ គន្ធេសុបិ និព្វិន្ទតិ ឃានវិញ្ញាណេបិ និព្វិន្ទតិ ឃានសម្ផស្សេបិ និព្វិន្ទតិ** នឿយណាយក្នុងច្រមុះផង នឿយណាយក្នុងក្លិនទាំងឡាយផង នឿយណាយក្នុងវិញ្ញាណ អាស្រ័យនឹងច្រមុះផង នឿយណាយក្នុងសម្ផស្សអាស្រ័យនឹងច្រមុះផង

**យម្បិទំ ឃានសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ** សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះឃានសម្ផស្សជាបច្ច័យឯណា ក៏នឿយណាយក្នុងសេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ។

**ជិវ្ហាយបិ និព្វិន្ទតិ រសេសុបិ និព្វិន្ទតិ ជិវ្ហាវិញ្ញា-**

**ណេបិ និព្វិន្ទតិ ជិវ្ហាសម្ផស្សេបិ និព្វិន្ទតិ** នឿយណាយក្នុងអណ្តាតផង នឿយណាយក្នុងរសទាំងឡាយផង នឿយណាយក្នុងវិញ្ញាណ អាស្រ័យនឹងអណ្តាតផង នឿយណាយក្នុងសម្ផស្សអាស្រ័យនឹងអណ្តាតផង

**យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ** សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះជិវ្ហាសម្ផស្សជាបច្ច័យឯណា ក៏នឿយណាយក្នុងសេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ ។

**កាយស្មឹបិ និព្វិន្ទតិ ផោដ្ឋព្វេសុបិ និព្វិន្ទតិ កាយវិញ្ញាណេបិ និព្វិន្ទតិ កាយសម្ផស្សេបិ និព្វិន្ទតិ** នឿយណាយក្នុងកាយផង នឿយណាយក្នុងផោដ្ឋព្វៈទាំងឡាយផង នឿយណាយក្នុងវិញ្ញាណ អាស្រ័យនឹងកាយផង នឿយណាយក្នុងសម្ផស្សអាស្រ័យនឹងកាយផង

**យម្បិទំ កាយសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ** សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះកាយសម្ផស្សជាបច្ច័យឯណា ក៏





នឿយណាយក្នុងសេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ។

**មនស្មឹបិ និព្វិន្ទតិ ធម្មេសុបិ និព្វិន្ទតិ មនោវិញ្ញាណេបិ និព្វិន្ទតិ មនោសម្ផស្សេបិ និព្វិន្ទតិ** នឿយណាយក្នុងចិត្តផង នឿយណាយក្នុងធម៌ទាំងឡាយផង នឿយណាយក្នុងវិញ្ញាណ អាស្រ័យនឹងចិត្តផង នឿយណាយក្នុងសម្ផស្សអាស្រ័យនឹងចិត្តផង

**យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ** សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះមនោសម្ផស្សជាបច្ច័យឯណា ក៏នឿយណាយក្នុងសេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ ។

**និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ** កាលបើនឿយណាយ ( យ៉ាងនេះហើយ ) ក៏ប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះ ( ចាកអាសវៈ ) ព្រោះកិរិយាប្រាសចាកតម្រេក ។

**វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ** កាលដែលចិត្តផុតស្រឡះ ( ចាកអាសវៈ ) ហើយ ញាណ ( របស់អរិយសាវ័កនោះ ) ក៏កើតឡើងប្រាកដថា ចិត្ត ( របស់អញ ) ផុតស្រឡះ ( ចាកអាសវៈ ) ហើយ ។

**ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ** ( អរិយសាវក័នោះ ) ក៏ដឹងច្បាស់ដូច្នេះថា ជាតិ ( របស់អញ ) អស់ហើយ មគ្គព្រហ្មចរិយធម៌ អញបាននៅរួចហើយ កិច្ចដែលគួរធ្វើ អញក៏បានធ្វើរួចហើយ កិច្ចឯទៀតក្រៅពីនេះ មិនមាន (ដល់អញ ) ឡើយ ។

**ឥទមវោច ភគវា** ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បានត្រាស់សម្ដែងនូវព្រះសូត្រនេះហើយ

**អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុំ** ភិក្ខុទាំងឡាយនោះ ក៏មានចិត្តត្រេកអរ រីករាយចំពោះភាសិតនៃព្រះដ៏មានព្រះភាគជាម្ចាស់ ។

**ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញមានេ តស្ស ភិក្ខុសហស្សស្ស អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចឹសូតិ** ក៏កាលដែលព្រះដ៏មានព្រះភាគជាម្ចាស់ កំពុងត្រាស់សម្ដែងនូវវេយ្យាករណ៍នេះ ចិត្តរបស់ភិក្ខុទាំង ១០០០ រូបនោះ បានរួចស្រឡះហើយចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ( ថាអញថាយើងទៀតឡើយ ) ។ (លំនាំសូត្រតាមភាណវារៈ)

**( អាទិត្តបរិយាយសូត្រ ចប់ )**





# ប្រវត្តិសង្ខេបបងប្អូនបីនាក់

## ១-ព្រះឧរុវេលកស្សបត្ថេរ

ព្រះឧរុវេលកស្សបត្ថេរ លោកកើតនៅនគរមគធៈ ក្នុងត្រកូលព្រាហ្មណ៍ កស្សបគោត្រ ។ លោកមានប្អូនប្រុសពីរនាក់គឺ **នទីកស្សបៈ និងគយាកស្សបៈ** ។ បងប្អូនទាំងបីនាក់ រួមទាំងបរិវារ ១.០០០នាក់បាននាំគ្នាចេញបួសតាំងតែមុនព្រះពុទ្ធបានត្រាស់ម្ល៉េះគឺ បួសជាជដិលបូជាភ្លើង។កន្លែងដែលអ្នកទាំងបីព្រមទាំងបរិវារបួសនោះ នៅមិនឆ្ងាយពីកន្លែងត្រាស់ដឹងនៃព្រះសម្មាសម្ពុទ្ធឡើយ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់យាងទៅសម្ដែងបាដិហារិយ៍ ៣.៥០០ មុខ រហូតទាល់តែអ្នកទាំងអស់នោះ ដាក់ចុះនូវមានះ ហើយសូមឧបសម្បទានឹងព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះករុណាប្រោសប្រទាននូវឧបសម្បទា ដោយឯហិភិក្ខុឧបសម្បទាគ្រប់គ្នាទាំងអស់ ។

ពេលនោះ ព្រះបរមសាស្ដាទ្រង់គង់ប្រថាប់នៅគយាសីស-ប្រទេស លើផែនថ្មភ្នំ ឱ្យបុរាណជដិលភិក្ខុជួបជុំទាំង ១.០០០ អង្គ ទ្រង់ប្រកាសសម្ដែងនូវ **អាទិត្តបរិយាយសូត្រ** ។ ភពទាំង ៣

ប្រាកដដល់ភិក្ខុទាំងនោះ ដូចជាភ្លើងកំពុងឆេះសន្ធោសន្ធៅ កាលដែលចេះតែពិចារណាតាមក្រសែនៃធម៌ទៅ ចិត្តក៏ផុតស្រឡះចាកអាសវក្កិលេស សម្រេចបានជាព្រះអរហន្តទាំងអស់អង្គ ព្រមដោយអភិញ្ញា និងបដិសម្ភិទា ។

ការដែលបានចាក់ឫសគល់ព្រះពុទ្ធសាសនាជ្រៅ នៅនគរមគធៈនោះ គឺបានព្រះឧរុវេលកស្សបៈនេះឯង ជាកម្លាំងដ៏សំខាន់នៃព្រះដ៏មានព្រះភាគ ដែលជួយធ្វើឱ្យអ្នកនគរមគធៈជាដើម រាប់-អានព្រះពុទ្ធសាសនាបានដោយងាយ ។ ព្រោះថា កាលដើមឡើយ អ្នកនគរមគធៈ និងអង្គៈ មានការរាប់អានឧរុវេលកស្សបៈនេះជាខ្លាំង ដោយសម្គាល់ថាជាព្រះអរហន្តរបស់ខ្លួនទៀតផង ។ លុះដល់ព្រះឧរុវេលកស្សបៈ សម្ដែងឫទ្ធិហោះទៅលើមេឃ ហើយចុះមកថ្វាយបង្គំព្រះបរមសាស្ដា ចុះឡើងច្រើនសា ប្រកាសខ្លួនជាសាវ័ករបស់ព្រះដ៏មានព្រះភាគ ដូច្នេះអ្នកស្រុកទាំងអស់មានព្រះ-បាទពិម្ពិសារជាប្រមុខ ក៏បានតាំងចិត្តស្ដាប់ព្រះធម៌ ហើយក៏បានឃើញនូវសច្ចៈទាំង ៤ ។

គុណសម្បត្តិរបស់ព្រះឧរុវេលកស្សបត្ថេរ គឺជាអ្នកជួយក្នុងការប្រតិស្ឋានព្រះពុទ្ធសាសនា ក្នុងនគរមគធៈ និងជាអ្នកជួយប្រកាសព្រះពុទ្ធសាសនា ដោយការចេះដឹងប្រកបដោយសមត្ថភាព



ខ្ពស់ ព្រមទាំងពូកែក្នុងការគ្រប់គ្រងបរិស័ទ ។ ព្រោះអាស្រ័យហេតុដូច្នេះ លោកទើបមានបរិស័ទជាបរិវារច្រើន រហូតដល់ទៅបានជាឯតទគ្គៈលើភិក្ខុទាំងឡាយ ផ្នែកខាងមានបរិវារច្រើនទៀតផង ។

នៅក្នុងព្រះថេរគាថា ព្រះឧរុវេលកស្សបត្ថេរ បានសម្ដែងថា :

ខ្ញុំឃើញបាដិហារិយ៍របស់ព្រះគោតម ព្រះអង្គមានយសដល់ម្ល៉េះ ក៏នៅតែមិនក្រាបសំពះ ព្រោះតែសេចក្ដីច្រណែន និងសេចក្ដីប្រកាន់ ធ្វើឱ្យភាន់ច្រឡំ ។

ព្រះបរមសាស្ដា ជាសារថីរបស់ជន ទ្រង់ជ្រាបសេចក្ដីត្រិះរិះរបស់ខ្ញុំហើយ បានដាស់តឿន លំដាប់នោះ ខ្ញុំមានសេចក្ដីសង្វេគ និងសេចក្ដីព្រឺរោម ដែលមិនធ្លាប់កើតមាន ។

ការសម្រេចនូវលាភសក្ការៈណាបន្តិចបន្តួច គ្រាកាលដែលខ្ញុំធ្លាប់នៅជាជដិលនោះ ខ្ញុំបានលះបង់នូវការសម្រេចលាភសក្ការៈនោះហើយ មកបួសក្នុងសាសនាព្រះជិនស្រី ។

កាលពីដើម ខ្ញុំជាអ្នកត្រេកអរក្នុងការបូជាភ្លើង មានកាមា-រម្មណ៍ជាប្រមុខ (ប្រាថ្នាកាមក្នុងសុគតិភព) លុះក្រោយមក ខ្ញុំបានដករាគៈ ទោសៈ និងមោហៈចោលហើយ ។

ខ្ញុំដឹងខ្លួនដែលធ្លាប់អាស្រ័យនៅ ក្នុងកាលពីដើមបានជម្រះនូវទិព្វចក្ខុឱ្យស្អាត ជាអ្នកមានឫទ្ធិ ដឹងចិត្តអ្នកដទៃ ទាំងបានសម្រេចទិព្វសោត ។

មួយទៀត កុលបុត្រចេញចាកផ្ទះ មកបួសក្នុងធម្មវិន័យណា ប្រយោជន៍នោះខ្ញុំបានដល់ហើយ តាមលំដាប់ ទាំងធ្វើឱ្យអស់នូវសំយោជនធម៌ទាំងពួង ។

**២-នទីកស្សបត្ថេរ** បានសម្តែងដូច្នេះថា :

អាត្មាអញបានស្តាប់ព្រះធម៌ របស់ព្រះពុទ្ធអង្គណា ហើយវៀរបង់មិច្ឆាទិដ្ឋិ ព្រះពុទ្ធអង្គនោះយាងមកហើយកាន់ស្ទឹងនេរញ្ជរា ដើម្បីប្រយោជន៍ដល់អាត្មាអញមែនពិត ។

អាត្មាអញបានបូជាយញ្ញទាំងឡាយ ទាំងខ្ពស់ទាំងទាប និងបានបូជាភ្លើង កាលនៅជាបុថុជ្ជន ងងឹតងងល់ សម្គាល់ថាការបូជានេះឯង ជាសេចក្តីបរិសុទ្ធ ។

អាត្មាអញស្ទុះទៅកាន់ព្រៃស្បាតគឺទិដ្ឋិមានការស្ទាបអង្អែល ដោយទិដ្ឋិប្រកបដោយការវង្វេង ជាមនុស្សងងឹត ល្ងង់ខ្លៅមិនដឹងអ្វី សម្គាល់ផ្លូវមិនបរិសុទ្ធ ថាជាផ្លូវបរិសុទ្ធ ។

មិច្ឆាទិដ្ឋិ អាត្មាអញបានលះបង់ហើយ ភពទាំងពួងអាត្មា



អញបានទម្លាយហើយ អាត្មាអញបូជាភ្លើង គឺព្រះសម្មាសម្ពុទ្ធ ជាទក្ខិណេយ្យបុគ្គល ខ្ញុំសូមនមស្ការចំពោះព្រះតថាគត ។

មោហៈទាំងពួង អាត្មាអញបានលះបង់ហើយ ភវតណ្ហា អាត្មាអញបានទម្លាយចេញហើយ ជាតិសង្សារអស់រលីងហើយ ឥឡូវនេះភពថ្មីទៀតនៃអាត្មាអញមិនមានទេ ។

**៣-គយាកស្សបត្ថេរ** បានសម្តែងដូច្នេះថា :

អាត្មាអញចុះទឹកក្នុងកំពង់ឈ្មោះ គយា ក្នុងមួយថ្ងៃ ៣ ដង គឺពេលព្រឹក ថ្ងៃត្រង់ និងល្ងាច ក្នុងកាលមហោស្រពឈ្មោះគយផគ្គុ ។ បាបណាដែលអាត្មាអញធ្វើហើយ ក្នុងជាតិទាំងឡាយអំពីកាលមុន ឥឡូវនេះ អាត្មាអញបណ្តែតចោលនូវបាបនោះ ក្នុងកំពង់ឈ្មោះ គយានេះ ទិដ្ឋិយ៉ាងនេះ មានហើយក្នុងកាលមុន ។

អាត្មាអញស្តាប់វាចាជាសុភាសិត ជាបទប្រកបដោយធម៌ និងអត្ថ (គឺប្រកបដោយហេតុផល ) ហើយពិចារណានូវសេចក្តីតាមគួរដល់ការពិត ដោយឧបាយនាំឱ្យកើតប្រាជ្ញា ។

អាត្មាអញមានបាបទាំងពួងលាងចេញហើយមិនមានមន្ទិល មានកិលេសលាងចេញហើយ ជាអ្នកស្អាតបរិសុទ្ធ ជាពុទ្ធទាយាទ (អ្នកគួរទទួលនូវមរតកអំពីព្រះពុទ្ធ ) ជាកូនកើតអំពីព្រះឱរា គឺទ្រូង

នៃព្រះពុទ្ធ ( មានទេសនាញាណនៃព្រះពុទ្ធជាសមុដ្ឋាន ) ។

អាត្មាអញចុះកាន់ខ្សែនៃមគ្គប្រកបដោយអង្គ ៨ ហើយបណ្ដេតចោលនូវបាបទាំងពួង ដល់នូវវិជ្ជា ៣ សាសនារបស់ព្រះពុទ្ធ អាត្មាអញបានធ្វើស្រេចហើយ ។

*-មាត់ស្ទឹងនេរញ្ជរាត្រើយខាងកើត មានទីដែលព្រះអង្គទ្រង់សោយមធុបាយាសក្នុងថ្ងៃត្រាស់ដឹង ទីបណ្ដែតភាជន៍មាស និងទីដែលព្រះអង្គទ្រង់ទទួលនូវស្បូវ ៨ ក្ដាប់ពីសោត្ថិយព្រាហ្មណ៍។ ទីទាំងនេះនៅពីខាងកើតព្រះពោធិព្រឹក្ស ស្ថានដែលព្រះអង្គទ្រង់ត្រាស់ដឹងហ្នឹងឯង ។

*-កន្លែងដែលព្រះអង្គទ្រង់ធ្វើទុក្ករកិរិយា មើលពីផ្ទះនាងសុជាតា ទៅទិសឦសាន ប្រមាណបីគីឡូម៉ែត្រ ។ នឹកឃើញព្រះអង្គទ្រង់ភ្ញាក់ត្រូវនឹងពាក្យថា **ពុទ្ធខ្លោ** គឺព្រះអង្គទ្រង់ភ្ញាក់ពីកណ្ដាលកាមគុណក្នុងព្រះរាជវាំង ភ្ញាក់ពីអាកិញ្ចញ្ញាយតនជ្ឈាន និងនេវសញ្ញានាសញ្ញាយតនជ្ឈាន ក្នុងសំណាក់តាបសទាំងពីរ និងភ្ញាក់ពីទុក្ករកិរិយាដែលមនុស្សសម័យនោះ គេប្រកាន់ថាជាអំពើសំខាន់បំផុតរបស់អ្នកបួស ។ ទីបំផុតព្រះអង្គទ្រង់ភ្ញាក់ពីអនុស័យ ដែលជាដំណេកមួយសង្សារវដ្ដ ។



*-**ភ្នំកុក្កុដបាទ** ទីព្រះមហាកស្សបបរិនិព្វាន។ ធ្វើដំណើរដោយរថយន្តតូច ចេញពីពុទ្ធគយា វេលាប្រមាណមួយម៉ោងកន្លះ ហើយត្រូវដើរឡើងភ្នំប្រមាណមួយម៉ោងកន្លះទៀត ។

## មហាកស្សបត្ថេរគាថា

**៣ គាថា** ព្រោះឃើញភិក្ខុទាំងឡាយច្របូកច្របល់ដោយគណៈ និងត្រកូល ហើយពោលដោយការប្រទានឱវាទដល់ភិក្ខុទាំងនោះ ( ក្នុងបិដកលេខ ៥៧ ) ។

ភិក្ខុមិនគប្បីប្រព្រឹត្តមានគណៈចោមរោម (ព្រោះ) រមែងមានចិត្តក្ដៅក្រហាយ បានសមាធិដោយលំបាក ការសង្គ្រោះជននានា នាំមកនូវសេចក្ដីទុក្ខ ភិក្ខុឃើញដូច្នេះហើយ មិនគប្បីត្រេកអរនឹងគណៈឡើយ ។

អ្នកប្រាជ្ញ មិនគប្បីចូលទៅអែបអប នឹងត្រកូលទាំងឡាយទេ (ព្រោះ) រមែងមានចិត្តក្ដៅក្រហាយ បានសមាធិដោយលំបាក ភិក្ខុណា ជាអ្នកល្មោភក្នុងរសមានចម្ងាញ់ ភិក្ខុនោះ ជាអ្នកននះនរនាទ ជាប់ចិត្តក្នុងរស រមែងខូចបង់ប្រយោជន៍ ។

មែនពិត អ្នកប្រាជ្ញទាំងឡាយ បានដឹងនូវការថ្វាយបង្គំ និង

ការបូជាក្នុងត្រកូលទាំងឡាយ ថាដូចជាភក់ (ព្រោះថា) សរគឺកិលេសល្អិតៗ ភិក្ខុកន្លងបង់បានដោយលំបាក គ្រឿងសក្ការៈ បុរសលាមក លះបង់បានដោយក្រ ។

**៤ គាថា** ជាឱវាទដល់ភិក្ខុទាំងឡាយ ឱ្យតាំងនៅក្នុងធម៌សន្តោស មានខ្លួនលោកជាតួយ៉ាង ។

ខ្ញុំចុះចាកសេនាសនៈ (លើភ្នំ) ចូលទៅកាន់នគរ ដើម្បីបិណ្ឌបាត ។ ខ្ញុំបានយកចិត្តទុកដាក់ចូលទៅជិតបុរសឃ្លង់ ដែលកំពុងតែបរិភោគ ។

បុរសនោះ បានបង្អោនពំនូតបាយដល់ខ្ញុំដោយដៃ ដែលមានរោគឃ្លង់ទុំផេរៗ ហើយ កាលបុរសនោះកំពុងដាក់ពំនូតបាយម្រាមដៃក៏ដាច់ធ្លាក់ទៅក្នុងបាត្រនោះ ។

ខ្ញុំផ្អែកនឹងជញ្ជាំងផ្ទះ ហើយក៏បានឆាន់នូវពំនូតបាយនោះ កាលពំនូតបាយដែលខ្ញុំកំពុងបរិភោគក្ដី បរិភោគរួចហើយក្ដី ខ្ញុំមិនមានសេចក្ដីខ្ពើមរអើមឡើយ ។

ដុំបាយដែលភិក្ខុទៅឈរទៀបទ្វារ ផ្ទះនៃជនដទៃ ហើយបានមកជាអាហារ ១ សម៉ដែលត្រាំដោយទឹកមូត្រគោស្អុយជាឱសថ ១ ម្លប់ឈើជាសេនាសនៈ ១ សំពត់បង្សុកូលចីវរ ១ ភិក្ខុណា បានបរិភោគនូវរបស់ទាំងនេះហើយ ភិក្ខុនោះ អាចនៅក្នុងទិសទាំង ៤ បាន ។



**៤ គាថា** ជាការសម្ដែងវិហារធម៌របស់លោក ពេលដែលលោកចាស់ជរា មនុស្សទាំងឡាយសួរលោកពីការឡើងភ្នំ ។

ពួកមនុស្សខ្លះ កាលឡើងភ្នំតែងតែលំបាកចិត្តក្នុងបច្ឆិមវ័យណា កស្សប ជាទាយាទរបស់ព្រះពុទ្ធ ជាអ្នកដឹងខ្លួន មានស្មារតីមាំ រឹងប៉ឹងដោយកម្លាំងឫទ្ធិ ឡើង (ភ្នំ) ក្នុងបច្ឆិមវ័យនោះបាន ។

កស្សបៈ តែឆាន់រួចហើយ ឡើងទៅលើភ្នំ ហើយចម្រើនឈាន ជាអ្នកមិនមានសេចក្ដីប្រកាន់ មានភ័យដ៏ពន្លឹកលះចោលហើយ ។

កស្សបៈ តែឆាន់រួចហើយ ឡើងទៅលើភ្នំ ហើយចម្រើនឈាន ជាអ្នកមិនមានសេចក្ដីប្រកាន់ កាលពួកសត្វក្ដៅក្រហាយ កស្សបជាបុគ្គលត្រជាក់ ។

កស្សបៈ តែឆាន់រួចហើយ ឡើងទៅលើភ្នំ ហើយចម្រើនឈាន ជាអ្នកមិនមានសេចក្ដីប្រកាន់ មានកិច្ចធ្វើហើយ មិនមានអាសវៈ ។

**១០ គាថា** សម្តែងអំពីភ្នំក្នុងព្រៃជាទីមនោរម្យ ពេលដែលមនុស្សទាំងឡាយសួរលោកថា លោកម្ចាស់ដ៏ចម្រើន រហូតដល់ពេលចាស់ហើយ លោកម្ចាស់នៅតែលើភ្នំក្នុងព្រៃរហូតឬ ?

ចំណែកផែនដី ដែលផ្សាយទៅដោយក្លិននៃផ្កាក្តម្ព ជាទីត្រេកអរនៃចិត្ត សម្រែកនៃដំរី ជាទីត្រេកអរ ភ្នំទាំងឡាយនោះរមែងញ៉ាំងខ្ញុំឱ្យត្រេកអរ ។

ភ្នំទាំងនោះ មានពណ៌ដូចពពកខៀវ ដ៏រុងរឿង មានទឹកត្រជាក់ទ្រទ្រង់នូវវត្ថុដ៏ស្អាត ដេរដាសដោយក្អៀង តែងញ៉ាំងខ្ញុំឱ្យត្រេកអរ ។

ភ្នំទាំងនោះ ប្រាកដស្មើដោយកំពូលពពកដ៏ខៀវ ឧបមាដូចផ្ទះមានកំពូលដ៏ប្រសើរ មានសម្រែកនៃដំរី ជាទីត្រេកអរ តែងញ៉ាំងខ្ញុំឱ្យត្រេកអរ ។

ភ្នំថ្មទាំងនោះ ដែលភ្លៀងបន្ទរហើយ មានផ្ទៃជាទីត្រេកអរដែលឥសីទាំងឡាយធ្លាប់អាស្រ័យនៅហើយ ដែលពួកសត្វក្ងោកស្រែកយំហើយ តែងញ៉ាំងខ្ញុំឱ្យត្រេកអរ ។

ភ្នំទាំងឡាយ គួរដល់ខ្ញុំដែលប្រាថ្នាដើម្បីចម្រើនឈាន មានចិត្តស្លុងទៅរកព្រះនិព្វាន គួរដល់ខ្ញុំដែលប្រាថ្នាប្រយោជន៍ ជាភិក្ខុមានចិត្តស្លុងទៅរកព្រះនិព្វាន ។





ភ្នំទាំងឡាយ គួរដល់ខ្ញុំដែលប្រាថ្នារកសេចក្តីស្រួល មានចិត្តស្លុងទៅរកព្រះនិព្វាន ជាអ្នកសិក្សា គួរដល់ខ្ញុំដែលប្រាថ្នាព្យាយាម មានចិត្តស្លុងទៅរកព្រះនិព្វាន ជាតាទិបុគ្គល ។

ភ្នំទាំងនោះ ដ៏ដេរដាសដោយផ្កាកណិការ រីកព្រោងព្រាតដូចផ្ទៃមេឃ ដេរដាសដោយពួកបក្សីផ្សេងៗ តែងញ៉ាំងខ្ញុំឱ្យត្រេកអរ ។

ភ្នំទាំងឡាយនោះ មិនច្រឡូកច្រឡំដោយពួកគ្រហស្ថ មានតែពួកម្រឹគនៅអាស្រ័យ ដេរដាសដោយពួកបក្សីផ្សេងៗ តែងញ៉ាំងខ្ញុំឱ្យត្រេកអរ ។

ភ្នំទាំងនោះ មានទឹកថ្លា មានថ្មក្រាស់ ប្រកបដោយពួកម្រឹគ មានកន្ទុយដូចគោ ដេរដាសដោយសារាយ តែងញ៉ាំងខ្ញុំឱ្យត្រេកអរ ។

សេចក្តីត្រេកអរ (នៃខ្ញុំ) ដោយសារតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ប្រាកដដូច្នោះមិនមានឡើយ ដូច ( ការមិនមានសេចក្តីត្រេកអរ ) នៃព្រះយោគី ដែលមានចិត្តមូលក្នុងអារម្មណ៍តែមួយឃើញច្បាស់នូវធម៌ដោយប្រពៃ ។

**២ គាថា** ព្រះមហាកស្សបត្ថេរ ប្រទានឱវាទដល់ភិក្ខុទាំង-

ឡាយ ដែលមានការងារជាទីត្រេកអរ និងប្រាថ្នាក្នុងបច្ច័យ ។

បុគ្គលមិនត្រូវធ្វើការងារឱ្យច្រើន ត្រូវវៀរជន (មិនមែនជាកល្យាណមិត្ត ) មិនត្រូវខ្នះខ្នែង (ដើម្បីបច្ច័យ ) បុគ្គលណាជាអ្នកល្មោភក្នុងរសមានចម្ងាញ់ បុគ្គលនោះ ជាអ្នកខ្នះខ្នែងជាប់ចិត្តក្នុងរស រមែងខូចបង់ប្រយោជន៍ ។

បុគ្គលមិនត្រូវធ្វើការងារឱ្យច្រើន ត្រូវវៀរចាកជន ( មិនមែនជាកល្យាណមិត្តព្រោះ) ការងារនោះ មិនមែនជាប្រយោជន៍ កាយរមែងលំបាកនឿយហត់ បុគ្គលអ្នកដល់នូវសេចក្តីនឿយហត់នោះ រមែងមិនបាននូវសេចក្តីស្ងប់រម្ងាប់ឡើយ ។

**២ គាថា** តិះដៀលបុគ្គលដែលមាននូវមានះ ថាខ្លួនជាបណ្ឌិត ដោយគ្រាន់តែចេះសូត្រនូវព្រះពុទ្ធវចនៈ ។

បុគ្គលមិនពិចារណាឃើញដោយខ្លួនឯង បានត្រឹមតែរលាស់បបូរមាត់ (ស្វាធ្យាយពុទ្ធវចនៈ) បុគ្គលប្រព្រឹត្តរឹងរូស តែងសម្គាល់ថា អាត្មាអញប្រសើរ ។

បុគ្គលពាលមិនប្រសើរ តែងសម្គាល់ខ្លួនថាស្មើនឹងបុគ្គលប្រសើរ អ្នកប្រាជ្ញទាំងឡាយ មិនសរសើរជនអ្នកមានចិត្តរឹងរូសនោះឡើយ ។



**២ គាថា** ជាពាក្យសរសើរបណ្ឌិតពិតប្រាកដ ។

បុគ្គលណាមិនញាប់ញ័រក្នុងមានះ(ទាំង ៩ ណាមួយ) ដោយចិត្តកើតឡើងថា អញជាមនុស្សប្រសើរ ឬថា អញជាមនុស្ស មិនប្រសើរ អញជាមនុស្សថោក ឬថាអញជាមនុស្សប្រហែលនឹងគេទេ អ្នកប្រាជ្ញទាំងឡាយ តែងសរសើរបុគ្គលនោះ ថាជាអ្នកមានប្រាជ្ញា អ្នកនិយាយទៀងទាត់ អ្នកមានចិត្តតម្កល់មាំក្នុងសីលទាំងឡាយ អ្នកប្រកបរឿយៗនូវការស្ងប់ចិត្ត ។

**២ គាថា** ប្រកាសទោសនៃភិក្ខុដែលគេប្រដៅបានដោយក្រ និងអានិសង្សនៃការប្រដៅបានដោយងាយ ។

បុគ្គលណា មិនបានគោរពនូវសព្រហ្មចារីទាំងឡាយទេ បុគ្គលនោះ រមែងឆ្ងាយចាកព្រះសទ្ធម្មដូចផែនដី (ឆ្ងាយ ) ពីមេឃ។

បុគ្គលទាំងឡាយណា មានហិរិនិងឱត្តប្បៈតម្កល់នៅដោយប្រពៃគ្រប់ពេល បុគ្គលទាំងនោះ មានព្រហ្មចារ្យដុះចម្រើនហើយ មានភពថ្មីអស់ហើយ ។

**២ គាថា** សម្តែងប្រាប់ភិក្ខុអំពីការមិនសមស្លៀកដណ្តប់នូវសំពត់បង្សុកូល និងជាការសមរម្យក្នុងការស្លៀកដណ្តប់សំពត់

បង្សុកូល ។

ភិក្ខុណា មានចិត្តរវើរវាយ ឃ្លេងឃ្លោង ស្មៀកដណ្តប់សំពត់បង្សុកូល ភិក្ខុនោះមិនសមនឹងសំពត់បង្សុកូលនោះឡើយ ដូចស្វាដណ្តប់ស្បែកសីហៈ ។

ភិក្ខុណា មានចិត្តមិនរវើរវាយ មិនឃ្លេងឃ្លោង ជាអ្នកមានប្រាជ្ញាចាស់ សង្រួមឥន្ទ្រិយ ទើបសមនឹងសំពត់បង្សុកូល ដូចសីហៈក្នុងច្រកភ្នំ ។

**៥ គាថា** ព្រះមហាកស្សបត្ថេរ បានឃើញព្រះព្រហ្មនមស្ការចំពោះព្រះសារីបុត្ត និងពោលអំពីព្រះមហាកប្បិនញញឹម។

ពួកទេវតាដ៏ច្រើន មានឫទ្ធិ មានយសសក្តិ ទេវតាមួយហ្មឺនទាំងអស់នោះ ជាពួកព្រហ្ម ឈរនមស្ការ ប្រណម្យអញ្ជលីចំពោះព្រះសារីបុត្ត ជាធម្មសេនាបតី ជាអ្នកប្រាជ្ញ មានឈានច្រើន មានចិត្តតម្កល់មាំថា បពិត្របុរសអាជានេយ្យ ខ្ញុំសូមក្រាបថ្វាយបង្គំលោកម្ចាស់ លោកម្ចាស់ចម្រើនឈាន អាស្រ័យអារម្មណ៍ណា ពួកយើងខ្ញុំមិនបានដឹងនូវអារម្មណ៍នោះ របស់លោកម្ចាស់ទេ ។

អស្ចារ្យហ្ន៎ អារម្មណ៍របស់ពួកលោកអ្នកត្រាស់ដឹងនូវសច្ចៈទាំង ៤ ជាអារម្មណ៍ដ៏ជ្រាលជ្រៅ ( លំបាកដឹងណាស់ ) ពួកយើង (រាប់ថាជាអ្នកមានបញ្ញា ) ដូចពួកខ្នាន់ធ្នូ បាញ់នូវរោមកន្ទុយសត្វមកប្រជុំគ្នា ( ពិចារណា ) នៅតែមិនដឹង ។

ព្រះកប្បិនត្ថេរបានញញឹម ព្រោះឃើញព្រះសារីបុត្តត្ថេរនោះ គួរជាទីបូជា ដែលពពួកទេវតាបូជាហើយ ដោយប្រការដូច្នោះ ។

**២ គាថា** ព្រះថេរៈបន្លឺសីហនាទ ។

ក្នុងពុទ្ធខេត្តទាំងមូល ខ្ញុំជាមនុស្សវិសេសខាងធុតង្គគុណ គ្មានលោកណាស្មើនឹងខ្ញុំទេ លើកលែងតែព្រះមហាមុនីចេញ ។

ព្រះសាស្តាខ្ញុំបានបម្រើហើយ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ភារៈធ្ងន់ខ្ញុំដាក់ចោលហើយ តណ្ហាជាគ្រឿងនាំសត្វទៅកាន់ភពទៀត ខ្ញុំក៏ដកចោលហើយ ។

**១ គាថាកន្លះ** ព្រះថេរៈពោលសរសើរព្រះគុណនៃព្រះដ៏-មានព្រះភាគ ។

ព្រះគោតម មានគុណប្រមាណមិនបាន មានព្រះហឫទ័យឱនទៅរកនេក្ខម្មៈ រលាស់ចោលនូវភពទាំង ៣ មិនជាប់ជំពាក់ក្នុងចីវរ មិនជាប់ជំពាក់ក្នុងសេនាសនៈ មិនជាប់ជំពាក់ក្នុងភោជន

ដូចផ្កាឈូកមិនមានមន្ទិលសៅហ្មង មិនជាប់ដោយទឹក ។

**១ គាថា** ចុងក្រោយ ព្រះមហាកស្សបត្ថេរ ពោលអំពីសតិប្បដ្ឋានជាដើម របស់ព្រះសម្មាសម្ពុទ្ធ ។

**សតិប្បដ្ឋានគីវោ សោ សទ្ធាហត្ថោ មហាមុនិ**
**បញ្ញាសីសោ មហាញាណី សទា ចរតិ និព្វុតោតិ ។**

ព្រះមហាមុនីនោះ មានសតិប្បដ្ឋានជាព្រះសូរង មានសទ្ធាជាព្រះហស្ត មានប្រាជ្ញាជាព្រះសីសៈ មានព្រះញាណធំ ព្រះអង្គប្រព្រឹត្តរំលត់ទុក្ខគ្រប់ពេល ។

## ប្រវត្តិសង្ខេបព្រះមហាកស្សបត្ថេរ

ព្រះមហាកស្សបត្ថេរ នាមដើមថា បិប្ផលិ តែសព្រហ្មចារី តែងហៅថា កស្សបៈ តាមត្រកូល។ លោកកើតនៅស្រុកព្រាហ្មណ៍ឈ្មោះថា មហាតិត្ថៈ ក្នុងនគរមគធៈ ។ កាលមានអាយុ ២០ ឆ្នាំ បានរៀបការជាមួយនឹងនាង ភទ្ទកាបិលានី ស្រីរូបស្អាតនៅសាគលនគរ អាយុ ១៦ ឆ្នាំ ។





ដោយអ្នកទាំងពីរនាក់នេះ ជាអ្នកចុតិពីព្រហ្មលោកមកទាំងអស់គ្នា និងជាអ្នកបំពេញនូវនេក្ខម្មបារមីក្នុងជាតិមុននឹងទៅកាន់ព្រហ្មលោកនោះ ម្ល៉ោះហើយទើបមិនត្រេកអរក្នុងកាមារម្មណ៍ ឃើញទោសក្នុងការគ្រប់គ្រងផ្ទះដោយប្រការផ្សេងៗ ។ លុះដល់មានឱកាសហើយក៏ប្រគល់ទ្រព្យសម្បត្តិឱ្យអ្នកដទៃទាំងអស់ នាំគ្នាកោរសក់ ស្លៀកដណ្ដប់សំពត់កាសាវៈ បួសឧទ្ទិសចំពោះព្រះសម្មាសម្ពុទ្ធ ។

ទាំងពីររូបនេះជាគូឧបនិស្ស័យ ធ្លាប់ជាភរិយាស្វាមីនឹងគ្នាបំពេញបុណ្យបារមីជាមួយគ្នា រាប់ជាតិជាអនេក ហ្មឺនសែនផែនដីកន្លងមកហើយ ។ ជាតិនេះជាជាតិចុងក្រោយ អ្នកទាំងពីរបានកោរសក់ឱ្យដល់គ្នា សាងផ្នួសលាលោកិយ ផែនដីកក្រើកញាប់ញ័រដោយទ្រគុណអ្នកទាំងពីរមិនបាន ។

ព្រះបរមសាស្ដា ទ្រង់គង់នៅព្រះគន្ធកុដិ នាវត្តវេឡុវ័ន ព្រះអង្គទ្រង់ជ្រាបសព្វគ្រប់ហើយ ក៏បានយាងមកគង់នៅក្រោមដើមជ្រៃ ឈ្មោះពហុបុត្តកនិគ្រោធ នៅវវាងក្រុងរាជគ្រឹះ និងនាលន្ទគ្រាម រង់ចាំទទួលព្រះមហាកស្សបៈ ។ ព្រះអង្គទ្រង់ប្រទានឧបសម្បទាឱ្យដល់ព្រះមហាកស្សបៈ ដោយការប្រទាននូវឱវាទ ៣ យ៉ាងគឺ

១.ម្នាលកស្សបៈ អ្នកគប្បីសិក្សាថា ហិរិនិងឱត្តប្បៈដ៏ក្លៀវក្លា អាត្មាអញនឹងតម្កល់ទុក ក្នុងភិក្ខុចាស់ទាំងឡាយ ក្នុងភិក្ខុថ្មីទាំងឡាយ និងក្នុងភិក្ខុកណ្តាលទាំងឡាយ ។

២.ម្នាលកស្សបៈ អ្នកគប្បីសិក្សាថា អាត្មាអញនឹងស្តាប់នូវធម៌ ដែលប្រកបដោយកុសលណានីមួយ ហើយធ្វើនូវធម៌ទាំងអស់នោះ ឱ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ផ្ចង់ចិត្តទាំងពួង ផ្ទង់ត្រចៀកចាំស្តាប់ធម៌ ។

៣.ម្នាលកស្សបៈ អ្នកគប្បីសិក្សាថា អាត្មាអញមិនគប្បីលះបង់នូវកាយគតាសតិដែលប្រកបដោយសេចក្តីសុខ ។

ព្រះមហាកស្សបត្ថេរ បានឧបសម្បទាជាភិក្ខុ ដោយការទទួលយកនូវព្រះបរមពុទ្ធោវាទ ៣ ប្រការនេះឯង ។ គ្រាបួសហើយ លោកច្រើនគង់នៅបិប្ផលិគុហា នាភ្នំវេភារៈ លោកសមាទានធុតង្គ ១៣ អំពីព្រះសាស្តា ប្រារព្ធសេចក្តីព្យាយាមហើយបានជាព្រះអរហន្តចាប់តាំងពីថ្ងៃទី ៨ បន្ទាប់ពីឧបសម្បទាហើយ។

ព្រះមហាកស្សបត្ថេរ បានជួយផ្សព្វផ្សាយព្រះពុទ្ធសាសនា សម្រេចប្រយោជន៍ដ៏អស្ចារ្យដល់មហាជន ជាទីគោរពសក្ការៈដល់ពុទ្ធបរិស័ទជាទូទៅ ទាំងមនុស្ស ទាំងទេវតា ។ ជាពិសេសក្រៃលែង ដែលមិនមានក្នុងសាវ័កដទៃគឺ ព្រះដ៏មានព្រះភាគជា





ព្រះសាស្តា បានប្តូរផ្លាស់សង្ឃាដី ជាមួយនឹងលោក ជាកិត្តិយសពោរពេញដោយអត្ថន័យ ។

ព្រះថេរៈជាគំរូដ៏ល្អដល់អ្នកបួសតមកក្រោយៗ ព្រោះទោះបីលោកបានសម្រេចនូវព្រះអរហត្តផលហើយក៏ដោយ លោកនៅតែសមាទានធុតង្គដ៏យ៉ាងតឹងរ៉ឹង ដោយចំពោះធុតង្គ ៣ មុខ លោកកាន់ជាកិច្ចវត្តរហូតជីវិត គឺ ១.ទ្រង់សំពត់បង្សុកូលជាវត្ត ២.និមន្តបិណ្ឌបាតជាវត្ត ៣.នៅព្រៃជាវត្ត ។ លោកបានទទួលតំណែងឯតទគ្គៈខាងទ្រទ្រង់នូវធុតង្គ និងឱ្យឱវាទដល់ភិក្ខុទាំងឡាយ អំពីការកម្ចាត់បង់នូវកិលេសដោយធុតង្គគុណ ។

ជីវិតចុងក្រោយរបស់ព្រះមហាកស្សបត្ថេរ មានសេចក្តីសំខាន់ដ៏ក្រៃលែង លោកបានជាប្រធានក្នុងការធ្វើសង្គាយនាគ្រាទី ១ នៅសត្តបណ្ណគុហា នាភ្នំវេភារៈ ។ លោកមានព្រះជន្មាយុ ១២០ ឆ្នាំ ។ ក្នុងគម្ពីរមហាសាវកនិព្វាន បានសម្តែងថាព្រះមហាកស្សបត្ថេរ បរិនិព្វាននៅភ្នំកុក្កុដសមបាត សព្វថ្ងៃហៅភ្នំកុក្កុដបាទ ។

*-**វត្តខ្មែរពុទ្ធគយា** ជាទីរីករាយនៃពុទ្ធបរិស័ទ ។

# មហានគរមគធៈ

## នគរមគធៈ ក្រុងរាជគ្រឹះ

ក្នុងបករណបាលី ពោលថា អ្នកស្រុកបានដេញតាមម្រឹគមករហូតដល់ទីនេះ ទើបបានហៅអាណាចក្រនេះថា **មគធៈ** (មិគេន ធាវន្តិ = មាគធោ) ។

ពាក្យថា **រាជគ្រឹះ** ជាភាសាសំស្ក្រឹត ត្រូវគ្នានឹងភាសាបាលីថា **រាជគហ** បានសេចក្តីថា ផ្ទះរបស់ព្រះរាជា គឺព្រះរាជវាំងហ្នឹងឯង ។

ក្រុងរាជគ្រឹះ មានឋានៈជារាជធានីនៃនគរមគធៈ ។ ក្នុងសម័យពុទ្ធកាល មានដែន **កាសី** ដែលមានទីក្រុងឈ្មោះ **ពារាណសី** និងដែន **អង្គ:** មានទីក្រុងឈ្មោះ **ចម្បា** (ទីក្រុងសម្បូណ៌ដោយដើមចម្ប៉ា កន្លែងខ្លះ ហៅ **កាលចម្បាក** ) ដែនទាំងពីរនេះ ក៏ឋិតនៅក្នុងអំណាចនៃអាណាចក្រ **មគធៈ** ផងដែរ ។ **មគធៈ** ជាព្រះរាជាណាចក្រដ៏ធំធេងក្នុងសម័យពុទ្ធកាល មានអំណាចកងទ័ពខ្លាំងក្លាមាំមួន ជានគរពាណិជ្ជកម្មដ៏សំខាន់ ដោយក្រុមរទេះមួយក្រុមៗ



រាប់រយ មកពីតក្កសិលានគរ និងសាវត្ថីជាដើម ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់បានជ្រើសរើសយកទីក្រុងរាជគ្រឹះនគរ **មគធៈ** នេះ ជាទីតាំងមុនដំបូង ក្នុងការផ្សព្វផ្សាយព្រះ-ពុទ្ធសាសនា ដោយមានការទំនុកបម្រុងអំពីព្រះបាទពិម្ពិសារដ៏យ៉ាងក្រៃលែង ។

ពេលខ្លះក្រុងរាជគ្រឹះហៅថា **គិរិព្វជនគរ** ព្រោះមានភ្នំព័ទ្ធជុំវិញ ឬហៅថា **បញ្ចគិរិនគរ** ព្រោះមានភ្នំ ៥ ព័ទ្ធជុំវិញហ្នឹងឯង ។ រីឯឈ្មោះភ្នំមានការហៅផ្សេងគ្នាខ្លះ ប៉ុន្តែក្នុងព្រះពុទ្ធដីកា មានឥសិគិលិសូត្រជាដើម គឺ

**១.ភ្នំវេបុល្លៈ** ធំខ្ពស់ជាងគេនៅនគរមគធៈ ។

**២.ភ្នំវេភារៈ** មានសត្តបណ្ណគុហា កន្លែងបឋមសង្គាយនា (ចន្លោះភ្នំទាំង ២ នេះ ជាទ្វារធំខាងជើងនៃក្រុងរាជគ្រឹះ វេបុល្លៈនៅខាងកើត វេភារៈនៅខាងលិច ) ។

**៣.ភ្នំគិជ្ឈកូដ** មានព្រះគន្ធកុដិគួរជាទីជ្រះថ្លា (នៅខាងកើតក្រុង និងខាងត្បូងភ្នំវេបុល្លៈ) ។

**៤.ភ្នំឥសិគិលិ** មានកាឡសិលា ទីព្រះមហាមោគ្គល្លានបរិនិព្វាន និងជាទីនៅនៃតាបសដ៏ច្រើន មានអាឡារតាបស និងឧទកតាបសជាដើម (នៅខាងត្បូងក្រុង វែងបញ្ឆិតទៅទិសនិរតី។

នៅខាងកើតភ្នំឥសិគិលិនេះ មានភ្នំវេទយិកៈ សព្វថ្ងៃហៅភ្នំឧទ័យ វែងបញ្ឆិតទៅទិសឦសាន ខាងត្បូងភ្នំគិជ្ឈកូដ ។ ចន្លោះក្បាលភ្នំទាំងពីរនេះ ជាទ្វារធំខាងត្បូងនៃក្រុងរាជគ្រឹះ ផ្លូវចេញទៅពុទ្ធ-គយា ។ វេទយិកៈនៅខាងកើត ឥសិគិលិនៅខាងលិច ) ។

**៥_ភ្នំបណ្ឌវៈ** កន្លែងសោយអាហារនៃព្រះមហាបុរស ដែលទើបនឹងបួសហើយថ្មីៗ អាមាត្យរបស់ព្រះបាទពិម្ពិសារ បានតាមឃ្លាំមើល ឃើញព្រះអង្គសោយអាហារនៅភ្នំនេះឯង (នៅចន្លោះភ្នំឥសិគិលិ និងភ្នំវេភារៈ ) ។

## ផ្នែកសាសនា

ព្រះពុទ្ធសាសនាបានតាំងមាំនៅនគរនេះ គឺក្រោយអំពីព្រះបាទពិម្ពិសារបានក្លាយមកជាពុទ្ធសាវ័កហើយ ដូច្នេះទើបនគរនេះមានវត្តអារាមយ៉ាងច្រើន ដូចជាវេឡុវនារាម , តបោទារាម , សត្តបណ្ណគុហារាម ,កស្សបារាម , សីតវនារាម , ជីវកម្ពវនារាម , បាវារិការាម , ឥន្ទសាលារាម , កាឡសិលារាម , លដ្ឋិវនារាម , គោតមនិគ្រោធារាម, វត្តភ្នំគិជ្ឈកូដ, វត្តទក្ខិណាគីរី,វត្តឯកនាលា , និងវត្តបាសាណកចេតិយជាដើម ។ វត្តទាំងអស់នេះ មានព្រះសង្ឃគង់ចាំវស្សាច្រើនអង្គ ជាពិសេសវត្តវេឡុវ័ន មហាវិហារ ។





នគរមគធៈ មុនការត្រាស់ដឹងនៃព្រះសម្មាសម្ពុទ្ធ សម្បូណ៌ទៅដោយម្ចាស់លទ្ធិ ជាគណាចារ្យច្រើនសន្ធឹកសន្ធាប់ ។ ម្ចាស់លទ្ធិដែលសំខាន់ៗ គឺ **អាឡារតាបស កាលាមគោត្រ** និង **ឧទកតាបស រាមបុត្រ** ដែលធ្លាប់ជាអាចារ្យរបស់ព្រះពុទ្ធមុនការត្រាស់-ដឹង ។ ក្រៅអំពីនេះនៅមានសំណាក់គ្រូទាំង ៦ គឺ

**១-បូរណកស្សបៈ** ម្ចាស់លទ្ធិបដិសេធការធ្វើទាំងពួង គ្មានបុណ្យ គ្មានបាប ជា **អកិរិយទិដ្ឋិ** ។

**២-មក្ខលិគោសាល** ម្ចាស់លទ្ធិបដិសេធហេតុដោយប្រការទាំងពួង សត្វទាំងពួងបរិសុទ្ធ ឬសៅហ្មងឯងៗ ជា **អហេតុកទិដ្ឋិ** ។

**៣-អជិតកេសកម្ពល** ម្ចាស់លទ្ធិបដិសេធផលកម្មគ្រប់យ៉ាង សត្វស្លាប់ទៅសូន្យ មាតាបិតាអត់គុណ ជា **នត្ថិកទិដ្ឋិ** ។

**៤-បកុធកច្ចាយនៈ** ម្ចាស់លទ្ធិ ប្រកាន់ថា សភាវៈទាំង ៧ គឺ ដី ទឹក ភ្លើង ខ្យល់ សុខ ទុក្ខ និងជីវៈ មិនមានអ្នកណាធ្វើ ជាសភាវៈឋិតថេរ មិនអាចសម្លាប់បាន ... ជា **សស្សតទិដ្ឋិ** ។

**៥-និគន្ថនាដបុត្រ** ម្ចាស់លទ្ធិ ប្រកាន់ការសង្រួមខុសទំនង មានការមិនស្លៀកពាក់ និងធ្វើខ្លួនឱ្យសៅហ្មងផ្សេងៗជាដើម យល់ថាកាលណាបើសង្រួមយ៉ាងនេះ នឹងបរិសុទ្ធដល់ទីបំផុត នៅ

ជាសាសនា **ជេន** សព្វថ្ងៃនេះ ។

**៦-សញ្ជ័យ វេលដ្ឋបុត្រ** ម្ចាស់លទ្ធិបោះពាក្យបោះសម្តីកុំឱ្យស្លាប់ខ្លួន ជា **អមរាវិក្ខេបទិដ្ឋិ** ។

សូម្បីថាព្រះពុទ្ធសាសនា ចម្រើនរុងរឿង មានពុទ្ធសាវក័ដ៏ច្រើនសន្ធឹកសន្ធាប់ តាំងតែពីព្រះមហាក្សត្រ រហូតដល់អ្នកស្រុកធម្មតា យ៉ាងណាក៏ដោយ នគរមគធៈ នៅតែជានគរដែលមានសាសនាដទៃធំដុំដែរ ជាពិសេសគឺ សាសនាព្រាហ្មណ៍ បច្ចុប្បន្ន គឺសាសនា **ហិណ្ឌូ** ។

## ផ្នែកសេដ្ឋកិច្ច

ក្រុងរាជគ្រឹះ ជាទីក្រុងដែលមានពាណិជ្ជកម្មចម្រើនលូតលាស់ រហូតដល់កើតមានសេដ្ឋីសន្ធឹកសន្ធាប់ ដែលហៅថា **រាជគហសេដ្ឋី** ជាមហានគរស្តុកស្តម្ភទៅដោយទ្រព្យសម្បត្តិ ។

ពាណិជ្ជកម្មសម័យនោះ គេប្រើរទេះអូសដោយសត្វចិញ្ចឹម រហូតដល់ប្រាកដឡើងនូវស្នាមរទេះ ខូងជ្រៅទៅក្នុងថ្ម នៅតាមជើងភ្នំឧទ័យ ច្រកទ្វារក្រុងខាងត្បូង ។

**អនាថបិណ្ឌិកសេដ្ឋី** បាននាំអីវ៉ាន់ដឹកដោយកងរទេះរាប់រយ





ពីក្រុងសាវត្ថី មកលក់នៅក្រុងរាជគ្រឹះ ជាប្រចាំ រហូតដល់បានជួបព្រះពុទ្ធអង្គ នៅសីតវ័ន ក្បែរក្រុង ហើយបានសម្រេចនូវសោតាបត្តិផល ក្នុងពេលចូលគាល់ព្រះអង្គលើកទី ១ ។

## ផ្នែកការគ្រប់គ្រង

រាជាណាចក្រមគធៈ ធំទូលាយ ដោយរួមដែនកាសី និងដែនអង្គៈចូលមកផង ការគ្រប់គ្រងតាមបែប **រាជាធិបតេយ្យ** ។ មានមហាមាត្យជួយក្នុងការរាជការ ជួយទាំងផ្នែកកងទ័ព ផ្នែកសេដ្ឋកិច្ច និងផ្នែកសង្គមជាដើម ។ មហាមាត្យដ៏ល្បីល្បាញ គឺ **វស្សការព្រាហ្មណ៍** គាត់មានជីវិតនៅក្នុងការងារទាំងពីររជ្ជកាល គឺកាលនៃព្រះបាទពិម្ពិសារ និងកាលនៃព្រះបាទអជាតសត្តុ ។

ជុំវិញក្រុងរាជគ្រឹះ មានការសាងកំពែង និងខ្លោងទ្វារដ៏យ៉ាងមាំទាំ ។ នៅតាមខ្នងភ្នំក៏ធ្វើកំពែងដែរ សឹងមានប្រាកដដល់បច្ចុប្បន្ន មាននៅតាមខ្នងភ្នំឧទ័យ និងខ្នងភ្នំឥសិគិលិជាដើម ។ ទ្វារក្រុងមានពេលបើក មានពេលបិទ យ៉ាងតឹងរ៉ឹង ដោយមិនអនុញ្ញាតឱ្យបើកខុសពេលឡើយ សូម្បីតែព្រះអង្គឯង ។

មានរឿងរ៉ាវចំពោះព្រះបាទពិម្ពិសារផ្ទាល់ កាលដែល

ព្រះអង្គមានបំណងស្រង់ទឹក **តបោទា** នារដូវត្រជាក់ ។ កាលនោះព្រះភិក្ខុសង្ឃស្រង់ទឹកយូរពេក ព្រះរាជារង់ចាំទាល់តែគេបិទទ្វារព្រះនគរ (ទ្វារក្រុង ) ។ សូម្បីទាហានប្រចាំទ្វារដឹងថាជាព្រះរាជារបស់ខ្លួនឯងហើយក៏ដោយ ក៏នៅតែរក្សាច្បាប់យ៉ាងមាំមួន ដោយមិនព្រមបើកថ្វាយ រហូតទល់ភ្លឺ ទើបបានបើកតាមប្រក្រតី ។

## មគធៈរជ្ជកាលព្រះបាទពិម្ពិសារ

តាមគម្ពីរមហាវង្ស ព្រះបាទពិម្ពិសារទទួលរាជ្យអំពីព្រះ-បិតាតាំងពីព្រះជន្ម ១៥ ព្រះវស្សា ។ ក្រោយអំពីការគ្រងរាជ្យបាន ១៦ ឆ្នាំ ទើបព្រះអង្គបានជួបនឹងព្រះសម្មាសម្ពុទ្ធ ស្តាប់ព្រះធម៌ទេសនា ក៏បានជាព្រះអរិយបុគ្គលក្នុងព្រះជន្ម ៣១ ព្រះវស្សា ។

ក្នុងរជ្ជកាលព្រះបាទពិម្ពិសារ ទីក្រុងរាជគ្រឹះ ជារាជធានីមាំទាំជាទីបំផុត ច្រើនទៅដោយមហាសេដ្ឋី មានជោតិកសេដ្ឋីជាដើម ។ **ព្រះបាទបសេនទិកោសល** ព្រះចៅក្រុងសាវត្ថី ពេលមួយបានយាងមកធ្វើទស្សនកិច្ចក្រុងរាជគ្រឹះ បានសូមចែកសេដ្ឋីយកទៅនគររបស់ព្រះអង្គ ទើបបានក្រុមគ្រួសាររបស់នាងវិសាខាដែលមានធនញ្ជ័យសេដ្ឋីជាប្រមុខ មកនៅដែនកោសល ។





ក្នុងអដ្ឋកថាធម្មបទ ពាលវគ្គ រឿងសុមនមាលាការ បានប្រាប់ថាមនុស្សសម័យនោះក្នុងនគរមគធៈ មានចំនួន ១៨០ លាននាក់ ទាំងក្នុងក្រុង ទាំងក្រៅក្រុង ។

ព្រះបាទពិម្ពិសារទំនុកបម្រុងព្រះពុទ្ធសាសនា បាន ៣៦ ឆ្នាំព្រះអង្គសោយព្រះទិវង្គត ក្នុងព្រះជន្មវស្សា ៦៧ មុនព្រះសម្មា-សម្ពុទ្ធបរិនិព្វាន ៨ ឆ្នាំ ។

## រជ្ជកាលព្រះបាទអជាតសត្តុជាដើម

ព្រះបាទអជាតសត្តុ ជាព្រះរាជឱរសរបស់ព្រះបាទពិម្ពិសារឡើងគ្រប់គ្រងទីក្រុងរាជគ្រឹះ ដែនមគធៈ បន្តអំពីព្រះបាទពិម្ពិសារដោយការដណ្តើមអំណាចពីព្រះបិតា ព្រោះវង្វេងជឿតាមពាក្យញុះញង់របស់ព្រះទេវទត្ត ។ ព្រះបាទអជាតសត្តុមានព្រះរាជឱរសប្រសូតក្នុងពេលព្រះបាទពិម្ពិសារសោយព្រះទិវង្គត ដែលធ្វើឱ្យព្រះបាទអជាតសត្តុភ្ញាក់ខ្លួន ហើយបានយល់ដឹង ពីទឹកចិត្តបិតាដែលស្រឡាញ់បុត្រ ។

ព្រះនគរមគធៈសម័យព្រះអង្គ ក៏មានការចម្រើនរុងរឿងដូចសម័យព្រះបិតាដែរ ប៉ុន្តែដោយការក្តៅក្រហាយស្តាយក្រោយក្នុងរឿងធ្វើឃាតព្រះបិតា ព្រះអង្គមិនអាចផ្ទំលក់ឡើយ ទើបបាន

ឱ្យកសាងនូវព្រះរាជវាំងថ្មី ចេញអំពីកំពែងភ្នំ ទៅតាំងនៅខាងជើង ហួសពីវត្តវេឡុវ័នទៅបន្តិច សឹងដែលសព្វថ្ងៃនៅសំណល់បាក់បែក មានកំពែងនិងគ្រឹះជាដើម ។

ក្នុងរជ្ជកាលព្រះបាទអជាតសត្តុ អាណាចក្រមគធៈ មានអាណាបរិវេណធំទូលាយដ៏ក្រៃលែង ។ ព្រះអង្គដណ្តើមយកនគរវេសាលីបាន ដោយឱ្យវស្សការព្រាហ្មណ៍បង្កប់ខ្លួនចូលទៅញុះញង់អ្នកក្រុងវេសាលី បន្ទាប់អំពីកងទ័ពវេសាលី ធ្លាប់មកច្បាំងនឹងព្រះអង្គមុនហើយ ។

សម័យនោះព្រះបាទបសេនទិកោសល បានលើកទ័ពមកច្បាំងដណ្តើមយកដែនកាសីវិញ (ដែនកាសីនេះមានទីក្រុងឈ្មោះពារាណសី ដែលព្រះបាទមហាកោសល ជាព្រះបិតានៃព្រះបាទបសេនទិ បានទុកជាសម្បត្តិរបស់បុត្រី ព្រះនាម **វេទេហី** ហើយកាលដែលប្រគល់បុត្រីមកជាអគ្គមហេសីនៃព្រះបាទពិម្ពិសារ ក៏ប្រគល់ទាំងដែនកាសីមកជាសម្បត្តិរបស់នគរមគធៈផងដែរ )ព្រះ-បាទអជាតសត្តុវេទេហីបុត្រ បានច្បាំងជាមួយស្តេចអ៊ំ ទីបំផុតរក្សាដែនកាសីបាន ។

ក្រោយព្រះពុទ្ធបរិនិព្វានបាន ៣ ខែ ក្រុងរាជគ្រឹះបានទទួលកិត្តិយសដ៏ធំមួយ គឺសង្ឃបានជ្រើសយកជាកន្លែងធ្វើសង្គាយនា





គ្រាទី១ នៅភ្នំវេភារៈ ដោយមានព្រះបាទអជាតសត្តុជាអង្គសាសនូបត្ថម្ភ គាំទ្រឧបត្ថម្ភគ្រប់យ៉ាង ។

ព្រះបាទអជាតសត្តុ ឋិតនៅក្នុងអំណាច បានមកដល់ ព.ស.២៤ (ក្រោយពីព្រះបាទពិម្ពិសារសោយព្រះទិវង្គតទៅបាន ៣២ ឆ្នាំ) ត្រូវឧទយភទ្ទជាព្រះរាជបុត្រធ្វើឃាតដណ្តើមរាជ្យ ។

**ឧទយភទ្ទ** (កន្លែងខ្លះថា **ឧទាយិភទ្ទ** ) សោយរាជ្យបាន ១៦ ឆ្នាំ ក្នុងព.ស. ៤០ ត្រូវអនុរុទ្ធជាបុត្រធ្វើឃាតដណ្តើមរាជ្យ ។

ព្រះបាទ **អនុរុទ្ធ** សោយរាជ្យបាន ៤ ឆ្នាំ ត្រូវមុណ្ឌៈ ជាបុត្រធ្វើឃាតដណ្តើមរាជ្យ ។

ព្រះបាទ **មុណ្ឌៈ** សោយរាជ្យបាន ៤ ឆ្នាំ ក្នុង ព.ស. ៤៨ ត្រូវនាគទាសកៈ ជាបុត្រធ្វើឃាតដណ្តើមរាជ្យ ។

ព្រះបាទ **នាគទាសកៈ** សោយរាជ្យបាន ២៤ ឆ្នាំ ក្នុង ព.ស.៧២ ត្រូវដូរផ្លាស់វង្សសោយរាជ្យ មកខាងវង្សសុសុនាគៈ (វង្សខាងនគរវេសាលីពីមុន ) ។

ព្រះបាទ**សុសុនាគៈ** សោយរាជ្យបាន ១៨ ឆ្នាំ ព.ស.៩០ ។

ព្រះបាទ **កាលាសោក** សោយរាជ្យបាន ២៨ ឆ្នាំ ( ក្នុងរវាងរាជ្យនេះឯង ដែលមាន **ទុតិយសង្គាយនា** ក្នុង ព.ស. ១០០ នៅវាលុការាម ក្រុងវេសាលី ) ។

ស្តេច ១០ អង្គ សោយរាជ្យបាន ២២ ឆ្នាំ ដល់ព.ស. ១៤០ ទើបមានវង្សក្សត់ដណ្តើមរាជ្យ ។

ស្តេច ៩ អង្គ (វង្សក្សត់) សោយរាជ្យបាន ២២ ឆ្នាំ ដល់ ព.ស. ១៦២ ទើបដូរមកគ្រប់គ្រងដោយព្រះរាជវង្ស **ចន្ទគុត្តៈ** (ព្រះបាទចន្ទគុត្តៈ យាងមកពីជើងភ្នំហិមពាន្ត បានឮមកថា អ្នកនគរកបិលពស្តុ រត់គេចអំពីព្រះបាទវិឌូឌភៈ ទៅនៅទីនោះ បានតាំងវង្ស ១ ឈ្មោះមោរិយវង្ស បន្តមកដល់ព្រះចន្ទគុត្តៈនេះឯង)។

ព្រះបាទ **ចន្ទគុត្តៈ** សោយរាជ្យបាន ២៤ ឆ្នាំ ដល់ ព.ស.១៨៦ ។

ព្រះបាទ **ពិន្ទុសារ** សោយរាជ្យបាន ២៨ ឆ្នាំ ដល់ ព.ស.២១៤ (ព្រះអង្គត្រូវជាព្រះបិតានៃអសោកមហារាជ)។

ព្រះបាទ **អសោក** នៅមិនទាន់អភិសេកសោយរាជ្យ ៤ ឆ្នាំ លុះដល់ ព.ស. ២១៨ ទើបបានអភិសេកឡើងគ្រងរាជ្យបន្តអំពីព្រះបាទពិន្ទុសារ ។

## រជ្ជកាលអសោកមហារាជ

ព្រះបាទអសោកមហារាជ ជាព្រះឱរសនៃព្រះបាទពិន្ទុសារ



ឡើងគ្រងរាជ្យបល្ល័ង្កក្នុង ព.ស. ២១៨ មានទីក្រុងឈ្មោះបាដលិបុត្រ ។ ទីក្រុងបាដលិបុត្រនេះ បានលើកអំពីក្រុងរាជគ្រឹះមកតាំងតែអំពីរជ្ជកាលនៃព្រះបាទឧទយភទ្ទ (ព្រះរាជបុត្រព្រះបាទ-អជាតសត្តុ) មកម្ល៉េះ ។ បាដលិបុត្របច្ចុប្បន្នជាក្រុងឈ្មោះ បតនៈ ( Patna ) មានមនុស្សកកកុញ ឋិតនៅខាងជើងព្រះនគរ ជាប់ទៅខាងនគរវេសាលី ។

ព្រះបាទអសោកមហារាជ ក្រោយមកដូរព្រះនាមថា ព្រះបាទ **ធម្មាសោក** បានយាងទៅធ្វើទស្សនកិច្ចនៅទីក្រុងចាស់ គឺក្រុងរាជគ្រឹះ បន្ទាប់ពីព្រះអង្គបានក្លាយមកជាពុទ្ធមាមកជនហើយ ។ ព្រះអង្គបានចាត់ចែងក្នុងរឿង ព្រះបរមសារីរិកធាតុ ចំណាយទ្រព្យធនដ៏ច្រើនលើសលប់ ទំនុកបម្រុងព្រះសាសនា កសាងនូវព្រះ-ចេតិយ ព្រះវិហារ យ៉ាងច្រើន ។ល។

រាជគ្រឹះក្នុងសម័យព្រះអង្គ នៅមានមនុស្សតិចតួចប៉ុណ្ណោះ ព្រោះដោយច្រើនបានរើផ្ទះ រើកន្លែង ទៅនៅក្រុងបាដលិបុត្រអស់ហើយ ។ ព្រះបាទធម្មាសោកបានចាត់ចែងឱ្យមានពួកព្រាហ្មណ៍ជាងមួយពាន់គ្រួសារនៅគ្រប់គ្រងមើលថែរក្សាទីក្រុងចាស់នេះ ។ ព្រះអង្គបង្គាប់ឱ្យសាងស្តូបអនុស្សាវរីយ៍ក្នុងក្រុងរាជគ្រឹះ ជាក្រុងបុរាណ ច្រើនកន្លែង ។

## រាជគ្រឹះបច្ចុប្បន្ន

សង្ខារធម៌មិនទៀងទាត់ឡើយ រាជគ្រឹះដែលពោរពេញទៅដោយអ្វីៗគ្រប់យ៉ាង ឥឡូវនេះនៅសល់តែរូបរាងបាក់បែក និងពួកមនុស្សមួយចំនួន ដោយច្រើនគឺជាពួកព្រាហ្មណ៍ ។

### ខ្ញុំនឹកព្រះណាស់

ខ្ញុំឈរកណ្ដាលទីក្រុងចាស់ ខ្ញុំនឹកព្រះណាស់ពេលព្រលប់
បញ្ជូគីរីនៅឃើញគ្រប់ ចិត្តខ្ញុំប្រារព្ធព្រះសាស្ដា ។
ផល្គុនខ្នើតចាស់ចន្ទភ្លឺហើយ ខ្ញុំពុំឃើញឡើយព្រះបិតា
បាត់ស្មាត់សូន្យអស់អរហន្តា សល់តែសិលានិងព្រៃភ្នំ ។
ហាក់ដូចថ្មីៗ ឥឡូវសោះ ស្រាប់តែបាត់អស់ចាកចោលខ្ញុំ
ខ្ញុំបានត្រឹមតែថ្វាយបង្គំ ដួងចិត្តស្រែកយំនឹកសាស្ដា ។
នឹកអើយសែននឹកអង្គព្រះពុទ្ធ ខ្ញុំសូមលំអុតឱនសិរសា
សម្ដែងរៀបរាប់ចារអក្ខរា មគធៈសាស្ដាធ្លាប់អាស្រ័យ ។
ថ្វីដ្បិតរូបកាយស្ដេចយាងបាត់ ធម្មកាយមិនខ្វាត់ឋិតសព្វថ្ងៃ
អារាធនាអង្គព្រះពុទ្ធថ្ងៃ គង់ក្នុងហឫទ័យនៃយើងខ្ញុំ ។

ដោយ **ប.ស.ឆ.**

***-ហេតុការណ៍សំខាន់ៗ** ក្នុងនគរមគធៈនាសម័យពុទ្ធកាល និងក្រោយពុទ្ធកាល គឺ



១-ព្រះសិទ្ធត្ថសាងព្រះផ្នួសកាត់ព្រះកេសា ។

២-ព្រះអង្គបួសហើយ បានជួបសន្ទនាជាមួយព្រះបាទពិម្ពិសារ នៅខាងលិចក្រុង នាភ្នំបណ្ឌវៈ (ជាភ្នំមួយក្នុងបណ្ដាភ្នំទាំង ៥ ដែលព័ទ្ធជុំវិញក្រុងរាជគ្រឹះ) ។

៣-ហេតុការណ៍ ៦ ឆ្នាំក្នុងផ្នួសរបស់ព្រះអង្គ គឺទ្រង់គង់នៅក្នុងនគរមគធៈតែប៉ុណ្ណោះ ដូចជាក្នុងរឿងរ៉ាវ អាឡារតាបស ឧទកតាបស ទុក្ករកិរិយា បញ្ចវគ្គីយ៍មកគាល់បម្រើជាដើម ។

៤-ហេតុការណ៍ក្នុងថ្ងៃត្រាស់ដឹង ដូចជាទទួលចង្ហាន់នាងសុជាតា ទទួលស្បូវពីសោត្ថិយព្រាហ្មណ៍ រឿងមារាធិរាជព្រមទាំងសេនាជាដើម រហូតដល់ការត្រាស់ដឹងក្រោមព្រះពោធិព្រឹក្ស ។

៥-ហេតុការណ៍ ៤៩ ថ្ងៃក្រោយអំពីការត្រាស់ដឹងហើយក្នុងសត្តមហាឋាន ។

៦-ហេតុការណ៍ ព្រហ្មម៉ឺនចក្កវាឡ មានសហម្បតិព្រហ្មជាប្រមុខមកអារាធនាព្រះអង្គ នៅដើមអជបាលនិគ្រោធ ក្នុងថ្ងៃដែលព្រះអង្គឆាន់ចង្ហាន់របស់ **តបុស្សៈ** និង **ភល្លិកៈ** ហើយ ។ ក្នុងទីនេះមានសេចក្ដីសំខាន់ ៣ យ៉ាងគឺ

(១)-ទទួលចង្ហាន់នាងសុជាតា

(២)-សោយវិមុត្តិសុខក្នុងសប្ដាហ៍ទី ៥ ក្រោយពីត្រាស់ដឹង

(៣)_គង់ពិចារណាធម៌ដ៏មានជម្រៅ ក្នុងថ្ងៃទី៥០ បន្ទាប់ពីត្រាស់ដឹង ព្រហ្មអារាធនាសូមឱ្យព្រះអង្គត្រាស់សម្ដែងនូវព្រះធម៌-ទេសនា និងទ្រង់ពិចារណាមើលបុគ្គល ៤ ជំពូក ដូចផ្កាឈូកក្នុងជលដ្ឋាន ព្រមទាំងពិចារណានូវបុគ្គល ដែលព្រះអង្គត្រូវយាងទៅប្រោសជាដំបូង ។ ស្ថានទីនេះស្ថិតនៅខាងកើតស្ទឹងនេរញ្ជរា និងខាងកើតផ្ទះនាងសុជាតា មិនជាឆ្ងាយប៉ុន្មានឡើយ មើលឃើញច្បាស់ប្រមាណកន្លះគីឡូម៉ែត្រ ។ ព្រះអង្គយាងចេញពីទីឋាននេះឯង ក្នុងដំណើរទៅកាន់ព្រៃឥសិបតនមិគទាយវ័ន សម្ដែងព្រះធម្ម-ចក្កប្បវត្តនសូត្របឋមទេសនា ។

៧_ប្រោសជដិល ៣ នាក់បងប្អូន ព្រមទាំងបរិវារ នៅឧរុវេលាសេនានិគម ឱ្យបានជាឯហិភិក្ខុ សម្ដែងអាទិត្តបរិយាយ-សូត្រ នៅភ្នំគយាសីសៈ មាត់ស្ទឹងគយា ធ្វើឱ្យទាំង ៣ អង្គបងប្អូនព្រមទាំងបរិវារ រួមគ្នាទាំងអស់ ១.០០០ អង្គបានសម្រេចនូវព្រះ-អរហត្តផល ។ ទីនេះនៅមិនឆ្ងាយពីកន្លែងដែលព្រះអង្គត្រាស់ដឹងប៉ុន្មានឡើយ តាមផ្លូវទៅក្រុងរាជគ្រឹះ ធ្វើដំណើរដោយរថយន្តប្រមាណ ៣០ នាទី ។

៨_ប្រោសព្រះបាទពិម្ពិសារព្រមដោយបរិវារដ៏ច្រើននៅព្រៃត្នោត ជិតក្រុងរាជគ្រឹះ ។



៩_ព្រះបាទពិម្ពិសារ ថ្វាយវេឡុវនារាមដល់ព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាព្រះប្រធាន ។

១០_ព្រះអគ្គសាវ័កទាំង ២ ឧបសម្បទា ព្រមដោយបរិវាររួមទាំងអស់ត្រូវជា ២៥០ អង្គ ដោយឯហិភិក្ខុឧបសម្បទា ។

១១_កំណើតមាឃបូជា ចាប់ផ្ដើមដោយចតុរង្គសន្និបាតក្នុងថ្ងៃ ១៥ កើតខែមាឃ ថ្ងៃព្រះសារីបុត្តបានសម្រេចនូវព្រះ-អរហត្តផល ក្រោយការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ ៩ ខែគត់។

១២_ព្រះមហាកស្សបៈឧបសម្បទា ដោយទទួលយកនូវព្រះឱវាទ ៣ យ៉ាងអំពីព្រះសម្មាសម្ពុទ្ធ ។

១៣_ព្រះសម្មាសម្ពុទ្ធ ត្រាស់បង្គាប់ឱ្យធ្វើរូបរាងចីវរ តាមបែបស្រែនិងភ្លឺស្រែនៃអ្នកនគរមគធៈ ។

១៤_ហេតុការណ៍ ក្នុងរឿងពេទ្យជីវកកោមារភច្ច ជាពេទ្យពូកែអស្ចារ្យក្នុងសម័យនោះឯង ទាំងជាព្រះសោតាបន្ន មានឧបការៈច្រើនក្នុងព្រះពុទ្ធសាសនា ។

១៥_មានសេដ្ឋី និងមហាសេដ្ឋី ច្រើនជាងនគរណាៗទាំងអស់ ដូចជា ជោតិកសេដ្ឋី ជដិលសេដ្ឋី និងមេណ្ឌកសេដ្ឋីជាដើម ។

១៦_សម្បូណ៌ព្រៃភ្នំល្ហាងគុហា ទាំងអាកាសធាតុក៏សមរម្យ

ទើបជាទីប្រជុំនៃអ្នកប្រព្រឹត្តតបធម៌ មានតាបសឥសី សូម្បីគ្រូមិច្ឆាទិដ្ឋិទាំង ៦ ក៏នៅក្នុងនគរនេះទាំងអស់ ។

១៧.មានការបង្កហេតុនាំឱ្យព្រះសម្មាសម្ពុទ្ធប្រកាសថា ៤ ខែទៀតនឹងសម្តែងយមកប្បាដិហារ្យ នៅជិតទ្វារក្រុងសាវត្ថី ។

១៨.មានធារទឹកក្តៅហូរចេញពីក្រោមភ្នំវេភារៈ រហូតដល់សព្វថ្ងៃ សម័យនោះមានវត្តឈ្មោះតបោទារាម ។

១៩.ព្រះទេវទត្តលបធ្វើឃាតព្រះសាស្តាដោយការទម្លាក់ថ្មលើព្រះអង្គ និងចាត់ចែងឱ្យខ្មាន់ធ្នូមកបាញ់ព្រះអង្គនិងម្យ៉ាងទៀតរៀបចំដំរីនាឡាគីរីឱ្យមកព្រេចព្រះអង្គទៀតផង ។

២០.ព្រះទេវទត្តបំបែកសង្ឃ ហើយនាំភិក្ខុ ៥០០ អង្គទៅកាន់ភ្នំគយាសីសៈ កន្លែងដែលព្រះអង្គសម្តែងអាទិត្តបរិយាយសូត្រប្រោសបុរាណជដិល ១.០០០ អង្គ ។ ទីនោះមានភ្នំព្រៃកដូចក្បាលដំរី សព្វថ្ងៃអ្នកស្រុកហៅភ្នំព្រហ្មយោនី (កំណើតព្រហ្ម)។

២១.ព្រះបាទអជាតសត្តុ ដណ្តើមរាជ្យពីបិតា រហូតដល់ធ្វើឃាតព្រះបិតា ព្រោះមកអំពីការសេពគប់ជាមួយនឹងភិក្ខុទេវទត្ត ។ ក្រោយមកបានពេទ្យជីវកកោមារភច្ច នាំទៅគាល់ព្រះសម្មាសម្ពុទ្ធនៅជីវកម្ពវ័ន ក្នុងក្រុងរាជគ្រឹះនោះឯង ហើយបានស្តាប់ព្រះធម៌កើតការជ្រះថ្លាដ៏ក្រៃលែងក្នុងព្រះរតនត្រៃ ។



២២.ព្រះសារីបុត្ត បរិនិព្វាននៅផ្ទះដែលលោកប្រសូត គឺនៅឧបតិស្សគ្រាម ក្នុងស្រុកនាលន្ទា ។

២៣.ព្រះមហាមោគ្គល្លាន បរិនិព្វាននៅកាឡសិលាគុហានាភ្នំឥសិគិលិ ទិសនិរតីក្រុងរាជគ្រឹះ ។

២៤.ព្រះបាទអជាតសត្តុ បញ្ចុះព្រះបរមសារីរិកធាតុ ១ ចំណែកក្នុងក្រុងរាជគ្រឹះ ដែលដង្ហែមកអំពីនគរកុសិនារា ។

២៥.សង្គាយនាលើកទី ១ នៅសត្តបណ្ណគុហានាភ្នំវេភារៈទិសពាយព្យនៃក្រុងរាជគ្រឹះ ។

២៦.ព្រះមហាកស្សបត្ថេរ ជាព្រះប្រធាន រួមសហការជាមួយនឹងព្រះបាទអជាតសត្តុ បានធ្វើនូវធាតុនិធាន គឺកិរិយាកប់ទុកព្រះបរមសារីរិកធាតុ ៧ ចំណែក (វៀរព្រះធាតុនៅរាមគ្រាម ១ ចំណែក) ជាការកប់ទុកក្នុងទីដ៏ប្រណីតអស្ចារ្យ ការពារអន្តរាយតាមដែលព្រះមហាកស្សបត្ថេរបានជ្រាប ។

២៧.ព្រះមហាកស្សបត្ថេរ បរិនិព្វាននៅភ្នំកុក្កុដសមបាតក្នុងនគរមគធៈហ្នឹងឯង ។

២៨.សង្គាយនាលើកទី ៣ នៅអសោការាមក្រុងបាដលិ-បុត្រ សម័យកាលនៃព្រះបាទធម្មាសោក ។

២៩.សង្គាយនាលើកទី៣ រួចភ្លាម មានការចាត់គណៈសង្ឃ

ធម្មទូតចេញទៅផ្សព្វផ្សាយព្រះពុទ្ធសាសនា ៩ ផ្លូវ មានដំណើរទៅកាន់គន្ធាររដ្ឋ,សុវណ្ណភូមិ និងតម្ពបណ្ណិទ្វីប (លង្កា) ជាដើម ។

៣០_ព្រះបាទធម្មាសោកស្វែងរកនូវធាតុនិធានឃើញហើយបានកសាងព្រះចេតិយ ៨៤.០០០ ស្មើនឹងចំនួនព្រះធម្មក្ខន្ធ ហើយបានធ្វើបុណ្យឆ្លងព្រះចេតិយ បញ្ចុះព្រះបរមសារីរិកធាតុ ៧ ឆ្នាំ , ៧ ខែ , ៧ ថ្ងៃ នៅអសោការាម និងនៅក្រុងបាដលិបុត្រ ។

៣១_ហេតុការណ៍ទាក់ទងនឹងព្រះបាទធម្មាសោក សំខាន់ៗច្រើនរឿងទៀត ដូចជាប្រតិស្ឋានសសរថ្មភ្នំនៅពុទ្ធស្ថានផ្សេងៗជាដើម ។

៣២_ក្នុង៤៥ព្រះវស្សា ទ្រង់ត្រាស់សម្តែងព្រះធម៌តែភាសាមគធៈប៉ុណ្ណោះ ។

*_សរុបស្ថានទីចាំព្រះវស្សានៃព្រះសម្មាសម្ពុទ្ធ :

១_ព្រៃឥសិបតនមិគទាយវន័, នគរពារាណសី
២_វត្តវេឡុវន័មហាវិហារ , **នគរមគធៈ**
៣_វត្តវេឡុវន័មហាវិហារ , **នគរមគធៈ**
៤_វត្តវេឡុវន័មហាវិហារ , **នគរមគធៈ**





៥_កូដាគារសាលានាមហាវន័ , នគរវេសាលី
៦_មកុលបព៌ត , **នគរមគធៈ**
៧_ក្រោមដើមបារិច្ឆត្តកៈ , ឋានតាវត្តិង្ស
៨_ភេសកឡាវន័ , ភគ្គជនបទ
៩_ឃោសិតារាម , នគរកោសម្ពី
១០_ក្រោមដើមសាលៈ , ព្រៃបារិលេយ្យកៈ
១១_ភូមិព្រាហ្មណ៍ឯកនាលា , **នគរមគធៈ**
១២_ក្រោមដើមស្តៅ , នគរវេរញ្ជា
១៣_ចាលិកបព៌ត , នគរចាលិកា
១៤_វត្តជេតពនមហាវិហារ ,នគរសាវត្ថី
១៥_និគ្រោធារាម , នគរកបិលពស្តុ
១៦_អគ្គាឡវចេតិយ , នគរអាឡវី
១៧_វត្តវេឡុវន័មហាវិហារ , **នគរមគធៈ**
១៨_ចាលិកបព៌ត , នគរចាលិកា
១៩_ចាលិកបព៌ត , នគរចាលិកា
២០_វត្តវេឡុវន័មហាវិហារ , **នគរមគធៈ**
២១-៤៤_ជេតពន+បុព្វារាម , នគរសាវត្ថី
៤៥_វេឡុវគ្រាម , នគរវេសាលី ។

-ព្រះអង្គគង់ចាំព្រះវស្សានៅនគរមគធៈចំនួន ៧ វស្សា (២-៣-៤-៦-១១-១៧-២០) ។

(ចាកអដ្ឋកថាគម្ពីរពុទ្ធវង្ស)

**⁕-មគធៈនគរបឋម :**

១.បឋមក្នុងការទទួលព្រះសិទ្ធត្ថសាងព្រះផ្នួស

២.បឋមក្នុងការទទួលព្រះពុទ្ធត្រាស់ដឹង

៣.បឋមក្នុងការដែលព្រះពុទ្ធសាសនាចូលដល់ទីក្រុង

៤.បឋមក្នុងការដែលព្រះរាជាបានសម្រេចមគ្គផល

៥.បឋមក្នុងការទទួលវត្តវេឡុវន័

៦.បឋមក្នុងបុណ្យទក្ខិណានុប្បទាន

៧.បឋមក្នុងការទទួលអគ្គសាវក័ទាំងពីរអង្គ

៨.បឋមក្នុងការទទួលអគ្គសាវិកាស្តាំ

៩.បឋមមាឃបុណ្ណមីថ្ងៃមាឃបូជា

១០.បឋមក្នុងរឿងធ្វើសង្ឃភេទ (ភិក្ខុទេវទត្តបំបែកសង្ឃ)

១១.បឋមសង្គាយនាព្រះធម៌វិន័យ ។

**⁕-សំណាក់អាឡារតាបស** ចូលពីច្រកខាងត្បូងនៃក្រុងរាជគ្រឹះ នៅខាងកើតផ្លូវ គឺកន្លែងដែលពុទ្ធបរិស័ទច្រឡំថា កន្លែង





ព្រះបាទពិម្ពិសារ ស្តេចយាងមកជួបព្រះសិទ្ធត្ថ ដែលព្រះអង្គទើបតែសាងព្រះផ្នួសថ្មីៗ ។ តាមពុទ្ធប្បវត្តិ ព្រះបាទពិម្ពិសារ ស្តេចយាងមកជួបព្រះសម្មាសម្ពុទ្ធ កាលដែលព្រះអង្គទើបតែសាងព្រះ-ផ្នួសនោះ នៅភ្នំបណ្ឌវៈ ។ ភ្នំបណ្ឌវៈនៅខាងលិចក្រុងរាជគ្រឹះ រវាងភ្នំឥសិគិលិ និងភ្នំវេភារៈ ។

**⁕-ស្ពានកង់រទេះពីបុរាណ** ឃើញមាននៅទិសខាងជើងសំណាក់អាឡារតាបសបន្តិច ។ គួរនឹកឃើញដល់មនុស្សទាំងឡាយពីបុរាណនោះ ខំប្រឹងរកទ្រព្យសម្បត្តិដោយជំនួញជួញដូរជាដើម ផ្លូវទឹកមានសំពៅ មានទូក ផ្លូវគោកមានរទេះ ។ ទោះជាខំប្រឹងដើម្បីរស់នៅយ៉ាងណាក៏ដោយ តាមពិត ជីវិតមនុស្សពីបុរាណទាំងអស់នោះ បានស្លាប់អស់ទៅហើយ ។ គ្រប់គ្នាកើតមកហើយគ្មានយកអ្វីពីលោកនេះបានឡើយ គួរតែស្វែងរកផ្លូវចេញពីលោកនេះវិញ ។

**⁕-ព្រះគន្ធកុដិលើកំពូលភ្នំគិជ្ឈកូដ** ភ្នំគិជ្ឈកូដនៅខាងត្បូងភ្នំវេបុល្លៈ និងខាងកើតក្រុង ភ្នំបន្តពីភ្នំគិជ្ឈកូដមករហូតដល់ខាងត្បូងក្រុង សព្វថ្ងៃគេហៅភ្នំឧទ័យ ។

ពុទ្ធបរិស័ទចម្រើនសេចក្តីជ្រះថ្លា សូត្រធម៌ ប្រទក្សិណព្រះគន្ធកុដិ និងស្តាប់ព្រះធម៌តាមកាលដ៏សមគួរ ។ ព្រះអង្គធ្លាប់គង់ទីនេះ ទ្រង់យាងចុះទៅបំពេញពុទ្ធកិច្ចខាងក្រោម ព្រះអង្គស្តេចយាងឡើងមកវិញ ហើយទ្រង់ធ្វើធម្មបដិសណ្ឋារៈដល់មនុស្សដែលឡើងមក និងពួកទេវតាដែលចុះមក ។ ឥឡូវព្រះរូបកាយរបស់ព្រះអង្គបានរលត់បាត់ទៅជាង ២.៥០០ ឆ្នាំហើយ នៅឡើយតែទីកន្លែងប៉ុណ្ណោះ ។ ទីនេះជាបរិភោគចេតិយ ពុទ្ធបរិស័ទគប្បីនឹករលឹកដល់ព្រះបរមពុទ្ធោវាទ ហើយគាល់នូវព្រះធម្មកាយរបស់ព្រះអង្គដោយបញ្ញារបស់ខ្លួនរៀងៗ ខ្លួន ។ ព្រះមហាបជាបតិ-គោតមីធ្លាប់បានពោលថា :

ព្រះរូបកាយរបស់ព្រះអង្គ ខ្ញុំម្ចាស់បានចិញ្ចឹម មើលថែឱ្យចម្រើនធំធាត់ ប៉ុន្តែធម្មកាយរបស់ខ្ញុំម្ចាស់ គឺព្រះអង្គនេះហើយដែលបានឱ្យចម្រើនធំធាត់ ខ្ញុំម្ចាស់ជាព្រះមាតានៃព្រះអង្គ ចំណែកព្រះអង្គជាព្រះបិតារបស់ខ្ញុំម្ចាស់ ។

*-**កុដិព្រះអានន្ទ** លើភ្នំគិជ្ឈកូដ ខាងស្តាំដៃផ្លូវចូលទៅព្រះគន្ធកុដិ ។





# គាថាព្រះអានន្ទត្ថេរ

(បិដក ៥៧ , ទំព័រ ៩៣_៩៨)

**២ គាថា** ជាឱវាទដល់ភិក្ខុ ដែលច្រឡូកច្រឡំជាមួយពួកភិក្ខុខាងទេវទត្ត ។

បណ្ឌិតមិនគួរធ្វើសខិភាព គឺភាពជាសម្លាញ់នឹងបុគ្គលអ្នកញុះញង់ អ្នកក្រេវក្រោធ អ្នកកំណាញ់ ទាំងជាអ្នកត្រេកអរនឹងសេចក្តីវិនាសទេ (ព្រោះថា) ការសមគប់នឹងបុរសអាក្រក់ ជាអំពើដ៏លាមក ។

បណ្ឌិតគួរធ្វើសខិភាពនឹងបុគ្គលអ្នកមានសទ្ធា មានសីលជាទីស្រឡាញ់ អ្នកមានប្រាជ្ញា មានការចេះដឹងច្រើន ( ព្រោះថា ) ការសមគប់នឹងពួកសប្បុរស ជាការចម្រើន ។

**១ គាថា** ជាឱវាទកាត់ការពេញចិត្តក្នុងរូបកាយ ។

អ្នកចូរមើលនូវពុម្ព គឺអត្តភាពដែលធ្វើឱ្យវិចិត្រ ជាទីប្រជុំនៃដំបៅផ្តុំឡើង ( ដោយឆ្អឹង ៣០០ កំណាត់ ) ជាគ្រឿងរោលរាលជាទីប្រាថ្នានៃជនច្រើន ជាកាយឥតទៀងទាត់ឋិតថេរ ។

**២ គាថា** ជាឧទានពេលដែលលោកបានសម្រេចនូវព្រះ-អរហត្តហើយ ។

ព្រះអានន្ទត្ថេរ ជាគោតមគោត្រ ជាអ្នកចេះដឹងច្រើន មានវាចាដ៏វិចិត្រ ជាអ្នកបម្រើនូវព្រះពុទ្ធ បានដាក់ចុះនូវភារៈ ជាអ្នកប្រាសចាកកិលេសជាគ្រឿងប្រកប សម្រេចនូវការសិង ។

ព្រះអានន្ទត្ថេរ ជាខីណាស្រពប្រាសចាកកិលេសជាគ្រឿងប្រកប កន្លងនូវកិលេសជាគ្រឿងជាប់ជំពាក់ មានចិត្តត្រជាក់ល្អ ដល់នូវត្រើយនៃជាតិនិងមរណៈ ទ្រទ្រង់ទុកនូវអត្តភាពជាបំផុត ។

**១ គាថា** គឺសុទ្ធាវាសព្រហ្មជាខីណាស្រព បានប្រកាសក្នុងថ្ងៃផ្តើមបឋមសង្គាយនា ថាព្រះអានន្ទត្ថេរជាព្រះអរហន្ត ។

សាសនធម៌ទាំងឡាយ របស់ព្រះពុទ្ធ ជាអាទិច្ចពន្ធុ ប្រតិស្ឋានក្នុងព្រះអានន្ទត្ថេរណា ព្រះអានន្ទត្ថេរនោះ ជាគោតម-គោត្រ ឋិតនៅក្នុងផ្លូវជាទីទៅកាន់ព្រះនិព្វាន ។

**១ គាថា** ព្រះអានន្ទត្ថេរឆ្លើយសំណួររបស់គោបកមោគ្គ-ល្លានព្រាហ្មណ៍ដែលសួរថា : លោកម្ចាស់ប្រាកដក្នុងព្រះពុទ្ធ-សាសនា ថាជាពហុស្សូត តើធម៌ទាំងឡាយមានប្រមាណប៉ុន្មាន





ដែលព្រះសាស្តាបានសម្តែងហើយដល់លោក និងដែលលោកទ្រទ្រង់ចាំទុកហើយ ?

សាសនធម៌ទាំងឡាយណា ដែលប្រព្រឹត្តទៅ (ក្នុងហឫទ័យ) របស់ខ្ញុំ សាសនធម៌ទាំងឡាយនោះ មាន ៨ ម៉ឺន ៤ ពាន់ធម្មក្ខន្ធ ខ្ញុំបានរៀនអំពីព្រះពុទ្ធ ៨ ម៉ឺន ២ ពាន់ធម្មក្ខន្ធ អំពីពួកភិក្ខុ ២ ពាន់ធម្មក្ខន្ធ ។

**១ គាថា** ប្រកាសទោសព្រោះមិនមានពាហុសច្ចៈ ជាបុគ្គលដែលមិនប្រកបក្នុងវិបស្សនាធុរៈ និងគន្ថធុរៈ ។

បុរសនេះមិនបានរៀនសូត្រ រមែងចាស់ (ឥតអំពើ) ដូចគោបម្រើ ចម្រើនតែសាច់ ត្រង់ប្រាជ្ញារបស់វា មិនចម្រើនឡើយ។

**១ គាថា** ជាឱវាទដល់ភិក្ខុមួយអង្គ ជាអ្នកមើលងាយភិក្ខុដទៃ ព្រោះអាស្រ័យខ្លួនជាពហុស្សូត ។

បុគ្គលណាជាអ្នករៀនសូត្រច្រើន ហើយមើលងាយបុគ្គលអ្នកមិនបានរៀនសូត្រ ដោយការរៀនសូត្រ (របស់ខ្លួន) បុគ្គលនោះដូចមនុស្សខ្វាក់កាន់ប្រទីប រមែងភ្លឺច្បាស់ដល់ខ្ញុំយ៉ាងនេះឯង ។

**១ គាថា** សម្តែងអានិសង្សនៃការស្តាប់ច្រើន ។

បុគ្គលគួរចូលទៅអង្គុយជិតនឹងអ្នករៀនសូត្រច្រើនផង មិនគប្បីញុាំងការរៀនសូត្រឱ្យវិនាសផង (ព្រោះថា) ការរៀនសូត្រនោះ ជាឫសគល់នៃព្រហ្មចរិយធម៌ ហេតុនោះ បុគ្គលគួរជាអ្នកទ្រទ្រង់ធម៌ ។

**១ គាថា** សម្តែងបញ្ជាក់សេចក្តីដែលបុគ្គលគប្បីសម្រេចក្នុងការស្តាប់ច្រើន រៀនច្រើន ។

បុគ្គលអ្នកចេះដឹងនូវខាងដើម និងខាងចុង (នៃភាសិត) ជាអ្នកដឹងអត្ថ ឈ្លាសវៃក្នុងនិរុត្តិ (ភាសា) និងបទ (ដ៏សេស) រមែងកាន់យកនូវធម៌ឱ្យជាធម៌ដែលកាន់យកល្អហើយផង ពិចារណានូវសេចក្តីផង ។

**២ គាថា** សម្តែងអំពីបដិបត្តិ និងបដិវេធ សម្រេចមកពីបរិយត្តិ ។

បុគ្គលអ្នកមានសេចក្តីប្រាថ្នា (ក្នុងធម៌) ដោយសេចក្តីអត់-ធន់ រមែងខ្មីឃ្មាត ពិចារណានូវនាមរូបនោះ បុគ្គលនោះមានចិត្តតាំងមាំល្អខាងក្នុងសន្តាន រមែងផ្តងចិត្តទុកក្នុងសម័យដ៏គួរ ។

បុគ្គល កាលប្រាថ្នានូវការដឹងធម៌ គប្បីគប់រកអ្នករៀនសូត្រ





ច្រើន អ្នកចងចាំនូវធម៌ អ្នកមានប្រាជ្ញា ជាសាវក៍របស់ព្រះពុទ្ធបែបដូច្នោះ ។

**១ គាថា** សម្តែងអំពីបុគ្គលជាពហុស្សូតដូចលោក ជាបុគ្គលគួរដល់ការបូជា ។

បុគ្គលអ្នករៀនសូត្រច្រើន រមែងជាអ្នកចងចាំនូវធម៌ ជាអ្នករក្សាទុកនូវឃ្លាំងធម៌របស់ព្រះពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ ឯបុគ្គលអ្នករៀនសូត្រច្រើននោះឈ្មោះថា ជាចក្ខុរបស់សត្វលោកទាំងពួង ជាបុគ្គលគួរគេបូជា ។

**១ គាថា** សម្តែងអំពីការមិនសាបសូន្យនៃបុគ្គលអ្នកប្រព្រឹត្តតាមកល្យាណមិត្ត ។

ភិក្ខុមានធម៌ជាទីត្រេកអរ ត្រេកអរក្នុងធម៌ កាលគិតរឿយៗនូវធម៌ រលឹករឿយៗនូវធម៌ រមែងមិនសាបសូន្យចាកព្រះសទ្ធម្ម ។

**១ គាថា** ជាឱវាទឱ្យកើតសង្វេគក្នុងរាងកាយដល់ភិក្ខុខ្ជិល។

បុគ្គលអ្នកធ្ងន់ដោយសេចក្តីកំណាញ់ (ថ្នម) កាយ (កាលបើកាយ និងជីវិត) សាបសូន្យទៅ ក៏មិនខ្មីឃ្មាត (ចំពោះកិច្ចគួរធ្វើ) បុគ្គលអ្នកជាប់ជំពាក់ដោយសេចក្តីសុខ ក្នុងសរីរៈ តើសេចក្តី

សប្បាយ ដោយសមណភាព (នឹងមានមក ) អំពីទីណា ។

**៣ គាថា** ព្រះអានន្ទត្ថេរ កាលជ្រាបច្បាស់ថា ព្រះសារីបុត្ត បរិនិព្វានហើយ ។

ទិសទាំងអស់ រមែងមិនប្រាកដ ធម៌មិនភ្លឺច្បាស់ដល់ខ្ញុំ កាលបើព្រះសារីបុត្ត ជាកល្យាណមិត្ត ទៅ ( កាន់និព្វាន ) ហើយ លោកប្រាកដដូចជាទីងងឹត ។

បុគ្គលដែលមានសម្លាញ់ព្រាត់ប្រាសហើយ មានសាស្តា កន្លងទៅហើយ រមែងមិនមានមិត្តបែបនោះ ដូចជាកាយគតាសតិ ឡើយ ។

ពួកព្រះថេរៈណាចាស់ៗ ពួកព្រះថេរៈនោះកន្លងទៅហើយ ចិត្តរបស់ខ្ញុំមិនល្មមនឹងភិក្ខុថ្មីៗ ថ្ងៃនេះខ្ញុំចម្រើនឈានតែម្នាក់ឯង ដូចសត្វបក្សីចូលទៅសំងំក្នុងសំបុក ក្នុងរដូវភ្លៀង ។

**១ គាថា** ព្រះបរមសាស្តាទ្រង់ត្រាស់សម្តែងដល់ព្រះអានន្ទ។

អ្នកកុំឃាត់ពួកជនច្រើន នៅក្នុងប្រទេសផ្សេងៗ ដែល ពុំទាន់ជួប ឯពួកអ្នកស្តាប់ ចូរមកជួបចុះ ព្រោះថាជាសម័យ ( គួរ ជួប ) នឹងតថាគតហើយ ។



**១ គាថា** ព្រះអានន្ទត្ថេរសម្តែង បន្ទាប់ពីបានស្តាប់ព្រះពុទ្ធ-ដីកាហើយ ។

ព្រះសាស្តាមានចក្ខុ ទ្រង់ប្រទានឱកាស មិនហាមឃាត់ពួក ជនច្រើននៅក្នុងប្រទេសផ្សេងៗ ដែលពុំទាន់បានជួប ។

**៨ គាថា** ព្រះអានន្ទត្ថេរ សម្តែងបញ្ជាក់អំពីខ្លួនលោកជា ពុទ្ធុបដ្ឋាកដ៏ក្រៃលែង ។

កាលខ្ញុំនៅជាសេក្ខបុគ្គលអស់ ២៥ ឆ្នាំ កាមសញ្ញាមិនកើត ឡើងទេ អ្នកចូរមើលនូវសភាពល្អរបស់ធម៌ចុះ ។

កាលខ្ញុំនៅជាសេក្ខបុគ្គលអស់ ២៥ ឆ្នាំ ទោសសញ្ញាមិន កើតឡើងទេ អ្នកចូរមើលនូវភាពល្អរបស់ធម៌ចុះ ។

ខ្ញុំបានបម្រើព្រះមានព្រះភាគ ដោយកាយកម្ម ប្រកបដោយ មេត្តាអស់ ២៥ ឆ្នាំ ដូចជាស្រមោលជាប់តាមរូប ។

ខ្ញុំបានបម្រើព្រះមានព្រះភាគ ដោយវចីកម្ម ប្រកបដោយ មេត្តាអស់ ២៥ ឆ្នាំ ដូចជាស្រមោលជាប់តាមរូប ។

ខ្ញុំបានបម្រើព្រះមានព្រះភាគ ដោយមនោកម្ម ប្រកបដោយ មេត្តាអស់ ២៥ ឆ្នាំ ដូចជាស្រមោលជាប់តាមរូប ។

កាលព្រះពុទ្ធជាអម្ចាស់ទ្រង់ចង្ក្រម ខ្ញុំបានចង្ក្រមតាម

ក្រោយព្រះអង្គ នាកាលធម៌ដែលព្រះអង្គសម្តែង ញាណរបស់ខ្ញុំក៏កើតឡើង ។

ខ្ញុំជាសេក្ខបុគ្គល ប្រកបដោយកិច្ច មានសេចក្តីប្រាថ្នាក្នុងចិត្តមិនទាន់សម្រេច ( អរហត្តផល ) ព្រះសាស្តា ព្រះអង្គអនុគ្រោះខ្ញុំ ទ្រង់បរិនិព្វាន ។

កាលព្រះសម្ពុទ្ធប្រកបដោយអាការដ៏ប្រសើរគ្រប់យ៉ាងទ្រង់បរិនិព្វានហើយ សេចក្តីស្ញប់ស្ញែងនៃខ្ញុំក៏កើតមាន សេចក្តីព្រឺរោមនៃខ្ញុំក៏កើតមាន ។

**៣ គាថា** ព្រះសង្គីតិកាចារ្យទាំងឡាយ នាំគ្នាសរសើរព្រះអានន្ទត្ថេរ ។

ព្រះអានន្ទជាពហុស្សូត អ្នកចងចាំនូវធម៌ រក្សាទុកនូវឃ្លាំងធម៌នៃព្រះពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ប្រសើរ លោកជាចក្ខុនៃសត្វលោកទាំងអស់ បរិនិព្វានហើយ (កិលេសនិព្វាន )។

ព្រះអានន្ទជាពហុស្សូត អ្នកចងចាំនូវធម៌ ជាឃ្លាំងរក្សាទុកធម៌នៃព្រះពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ប្រសើរ លោកជាចក្ខុនៃសត្វលោកទាំងអស់ ជាអ្នកបន្ទោបង់នូវភាពងងឹត ក្នុងទីដ៏ងងឹត ។

ព្រះអានន្ទមានញាណគតិ មានស្មារតី មានប្រាជ្ញាជាគ្រឿង





ទ្រទ្រង់ ជាអ្នកស្វែងរកនូវគុណ ទ្រទ្រង់ទុកនូវព្រះសទ្ធម្ម ជាអណ្តូងនៃធម្មរតនៈ ។

**ព្រះគាថាជាចុងក្រោយ** ព្រះអានន្ទត្ថេរសម្តែងក្នុងវេលាជិតបរិនិព្វាន ។

ព្រះសាស្តា ខ្ញុំបានបម្រើហើយ ។ល។ តណ្ហាជាគ្រឿងនាំទៅកាន់ភព ខ្ញុំក៏បានដកចេញហើយ ។

**✳-គុហាសូករខាតា** នៅខាងស្តាំដៃផ្លូវឡើងទៅព្រះគន្ធកុដិនាភ្នំគិជ្ឈកូដ ។ ជាកន្លែងដែលព្រះសារីបុត្តបានសម្រេចព្រះអរហត្តដោយបានស្តាប់ទីឃនខសូត្រ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងដល់ទីឃនខបរិព្វាជក ក្នុងថ្ងៃ ១៥ កើតខែមាឃ បន្ទាប់ពីព្រះបរមសាស្តាត្រាស់ដឹងបាន ៩ ខែគត់ ។

## ទីឃនខសូត្រ

( បិដកលេខ ២៤ , ទំព័រ ៤៨ ... )

(៣៣) ម្នាលអគ្គិវេស្សនៈ ក៏ឯកាយនេះមានរូបជាទីប្រជុំនៃ

មហាភូតទាំង ៤ (ដី ទឹក ភ្លើង ខ្យល់ ) កើតមកអំពីមាតាបិតា ចម្រើនឡើងដោយបាយនិងនំកុម្មាស មានការមិនទៀង មានការគក់ច្របាច់ ការដុសខាត់មន្ទិលក្លិនស្អុយ ការបែកធ្លាយ និងការរាត់រាយទៅជាធម្មតា បុគ្គលគួរពិចារណាឃើញច្បាស់ ដោយសភាពជារបស់មិនទៀង ជាទុក្ខ ជារោគ ថាបីដូចជាបូស ថាបីដូចជាកូនសរ ជាសេចក្តីលំបាក ជាជំងឺ ជារបស់អ្នកដទៃ ជារបស់វិនាសសាបសូន្យ មិនមែនខ្លួនប្រាណ ។ កាលបុគ្គលនោះពិចារណាឃើញច្បាស់នូវកាយនេះថា ជារបស់មិនទៀង ជាទុក្ខ ជារោគ ថាបីដូចជាបូស ថាបីដូចជាកូនសរ ជាសេចក្តីលំបាក ជាជំងឺ ជារបស់អ្នកដទៃ ជារបស់វិនាសសាបសូន្យ មិនមែនខ្លួនប្រាណ សេចក្តីប្រាថ្នាក្នុងកាយ និងសេចក្តីអាល័យកាយ ទាំងកិលេសដែលប្រព្រឹត្តទៅតាមកាយណា កិលេសតណ្ហានោះ គេក៏លះបង់បាន ។

ម្នាលអគ្គិវេស្សនៈ វេទនានេះមាន ៣ ប្រការ គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។ ម្នាលអគ្គិវេស្សនៈ សម័យណា បុគ្គលទទួលសុខវេទនា សម័យនោះ មិនទទួលទុក្ខវេទនា មិនទទួលអទុក្ខមសុខវេទនាទេ ក្នុងសម័យនោះ ទទួលចំពោះតែសុខវេទនា។ ម្នាលអគ្គិវេស្សនៈ សម័យណា បុគ្គលទទួលទុក្ខវេទនា





សម័យនោះ មិនទទួលសុខវេទនា មិនទទួលអទុក្ខមសុខវេទនាទេ សម័យនោះ ទទួលចំពោះតែទុក្ខវេទនា ។ ម្នាលអគ្គិវេស្សនៈ សម័យណា បុគ្គលទទួលអទុក្ខមសុខវេទនា សម័យនោះ មិនទទួលសុខវេទនា មិនទទួលទុក្ខវេទនាទេ សម័យនោះ ទទួលចំពោះតែអទុក្ខមសុខវេទនា ។ ម្នាលអគ្គិវេស្សនៈ សុខវេទនាជារបស់មិនទៀង ជារបស់ដែលសង្ខារតាក់តែងកើតឡើងហើយ មានកិរិយាអស់ទៅ និងសូន្យទៅជាធម្មតា មានកិរិយាក្លាយទៅទាំងមានកិរិយារលត់ទៅវិញជាធម្មតា ។ ម្នាលអគ្គិវេស្សនៈ ទុក្ខវេទនាក៏ជារបស់មិនទៀង ជារបស់ដែលសង្ខារតាក់តែងកើតឡើងហើយ តែងអស់ទៅនិងសូន្យទៅជាធម្មតា មានកិរិយាក្លាយទៅ ទាំងមានកិរិយារលត់ទៅជាធម្មតា ។ ម្នាលអគ្គិវេស្សនៈ សូម្បីអទុក្ខមសុខវេទនា ក៏ជារបស់មិនទៀង ជារបស់ដែលសង្ខារតាក់តែងកើតឡើងហើយ តែងអស់ទៅ និងសូន្យទៅជាធម្មតា មានកិរិយាក្លាយទៅនិងរលត់ទៅជាធម្មតា ។ ម្នាលអគ្គិវេស្សនៈ អរិយសាវក័អ្នកបានស្តាប់ហើយ កាលឃើញយ៉ាងនេះ រមែងនឿយណាយចាកសុខវេទនាផង នឿយណាយចាកទុក្ខវេទនាផង នឿយណាយចាកអទុក្ខមសុខវេទនាផង កាលបើនឿយណាយហើយ រមែងប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក ចិត្តរមែងរួចចាកកិលេស

កាលចិត្តរួចចាកកិលេសហើយ ញាណក៏កើតឡើងច្បាស់ថា ចិត្តរួចស្រឡះហើយ ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌បាននៅចប់ហើយ កិច្ចដែលគួរធ្វើបានធ្វើរួចស្រេចហើយ កិច្ចដទៃក្រៅពីនេះមិនមានឡើយ ។ ម្នាលអគ្គិវេស្សនៈ ភិក្ខុដែលមានចិត្តផុតស្រឡះយ៉ាងនេះ រមែងមិននិយាយផ្សំនឹងអ្នកណាៗ មិននិយាយទទឹងទាស់នឹងអ្នកណាៗ វាចាណាដែលគេនិយាយហើយក្នុងលោក ក៏ពោលទៅតាមវាចានោះ តែមិនបានស្ទាបអង្អែល (ដោយទិដ្ឋិ) ។

សម័យនោះឯង ព្រះសារីបុត្តមានអាយុ គង់ខាងព្រះ-ប្រឹស្ដាង្គនៃព្រះមានព្រះភាគ បក់ថ្វាយព្រះមានព្រះភាគ ។ ក្នុងលំដាប់នោះ ព្រះសារីបុត្តមានអាយុ មានសេចក្ដីត្រិះរិះយ៉ាងនេះថា បានឮថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ការលះបង់នូវពួកធម៌នោះៗ ដោយប្រាជ្ញាដ៏ក្រៃលែង ដល់យើងទាំងឡាយ បានឮថាព្រះសុគតទ្រង់ត្រាស់ការរលាស់ចោលនូវពួកធម៌នោះៗ ដោយប្រាជ្ញាដ៏ក្រៃលែង ដល់យើងទាំងឡាយ ។ កាលព្រះសារីបុត្តមានអាយុ កំពុងពិចារណាហេតុនេះ ស្រាប់តែចិត្តលោកក៏ផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំដោយប្រការដូច្នេះ ។ ធម្មចក្ខុដែលប្រាសចាកធូលី ប្រាសចាកមន្ទិលបានកើតឡើងហើយ



ដល់ទីឃនខបរិព្វាជកថា ធម្មជាតិអ្វីមួយ មានសេចក្ដីកើតឡើងជាធម្មតា ធម្មជាតិទាំងអស់នោះ រមែងរលត់ទៅវិញជាធម្មតា ។

គ្រានោះ ទីឃនខបរិព្វាជក បានឃើញធម៌ហើយ បានដល់ធម៌ហើយ បានដឹងច្បាស់នូវធម៌ហើយ មានចិត្តចុះស៊ប់ក្នុងធម៌ហើយ ឆ្លងផុតសេចក្ដីសង្ស័យហើយ ប្រាសចាកសេចក្ដីងឿងឆ្ងល់ដល់នូវសេចក្ដីក្លៀវក្លា មិនជឿស្ដាប់បុគ្គលដទៃ ក្នុងសាសនារបស់ព្រះសាស្ដា បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើនពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើន ទ្រង់ប្រកាសហើយ ដោយអនេកបរិយាយយ៉ាងនេះដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬបើកបង្ហាញវត្ថុ ដែលបិទបាំងទុក ឬក៏ប្រាប់ផ្លូវដល់មនុស្សវង្វេងទិស ពុំនោះសោត ដូចជាមនុស្សកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានភ្នែក (ភ្លឺ) មើលឃើញរូបទាំងឡាយបាន ខ្ញុំព្រះអង្គសូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក សូមព្រះគោតមដ៏ចម្រើនជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសកដល់សរណគមន៍ ស្មើដោយជីវិត ចាប់ដើមតាំងពីថ្ងៃនេះតទៅ ។

*-**គុហាព្រះមហាមោគ្គល្លាន** ចុះពីសូករខាតា មកក្រោម

បន្តិច ជាកន្លែងចាំវស្សារបស់ព្រះអគ្គសាវ័កកំពូលខាងឫទ្ធិ ។ ព្រះ-ដ៏មានព្រះភាគ ធ្លាប់គង់សម្តែងពោជ្ឈង្គធម៌ទីនេះផងដែរ ។

ពួកទេវតាជាច្រើនចំនួន ១ ម៉ឺនអង្គ មានឫទ្ធិ មានយស ទេវតាទាំងអស់នោះ ទាំងពួកព្រហ្មបុរោហិត ឈរប្រណម្យ នមស្ការព្រះមហាមោគ្គល្លានថា :

**នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម**
**យស្ស តេ អាសវា ខីណា ទក្ខិណេយ្យោសិ មារិស។**

បពិត្រលោកម្ចាស់ជាបុរសអាជានេយ្យ យើងខ្ញុំសូមនមស្ការ ចំពោះលោក បពិត្រលោកម្ចាស់ជាបុរសដ៏ឧត្តម យើងខ្ញុំសូម នមស្ការ ចំពោះលោក បពិត្រលោកម្ចាស់អ្នកនិរទុក្ខ លោកមាន អាសវៈអស់ហើយ លោកម្ចាស់ជាទក្ខិណេយ្យបុគ្គល ។

(បិដកលេខ ៥៧ , ទំព័រ ១២៥ )

*-**ភ្នំគិជ្ឈកូដ** សម័យពុទ្ធកាល ជាទីគង់នៅនៃភិក្ខុទាំង-ឡាយ ជាទីសប្បាយមនោរម្យ ក្នុងព្រះកម្មដ្ឋាន លោកគង់នៅ ជុំវិញភ្នំ និងនៅតាមជងភ្នំជាប់ៗ គ្នា ។ ភិក្ខុទេវទត្ត ប្រមៀលថ្ម ទម្លាក់ បំណងធ្វើឃាតព្រះសម្មាសម្ពុទ្ធ ។ ជ្រោះទម្លាក់ចោរ ។ ព្រះមហាមោគ្គល្លានឃើញប្រេតដោយទិព្វចក្ខុ ។ ពុទ្ធបរិស័ទគួរ ឧទ្ទិសបុណ្យ សូត្រធម៌ផ្សាយមេត្តាចិត្ត ។





*-**ជីវកម្ពវ័ន** ព្រៃស្វាយដែលពេទ្យជីវកៈវេរថ្វាយសង្ឃ មាននូវព្រះគន្ធកុដិសម្រាប់ព្រះដ៏មានព្រះភាគ មានសេនាសនៈ សម្រាប់សង្ឃ មានកន្លែងព្យាបាលព្រះសង្ឃអាពាធ ។ ព្រះបាទ អជាតសត្តុវេទេហីបុត្រចាប់ផ្តើមជ្រះថ្លានឹងព្រះពុទ្ធសាសនា ព្រោះ បានស្តាប់សាមញ្ញផលសូត្រអំពីព្រះបរមសាស្តា នៅទីនេះឯង ។

## ប្រវត្តិសង្ខេបរបស់ពេទ្យជីវកៈ

ពេទ្យជីវកកោមារភច្ច កើតនៅក្នុងក្រុងរាជគ្រឹះ ម្តាយឈ្មោះ **សាលវតី** ជានគរសោភិនីប្រចាំក្រុងរាជគ្រឹះ មានប្រវត្តិដែលគួរកត់ សម្គាល់ដូចតទៅ :

-ព្រោះម្តាយបោះបង់ចោល ទើបបានអភយរាជកុមាររើស យកមកចិញ្ចឹមឱ្យមានជីវិត ។

-ធំឡើងបានទៅរៀនវិជ្ជាពេទ្យ នៅឯនគរតក្កសិលា មាន ព្យាយាមមោះមុត ចេះចប់វិជ្ជាក្នុងវេលាតិចជាងសិស្សធម្មតា និង ជាពេទ្យពូកែបំផុត ។

-មានការដឹងគុណអភយរាជកុមារជាបិតាចិញ្ចឹមណាស់ ដែលធ្វើឱ្យអភយរាជកុមាររីងរឹតតែស្រឡាញ់ ។

-ពេទ្យជីវកកោមារភច្ច បានថ្វាយការព្យាបាលដល់ព្រះបាទពិម្ពិសារ និងក្លាយជាពេទ្យប្រចាំព្រះរាជវាំង ។

-បានថ្វាយការព្យាបាលដល់ព្រះរាជានគរដទៃ មាននគរឧជ្ជេនីជាដើម បានរង្វាន់ថ្លៃព្យាបាលច្រើនសន្ធឹកសន្ធាប់ ។

-បានថ្វាយការព្យាបាលដល់ព្រះដ៏មានព្រះភាគ ថ្វាយសំពត់ដ៏មានតម្លៃប្រមាណមិនបានដល់ព្រះសម្មាសម្ពុទ្ធ និងសំពត់ដទៃ ១.០០០ ផ្ទាំងដល់ភិក្ខុសង្ឃ ព្រមទាំងសូមពរ សូមព្រះមានព្រះភាគអនុញ្ញាតគហបតិចីវរ ដល់ភិក្ខុសង្ឃទទួលប្រើប្រាស់ ។ ព្រះអង្គទ្រង់អនុញ្ញាតគហបតិចីវរចាប់ពីពេលនោះមក ។

-ព្រះពុទ្ធគង់លើភ្នំគិជ្ឈកូដ សម្តែងព្រះធម៌ ពេទ្យជីវកៈបានសម្រេចសោតាបត្តិផល ។

-បានកសាងវត្តនៅនឹងចម្ការស្វាយរបស់ខ្លួន ថ្វាយសង្ឃមានព្រះពុទ្ធជាប្រធាន ។ វត្តនោះឈ្មោះថា **ជីវកម្ពវ័ន** នៅក្នុងក្រុងរាជគ្រឹះ ចុះពីភ្នំគិជ្ឈកូដចូលមកខាងក្នុង ។

-ក្នុងមហាខន្ធកៈ វិនយបិដកលេខ ៦ , ទំព័រ ២៣៩ ពេទ្យជីវកៈបានពិនិត្យឃើញមានបញ្ហា មនុស្សមានរោគ ៥ យ៉ាង គឺ **កុដ្ឋ** ឃ្លង់ ១ , **គណ្ឌ** ពកឬបូស ១ , **កិលាសោ** ស្រែង ១ , **សោសោ** រោគរីងរៃ ១ និង **អបមារោ** ឆ្កួតជ្រូក ១ នាំគ្នាបួសដោយគ្រាន់តែ





ដើម្បីងាយស្រួលក្នុងការរក្សាព្យាបាល ជាហើយក៏សឹកវិញ ។ ពេទ្យជីវកៈបានចូលគាល់ព្រះដ៏មានព្រះភាគ ក្រាបទូលព្រះអង្គថា « បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមពរថា លោកម្ចាស់ ទាំង-ឡាយកុំបំបួសមនុស្សដែលមានអាពាធទាំង ៥ យ៉ាងឡើយ » ...។ ទើបព្រះអង្គទ្រង់បញ្ញត្តថា « ម្នាលភិក្ខុទាំងឡាយ មនុស្សដែលមានអាពាធទាំង ៥ យ៉ាងហើយ អ្នកទាំងឡាយមិនគប្បីបំបួសឡើយ ភិក្ខុណាបំបួស ត្រូវអាបត្តិទុក្កដ » ។

-ក្នុងខុទ្ទកវត្ថុក្ខន្ធក បិដកលេខ ១០ , ទំព័រ ១៦៩ ពេទ្យជីវកៈបានពិនិត្យឃើញភិក្ខុទាំងឡាយ មានកាយច្រើនទៅដោយទោស (រោគទល់) មានអាពាធច្រើន ។ ពេទ្យជីវកៈបានចូលគាល់ព្រះដ៏មានព្រះភាគ ក្រាបទូលព្រះអង្គថា« បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ភិក្ខុទាំងឡាយមានកាយច្រើនទៅដោយទោស មានអាពាធច្រើន បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន ខ្ញុំព្រះអង្គសូមអង្វរ សូមព្រះអង្គអនុញ្ញាតទីចង្ក្រម និងរោងភ្លើងដល់ភិក្ខុទាំងឡាយ ជាការប្រពៃ កាលបើយ៉ាងនេះភិក្ខុទាំងឡាយនឹងមិនសូវមានអាពាធ »។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថាក្នុងវេលានោះ ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា « ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទីចង្ក្រម និងរោងភ្លើង » ...។

-ប្រវត្តិរឿងរ៉ាវរបស់ពេទ្យជីវកកោមារភច្ច មានពិស្តារក្នុង វិនយបិដកលេខ ៨ , ចីវរក្ខន្ធកៈ , ទំព័រ ៦១ បញ្ជាក់អំពីសមត្ថភាព និងទឹកចិត្តមនុស្សល្អ ដែលគួរឱ្យសិក្សាចម្រើនសេចក្តីជ្រះថ្លា ។

-ក្នុងគាថាធម្មបទ អរហន្តវគ្គ បានប្រារព្ធចំពោះព្រះអង្គ ទ្រង់ត្រូវរបួស ពងព្រះលោហិត ដោយសារភិក្ខុទេវទត្ត បំណងធ្វើ ឃាតព្រះអង្គ នៅភ្នំគិជ្ឈកូដ ។ ភិក្ខុទេវទត្តមានចិត្តប្រទូស្តចំពោះ ព្រះសម្មាសម្ពុទ្ធ ទម្លាក់ថ្មលើព្រះអង្គ ឯពេទ្យ **ជីវកៈ** ជ្រះថ្លានឹង ព្រះដ៏មានព្រះភាគដ៏ក្រៃលែង បានថ្វាយការរក្សា និងព្យាបាលដល់ ព្រះអង្គនៅជីវកម្ពវ័ន ដោយការបិទថ្នាំថ្វាយ ហើយបានក្រាបទូល សួរព្រះអង្គថា « បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីក្តៅក្រហាយ កើតឡើងក្នុងព្រះសរីរៈរបស់ព្រះអង្គឬទេ ? » ។

ព្រះសាស្តាទ្រង់ត្រាស់ថា « ជីវកៈ សេចក្តីក្តៅក្រហាយ ទាំងពួងរបស់តថាគត ស្ងប់រម្ងាប់ហើយ នៅគល់ពោធិព្រឹក្សនោះ ឯង »។ ដូច្នេះហើយ ព្រះអង្គទ្រង់បន្តអនុសន្ធិ ត្រាស់នូវព្រះគាថា នេះថា :

**គតទ្ធិនោ វិសោកស្ស វិប្បមុត្តស្ស សព្វធិ**
**សព្វគន្ថប្បហីនស្ស បរិឡាហោ ន វិជ្ជតិ ។**

សេចក្តីក្តៅក្រហាយ រមែងមិនមានដល់បុគ្គលដែលមាន





ផ្លូវឆ្ងាយបានដល់ហើយ មិនមានសេចក្តីសោក រួចផុតហើយពីធម៌ ទាំងពួងមានខន្ធ ៥ ជាដើម និងជាអ្នកលះបង់នូវកិលេសដែលជា គ្រឿងដោតក្រងទាំងពួងបានហើយ ។

-ជីវកម្ពវនារាម ជាអារាមដែលពេទ្យជីវកៈបានសាងថ្វាយ សង្ឃមានព្រះពុទ្ធជាប្រធាន ។ វត្តនេះឯងហើយ ដែលព្រះចូឡ-បន្ថកៈបានសម្រេចនូវគុណធម៌ដ៏ខ្ពង់ខ្ពស់ ចប់កិច្ចរបស់បព្វជិតក្នុង ព្រះសាសនា ។

-ក្នុងបិដកលេខ ៤៨ , ទំព័រ ១៣២ សម័យមួយព្រះដ៏មាន-ព្រះភាគទ្រង់គង់នៅក្នុងជីវកម្ពវ័ន ។ ពេទ្យជីវកៈបានទូលសួរព្រះដ៏ មានព្រះភាគអំពី ឧបាសកអ្នកមានសីល រហូតដល់ខាងចុងព្រះ-សូត្រ បានទូលសួរព្រះអង្គថា « បពិត្រព្រះអង្គដ៏ចម្រើន ឧបាសក អ្នកប្រតិបត្តិ ដើម្បីជាប្រយោជន៍ដល់ខ្លួនឯងផង ដើម្បីជា ប្រយោជន៍ដល់បុគ្គលដទៃផង តើដោយហេតុដូចម្តេច ? » ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ធម៌ ៨ គឺ

១-ឧបាសកបរិបូណ៌ដោយសទ្ធា ដោយខ្លួនឯងផង ទាំង បបួលបុគ្គលដទៃឱ្យបរិបូណ៌ដោយសទ្ធាផង ។

២-ជាអ្នកបរិបូណ៌ដោយសីល ដោយខ្លួនឯងផង ទាំង បបួលបុគ្គលដទៃឱ្យបរិបូណ៌ដោយសីលផង ។

៣.ជាអ្នកបរិបូណ៌ដោយចាគៈ ដោយខ្លួនឯងផង ទាំងបបួលបុគ្គលដទៃឱ្យបរិបូណ៌ដោយចាគៈផង ។

៤.ជាអ្នកចង់ឃើញពួកភិក្ខុ ដោយខ្លួនឯងផង ទាំងបបួលបុគ្គលដទៃឱ្យបានឃើញពួកភិក្ខុផង ។

៥.ជាអ្នកចង់ស្តាប់ព្រះសទ្ធម្ម ដោយខ្លួនឯងផង ទាំងបបួលបុគ្គលដទៃឱ្យបានស្តាប់នូវព្រះសទ្ធម្មផង ។

៦.ជាអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ ដែលបានស្តាប់ហើយ ដោយខ្លួនឯងផង ទាំងបបួលបុគ្គលដទៃឱ្យទ្រទ្រង់នូវធម៌ផង ។

៧.ជាអ្នកពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលបានស្តាប់ហើយ ដោយខ្លួនឯងផង ទាំងបបួលបុគ្គលដទៃឱ្យពិចារណានូវអត្ថផង ។

៨.ជាអ្នកដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ដោយខ្លួនឯងផង ទាំងបបួលបុគ្គលដទៃឱ្យប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ផង ។

ម្នាលជីវកៈ ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ឧបាសកទើបមានឈ្មោះថា ជាអ្នកប្រតិបត្តិដើម្បីជាប្រយោជន៍ដល់ខ្លួនឯងផង ដើម្បីជាប្រយោជន៍ដល់អ្នកដទៃផង ។

-ក្នុងបិដកលេខ ២៣ , ទំព័រ ៨៣ **ជីវកសូត្រ** ពេទ្យជីវកៈបាន





ទូលសួរព្រះដ៏មានព្រះភាគអំពីត្រី និងសាច់ដែលជាអាហារកិច្ចសម្រាប់បព្វជិត ។ ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីត្រីនិងសាច់យ៉ាងដូចម្តេចគួរ និងយ៉ាងដូចម្តេចមិនគួរ ។ សម្តែងអំពីព្រហ្មវិហារ ៤ យ៉ាង និងការសម្លាប់សត្វចំពោះតថាគត ឬសាវ័ករបស់តថាគតរមែងមានបាបច្រើន ដោយហេតុ ៥ យ៉ាង ។ បានសិក្សាក្នុងព្រះសូត្រនេះហើយ នឹងបានដឹងថា « អាហារបរិសុទ្ធ » នោះ តើដូចម្តេចតាមសេចក្តីពិត ។

-ដែលគួរកោតស្ញប់ស្ញែងដ៏ក្រៃលែង ដល់សមត្ថភាពរបស់ពេទ្យជីវកៈ គឺពេទ្យជីវកៈអាចយាងព្រះបាទអជាតសត្តុ ឱ្យបានមកគាល់ព្រះដ៏មានព្រះភាគ នេះជាគុណូបការៈដ៏ធំធេងរបស់ពេទ្យជីវកកោមារភច្ច ដែលមានចំពោះព្រះបាទអជាតសត្តុ ក៏ដូចជាមានចំពោះព្រះពុទ្ធសាសនា ។

-ក្នុងជីវិតរបស់ពេទ្យជីវកៈ មានអ្នកដទៃស្រឡាញ់រាប់អានច្រើន ទាំងស្តេចទាំងរាស្ត្រ ទាំងអ្នកតូចទាំងអ្នកធំ ទាំងគ្រហស្ថទាំងបព្វជិត ដោយអាស្រ័យលើការឆ្លាតវាងវៃ សមត្ថភាពជាក់ស្តែង មានទឹកចិត្តប្រកបដោយមេត្តាករុណាច្រើន ទាំងជាព្រះ-អរិយបុគ្គលទៀតផង។ ព្រះអង្គទ្រង់ស្ថាបនាក្នុងតំណែងជាឯតទគ្គៈលើឧបាសកទាំងឡាយផ្នែកខាង មានសេចក្តីជ្រះថ្លាក្នុងបុគ្គល គឺ

ជ្រះថ្លាក្នុងបុគ្គលដែលគួរជ្រះថ្លាពិត។ ។

***-គុកដាក់ព្រះបាទពិម្ពិសារ** នឹកឃើញដល់សត្វលោកប្រព្រឹត្តទៅតាមកម្ម ។ បញ្ចក្ខន្ធចងសត្វលោកឱ្យជាប់នឹងការងារចិញ្ចឹមជីវិត ។ តណ្ហាចងសត្វលោកឱ្យជាប់ក្នុងភព ជាប់នឹងរបស់ដែលឥតប្រយោជន៍ ។ ទិដ្ឋិធ្វើឱ្យសត្វលោកខ្វល់នឹងខ្លួនឯងរហូត ។

***-តបោទារាម** នៅនឹងជើងភ្នំវេភារៈ ជាអារាមរបស់សង្ឃក្នុងសម័យពុទ្ធកាល និងក្រោយមក ។ បច្ចុប្បន្នជាកន្លែងងូតទឹកនៃជនដែលប្រកាន់វណ្ណៈ ប្រកាន់មិច្ឆាទិដ្ឋិ ។ គួរសង្វេគដល់សេចក្ដីល្ងង់របស់សត្វលោក ។

***-បិប្ផលិគុហា** នៅខាងស្ដាំដៃផ្លូវឡើងភ្នំវេភារៈ ទៅកាន់សត្តបណ្ណិគុហា ។ ព្រះមហាកស្សបៈ មានប្រក្រតីគង់នៅនឹងគុហានេះ ។ សូម្បីព្រះដ៏មានព្រះភាគ ព្រះអង្គក៏ធ្លាប់យាងមកគង់សម្ដែងព្រះធម៌ផងដែរ មានពោជ្ឈង្គធម៌ជាដើម ។

បិដកលេខ ៣៧ , ទំព័រ ២០៥ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុង





រាជគ្រឹះ ។ សម័យនោះឯង ព្រះមហាកស្សបៈដ៏មានអាយុគង់នៅក្នុងបិប្ផលិគុហា លោកមានអាពាធ ដល់នូវសេចក្ដីទុក្ខ មានជំងឺជាទម្ងន់ ។

គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់ចេញអំពីទីសំងំក្នុងសាយណ្ហសម័យ ព្រះអង្គទ្រង់ចូលទៅរកព្រះមហាកស្សបៈដ៏មានអាយុ លុះចូលទៅដល់ហើយ ព្រះអង្គក៏បានគង់លើអាសនៈដែលគេក្រាលទុក ។ល។

ព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងនូវពោជ្ឈង្គធម៌ ៧ ប្រការ។ ព្រះមហាកស្សបៈក៏ត្រេកអរចំពោះព្រះពុទ្ធភាសិត ហើយក៏បានសះស្បើយចាកអាពាធនោះទៅ ។

ក្នុងសំយុត្តនិកាយ និទានវគ្គ កស្សបសំយុត្ត បឋមឱវាទ-សូត្រ នៅវត្តវេឡុវ័ន ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា : ម្នាលកស្សបៈ អ្នកចូរទូន្មាននូវភិក្ខុទាំងឡាយ ចូរធ្វើនូវធម្មីកថាដល់ភិក្ខុទាំងឡាយ តថាគត ឬអ្នកគប្បីទូន្មាននូវភិក្ខុទាំងឡាយ តថាគត ឬអ្នកគប្បីធ្វើនូវធម្មីកថាដល់ភិក្ខុទាំងឡាយ ។ អដ្ឋកថាបានពន្យល់ថា ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះ ដើម្បីតាំងព្រះមហាកស្សបៈទុកក្នុងឋានៈនៃព្រះអង្គ ។ សួរថា ព្រះសារីបុត្តនិងព្រះមហាមោគ្គល្លានមិនមានទេឬ ? ឆ្លើយថា មាន ។ ប៉ុន្តែ

ព្រះអង្គទ្រង់ព្រះតម្រិះយ៉ាងនេះថា : អគ្គសាវ័កទាំងពីរនេះ គង់នៅមិនបានយូរឡើយ ចំណែកកស្សបៈមានអាយុ ១២០ ឆ្នាំ ។ កាលយើងតថាគតបរិនិព្វានហើយ កស្សបៈនោះនឹងអង្គុយក្នុងសត្តបណ្ណគុហា ធ្វើការរួបរួមព្រះធម៌វិន័យ ឱ្យព្រះធម៌វិន័យរបស់យើង តថាគតឋិតនៅបានប្រមាណ ៥.០០០ ឆ្នាំ ។ ដូច្នេះហើយទើបព្រះតថាគតតាំងព្រះមហាកស្សបៈ ទុកក្នុងឋានៈនៃព្រះអង្គដើម្បីឱ្យពួកភិក្ខុសម្គាល់នូវពាក្យរបស់ព្រះមហាកស្សបៈ ថាខ្លួនគប្បីស្តាប់ដោយល្អ ។

*-**សត្តបណ្ណគុហា** នៅលើភ្នំវេភារៈ ជាកន្លែងធ្វើបឋមសង្គាយនា ។ គួរនឹករលឹកដល់ព្រះពុទ្ធដីកា ពេលដែលព្រះអង្គជិតនឹងបរិនិព្វាន ។

**យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ សោ វោ មមច្ចយេន សត្ថា** ។ ម្នាលអានន្ទ ធម៌ណាក្តី វិន័យណាក្តី ដែលតថាគតសម្តែងហើយ បញ្ញត្តហើយ ដល់អ្នកទាំងឡាយ លុះអំណើះតអំពីតថាគតទៅ ធម៌និងវិន័យនោះ ជាគ្រូរបស់អ្នកទាំងឡាយ ។

នៅពីខាងកើតភ្នំវេភារៈ គឺជាភ្នំវេបុល្លៈ ។ ភ្នំវេបុល្លៈនេះ





ជាភ្នំធំជាងគេនៅដែនមគធៈ ។

*-**វត្តវេឡុវ័ន** ជាវត្តទីមួយកើតមានក្នុងព្រះពុទ្ធសាសនា ឋិតនៅក្រៅក្រុងទិសខាងជើង ជិតតបោទារាម ។ ព្រះអគ្គសាវ័កទាំងពីរឧបសម្បទានៅវត្តនេះ ទាំងដែលជាវត្តព្រះអង្គទ្រង់សម្តែងនូវឱវាទបាតិមោក្ខ ដល់ព្រះអរហន្ត ១.២៥០ អង្គ ក្នុងថ្ងៃចតុរង្គសន្និបាត ១៥ កើត ខែមាឃ បន្ទាប់ពីការត្រាស់ដឹងរបស់ព្រះអង្គ ៩ ខែមក ។

## ភាសិតោវាទសង្ខេប

**ឱកាស** ខ្ញុំសូមគោរព !

**យោ ខោ ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ បដិបត្តិបូជាយ។**

អ្នកឯណាមួយ ជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិដោយត្រឹមត្រូវ ជាអ្នកប្រព្រឹត្តតាមធម៌ជាប្រក្រតី អ្នកនោះ ឈ្មោះថាធ្វើសក្ការៈ ធ្វើសេចក្តីគោរពរាប់អាន បូជានូវព្រះតថាគត ដោយបដិបត្តិបូជា ជាបូជាដ៏ឧត្តម ។

**សព្វបាបស្ស អករណំ    កុសលស្សូបសម្បទា**
**សចិត្តបរិយោទបនំ    ឯតំ ពុទ្ធាន សាសនំ ។**

កិរិយាមិនធ្វើនូវបាបទាំងពួង កិរិយាបំពេញកុសល កិរិយាធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់ ទាំងនេះជាពាក្យប្រៀនប្រដៅ នៃព្រះពុទ្ធទាំងឡាយ ។

**ខន្តិ បរមំ តបោ តីតិក្ខា**
**និព្វានំ បរមំ វទន្តិ ពុទ្ធា**
**ន ហិ បព្វជិតោ បរូបឃាតី**
**សមណោ ហោតិ បរំ វិហេឋយន្តោ ។**

អំណត់គឺសេចក្ដីអត់ធន់ ជាតបធម៌ដ៏ឧត្ដម ព្រះពុទ្ធទាំងឡាយទ្រង់ត្រាស់ថា ព្រះនិព្វានជាគុណជាតដ៏ឧត្ដម អ្នកបួសដែលបៀតបៀនសត្វដទៃ សម្លាប់សត្វដទៃ មិនមែនជាបព្វជិត មិនមែនជាសមណៈឡើយ ។

**អនូបវាទោ អនូបឃាតោ បាតិមោក្ខេ ច សំវរោ**
**មត្តញ្ញុតា ច ភត្តស្មឹ    បន្តញ្ច សយនាសនំ**
**អធិចិត្តេ ច អាយោគោ    ឯតំ ពុទ្ធាន សាសនំ ។**

កិរិយាមិនតិះដៀល ( អ្នកដទៃ ) ១ កិរិយាមិនបៀតបៀន ( អ្នកដទៃ ) ១ កិរិយាសង្រួមក្នុងបាតិមោក្ខ ១ ភាវៈដឹងប្រមាណ





ក្នុងភត្តាហារ ១ ទីដេកនិងទីអង្គុយដ៏ស្ងាត់ ១ កិរិយាបំពេញព្យាយាមក្នុងអធិចិត្ត ១ ទាំងនេះជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

**សីលសមាធិគុណានំ    ខន្តិ បធានការណំ**
**សព្វេបិ កុសលា ធម្មា    ខន្ត្យាយេវ វឌ្ឍន្តិ តេ ។**

សេចក្ដីអត់ធន់ ជាហេតុជាទីតាំង នៃគុណគឺសីលនិងសមាធិទាំងឡាយ ធម៌ទាំងឡាយជាកុសលទាំងអស់នោះ តែងចម្រើនដោយសេចក្ដីអត់ធន់មែនពិត ។

**កេវលានំបិ បាបានំ    ខន្តិ មូលំ និកន្តតិ**
**គរហកលហាទីនំ    មូលំ ខណតិ ខន្តិកោ ។**

សេចក្ដីអត់ធន់ តែងកាត់បង់បាននូវឫសនៃបាបទាំងឡាយទាំងអស់ បុគ្គលអ្នកអត់ធន់ ឈ្មោះថាជីករំលើងនូវឫសនៃទោសទាំងឡាយ មានពាក្យតិះដៀលនិងការឈ្លោះប្រកែកជាដើម ។

**ខន្តិ ធីរស្សលង្ការោ    ខន្តិ តបោ តបស្សិនោ**
**ខន្តិ ពលំ វ យតីនំ    ខន្តិ ហិតសុខាវហា ។**

សេចក្ដីអត់ធន់ ជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញ សេចក្ដីអត់ធន់ជាគ្រឿងដុតបង់នូវបាបរបស់អ្នកដែលមានតបធម៌ សេចក្ដីអត់ធន់ ជាកម្លាំងរបស់អ្នកប្រព្រឹត្តធម៌ សេចក្ដីអត់ធន់ជាគុណជាត

នាំមកនូវប្រយោជន៍និងសេចក្ដីសុខ ។

**ខន្តិកោ មេត្តវា លាភី យសស្សី សុខសីលវា**

**បិយោ ទេវមនុស្សានំ មនាបោ ហោតិ ខន្តិកោ។**

អ្នកអត់ធន់ ជាអ្នកមានមិត្រសម្លាញ់ ជាអ្នកមានលាភ ជាអ្នកមានយស ជាអ្នកមានសេចក្ដីសុខជាប្រក្រតី អ្នកអត់ធន់ រមែងជាទីស្រឡាញ់ជាទីគាប់ចិត្ត នៃទេវតានិងមនុស្សទាំងឡាយ ។

**អត្តនោបិ បរេសញ្ច អត្ថាវហោ វ ខន្តិកោ**

**សគ្គមោក្ខគមំ មគ្គំ អារុឡ្ហោ ហោតិ ខន្តិកោ។**

អ្នកអត់ធន់ ជាអ្នកនាំមកនូវប្រយោជន៍ដល់ខ្លួនផង ដល់ជនទាំងឡាយឯទៀតផង អ្នកអត់ធន់ ជាអ្នកឡើងកាន់ផ្លូវជាទីទៅឋានសួគ៌និងព្រះនិព្វាន ។

**សត្ថុនោ វចនោវាទំ ករោតិយេវ ខន្តិកោ**

**បរមាយ ច បូជាយ ជិនំ បូជេតិ ខន្តិកោ ។**

អ្នកអត់ធន់ ឈ្មោះថាធ្វើតាម នូវព្រះពុទ្ធដីកាជាឱវាទ នៃព្រះសាស្ដាមែនពិត អ្នកអត់ធន់ ឈ្មោះថាបូជានូវព្រះវិជិតមារ ដោយការបូជាដ៏ឧត្ដម ។

**ទុល្លភញ្ច មនុស្សត្តំ ពុទ្ធុប្បាទោ ច ទុល្លភោ**

**ទុល្លភា ខណសម្បត្តិ សទ្ធម្មោ បរមទុល្លភោ ។**





ភាវៈកើតជាមនុស្ស គឺសត្វទាំងឡាយបានដោយកម្រ កិរិយាត្រាស់ជាព្រះពុទ្ធ គឺសត្វទាំងឡាយបានដោយកម្រ កិរិយាដល់ព្រមដោយខណៈគឺបានកើតជួបនឹងព្រះពុទ្ធ ឬ នឹងព្រះពុទ្ធសាសនា គឺសត្វទាំងឡាយបានដោយកម្រ ធម៌របស់សប្បុរសគឺសត្វទាំងឡាយបានដោយកម្រក្រៃលែង ។

**សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា**

**សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ ។**

កិរិយាបានត្រាស់នៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្ដីសុខ កិរិយាសម្ដែងនូវធម៌របស់សប្បុរស នាំមកនូវសេចក្ដីសុខ សេចក្ដីព្រមព្រៀងគ្នារបស់សង្ឃ ឬ ពួកក្រុម នាំមកនូវសេចក្ដីសុខ សេចក្ដីព្យាយាមរបស់អ្នកដែលព្រមព្រៀងគ្នាទាំងឡាយ នាំមកនូវសេចក្ដីសុខ ។

**សុខោ វិវេកោ តុដ្ឋស្ស សុតធម្មស្ស បស្សតោ**

**អព្យាបជ្ជំ សុខំ លោកេ បាណភូតេសុ សញ្ញមោ។**

សេចក្ដីស្ងប់ស្ងាត់ របស់អ្នកដែលត្រេកអរ ( ក្នុងទីស្ងាត់ ) ជាអ្នកមានធម៌បានស្ដាប់ហើយ ពិចារណាឃើញ ( នូវធម៌ ) នាំមកនូវសេចក្ដីសុខ កិរិយាមិនបៀតបៀន គឺកិរិយាសង្រួមចំពោះសត្វទាំងឡាយ នាំមកនូវសេចក្ដីសុខក្នុងលោក ។

**សុខា វិរាគតា លោកេ   កាមានំ សមតិក្កមោ**
**អស្មិមានស្ស វិនយោ   ឯតំ វេ បរមំ សុខំ ។**

ភាវៈប្រាសចាករាគៈ គឺកិរិយាកន្លងនូវកាមទាំងឡាយ នាំមកនូវសេចក្ដីសុខក្នុងលោក កិរិយាធ្វើឱ្យវិនាសនូវអស្មិមានៈ នេះឯង នាំមកនូវសេចក្ដីសុខដ៏ឧត្ដម ។

**កិច្ឆោ មនុស្សប្បដិលាភោ កិច្ឆំ មច្ចាន ជីវិតំ**
**កិច្ឆំ សទ្ធម្មស្សវនំ   កិច្ឆោ ពុទ្ធានមុប្បាទោ។**

កិរិយាត្រឡប់បានអត្តភាពជាមនុស្ស ជាការលំបាក សេចក្ដីរស់នៅរបស់សត្វទាំងឡាយ ជាការលំបាក កិរិយាស្ដាប់ នូវព្រះ-សទ្ធម្ម ជាការកម្រ កិរិយាបានត្រាស់នៃព្រះពុទ្ធទាំងឡាយ ជាការលំបាក ។

**សត្ថុនោ សទ្ធម្មំ សុត្វា   សព្វស្មឹ ជិនសាសនេ**
**កប្បានិ សតសហស្សានិ   ទុគ្គតឹ សោ ន គច្ឆតិ ។**

បុគ្គលឯណា បានស្ដាប់នូវព្រះសទ្ធម្មរបស់ព្រះសាស្ដា( ដែលរាប់បញ្ចូល ) ក្នុងពាក្យប្រៀនប្រដៅនៃព្រះវិជិតមារទាំងពួង បុគ្គលនោះរមែងមិនទៅកាន់ទុគ្គតិអស់សែនកប្ប ។

**បុព្វណ្ហេ បិណ្ឌបាតញ្ច   សាយណ្ហេ ធម្មទេសនំ**
**បទោសេ ភិក្ខុឱវាទំ   អឌ្ឍរត្តេ ទេវបញ្ហនំ ។**





**បច្ចូសេវ គតេ កាលេ   ភព្វាភព្វេ វិលោកនំ**
**ឯតេ បញ្ចវិធេ កិច្ចេ   វិសោធេតិ មុនិបុង្គវោតិ។**

ព្រះសម្មាសម្ពុទ្ធ ជាចម្បងជាងអស់អ្នកប្រាជ្ញ ទ្រង់ជម្រះនូវពុទ្ធកិច្ចទាំងឡាយ ៥ ប្រការនេះ គឺក្នុងពេលព្រឹក ទ្រង់ស្ដេចទៅបិណ្ឌបាត ១ ក្នុងពេលល្ងាច ទ្រង់សម្ដែងធម៌ទេសនា ១ ក្នុងពេលព្រលប់ ទ្រង់ប្រទានឱវាទដល់ពួកភិក្ខុ ១ ក្នុងពេលអធ្រាត្រ ទ្រង់ដោះប្រស្នានៃទេវតា ១ ក្នុងពេលជិតភ្លឺ ទ្រង់ប្រមើលនូវសត្វលោកដែលគួរត្រាស់ដឹងនិងមិនគួរត្រាស់ដឹង ១ ។

**កុក្កុដេ គព្ភវាសោ ច   សោណេ ចុតនិក្ខមិ**
**ឧសភេ រាជសម្បត្តិ   សសេ បព្វជិតោ ជិនោ។**

ព្រះវិជិតមារ ទ្រង់យាងចុះមកអាស្រ័យនៅក្នុងព្រះគភ៌ (នៃព្រះវរមាតា ) ក្នុងឆ្នាំរកា ទ្រង់ប្រសូតចាកព្រះគភ៌ក្នុងឆ្នាំច ទ្រង់សោយរាជសម្បត្តិក្នុងឆ្នាំឆ្លូវ ទ្រង់ព្រះផ្នួសក្នុងឆ្នាំថោះ ។

**កុក្កុដេ សព្វញ្ញូ ពុទ្ធោ   តត្ថ ចក្កំ បវត្តយិ**
**និព្វានគមនំ សប្បេ   សហស្សំ បញ្ច មូសិកេ។**

ទ្រង់ត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធក្នុងឆ្នាំរកា ទ្រង់សម្ដែងនូវព្រះធម្មចក្កក្នុងឆ្នាំនោះ ទ្រង់យាងចូលកាន់ព្រះនិព្វានក្នុងឆ្នាំម្សាញ់ ព្រះពុទ្ធសាសនានឹងគ្រប់ ៥.000 គត់ ក្នុងឆ្នាំជូត ។

**ឱក្កន្តោ ច គរុវារស្មឹ   សុក្រវារេ ច និក្ខមិ**
**សម្ពុទ្ធោ ពុធវារស្មឹ   អង្គារេ បរិនិព្វុតោ ។**

ទ្រង់យាងចុះកាន់ព្រះគភ៌ ( នៃព្រះវរមាតា ) ក្នុងថ្ងៃព្រហស្បតិ៍ ប្រសូតក្នុងថ្ងៃសុក្រ បានត្រាស់ជាព្រះសម្ពុទ្ធក្នុងថ្ងៃពុធ បរិនិព្វានក្នុងថ្ងៃអង្គារ ។

**អាសាឡ្ហបុណ្ណមោក្កន្តោ   វិសាខេយេវ និក្ខមិ**
**វិសាខបុណ្ណមី សម្ពុទ្ធោ   វិសាខេ បរិនិព្វុតោ ។**

ព្រះអង្គយាងចុះកាន់ព្រះគភ៌ ( នៃព្រះវរមាតា ) ក្នុងថ្ងៃពេញបូណ៌មីខែអាសាធ ប្រសូតក្នុងថ្ងៃពេញបូណ៌មីខែវិសាខ បានត្រាស់ជាព្រះសម្ពុទ្ធក្នុងថ្ងៃពេញបូណ៌មីខែវិសាខ បរិនិព្វានក្នុងថ្ងៃពេញបូណ៌មីខែវិសាខ ។

**និព្វុតេ លោកនាថម្ហិ   សម្ពុទ្ធេ អគ្គបុគ្គលេ**
**បដិមា ពោធិរុក្ខា ច   ថូបា ច ជិនធាតុយោ**
**ចតុរាសីតិសហស្ស-   ធម្មក្ខន្ធា សុទេសិតា**
**អគ្គប្បវត្តនដ្ឋានេ   ឋបិតា ហោន្តិ បាណិនំ ។**

កាលព្រះសម្មាសម្ពុទ្ធ ជាអគ្គបុគ្គល ជាទីពឹងនៃសត្វលោក បរិនិព្វានទៅហើយ ព្រះបដិមាផង ព្រះពោធិព្រឹក្សផង ព្រះស្តូបផង ព្រះជិនធាតុផង ព្រះធម៌ ៨ ហ្មឺន ៤ពាន់ធម្មក្ខន្ធ ដែលព្រះអង្គ





ទ្រង់សម្តែងហើយដោយប្រពៃផង ជាវត្ថុគឺព្រះសម្មាសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក ក្នុងឋានដ៏ប្រព្រឹត្តទៅ ដើម្បីជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វទាំងឡាយ ។

**ឥតិ សម្មាសម្ពុទ្ធេន   ទេសិតំ ឱវាទំ ចិត្តេ**
**ឋបេត្វា សម្មាសម្ពុទ្ធេន   វុត្តប្បការេន បដិបត្តិ-**
**បូជាយ បូជំ ករោន្តេន   លោកិយលោកុត្តរ-**
**សម្បត្តិសិទ្ធំ ភាគព្វំ   ឱកាស អារាធនំ ករោមិ។**

បុគ្គលគួរតម្កល់នូវឱវាទ ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងហើយ ទុកក្នុងចិត្ត ហើយធ្វើការបូជា ដោយបដិបត្តិបូជា ដោយនូវប្រការដែលព្រះសម្មាសម្ពុទ្ធ ត្រាស់សម្តែងហើយ គួរធ្វើឱ្យសម្រេចនូវសម្បត្តិជាលោកិយៈ និងលោកុត្តរៈ ខ្ញុំសូមគោរពអារាធនាទុកដោយប្រការដូច្នេះ ។

**ឱកាស សិរីសក្យមុនិសព្វញ្ញុពុទ្ធស្ស ពលវប្បច្ចូសសមយេ កុសិនារាយ យមកសាលានមន្តរេ អម្ហិ សប្បសំវច្ឆរេ គិម្ហឧតុម្ហិ វិសាខមាសេ សុក្កប្បក្ខេ បណ្ណរសិយា តិថិយំ ភុម្មវារេ ភុម្មយាមេ អនុរាធនក្ខត្តទិវសេ បរិនិព្វានំ អហោសិ អនុបាទិសេសាយ និព្វានធាតុយា ។**

ខ្ញុំសូមគោរព សម្តេចព្រះសិរីសក្យមុនីសព្វញ្ញុពុទ្ធជាម្ចាស់

ទ្រង់បរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ក្នុងចន្លោះដើមសាលព្រឹក្សទាំងគូ ជិតក្រុងកុសិនារា ក្នុងបច្ចូសសម័យដ៏មានកម្លាំង ក្នុងថ្ងៃនៃនក្ខត្តឫក្សឈ្មោះអនុរាធា ក្នុងថ្ងៃអង្គារ យាមអង្គារ ជាតិថីពេញបូណ៌មីខាងខ្នើតខែវិសាខ ក្នុងគិម្ហរដូវ ឆ្នាំម្សាញ់ ឯណោះហោង ។ (តាមប្រជុំភាណវារៈ , សែម សូរ )

( ភាសិតោវាទចប់ )

*-អជាតសត្តុស្តូប គឺស្តូបដែលព្រះបាទអជាតសត្តុសាងឡើង ដើម្បីបញ្ចុះព្រះបរមសារីរិកធាតុដែលបានទទួលមកអំពីក្រុងកុសិនារា ។ មានរឿងប្រេតនៅក្នុងបិដកលេខ ៥៦,ទំព័រ ៨៨-៨៩។

## រឿងធាតុវិវណ្ណប្រេត

ព្រះមហាកស្សបសួរធាតុវិវណ្ណប្រេតថា អ្នកឋិតនៅឰដ៏អាកាស មានក្លិនអាក្រក់ ស្អុយផ្សាយទៅផង ពួកដង្កូវរុកស៊ីមាត់របស់អ្នក ដែលមានក្លិនស្អុយផង តើអ្នកបានធ្វើអំពើដូចម្តេច ក្នុងកាលមុន ។ ព្រោះតែផ្សាយក្លិនអាក្រក់ និងមាត់ដែលដង្កូវរុកស៊ី





នោះ (បានជាពួកសត្វដែលកម្មដាស់តឿន ) កាន់គ្រឿងសស្ត្រាមកវះ (មាត់អ្នក ) រឿយៗ ហើយស្រោចដោយទឹកខារ (ទឹកក្រុត ) រួចវះញយៗ ថែមទៀត ។ អំពើអាក្រក់ដូចម្តេច ដែលអ្នកបានធ្វើដោយកាយ វាចា ចិត្ត អ្នករងទុក្ខនេះ តើដោយផលនៃកម្មដូចម្តេច ។

(ធាតុវិវណ្ណប្រេតនោះឆ្លើយថា ) បពិត្រលោក អ្នកនិរទុក្ខ ខ្ញុំជាឥស្សរៈលើទ្រព្យ និងធញ្ញជាតិ ដ៏ច្រើនក្រៃលែង (នៅ ) ក្នុងក្រុងរាជគ្រឹះ មានភ្នំដូចជាក្រោល គួរត្រេកអររីករាយ ។ (កាលពីជាតិមុន ) ស្រីនេះជាប្រពន្ធរបស់ខ្ញុំផង ស្រីនេះជាធីតារបស់ខ្ញុំផង ស្រីនេះជាកូនប្រសាររបស់ខ្ញុំផង ខ្ញុំបានឃាត់ (ស្រីនោះ ) ដែលនាំផ្កាពុំសែន ផ្កាឧប្បល និងគ្រឿងលាបមានតម្លៃ ទៅកាន់ព្រះស្តូបបាបនោះឯង ដែលខ្ញុំបានធ្វើហើយ ។ ពួកយើងចំនួន ៨៦ ពាន់នាក់ រងទុក្ខវេទនាចំពោះខ្លួន ៗ ឆេះនៅក្នុងនរកយ៉ាងខ្លាំង ព្រោះតិះដៀលនូវការបូជាចំពោះព្រះស្តូប ។ ពួកជនណាប្រកាសទោសក្នុងការបូជា ព្រះអរហន្តសម្មាសម្ពុទ្ធ ដែលប្រព្រឹត្តទៅដោយការបូជានូវព្រះស្តូប ( ដូចជាខ្ញុំ ) ពួកជននោះ រមែងឃ្លាតឆ្ងាយអំពីបុណ្យ សូមលោកម្ចាស់ញ៉ាំងពួកជននោះ ឱ្យងាកចេញចាកបាបនោះផង ។ សូមលោកម្ចាស់ មើលស្រីទាំងនោះដែលទ្រទ្រង់

កម្រងផ្កា មានខ្លួនប្រដាប់ហើយ កំពុងមកតាមអាកាសផង ។ ពួកស្រីទាំងនោះ បានសម្រេច ( សម្បត្តិទិព្វ ) មានយសបរិវារ កំពុងសោយផលនៃការបូជាដោយកម្រងផ្កា សេចក្តីព្រឺរោមក៏កើតឡើងព្រោះឃើញហេតុជាអស្ចារ្យចម្លែកនោះ ។ ពួកអ្នកមានប្រាជ្ញាតែងនមស្ការថ្វាយបង្គំ សរសើរព្រះមហាមុនីនោះ ខ្ញុំនោះ លុះទៅអំពីបេតលោកនេះ ហើយបាននូវកំណើតជាមនុស្ស ជាអ្នកលែងធ្វេសប្រហែស និងធ្វើការបូជាចំពោះព្រះស្តូបរឿយៗ ដោយពិត ។

✳-**ឃ្លាំងទ្រព្យសម្បត្តិរបស់ព្រះបាទពិម្ពិសារ** នឹករលឹកដល់ព្រះបាទពិម្ពិសារ បរិច្ចាគទ្រព្យសាងវត្តវេឡុវ័ន មានការសាងព្រះគន្ធកុដិជាដើម និងទំនុកបម្រុងព្រះភិក្ខុសង្ឃ ។ ទិដ្ឋភាពទាំង-ឡាយ បញ្ឆាក់ពីអ្វីៗ ក្នុងលោករមែងប្រែប្រួល អស់ទៅ សូន្យទៅគួរខំសន្សំបុណ្យ អប់រំចិត្ត ។

✳-**កណ្តាលទីក្រុងចាស់** មើលឃើញច្បាស់ភ្នំជុំវិញ
នឹកព្រះខំបំពេញ ធម៌ដើរចេញចាកលោកា ។
ដើរតាមស្នាមព្រះបាទ ព្រះលោកនាថជាសាស្តា
ព្រមទាំងអរហន្តា ចាកលោកាចូលនិព្វាន ។



លោកនេះមិនគួរនៅ សុទ្ធសត្រូវតែងរុករាន
ព្រះនាំទៅនិព្វាន សត្វកោដិលានចេញចាកឋាន។
ឥឡូវទៅអស់ហើយ គឺនៅឡើយតែលំអាន
មិនយូរនឹងបាត់ដាន ផ្លូវនិព្វានគ្មានអ្នកដើរ ។
កាលនោះដែនមគធៈ សុទ្ធអរិយៈអ្នកប្រសើរ
ឥឡូវចេញដំណើរ ដើរទៅបាត់ស្ងាត់អស់ហើយ។

ដោយ **ម.ស.ទ.**

✳-មានរឿងប្រេតជាញាតិព្រះបាទពិម្ពិសារ ដែលជាហេតុនាំឱ្យព្រះសុគតសាស្តា សម្តែងនូវតិរោកុឌ្ឌសូត្រ ។

## តិរោកុឌ្ឌសូត្រ

( បិដកលេខ ៥៦ , ទំព័រ ៤-៦ )

**តិរោកុឌ្ឌេសុ តិដ្ឋន្តិ សន្ធិសិង្ឃាដកេសុ ច**
**ទ្វារពាហាសុ តិដ្ឋន្តិ អាគន្ត្វាន សកំ ឃរំ ។**

ពួកប្រេតទាំងឡាយមកហើយ កាន់ផ្ទះនៃញាតិដោយគិតថា ផ្ទះរបស់ខ្លួន រមែងឈរនៅជិតខាងក្រៅជញ្ជាំងទាំងឡាយខ្លះនាផ្លូវបែកជា ៤ និងផ្លូវបែកជា ៣ ទាំងឡាយខ្លះ ជិតទ្វារក្រុងនិងទ្វារផ្ទះទាំងឡាយខ្លះ ។

**បហុតេ  អន្នបានម្ហិ    ខជ្ជភោជ្ជេ  ឧបដ្ឋិតេ**

នាកាល បាយនិងទឹក និងបង្អែម និងចម្អាបដ៏ល្មមគ្រាន់ គឺពួកញាតិចូលទៅតាំងទុកហើយ

**ន  តេសំ  កោចិ  សរតិ    សត្តានំ  កម្មប្បច្ចយា** ។

ញាតិណាមួយមិននឹកដល់ប្រេតទាំងឡាយនោះ ព្រោះកម្មរបស់សត្វទាំងឡាយជាបច្ច័យ ។

**ឯវំ  ទទន្តិ  ញាតីនំ    យេ  ហោន្តិ  អនុកម្បកា**

**សុចឹ  បណីតំ  កាលេន    កប្បិយំ  បានភោជនំ**

ញាតិទាំងឡាយឯណា តែងអនុគ្រោះ ញាតិទាំងឡាយនោះ រមែងឧទ្ទិសឱ្យនូវទឹកនិងភោជនដ៏ហ្មត់ចត់ដ៏ប្រសើរ ជារបស់គួរតាមកាលដល់ញាតិទាំងឡាយ ជាអ្នកលះលោកនេះទៅហើយនោះយ៉ាងនេះថា

**ឥទំ  វោ  ញាតីនំ  ហោតុ  សុខិតា  ហោន្តុ  ញាតយោ** ។

ទាននេះ ចូលមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយចូរជាអ្នកដល់នូវសេចក្តីសុខ ។

**តេ  ច  តត្ថ  សមាគន្ត្វា    ញាតិបេតា  សមាគតា**

ក៏ប្រេតជាញាតិទាំងឡាយនោះ មកប្រជុំគ្នាហើយក្នុងស្ថានដែលឱ្យទាននោះ ជាអ្នកមកហើយដោយបំណងល្អ





**បហុតេ  អន្នបានម្ហិ    សក្កច្ចំ  អនុមោទរេ**

កាលបើថ្វាយបាយនិងទឹកដ៏ល្មមគ្រាន់ ក៏គប្បីអនុមោទនាដោយគោរពថា

**ចិរំ  ជីវន្តុ  នោ  ញាតី    យេសំ  ហេតុលភាមសេ**

យើងទាំងឡាយបានសម្បត្តិនេះ ព្រោះហេតុនៃញាតិទាំងឡាយឯណា សូមញាតិទាំងឡាយនោះរបស់យើងទាំងឡាយចូររស់នៅយឺនយូរ

**អម្ហាកញ្ច  កតា  បូជា** ក៏បូជាគឺញាតិទាំងឡាយ ធ្វើហើយ ដល់យើងទាំងឡាយ

**ទាយកា  ច  អនិប្ផលា** ឯទាយកគឺអ្នកឱ្យទាន ក៏មិនឥតផល ។

**ន  ហិ  តត្ថ  កសី  អត្ថិ** កសិកម្ម គឺការភ្ជួរស្រែចម្ការ ក៏មិនមានក្នុងភូមិនៃប្រេតនោះ

**គោរក្ខេត្ថ  ន  វិជ្ជតិ** គោរក្ខកម្ម គឺការរក្សាគោ ក៏មិនមានក្នុងភូមិនៃប្រេតនោះ

**វណិជ្ជា  តាទិសី  នត្ថិ** ពាណិជ្ជកម្ម គឺការជួញ ដែលជាហេតុបានសម្បត្តិដូច្នោះក៏មិនមាន

**ហិរញ្ញេន  កយាកយំ** មិនមានការលក់ទិញ ផ្លាស់ប្តូរ

ដោយប្រាក់ ។

**ឥតោ ទិន្នេន យាបេន្តិ បេតា កាលគតា តហឹ**

បុគ្គលទាំងឡាយធ្វើកាលកិរិយាទៅកើតជាប្រេត រមែងញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងប្រេតវិស័យនោះ ដោយផលទានដែលញាតិឱ្យហើយអំពីលោកនេះ

**ឧន្នតេ ឧទកំ វុដ្ឋំ យថា និន្នំ បវត្តតិ**
**ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ ។**

ទឹកធ្លាក់ចុះក្នុងទីទួល រមែងហូរទៅកាន់ទីទំនាបដូចម្តេច-មិញ ទានដែលបុគ្គលឱ្យហើយអំពីលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយដូច្នោះដែរ ។

**យថា វារិវហា បូរា បរិបូរេន្តិ សាគរំ**
**ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ ។**

ជ្រលងផ្លូវទឹកទាំងឡាយ មានទន្លេនិងស្ទឹងជាដើម រមែងញ៉ាំងសាគរឱ្យពេញព្រៀបដូចម្តេចមិញ ទានដែលបុគ្គលឱ្យហើយអំពីលោកនេះរមែងសម្រេចផលដល់ប្រេតទាំងឡាយដូច្នោះដែរ ។

**អទាសិ មេ អកាសិ មេ ញាតិមិត្តា សខា ច មេ**
**បេតានំ ទក្ខិណំ ទជ្ជា បុព្វេ កតមនុស្សរំ ។**

បុគ្គលកាលរលឹកឃើញនូវឧបការគុណ ដែលលោកធ្វើ



ទុកដល់ខ្លួនក្នុងកាលមុនថា អ្នកនេះបានឱ្យរបស់នេះដល់អញ អ្នកនេះបានធ្វើគុណនេះដល់អញ ជនទាំងឡាយនោះ ជាញាតិមិត្ត និងជាសម្លាញ់របស់អញដូច្នេះហើយ គួរឱ្យទក្ខិណាទានដើម្បីប្រេតទាំងឡាយ ។

**ន ហិ រុណ្ណំ វា សោកោ វា យាវញ្ញា បរិទេវនា**

ការយំឬសោកសៅ ឬការខ្សឹកខ្សួលដទៃៗ មិនមានប្រយោជន៍ឡើយ

**ន តំ បេតា នមត្ថាយ** ធ្វើដូច្នោះរកបានជាប្រយោជន៍ដល់ប្រេតទាំងឡាយគ្មាន

**ឯវំ តិដ្ឋន្តិ ញាតយោ** ញាតិទាំងឡាយរមែងស្ថិតនៅឥតបានដឹងបានឮយ៉ាងនេះ ។

**អយញ្ច ខោ ទក្ខិណា ទិន្នា** បើទក្ខិណាទានដែលបុគ្គលបានឱ្យហើយនេះឯង

**សង្ឃម្ហិ សុបតិដ្ឋិតា** ជាទានតម្កល់នៅល្អហើយក្នុងសង្ឃ

**ទីឃរត្តំ ហិតាយស្ស ឋានសោ ឧបកប្បតិ ។**

ទក្ខិណាទាននោះ ទើបចូលទៅសម្រេចតាមស្ថាន ដើម្បីជាប្រយោជន៍ដល់ប្រេតនោះ អស់កាលជាអង្វែង ។

**សោ ញាតិធម្មោ ច អយំ និទស្សិតោ** ក៏ញាតិធម៌

នោះ គឺអ្នកបានសម្តែងជាបែបយ៉ាងហើយ

**បេតាន បូជា ច កតា ឧឡារា** ការបូជាដ៏ថ្លៃថ្លា ចំពោះដល់ប្រេតទាំងឡាយ គឺអ្នកបានធ្វើហើយ

**ពលញ្ច ភិក្ខូនមនុប្បទិន្នំ** កម្លាំងកាយនៃភិក្ខុទាំងឡាយ ឈ្មោះថា គឺអ្នកបានបំពេញឱ្យហើយ

**តុម្ហេហិ បុញ្ញំ បសុតំ អនប្បកន្តិ** បុណ្យ គឺអ្នកសន្សំទុកហើយ មិនមែនតិចដូច្នេះ ។ (លំនាំសូត្រតាមភាណវារៈ)

**(តិរោកុឌ្ឌសូត្រចប់)**

*-**នាលន្ទា** ជាស្រុកធំមួយក្នុងដែនមគធៈ ជាប់ពីក្រុងរាជគ្រឹះទៅទិសខាងជើង មានមហាវិទ្យាល័យនាលន្ទា មានស្រុកភូមិកំណើតព្រះសារីបុត្តនៅឧបតិស្សគ្រាម និងស្រុកភូមិកំណើតព្រះមហាមោគ្គល្លាននៅកោលិតគ្រាម ។ ភូមិកំណើតនៃព្រះអគ្គសាវ័កទាំងពីរនៅជាប់គ្នាក្នុងស្រុកនាលន្ទា ហើយត្រកូលអ្នកទាំងពីរនេះ ជាសម្លាញ់នឹងគ្នាត១ មក ៧ ជួរ ឬ ៧ ជំនាន់ហើយ គឺតាំងពីជីដូនជីតារហូតមកដល់ម៉ែឪ ទីបំផុតព្រះអគ្គសាវ័កទាំងពីរនេះឯង ។





នៅក្នុងមហាវិទ្យាល័យនាលន្ទា មានស្តូបព្រះសារីបុត្តដែលសាងឡើងដោយព្រះបាទធម្មាសោក ព្រោះកាលនោះ ទីនេះឯងជាវត្តដែលបាវារិកសេដ្ឋី បានវេរថ្វាយសង្ឃ មានឈ្មោះថា បាវារិការាម (មិនមែនបាវារិការាមនៅកោសម្ពីទេ) ។ បានឮមកថាការសាងមហាវិទ្យាល័យថ្នាក់ពិភពលោក នៅទីនេះ ព្រោះប្រារព្ធព្រះសារីបុត្ត ដែលជាភិក្ខុកំពូលខាងមានបញ្ញា លោកកើតនៅស្រុកនាលន្ទានេះឯង ។

## គាថានៃព្រះសារីបុត្ត

(បិដកលេខ ៥៧ , ទំព័រ ៨៨-៩៣)

គាថាខ្លះ ព្រះថេរៈបានសម្តែងទុកហើយ គាថាខ្លះ ព្រះដ៏មានព្រះភាគទ្រង់ប្រារព្ធព្រះថេរៈហើយត្រាស់សម្តែង ឯគាថាចុងក្រោយជាគាថារបស់ព្រះថេរៈតែប៉ុណ្ណោះ ព្រោះព្រះថេរៈបានសម្តែងទុក ដើម្បីប្រកាសនូវការប្រព្រឹត្តរបស់លោក ។

**៥ គាថា** ព្រះថេរៈប្រទានឱវាទដល់ភិក្ខុទាំងឡាយ ដែលមានសេចក្តីប្រាថ្នាច្រើន មិនសន្តោស ។

បុគ្គលណា ជាអ្នកប្រព្រឹត្តសមគួរ ជាអ្នកស្ងប់សមគួរ មាន

ស្មារតី ជាអ្នកមិនធ្វេសប្រហែស ក្នុងការត្រិះរិះ និងការប្រព្រឹត្ត សមគួរ ត្រេកអរដោយភាវនាក្នុងសន្ដាន មានចិត្តតាំងមាំ ជាបុគ្គលម្នាក់ឯង មានសេចក្ដីសន្ដោស អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គល នោះថាជាភិក្ខុ ។

ភិក្ខុកាលបរិភោគនូវអាហារស្រស់ ឬក្រៀម មិនគប្បីឱ្យឆ្អែតជ្រុលទេ គប្បីជាអ្នកមានពោះធូរ មានអាហារដ៏ល្មម មានស្មារតីវៀរចេញ ។

ភិក្ខុឈប់បរិភោគ ៤ ឬ៥ពំនូត (ក្នុងកាលជិតឆ្អែត) ហើយគប្បីឆាន់ទឹក នេះជាការល្មមដល់កិរិយានៅជាសុខ នៃភិក្ខុអ្នកមានចិត្តស្ទុងទៅរក ( ព្រះនិព្វាន ) ។

ភិក្ខុស្លៀកដណ្ដប់ នូវចីវរជាកប្បិយៈ ប្រយោជន៍ ( ត្រឹមតែការពារត្រជាក់ជាដើម ) នេះ ជាការគួរដល់កិរិយានៅជាសុខ នៃភិក្ខុអ្នកមានចិត្តស្ទុងទៅរក ( ព្រះនិព្វាន ) ។

កាលភិក្ខុអង្គុយដោយភ្នែន ភ្លៀងមិនស្រក់ត្រូវត្រង់ជង្គង់ទាំងពីរ នេះជាការគួរដល់កិរិយានៅជាសុខ នៃភិក្ខុអ្នកមានចិត្តស្ទុងទៅរក ( ព្រះនិព្វាន ) ។

**១ គាថា** សម្ដែងដល់សេចក្ដីសន្ដោស ដោយការត្រេកអរក្នុងភាវនា សំដៅយកវេទនាជាអារម្មណ៍ ។



បុគ្គលណាបានឃើញសុខ ថាជាទុក្ខ បានឃើញទុក្ខ ថាជាគ្រឿងចាក់ដោត ដូចកូនសរ ការជាប់ជំពាក់មិនមានក្នុងចន្លោះនៃសុខនិងទុក្ខទាំងពីរ បុគ្គលនោះ គប្បីជាប់ក្នុងលោកដូចម្ដេច គប្បីមានដោយកិលេសដូចម្ដេចបាន ។

**៤ គាថា** ព្រះថេរៈតិះដៀលបុគ្គលដែលបដិបត្តិខុស និងសរសើរបុគ្គលដែលបដិបត្តិត្រូវ ។

បុគ្គលមានសេចក្ដីប្រាថ្នាអាក្រក់ ជាអ្នកខ្ជិលច្រអូស មានការព្យាយាមថោកទាប ជាអ្នករៀនសូត្រតិច មិនអើពើ ( ចំពោះធម៌និងវិន័យ ) សូមកុំមានក្នុងសំណាក់ខ្ញុំ ក្នុងកាលណាៗឡើយ ប្រយោជន៍អ្វីដោយឱវាទក្នុងលោក គប្បីមាន ( ដល់បុគ្គលនោះ ) ដោយបការៈដូចម្ដេច ។

មួយទៀត បុគ្គលអ្នកចេះដឹងច្រើន មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស តាំងមាំក្នុងសីល ប្រកបរឿយៗនូវចេតោសមថៈ សូមឋិតនៅសូម្បីលើក្បាល ។

បុគ្គលណា មានចិត្តប្រកបរឿយៗនូវធម៌ជាគ្រឿងយឺតយូរ ត្រេកអរចំពោះធម៌ជាគ្រឿងយឺតយូរ បុគ្គលនោះឈ្មោះថា ឃ្លាតចាកព្រះនិព្វាន ជាទីក្សេមចាកយោគៈដ៏ប្រសើរ ។

បុគ្គលណា លះបង់នូវធម៌ជាគ្រឿងយឺតយូរ ត្រេកអរក្នុងធម៌ជាផ្លូវមិនយឺតយូរ បុគ្គលនោះ ឈ្មោះថាត្រេកអរនឹងព្រះនិព្វានជាទីក្សេមចាកយោគៈដ៏ប្រសើរ ។

**២ គាថា** ព្រះថេរៈឃើញព្រះរេវតៈប្អូនប្រុសរបស់លោកនៅក្នុងព្រៃជ្រៅ សុទ្ធតែបន្លា ហើយបានពោលសរសើរ ។

ព្រះអរហន្តទាំងឡាយនៅក្នុងទីណា ទោះបីស្រុក ឬព្រៃ ទោះបីទំនាប ឬទួល ទីនោះឯង ជាទីគួរត្រេកអរ ។

ជនអ្នក ( ស្វែងរកកាម ) រមែងមិនត្រេកអរក្នុងព្រៃជាទីគួរត្រេកអរទេ ពួកបុគ្គលអ្នកប្រាសចាករាគៈ ទើបត្រេកអរ ព្រោះពួកលោកទាំងនោះ មិនមែនជាអ្នកស្វែងរកកាម ។

**២ គាថា** ព្រះថេរៈអាស្រ័យសេចក្ដីអនុគ្រោះ បានឱ្យរាធ-ព្រាហ្មណ៍បព្វជ្ជាឧបសម្បទា ហើយនិមន្តតាមក្រោយ ថ្ងៃមួយព្រះថេរៈបានប្រទានឱវាទ ព្រមដោយការសរសើរព្រះរាធៈថាជាអ្នកប្រដៅបានដោយងាយ ។

បុគ្គលឃើញអ្នកប្រាជ្ញណា ជាអ្នកពោលសង្កត់សង្កិន ជាអ្នកបង្ហាញទោស ដូចគេបង្ហាញនូវកំណប់ទ្រព្យ គួរគប់រកអ្នកប្រាជ្ញមានសភាពដូច្នោះ ។



កាលបើបុគ្គល គប់រកអ្នកប្រាជ្ញប្រាកដដូច្នោះ សេចក្ដីប្រសើររមែងមាន សេចក្ដីអាក្រក់ពុំមានទេ ។

**១ គាថា** ព្រះថេរៈប្រារព្ធភិក្ខុពីរអង្គនៅវត្តកីដាគីរីជនបទជាភិក្ខុទ្រុស្តត្រកូល ហើយមិនអើពើនឹងឱវាទ ។

បុគ្គលណា ទូន្មានប្រៀនប្រដៅ ហាមឃាត់ (គេ) ចាកអសប្បុរិសធម៌ បុគ្គលនោះ រមែងជាទីស្រឡាញ់របស់ពួកសប្បុរស តែមិនជាទីស្រឡាញ់របស់ពួកអសប្បុរសទេ ។

**៣ គាថា** ប្រារព្ធដល់ការសម្រេចធម៌កំពូលរបស់លោក គឺការសម្រេចនូវព្រះអរហត្តព្រមដោយគុណវិសេសផ្សេង១ ។

ព្រះពុទ្ធ មានព្រះភាគ មានចក្ខុ បានសម្ដែងធម៌ដល់បុគ្គលដទៃ នាកាលធម៌ដែលព្រះអង្គសម្ដែង ខ្ញុំមានសេចក្ដីត្រូវការផ្ទង់សោតប្បសាទ ។

ការស្ដាប់របស់ខ្ញុំនោះ មិនឥតអំពើទេ (ព្រោះ) ខ្ញុំជាអ្នកមិនមានអាសវៈ មានចិត្តរួចស្រឡះហើយ ខ្ញុំមិនមានការតាំងចិត្តចំពោះបុព្វេនិវាសានុស្សតិវិជ្ជាឬទិព្វចក្ខុវិជ្ជាឡើយ ។

ខ្ញុំមិនមានការតាំងចិត្តចំពោះចេតោបរិយវិជ្ជា ឥទ្ធិវិធវិជ្ជាចុតូបបាតវិជ្ជានិងសេចក្ដីបរិសុទ្ធនៃសោតធាតុឡើយ (គុណវិសេស

ទាំងនេះ បានកើតឡើងព្រម នៅពេលសម្រេចព្រះអរហត្ត ) ។

**៣ គាថា** ព្រះថេរៈសម្តែងដល់ការមិនញាប់ញ័ររបស់លោក នៅក្នុងវិហារឈ្មោះកបោតកន្ទរៈ ក្នុងពេលដែលយក្សវាយប្រហារលោក ។

ថេរៈឈ្មោះឧបតិស្សៈ ខ្ពង់ខ្ពស់ដោយប្រាជ្ញា គោរពហើយថ្មីៗ ដណ្តប់សង្ឃាដី អាស្រ័យនៅក្រោមម្លប់ឈើ ចម្រើនឈាន ។

សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ ចូលកាន់ឈាន មិនមានវិតក្កៈ ប្រកបដោយតុណ្ហីភាពដ៏ប្រសើរ ក្នុងខណៈនោះឯង ។

ភ្នំថ្ម មិនកម្រើក ឋិតនៅនឹងថ្កល់យ៉ាងណា ភិក្ខុ ព្រោះអស់ទៅនៃមោហៈ ក៏មិនញាប់ញ័រដូចភ្នំយ៉ាងនោះដែរ ។

**១ គាថា** កាលជាយស្បង់របស់ព្រះថេរៈ ធ្លាក់ចុះ ដោយមិនបានជ្រាប សាមណេរមួយអង្គបានតឿនថា លោកម្ចាស់គួរស្លៀកស្បង់ឱ្យជាបរិមណ្ឌល ។ ព្រះថេរៈកាលដែលបានស្តាប់ពាក្យនោះហើយ ក៏ទទួលដោយសេចក្តីគោរពថា លោកបានពោលល្អហើយ ។ ក្នុងខណៈនោះឯង ព្រះថេរៈបានចេញទៅបន្តិច ហើយទ្រង់ស្បង់ឱ្យជាបរិមណ្ឌល ។ កាលដែលនឹងសម្តែងថា សូម្បីប៉ុណ្ណេះ ក៏រាប់ថាជាទោសរបស់មនុស្សដូចជាយើងនេះដែរ ទើប



ព្រះថេរៈពោលនូវគាថា ។

បុគ្គលអ្នកមិនមានទីទួលគឺកិលេស ស្វែងរកនូវធម៌ដ៏ស្អាតអស់កាលជានិច្ច សូម្បីបាបប្រមាណប៉ុនចុងរោមកន្ទុយសត្វ រមែងប្រាកដដូច ( ព្រះចន្ទ ) ដែលផុតចាកពពក ។

**៤ គាថាភន្លះ** ព្រះថេរៈសម្តែងថាលោកមានការគិតស្មើគ្នាចំពោះសេចក្តីស្លាប់ និងការរស់នៅតទៅទៀត ព្រមទាំងសម្តែងធម៌ដល់ជនដទៃផង ។

ខ្ញុំមិនត្រេកអរនឹងសេចក្តីស្លាប់ មិនត្រេកអរនឹងការរស់នៅខ្ញុំជាបុគ្គលដឹងខ្លួន មានស្មារតីខ្ជាប់ខ្ជួន ទម្លាយចោលនូវរាងកាយនេះ ។

ខ្ញុំមិនត្រេកអរនឹងសេចក្តីស្លាប់ មិនត្រេកអរនឹងការរស់នៅខ្ញុំរង់ចាំតែពេលស្លាប់ ដូចអ្នកស៊ីឈ្នួលទន្ទឹងតែការអស់ទៅនៃថ្ងៃ ។

មរណៈនេះឯង រមែងមានក្នុងវ័យទាំងពីរ មរណៈមិនមែនមានតែក្នុងវ័យចាស់ ឬវ័យក្មេងទេ អ្នកទាំងឡាយ ចូរប្រតិបត្តិអ្នកទាំងឡាយចូរកុំវិនាស កុំឱ្យខណៈប្រព្រឹត្តកន្លង ។

អ្នកទាំងឡាយ ចូរគ្រប់គ្រងខ្លួន ឱ្យដូចជានគរត្រង់ទីប្រទល់ដែន ដែលគេគ្រប់គ្រង ទាំងខាងក្នុង ទាំងខាងក្រៅ កុំឱ្យខណៈ

ប្រព្រឹត្តកន្លង ។

ព្រោះថា ពួកបុគ្គលដែលមានខណៈកន្លងហួសហើយ រមែងសោកស្តាយដេរដាស ក្នុងនរក ។

**៣ គាថា** ព្រះថេរៈប្រកាសគុណរបស់ព្រះមហាកោដ្ឋិតៈឯតទគ្គៈខាងបដិសម្ភិទា ។

បុគ្គលអ្នកស្ងប់ វៀរចាកបាប ពោលពាក្យដោយបញ្ញា ជាបុគ្គលមិនរាយមាយ រមែងកម្ចាត់បង់នូវធម៌ដ៏លាមកបាន ដូចខ្យល់កម្ចាត់បង់នូវស្លឹកឈើ ។

បុគ្គលអ្នកស្ងប់ វៀរចាកបាប ពោលពាក្យដោយបញ្ញា ជាបុគ្គលមិនរាយមាយ រមែងដកភើច នូវពួកធម៌ដ៏លាមកចេញបាន ដូចខ្យល់បក់ផ្តាច់នូវស្លឹកឈើ ។

បុគ្គលអ្នកស្ងប់ មិនមានសេចក្តីក្រវល់ក្រវាយ មានចិត្តថ្លាមិនល្អក់ មានកល្យាណសីល មានប្រាជ្ញាជាគ្រឿងទម្លាយបង់នូវកិលេស គប្បីធ្វើនូវទីបំផុតនៃទុក្ខបាន ។

**១ គាថា** ប្រារព្ធពួកវជ្ជីបុត្រ ជាអ្នកជឿពាក្យភិក្ខុទេវទត្តពេញចិត្តក្នុងទិដ្ឋិរបស់ភិក្ខុទេវទត្តនោះ ។

បុគ្គលមិនគប្បីស្និទ្ធស្នាលចំពោះបុថុជ្ជនពួកខ្លះ ទាំងគ្រហស្ថ



ទាំងបព្វជិត ព្រោះថា ពួកជន សូម្បីជាបុគ្គលល្អហើយ បែរទៅជាមិនល្អវិញក៏មាន ( ព្រោះសេពគប់បុគ្គលមិនល្អ) ជាបុគ្គលមិនល្អហើយ បែរទៅជាល្អវិញ ក៏មាន (ព្រោះសេពគប់បុគ្គលល្អ ) ។

**៣ គាថា** ប្រារព្ធបុគ្គលមិនល្អដោយនីវរណៈ ចំណែកបុគ្គលល្អដោយប្រាសចាកឧបក្កិលេសក្នុងសន្តាន ។

កាមច្ឆន្ទៈ១ ព្យាបាទៈ១ ថីនមិទ្ធៈ១ ឧទ្ធច្ចៈ១ វិចិកិច្ឆា១ ទាំង៥នោះ ជាគ្រឿងសៅហ្មងចិត្ត របស់ភិក្ខុ ។

ភិក្ខុណា កាលគេធ្វើសក្ការៈ ឬមិនធ្វើសក្ការៈទាំងពីរ (មិនត្រេកអរ មិនទោមនស្ស ) សមាធិ របស់ភិក្ខុអ្នកនៅដោយសេចក្តីមិនប្រមាទនោះ រមែងមិនញាប់ញ័រ ។

អ្នកប្រាជ្ញទាំងឡាយ សរសើរ នូវភិក្ខុអ្នកមានឈាន មានព្យាយាមទៀងទាត់ មានការឃើញច្បាស់ដោយសុខុមទិដ្ឋិ ត្រេកអរក្នុងធម៌ជាទីអស់ទៅនៃឧបាទាននោះថា ជាសប្បុរស ។

**៣ គាថា** គឺសម្តែងដល់ព្រះបរមសាស្តា និងព្រះថេរៈខ្លួនលោកជាឧទាហរណ៍ ដែលជាបុគ្គលដ៏ខ្ពង់ខ្ពស់បំផុត ។

មហាសមុទ្រ ប្រឹថពី ភ្នំ និងខ្យល់ មិនគួរឧបមា នឹងវិមុត្តិដ៏ប្រសើរ របស់ព្រះសាស្តាទេ ។

ព្រះថេរៈអ្នកញ៉ាំងចក្ក គឺធម៌ឱ្យប្រព្រឹត្តទៅតាមព្រះសាស្តា លោកមានប្រាជ្ញាច្រើន មានចិត្តខ្ជាប់ខ្ជួន ស្មើដោយដី ទឹក ភ្លើង មិនត្រេកអរ មិនប្រទូស្ត ។

ព្រះថេរៈ សម្រេចនូវបញ្ញាបារមី មានប្រាជ្ញាច្រើន គឺជាមហាមុនី ជាបុគ្គលមិនល្ងង់ខ្លៅ តែមានសភាពដូចជាល្ងង់ខ្លៅ (ព្រោះព្រះថេរៈប្រាថ្នាតិចក្រៃលែង) មានចិត្តដ៏ត្រជាក់គ្រប់កាល។

**គាថាចុងក្រោយ** ព្រះថេរៈប្រកាសដល់កិច្ចដែលខ្លួនបានធ្វើស្រេចហើយ ព្រមទាំងប្រទានឱវាទដល់ភិក្ខុទាំងឡាយ ដែលមកប្រជុំគ្នាក្នុងវេលាដែលលោកនឹងបរិនិព្វាន ។

ព្រះសាស្តាខ្ញុំបានបម្រើហើយ ព្រះពុទ្ធសាសនាខ្ញុំបានធ្វើហើយ ភារៈធ្ងន់ខ្ញុំបានដាក់ចុះហើយ តណ្ហាជាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំក៏បានដកចេញហើយ ។

អ្នកទាំងឡាយ ចូរញ៉ាំងសេចក្តីមិនប្រមាទឱ្យបរិបូណ៌ នេះជាពាក្យប្រៀនប្រដៅរបស់ខ្ញុំ ឥឡូវនេះ ខ្ញុំនឹងបរិនិព្វាន ខ្ញុំជាបុគ្គលផុតស្រឡះ ចាកកិលេសកាមទាំងអស់ ។

**( ចប់ សារីបុត្តត្ថេរគាថា )**



## គាថាព្រះមហាមោគ្គល្លាន

(បិដកលេខ ៥៧ , ទំព័រ ១២០-១២៩)

**៤ គាថា** ជាឱវាទដល់ភិក្ខុទាំងឡាយ ។

ពួកយើងជាអ្នកប្រព្រឹត្តនៅក្នុងព្រៃ ប្រព្រឹត្តបិណ្ឌបាត ត្រេក-អរក្នុងវត្ថុដែលមាននៅក្នុងបាត្រ ដោយការស្វែងរក ជាអ្នកមានចិត្តតាំងមាំល្អខាងក្នុង ចូរទម្លាយនូវសេនារបស់មច្ចុ (កិលេស) ។

ពួកយើងជាអ្នកប្រព្រឹត្តនៅក្នុងព្រៃ ប្រព្រឹត្តបិណ្ឌបាត ត្រេក-អរក្នុងវត្ថុដែលមាននៅក្នុងបាត្រ ដោយការស្វែងរក ចូរកម្ចាត់បង់នូវសេនារបស់មច្ចុ ដូចដំរីកម្ចាត់កម្ចាយនូវផ្ទះបបុស ។

ពួកយើងជាអ្នកប្រព្រឹត្តនៅក្រោមម្លប់ឈើ មានព្យាយាមប្រព្រឹត្តទៅរឿយៗ ត្រេកអរក្នុងវត្ថុដែលមាននៅក្នុងបាត្រ ដោយការស្វែងរក ជាអ្នកមានចិត្តតាំងមាំល្អខាងក្នុង ចូរទម្លាយនូវសេនារបស់មច្ចុ ។

ពួកយើងជាអ្នកប្រព្រឹត្តនៅក្រោមម្លប់ឈើ មានព្យាយាមប្រព្រឹត្តទៅរឿយៗ ត្រេកអរក្នុងវត្ថុដែលមាននៅក្នុងបាត្រ ដោយការស្វែងរក ចូរកម្ចាត់បង់នូវសេនារបស់មច្ចុ ដូចដំរីកម្ចាត់បង់នូវផ្ទះបបុស ។

**៤ គាថា** ជាឱវាទដល់នាងស្រីពេស្យាចារ ដែលចូលមកជិត ហើយលួងលោមព្រះថេរៈ ។

(នៃស្ត្រីផ្កាមាស) នាងរាប់អានខ្លួនអ្នកដទៃ ដែលជាខ្ទមគឺរាងឆ្អឹងបែបចម្លឹង១ មានសាច់និងសរសៃរួបរឹតហើយ ពេញ (ដោយគ្រឿងមិនស្អាត) មានក្លិនស្អុយ ។

ម្នាលនាងមានបូសព្វដ៏ទ្រូងដូចបិសាច ក្នុងកាយរបស់នាងដែលពេញដោយលាមក ស្រោបដោយស្បែក (នេះ) មានទ្វារសម្រាប់បង្ហូរចេញ ៩ តែងហៀរហូរគ្រប់ពេល ។

ភិក្ខុគប្បីវៀរបង់នូវសរីរៈនាង ដែលមានមុខហូរ ៩ មានក្លិនអាក្រក់ បុគ្គលអ្នកចូលចិត្តស្អាត ដើរវាងលាមក យ៉ាងណាមិញ ភិក្ខុចៀសវាងនូវសរីរៈរបស់នាង ក៏យ៉ាងនោះដែរ ។

អាត្មាដឹងនូវសរីរៈនាងយ៉ាងណា បើមហាជនដឹងនូវសរីរៈនោះយ៉ាងនោះ គប្បីចៀសវាងសរីរៈនាងអំពីចម្ងាយ ដូចគេចៀសវាងកន្លែងលាមកក្នុងកាលដែលភ្លៀងបង្អុរចុះ ។

**១ គាថា** នាងស្រីពេស្យាចារ មានការអៀនខ្មាសឱនមុខចុះ ធ្វើនូវការគោរពចំពោះព្រះថេរៈ ព្រោះបានស្ដាប់ព្រះថេរៈប្រកាសទោសនៃរាងកាយយ៉ាងនេះហើយ បានឈរនមស្ការព្រះថេរៈ ។





បពិត្រសមណៈលោកមានថេរវាចាយ៉ាងណា បពិត្រលោកអ្នកមានព្យាយាមច្រើន ហេតុនុ៎ះក៏យ៉ាងហ្នឹងមែនហើយ តែគង់មានជនពួកខ្លះ លិចនៅក្នុងសរីរៈនុ៎ះដែរ ដូចគោចាស់លិចនៅក្នុងភក់ ។

**៣ គាថា** ព្រះថេរៈសម្ដែងដល់នាងពេស្យាចារទៀត ។

នរណាសម្គាល់ដើម្បីជ្រលក់នូវអាកាស ដោយរមៀត ឬដោយគ្រឿងជ្រលក់ឯទៀត ការងាររបស់បុគ្គលនោះ នាំឱ្យតែកើតសេចក្ដីលំបាកទេ ។

ចិត្តដែលតម្កល់នៅល្អក្នុងសន្តាននោះ ក៏ស្មើគ្នានឹងអាកាស នាងកុំត្រេកអរ (នឹងយើង) ដោយចិត្តលាមក ដូចសត្វស្លាប (មមាច) ត្រេកអរនឹងគំនរភ្លើងឡើយ ។

នាងចូរមើលរាងកាយដែលធ្វើឱ្យវិចិត្រហើយ ជាទីប្រជុំនៃដំបៅ ដែលឆ្អឹង ៣០០ កំណាត់ផ្គុំគ្នាហើយ ឈឺជានិច្ច ដែលពួកជនពាលប្រាថ្នាដោយច្រើន សេចក្ដីទៀងទាត់និងការមាំមួនរបស់រាងកាយនេះ មិនមានឡើយ ។

**៤ គាថា** ព្រះថេរៈពោលប្រារព្ធអំពីការបរិនិព្វានរបស់ព្រះសារីបុត្ត។

កាលព្រះសារីបុត្ត បរិបូណ៌ដោយអាការដ៏ច្រើន បរិនិព្វាន ហើយ សេចក្ដីស្ញប់ស្ញែង សេចក្ដីព្រឺរោម ក៏កើតមានឡើងថា

ឱហ្ន៎ សង្ខារទាំងឡាយ មិនទៀងទេ មានការកើតឡើងនិង វិនាសទៅវិញជាធម្មតា កើតឡើងហើយតែងរលត់វិញ ការរម្ងាប់ នូវសង្ខារទាំងនោះ ទើបនាំមកនូវសុខ ។

ពួកព្រះយោគីណា ពិចារណាឃើញច្បាស់នូវខន្ធទាំង៥ ថា ជារបស់ដទៃ ទាំងមិនមែនជារបស់ខ្លួន ពួកព្រះយោគីនោះ តែង ចាក់ធ្លុះនូវធម៌ដ៏សុខុមបាន ដូចបុគ្គលបាញ់ចុងរោមទ្រាយ ដោយ ព្រួញ ។

មួយទៀត ពួកព្រះយោគីណា ពិចារណាឃើញច្បាស់ នូវ សង្ខារទាំងឡាយ ថាជារបស់ដទៃ ទាំងមិនមែនជារបស់ខ្លួន ពួក ព្រះយោគីនោះ ឈ្មោះថា បានចាក់ធ្លុះនូវធម៌ដ៏ល្អិត ដូចបុគ្គល បាញ់ចុងរោមទ្រាយ ដោយព្រួញ ។

**២ គាថា** ព្រះថេរៈសម្ដែងប្រារព្ធចំពោះព្រះតិស្សត្ថេរ និង ព្រះវឌ្ឍមានត្ថេរ ។

ភិក្ខុអ្នកមានស្មារតីវៀរចាក គប្បីលះបង់នូវកាមរាគៈ ដូចជា គេដកនូវលំពែង ពុំនោះសោត ដូចជាគេលត់ភ្លើងកំពុងឆេះព្វដ៏ ក្បាល ។





ភិក្ខុអ្នកមានស្មារតីវៀរចាក គប្បីលះបង់នូវភវរាគៈ ដូចជា គេដកនូវលំពែង ពុំនោះសោត ដូចជាគេលត់ភ្លើងកំពុងឆេះព្វដ៏ ក្បាល ។

**១ គាថា** ប្រារព្ធបាសាទកម្បនសូត្រ ។

ខ្ញុំ លុះព្រះសាស្ដាចារ្យ ព្រះអង្គមានព្រះកាយអប់រំហើយ ព្រះអង្គទ្រទ្រង់ នូវសរីរៈជាទីបំផុត ទ្រង់បានដាស់តឿនហើយ ក៏ ញ៉ាំងមិគារមាតុប្រាសាទ ឱ្យកក្រើកបាន ដោយចុងមេជើង ។

**២ គាថា** ប្រារព្ធភិក្ខុកំលោះ ឈ្មោះវេទៈ ជាអ្នកមាន ព្យាយាមថោកថយ ។

បុគ្គលប្រារព្ធការងារណាមួយធូរ១ ឬដោយកម្លាំងព្យាយាម ស្ដួចស្ដើង មិនងាយបានដល់ព្រះនិព្វាន ដែលជាគ្រឿងរួចចាក គន្ថធម៌ទាំងពួងទេ ។

ភិក្ខុកំលោះនេះក្ដី បុរសដ៏ឧត្តមនេះក្ដី បានឈ្នះនូវមារព្រម ទាំងសេនានៃមារ ហើយទ្រទ្រង់នូវរាងកាយ ជាទីបំផុតបាន ។

**២ គាថា** ព្រះថេរៈប្រារព្ធនូវវិវេកធម៌របស់លោកផ្ទាល់ ។

ផ្នែកបន្ទោរទាំងឡាយ រមែងធ្លាក់ក្នុងចន្លោះនៃភ្នំឈ្មោះវេភារៈ និងភ្នំឈ្មោះបណ្ឌវៈ ឯបុត្រនៃព្រះពុទ្ធជាតាទិបុគ្គល រកបុគ្គលប្រៀបស្មើមិនបាន លោកនៅក្នុងចន្លោះភ្នំ រមែងដុត ( នូវធមំ ជាសត្រូវ ) ។

មហាព្រហ្មថ្វាយបង្គំហើយ នូវមុនីអ្នកស្ងប់ស្ងាត់ ត្រេកអរនឹងការស្ងប់រម្ងាប់នៅក្នុងសេនាសនៈដ៏ស្ងាត់ ជាទាយាទរបស់ព្រះពុទ្ធដ៏ប្រសើរ ។

**៥ គាថា** ព្រះថេរៈឃើញព្រះមហាកស្សបត្ថេរ ចូលទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត ហើយឃើញព្រាហ្មណ៍ដែលជាបុគ្គលមិច្ឆាទិដ្ឋិ ត្រូវជាក្មួយរបស់ព្រះសារីបុត្ត ឈរមើលព្រះមហាកស្សបត្ថេរ ដោយគិតឃើញខុសថា យើងឃើញមនុស្សកាឡកណ្ណី ។ ដើម្បីនឹងកម្ចាត់បង់នូវចិត្តប្រទូស្តដ៏អាក្រក់របស់ព្រាហ្មណ៍ និងដោយសេចក្តីអនុគ្រោះ កុំឱ្យព្រាហ្មណ៍នេះដល់នូវសេចក្តីវិនាសដូច្នេះ ទើបប្រទានឱវាទហើយនាំព្រាហ្មណ៍ឱ្យទៅថ្វាយបង្គំព្រះមហាកស្សបត្ថេរ ។

ម្នាលព្រាហ្មណ៍ អ្នកចូរថ្វាយបង្គំព្រះកស្សបៈ ជាមុនី អ្នកស្ងប់ស្ងាត់ ត្រេកអរនឹងការស្ងប់ស្ងាត់ នៅក្នុងសេនាសនៈដ៏ស្ងាត់



ជាទាយាទរបស់ព្រះពុទ្ធដ៏ប្រសើរចុះ ។

បើបុគ្គលណា ទៅយកកំណើតជាព្រាហ្មណ៍គ្រប់ៗ ជាតិ អស់ ១០០ ជាតិ បុគ្គលនោះ ឈ្មោះថាព្រាហ្មណ៍ បរិបូណ៌ដោយវេទ ក្នុងពួកមនុស្សរឿយៗ ។ តែបើទុកជាព្រាហ្មណ៍នោះ ជាអ្នកចេះចាំមន្ត ដល់នូវត្រើយ នៃវេទទាំង ៣ ក៏ដោយចុះ ក៏នៅតែមិនដល់នូវមួយចំណិតនៃ ចំណែក ដែលគេចែក ១៦ ៗ ដង នៃការថ្វាយបង្គំចំពោះព្រះមហាកស្សបត្ថេរនុ៎ះឡើយ ។

ភិក្ខុណាបានវិមោក្ខ ៨ ក្នុងវេលាមុនភត្ត ជាអនុលោមបដិលោម លុះចេញចាកនិរោធសមាបត្តិនោះហើយ ទើបទៅ ដើម្បីបិណ្ឌបាត ។ ម្នាលព្រាហ្មណ៍ អ្នកចូរត្រេកអរនឹងភិក្ខុបែបនោះ អ្នកកុំគាស់រំលើងខ្លួនឡើយ អ្នកចូរធ្វើចិត្តឱ្យត្រេកអរចំពោះព្រះអរហន្ត ជាតាទិបុគ្គល ចូរប្រណម្យអញ្ជលី ថ្វាយបង្គំឱ្យឆាប់ កុំឱ្យក្បាលអ្នកបែកជា ៧ ភាគឡើយ ។

**២ គាថា** ព្រះថេរៈប្រារព្ធតុច្ឆបោដ្ឋិលភិក្ខុ ។

បោដ្ឋិលភិក្ខុនោះ ត្រូវចំណង គឺសង្សារវដ្តរួបរឹតហើយ មិនបានឃើញនូវព្រះសទ្ធម្ម ស្ទុះទៅរកមិច្ឆាជីវៈ ជាផ្លូវដែលមិនគួរទៅ ជាផ្លូវវៀច ផ្លូវអាក្រក់ ។

តុច្ឆបោដ្ឋិលភិក្ខុងប់ចុះក្នុងសង្ខារ (ដែលច្រឡំដោយកិលេស ជាគ្រឿងមិនស្អាត ) លិចចុះក្នុងលាភ និងសក្ការៈ ដូចជាដង្កូវ ប្រឡាក់ដោយលាមក ។

**២ គាថា** ព្រះថេរៈសរសើរព្រះសារីបុត្ត ។

អ្នកចូរមើលព្រះសារីបុត្ត ដ៏មានអាយុនេះ លោកជាអ្នក ឃើញដោយប្រពៃ ជាអ្នកផុតចាកចំណែកទាំងពីរ ជាអ្នកមានចិត្ត តម្កល់មាំក្នុងសន្តាន ។ លោកប្រាសចាកនូវសរ មានសំយោជនៈ អស់ហើយ បានសម្រេចវិជ្ជា ៣ ញុំាងមច្ចុរាជឱ្យវិនាស ជា ទក្ខិណេយ្យបុគ្គល ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់មនុស្សទាំងឡាយ។

**៤ គាថាកន្លះ** ព្រះសារីបុត្តត្ថេរ បានពោលទុកហើយ នូវ ពាក្យសរសើរព្រះមហាមោគ្គល្លាន ។

ពួកទេវតាជាច្រើនចំនួនមួយហ្មឺនអង្គ មានឫទ្ធិមានយស ទេវតាទាំងអស់នុ៎ះទាំងពួកព្រហ្មបុរោហិត ឈរប្រណម្យនមស្ការ ព្រះមោគ្គល្លានថា : បពិត្រលោកជាបុរសអាជានេយ្យ យើងខ្ញុំសូម នមស្ការ ចំពោះលោក បពិត្រលោកជាបុរសដ៏ឧត្តម យើងខ្ញុំសូម នមស្ការ ចំពោះលោក បពិត្រលោកនិរទុក្ខ លោកមានអាសវៈអស់





ហើយ លោកជាទក្ខិណេយ្យបុគ្គល ។

(ព្រះមោគ្គល្លាន ) ដែលនរជននិងទេវតាបូជាហើយ លោក កើត (ដោយអរិយជាតិ ) ជាអ្នកគ្របសង្កត់នូវសេចក្ដីស្លាប់បាន មិនជាប់ជំពាក់ក្នុងសង្ខារ ដូចផ្កាឈូកស មិនប្រឡាក់ដោយទឹក ។

ព្រះមោគ្គល្លានណា ជ្រាបនូវឱកាសលោកមួយពាន់ ក្នុង កាលមួយរំពេច ព្រះមោគ្គល្លាននោះ ស្មើនឹងមហាព្រហ្ម ជាអ្នក ស្ទាត់ក្នុងឥទ្ធិគុណនិងចុតូបបាតៈ លោកជាភិក្ខុ ឃើញពួកទេវតា ក្នុងកាលគួរ ។

**២៣ គាថាកន្លះ** ជាបន្តទៅទៀតនេះ ព្រះថេរៈប្រកាស គុណរបស់លោកផ្ទាល់ ។

ព្រះសារីបុត្តត្ថេរ ( ប្រសើរ ) ដោយប្រាជ្ញា ដោយសីល ដោយឧបសមៈ ទុកជាភិក្ខុណា ជាអ្នកដល់នូវត្រើយ ភិក្ខុនោះ គប្បីជាអ្នកមានគុណយ៉ាងក្រៃលែង ដូច្នេះឯង ។

ចំណែកអាត្មា អាចនិម្មិតនូវអត្តភាពមួយសែនកោដិបាន ដោយមួយរំពេច ជាអ្នកឈ្លាសវៃក្នុងការសម្ដែងឫទ្ធិផ្សេងៗ ជា អ្នកស្ទាត់ជំនាញក្នុងឫទ្ធិ ។

អាត្មា ជាមោគ្គល្លានគោត្រ ដល់នូវទីបំផុតដោយសមាធិ

និងភាវៈស្អាត់ក្នុងវិជ្ជា ជាអ្នកប្រាជ្ញ មានឥន្ទ្រិយតាំងមាំក្នុងសាស-នា (នៃព្រះសាស្តា) ប្រាសចាកតណ្ហានិស្ស័យជាដើម បានកាត់នូវចំណងគឺកិលេស ដូចដំរីផ្តាច់ទន្ទឹង ដែលគេធ្វើដោយវល្លិស្អុយ ។

ព្រះសាស្តា ខ្ញុំបម្រើហើយ ព្រះពុទ្ធសាសនាខ្ញុំបានធ្វើហើយ ភារៈធ្ងន់ខ្ញុំបានដាក់ចុះហើយ តណ្ហាដែលជាធម្មជាតិនាំសត្វទៅកាន់ភព ខ្ញុំបានដកហើយ ។

កុលបុត្រចេញចាកផ្ទះហើយទៅបួស ក្នុងសម្នាក់បុគ្គលមិនមានផ្ទះ ដើម្បីប្រយោជន៍ណា ប្រយោជន៍ជាគ្រឿងអស់សំយោ-ជនៈគ្រប់យ៉ាងនោះ ក៏ខ្ញុំបានសម្រេចហើយ ។

ទុស្សីមារ បៀតបៀននូវព្រាហ្មណ៍គឺអគ្គសាវ័កឈ្មោះវិធូរផង នូវព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកកុសន្ធៈផង ហើយឆេះនៅក្នុងនរកណា នរកនោះ ដូចម្តេចទៅ ។

ទុស្សីមារ បៀតបៀននូវព្រាហ្មណ៍គឺអគ្គសាវ័កឈ្មោះវិធូរផង នូវព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកកុសន្ធៈផង ហើយឆេះនៅក្នុងនរកណា នរកនោះប្រាកដដូច្នេះ គឺកង្វារដែក ១០០ កើតវេទនាផ្សេងៗ គ្នាគ្រប់យ៉ាង ។

ភិក្ខុណា ជាសាវ័ករបស់ព្រះពុទ្ធ ដឹងជាក់លាក់នូវផលនៃកម្មនោះ ម្នាលមារមានចិត្តខ្មៅ អ្នកបៀតបៀននូវភិក្ខុបែបនោះ



ហើយ នឹងដល់នូវសេចក្តីទុក្ខមិនខាន ។

វិមានទាំងឡាយណា តាំងនៅអស់មួយកប្ប ឋិតនៅក្នុងកណ្តាលសាគរ មានពណ៌ដូចជាកែវពិទូរ្យ ដ៏រុងរឿង មានពន្លឺភ្លឺផ្លេក មានពួកស្រីអប្សរដ៏ច្រើនមានវណ្ណៈផ្សេងៗ រាំក្នុងវិមានទាំង-នោះ ភិក្ខុណា ជាសាវ័ករបស់ព្រះពុទ្ធ ដឹងជាក់លាក់នូវផលនៃកម្មនោះ ម្នាលមារមានចិត្តខ្មៅ អ្នកនឹងដល់នូវសេចក្តីទុក្ខ ។

មួយទៀត ភិក្ខុណា ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ដាស់តឿនហើយ កាលភិក្ខុសង្ឃកំពុងមើល (ភិក្ខុនោះ) បានធ្វើមិគារមាតុ-ប្រាសាទឱ្យកក្រើកញាប់ញ័រ ដោយចុងមេជើង ។

ភិក្ខុណា ជាសាវ័ករបស់ព្រះពុទ្ធ ដឹងជាក់លាក់នូវផលនៃកម្មនោះ ម្នាលមារមានចិត្តខ្មៅ អ្នកនឹងដល់នូវសេចក្តីទុក្ខ ។

ភិក្ខុណាធ្វើវេជយន្តប្រាសាទ ឱ្យកក្រើកញាប់ញ័រ ដោយចុងមេជើង ភិក្ខុនោះ ជាអ្នកអង់អាចដោយកម្លាំងឫទ្ធិ ធ្វើពួកទេវតាឱ្យសង្វេគហើយ ។

ភិក្ខុណា ជាសាវ័ករបស់ព្រះពុទ្ធ ដឹងជាក់លាក់នូវផលនៃកម្មនោះ ម្នាលមារមានចិត្តខ្មៅ អ្នកនឹងដល់នូវសេចក្តីទុក្ខ ។

ភិក្ខុណា (គង់លើ) វេជយន្តប្រាសាទ ភិក្ខុនោះក៏សួរសក្ក-ទេវរាជថា ម្នាលអាវុសោ អ្នកដឹងនូវការអស់និងការផុតស្រឡះ

ចាកតណ្ហាដែរឬទេ ។ សក្កទេវរាជ ដែលព្រះថេរៈសួរប្រស្នាហើយ ក៏ឆ្លើយដោះស្រាយតាមសេចក្ដីពិតដល់លោក ភិក្ខុណា ជាសាវ័ក របស់ព្រះពុទ្ធ ដឹងជាក់លាក់នូវផលនៃកម្មនោះ ម្នាលមារមានចិត្ត ខ្មៅ អ្នកនឹងដល់នូវសេចក្ដីទុក្ខ ។

ភិក្ខុណា ជាបុគ្គលក្លៀវក្លាសួរប្រស្នានឹងព្រហ្ម ក្នុងសភា ឈ្មោះសុធម្មាថា ម្នាលអាវុសោ សេចក្ដីយល់ណារបស់អ្នក ដែល មានហើយ ក្នុងកាលពីដើម សេចក្ដីយល់របស់អ្នកនោះ នៅដូចថ្ងៃ នេះឬ អ្នកឃើញពន្លឺរស្មី ( នៃព្រះមានបុណ្យនិងសាវ័ក ) គ្រប សង្កត់ក្នុងព្រហ្មលោកដែរឬទេ ។ ព្រហ្មដែលព្រះថេរៈសួរប្រស្នា ហើយ ក៏ឆ្លើយដោះសាតាមសេចក្ដីពិតដល់លោកថា បពិត្រ លោកនិរទុក្ខ សេចក្ដីយល់ណារបស់ខ្ញុំ ដែលមានហើយ ក្នុងកាល ពីដើម សេចក្ដីយល់របស់ខ្ញុំនោះ មិនមានទេ ។ ខ្ញុំឃើញពន្លឺរស្មី ( របស់ព្រះមានបុណ្យនិងសាវ័ក ) គ្របសង្កត់ក្នុងព្រហ្មលោក ខ្ញុំ នោះនឹងលះបង់នូវពាក្យរបស់ខ្ញុំដែលយល់ឃើញថា អាត្មាអញជា បុគ្គលទៀងទាត់ ( នោះ ) ក្នុងថ្ងៃនេះហើយ ។ ភិក្ខុណា ជាសាវ័ក របស់ព្រះពុទ្ធ ដឹងជាក់លាក់នូវផលនៃកម្មនោះ ម្នាលមារមានចិត្ត ខ្មៅ អ្នកនឹងដល់នូវសេចក្ដីទុក្ខ ។

ភិក្ខុណា បានឃើញកំពូលភ្នំមហាសិនេរុផង ឃើញជម្ពូទ្វីប



ផង ឃើញបុព្វវិទេហទ្វីបផង ឃើញពួកមនុស្សដេកលើផែនដី (នៅក្នុងអបរគោយានទ្វីប និងឧត្តរកុរុទ្វីប ) ផង ដោយឈាន- វិមោក្ខ ។ ភិក្ខុណា ជាសាវ័ករបស់ព្រះពុទ្ធ ដឹងជាក់លាក់នូវផលនៃ កម្មនោះ ម្នាលមារមានចិត្តខ្មៅ អ្នកនឹងដល់នូវសេចក្ដីទុក្ខ ។

ធម្មតាភ្លើង មិនដែលគិតថា អញនឹងឆេះរលាកមនុស្សពាល ទេ តែប្រសិនជាមនុស្សពាលពាល់ភ្លើងដែលឆេះហើយ (ភ្លើង ) ក៏ ឆេះរលាកនូវបុគ្គលពាលនោះឯង ។ ម្នាលមារ អ្នកបៀតបៀននូវ ព្រះតថាគតនោះ មុខជានឹងឆេះរលាកខ្លួនឯងវិញ ដូចមនុស្សពាល ពាល់ភ្លើង យ៉ាងនោះដែរ ។ ម្នាលមារមានចិត្តបាប មារឯង បៀត បៀននូវព្រះតថាគតនោះ មុខជានឹងបានសោយបាប អ្នកសម្គាល់ ថា បាបនឹងមិនឱ្យផលដល់អញ ឬអ្វី ។

ម្នាលមារមានចិត្តលាមក បាបរបស់អ្នកកាលធ្វើ រមែង ប្រព្រឹត្តទៅ (មិនជាប្រយោជន៍ ) អស់កាលដ៏យូរ ម្នាលមារ អ្នកចូរ នឿយណាយ ( កុំប្រទូស្ត ) បុគ្គលអ្នកត្រាស់ដឹងនូវសច្ចៈទាំង ៤ ប្រការ អ្នកកុំធ្វើនូវសេចក្ដីប៉ុនប៉ង ដើម្បីបៀតបៀនភិក្ខុឡើយ ។

គាថាចុងក្រោយ ព្រះសង្គីតិកាចារ្យ បានសម្ដែងទុកមក ។

ភិក្ខុ (មោគ្គល្លានត្ថេរ ) បានគំរាមមារ ក្នុងភេសកឡាវ័ន

ដោយប្រការដូច្នេះហើយ មារជាយក្ខនោះ ក៏អាក់អន់ចិត្ត ហើយបាត់ទៅក្នុងទីនោះឯង ព្រោះហេតុតែសេចក្តីគំរាម នៃព្រះមហាមោគ្គល្លាន ។

ឮថា ព្រះមហាមោគ្គល្លានត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងឡាយដោយប្រការដូច្នេះឯង ។

( ចប់ មោគ្គល្លានត្ថេរគាថា )

*-**បាដលិបុត្រ អសោការាម** ជាកន្លែងធ្វើសង្គាយនាលើកទី ៣ ហើយសង្ឃបានចាត់គណៈធម្មទូតឱ្យចេញផ្សាយព្រះពុទ្ធសាសនាទៅច្រើនកន្លែង មានដែនសុវណ្ណភូមិជាដើម ។ គួរនឹករលឹកដល់ឧបការគុណនៃព្រះបាទធម្មាសោក ដែលបានស្តាប់ព្រះធម៌អំពីនិគ្រោធសាមណេរ ហើយចូលកាន់ព្រះពុទ្ធសាសនា ។ ព្រះអង្គបានធ្វើកិច្ចការច្រើនណាស់ ក្នុងការឧបត្ថម្ភព្រះសង្ឃ វត្តអារាម។ល។ ជាពិសេសព្រះអង្គបានប្រតិស្ឋាននូវព្រះស្តូបទុកតមកដល់សព្វថ្ងៃ តាមដែលព្រះអង្គស្តេចយាងជាមួយនឹងព្រះអរហន្តទាំងឡាយ ទៅតាមសំវេជនីយដ្ឋាន និងបរិភោគចេតិយផ្សេង ៗ ។

បាដលិបុត្រ ជារាជធានីនគរមគធៈ រើពីក្រុងរាជគ្រឹះមកឋិតនៅប៉ែកខាងជើងនៃព្រះនគរ ជាប់នឹងនគរវេសាលី ។





# សម្រស់វេឡុវ័នមហាវិហារ

គ្រាមួយព្រះបាទពិម្ពិសារ ហឫទ័យមេត្តាឱ្យគេច្រៀង
សរសើរវេឡុវ័នដោយសំនៀង អត្ថន័យសូរសៀងពីរោះក្រៃ ។
អ្នកណាមិនឃើញវេឡុវ័ន ដែលព្រះអរហន្តគង់អាស្រ័យ
អ្នកនោះមិនបានឃើញបុរី ឧទ្យានប្រពៃនៃទេវតា ។
អ្នកណាបានឃើញវេឡុវ័ន ពិតឥតធុញទ្រាន់បាត់សោកា
អ្នកនោះគឺដូចបានទស្សនា នន្ទវ័នអស្ចារ្យក្នុងទេវលោក ។
វត្តវេឡុវ័នកើតឡើងបាន ដោយបុណ្យកល្យាណព្រះមានជោគ
គុណវេឡុវ័នមានក្នុងលោក អ្នកណានឹងមករាប់អស់បាន ។
ព្រះនាងខេមាមហេសីស្តេច ស្តាប់ចប់ស្រេចបាច់រឿងឧទ្យាន
ហឫទ័យប៉ងទតមិនអាចខាន ខេមាកល្យាណគាល់រាជា ។
រីព្រះរាជាម្ចាស់ផែនដី ត្រាស់ថាមហេសីនាំបរិពារ
ទៅទតឧទ្យានព្រះភគវា គ្រប់គ្នានឹងបានសុខសួស្តី ។
គ្រានោះឧទ្យានវេឡុវ័ន មានព្រះអរហន្តជាសិរី
ព្រៃមានពន្លឺឆព្វណ្ណរង្សី ភ្លឺព្រោះសិរីព្រះសាស្តា ។
វត្តវេឡុវ័នតារាំយំ ឮសូររងំឃ្មុំក្រេបផ្កា
ជាភ័ព្វសំណាងព្រះខេមា ជួបព្រះសាស្តាសម្រេចធម៌ ។

ដោយ ម.ស.វ.

# នគរវេសាលី

*-ក្រុងវេសាលី ដែលទើបតែស្រាវជ្រាវរកឃើញថ្មីៗ ដោយក្រសួងបុរាណវត្ថុក្នុងប្រទេស ។ នឹករលឹកឃើញ កាលដែលព្រះបរមសាស្តាទ្រង់ប្រថាប់ឈរនៅនឹងខ្លោងទ្វារព្រះនគរវេសាលី ត្រាស់ហៅព្រះអានន្ទមកហើយ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ អ្នកចូររៀននូវរតនសូត្រនេះ ហើយកាន់ឧបករណ៍នៃពលិកម្ម និមន្តទៅជាមួយនឹងលិច្ឆវីកុមារទាំងឡាយ ក្នុងរវាងកំពែង ៣ ជាន់នៃនគរវេសាលី ចូរធ្វើនូវព្រះបរិត្ត ដូច្នេះហើយ ព្រះអង្គទ្រង់ត្រាស់នូវរតនសូត្រ ។

ព្រះអានន្ទ បានរៀននូវរតនសូត្រពីព្រះដ៏មានព្រះភាគ ហើយបានកាន់បាត្រនៃព្រះសម្មាសម្ពុទ្ធ ដាក់ទឹក និមន្តព្រោះព្រំពេញព្រះនគរ ។ តាមអដ្ឋកថារតនសូត្រ ។





# រតនសូត្រ

(បិដកលេខ ៥៤ , ទំព័រ ៧៣-៧៨)

**យានីធ ភូតានិ សមាគតានិ**
**ភុម្មានិ វា យានិ វ អន្តលិក្ខេ**

ពួកភូតឯណា ជាទេវតាស្ថិតនៅលើផែនដីក្តី ពួកភូតឯណា ជាទេវតាឋិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ

**សព្វេវ ភូតា សុមនា ភវន្តុ** សូមពួកភូតទាំងអស់នោះមានចិត្តល្អ

**អថោបិ សក្កច្ច សុណន្តុ ភាសិតំ**ម្យ៉ាងទៀត ចូរស្តាប់នូវភាសិត ដោយគោរព ។

**តស្មា ហិ ភូតា និសាមេថ សព្វេ**
**មេត្តំ ករោថ មានុសិយា បជាយ**

ព្រោះហេតុនោះ អ្នកទាំងឡាយជាភូតទាំងអស់ ចូរស្តាប់នូវព្រះបរិត្ត ចូរធ្វើនូវមេត្តាចិត្ត ចំពោះពពួកសត្វជាមនុស្សជាតិ

**ទិវា ច រត្តោ ច ហរន្តិ យេ ពលិំ** មនុស្សទាំងឡាយឯណា តែងនាំមកនូវពលិកម្ម ក្នុងពេលថ្ងៃនិងពេលយប់

**តស្មា ហិ នេ រក្ខថ អប្បមត្តា** ព្រោះហេតុនោះ សូម

អ្នកទាំងឡាយកុំមើលបំណាំឡើយ  សូមរក្សានូវមនុស្សទាំងឡាយនោះ ។

**យំ កិញ្ចិ វិត្តំ        ឥធ វា ហុរំ វា**

**សគ្គេសុ វា យំ        រតនំ បណីតំ**

ទ្រព្យឯណាមួយ  ក្នុងលោកនេះនិងក្នុងលោកឯទៀតក្តី រតនវត្ថុដ៏ឧត្តមឯណា ក្នុងឋានសួគ៌ក្តី

**ន នោ សមំ អត្ថិ តថាគតេន** ទ្រព្យនិងរតនវត្ថុទាំងនោះ ស្មើដោយព្រះតថាគត មិនមានឡើយ

**ឥទម្បិ ពុទ្ធេ រតនំ បណីតំ** កែវគឺព្រះពុទ្ធនេះឯងជាកែវដ៏ឧត្តម

**ឯតេន សច្ចេន សុវត្ថិ ហោតុ** ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។

**ខយំ វិរាគំ អមតំ បណីតំ**

**យទជ្ឈគា សក្យមុនី សមាហិតោ**

ព្រះសក្យមុនីជាម្ចាស់ មានព្រះទ័យតម្កល់មាំ បានត្រាស់ដឹងហើយ នូវព្រះធម៌ឯណា ជាទីក្ស័យនៃកិលេស ជាទីប្រាសចាករាគៈ ជាធម៌មិនស្លាប់ ជាធម៌ដ៏ឧត្តម

**ន តេន ធម្មេន សមត្ថិ កិញ្ចិ** របស់អ្វីមួយស្មើដោយ





ព្រះធម៌នោះ មិនមានឡើយ

**ឥទម្បិ ធម្មេ រតនំ បណីតំ** កែវគឺព្រះធម៌នេះឯងជាកែវដ៏ឧត្តម

**ឯតេន សច្ចេន សុវត្ថិ ហោតុ** ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។

**យម្ពុទ្ធសេដ្ឋោ បរិវណ្ណយី សុចឹ** ព្រះពុទ្ធដ៏ប្រសើរ ទ្រង់សរសើរនូវសមាធិឯណា ថាជាធម៌ដ៏ស្អាត

**សមាធិមានន្តរិកញ្ញមាហុ** បណ្ឌិតទាំងឡាយពោលហើយនូវសមាធិឯណា ថាជាធម៌ឱ្យផលដោយលំដាប់

**សមាធិនា តេន សមោ ន វិជ្ជតិ** សមាធិឯទៀតស្មើដោយសមាធិនោះ មិនមានឡើយ

**ឥទម្បិ ធម្មេ រតនំ បណីតំ** កែវគឺព្រះធម៌នេះឯងជាកែវដ៏ឧត្តម

**ឯតេន សច្ចេន សុវត្ថិ ហោតុ** ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។

**យេ បុគ្គលា អដ្ឋសតំ បសដ្ឋា**

**ចត្តារិ ឯតានិ យុគានិ ហោន្តិ**

បុគ្គលទាំងឡាយឯណា ៨ ជំពូក ដែលសប្បុរសទាំងឡាយ

សរសើរហើយ បើរាប់ជាគូបាន ៤ គូ

**តេ ទក្ខិណេយ្យា សុគតស្ស សាវកា** បុគ្គលទាំង-ឡាយនោះ ជាសាវកំរបស់ព្រះសុគត លោកគួរដល់ទក្ខិណាទាន

**ឯតេសុ ទិន្នានិ មហប្ផលានិ** ទានទាំងឡាយដែលបុគ្គលឱ្យហើយ ដល់ទក្ខិណេយ្យបុគ្គលទាំងឡាយនោះ ជាទានមានផលច្រើន

**ឥទម្បិ សង្ឃេ រតនំ បណីតំ** កែវគឺព្រះសង្ឃនេះឯងជាកែវដ៏ឧត្តម

**ឯតេន សច្ចេន សុវត្ថិ ហោតុ** ដោយពាក្យសច្ចៈនេះសូមសិរីសួស្តីកើតមាន ។

**យេ សុប្បយុត្តា មនសា ទឡ្ហេន**

**និក្ខាមិនោ គោតមសាសនម្ហិ**

អរិយបុគ្គលទាំងឡាយឯណា ក្នុងសាសនានៃព្រះសម្ពុទ្ធទ្រង់ព្រះនាមគោតម ប្រកបត្រូវល្អហើយ មានចិត្តខ្ជាប់ខ្ជួន ឥតមានកាមគឺសេចក្តីប្រាថ្នាឡើយ

**តេ បត្តិបត្តា អមតំ វិគយ្ហ**

**លទ្ធា មុធា និព្វុតឹ ភុញ្ជមានា**

អរិយបុគ្គលទាំងឡាយនោះ ដល់ហើយនូវព្រះអរហត្តផល





ហើយចូលទៅកាន់ព្រះនិព្វាន បាននូវកិរិយារលត់កិលេស ដោយទទេ គឺឥតមានទិញដូរឡើយ ហើយសោយនូវផល

**ឥទម្បិ សង្ឃេ រតនំ បណីតំ** កែវគឺព្រះសង្ឃនេះឯងជាកែវដ៏ឧត្តម

**ឯតេន សច្ចេន សុវត្ថិ ហោតុ** ដោយពាក្យសច្ចៈនេះសូមសិរីសួស្តីកើតមាន ។

**យថិន្ទខីលោ បថវឹ សិតោ សិយា**

**ចតុព្ភិ វាតេភិ អសម្បកម្បិយោ**

សសរខឿន ដែលគេបោះភ្ជាប់នឹងផែនដី ជារបស់មិនកម្រើកញាប់ញ័រដោយខ្យល់ព្យុះដែលបក់មកអំពីទិសទាំង ៤ យ៉ាងណាមិញ

**តថូបមំ សប្បុរិសំ វទាមិ**

**យោ អរិយសច្ចានិ អវេច្ច បស្សតិ**

អ្នកណាពិចារណាឃើញនូវអរិយសច្ចទាំងឡាយ តថាគតហៅអ្នកនោះថាជាសប្បុរស ( មិនញាប់ញ័រដោយលោកធម៌ទាំង-ឡាយ ) ប្រៀបដូចជាសសរខឿនដូច្នោះឯង

**ឥទម្បិ សង្ឃេ រតនំ បណីតំ** កែវគឺព្រះសង្ឃនេះឯងជាកែវដ៏ឧត្តម

**ឯតេន សច្ចេន សុវត្ថិ ហោតុ** ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។

**យេ អរិយសច្ចានិ វិភាវយន្តិ**

**គម្ភីរបញ្ញេន សុទេសិតានិ**

អរិយបុគ្គលទាំងឡាយឯណា ធ្វើឱ្យជាក់ច្បាស់នូវអរិយសច្ចទាំងឡាយ ដែលព្រះតថាគតព្រះអង្គមានប្រាជ្ញាដ៏ជ្រាលជ្រៅសម្តែងល្អហើយ

**កិញ្ចាបិ តេ ហោន្តិ ភុសប្បមត្តា** អរិយបុគ្គលទាំងឡាយនោះ ទុកជាប្រមាទដ៏លើសលន់ក៏ដោយ

**ន តេ ភវំ អដ្ឋមមាទិយន្តិ** អរិយបុគ្គលទាំងឡាយនោះ គង់មិនកាន់យកនូវភពជាគម្រប់ ៨ គឺមិនកើតទៀតហួសពី ៧ ជាតិឡើយ

**ឥទម្បិ សង្ឃេ រតនំ បណីតំ** កែវគឺព្រះសង្ឃនេះឯងជាកែវដ៏ឧត្តម

**ឯតេន សច្ចេន សុវត្ថិ ហោតុ** ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។

**សហាវស្ស ទស្សនសម្បទាយ**

**តយស្សុ ធម្មា ជហិតា ភវន្តិ**



**សក្កាយទិដ្ឋិ វិចិកិច្ឆិតញ្ច**

**សីលព្វតំ វាបិ យទត្ថិ កិញ្ចិ**

( សំយោជនកិលេស ៣ យ៉ាងគឺ ) សក្កាយទិដ្ឋិ វិចិកិច្ឆា និង សីលព្វតបរាមាសៈឯណាមួយតែងមាន ធម៌ទាំងឡាយ ៣ នោះ សោតាបន្នបុគ្គលនោះបានលះបង់ហើយ ជាមួយនឹងទស្សនសម្បទ័ គឺសោតាបត្តិមគ្គ

**ចតូហបាយេហិ ច វិប្បមុត្តោ** ម្យ៉ាងទៀត សោតាបន្នបុគ្គល បានរួចស្រឡះចាកអបាយទាំងឡាយ ៤ ហើយ

**ឆ ចាភិឋានានិ អភព្វោ កាតុំ** មិនអាចធ្វើនូវឋានដ៏អាក្រក់ទាំងឡាយ ៦ គឺអនន្តរិយកម្ម ៥ និងកិរិយាងាកចិត្តទៅកាន់សាសនាដទៃឡើយ ។

**ឥទម្បិ សង្ឃេ រតនំ បណីតំ** កែវគឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម

**ឯតេន សច្ចេន សុវត្ថិ ហោតុ** ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។

**កិញ្ចាបិ សោ កម្មំ ករោតិ បាបកំ**

**កាយេន វាចាយុទ ចេតសា វា**

ប្រសិនណាបើ សោតាបន្នបុគ្គលនោះ ធ្វើនូវបាបកម្មខ្លះ

ដោយកាយវាចា ឬក៏ដោយចិត្ត ( ព្រោះសេចក្ដីភ្លាំងភ្លាត់ )

**អភព្វោ សោ តស្ស បដិច្ឆទាយ** សោតាបន្នបុគ្គល នោះ មិនអាចបិទបាំងនូវបាបកម្មនោះឡើយ

**អភព្វតា ទិដ្ឋបទស្ស វុត្តា** ភាវៈនៃបុគ្គលមានផ្លូវនៃព្រះនិព្វានឃើញហើយ ជាបុគ្គលមិនអាចនឹងបិទបាំងនូវបាបកម្ម ព្រះពុទ្ធទាំងឡាយបានត្រាស់សម្ដែងហើយ

**ឥទម្បិ សង្ឃេ រតនំ បណីតំ** កែវគឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្ដម

**ឯតេន សច្ចេន សុវត្ថិ ហោតុ** ដោយពាក្យសច្ចៈនេះ សូមសិរីសួស្ដីកើតមាន ។

**វនប្បគុម្ពេ យថា ផុស្សិតគ្គេ**

**គិម្ហានមាសេ បឋមស្មឹ គិម្ហេ**

គុម្ពឈើក្នុងព្រៃ មានត្រួយលូតលាស់ ក្នុងខាងដើម គិម្ហរដូវគឺខែក្ដៅ យ៉ាងណាមិញ

**តថូបមំ ធម្មវរំ អទេសយិ**

**និព្វានគាមឹ បរមំ ហិតាយ**

ព្រះសម្ពុទ្ធបានត្រាស់សម្ដែងហើយនូវធម៌ដ៏ប្រសើរ ជាធម៌អាចញុំាងសត្វទាំងឡាយឱ្យដល់នូវព្រះនិព្វាន ដើម្បីប្រយោជន៍





ដ៏ឧត្ដម ប្រៀបដូចជាគុម្ពឈើក្នុងព្រៃ ដូច្នោះឯង

**ឥទម្បិ ពុទ្ធេ រតនំ បណីតំ** កែវគឺព្រះពុទ្ធនេះឯង ជាកែវដ៏ឧត្ដម

**ឯតេន សច្ចេន សុវត្ថិ ហោតុ** ដោយពាក្យសច្ចៈនេះ សូមសិរីសួស្ដីកើតមាន ។

**វរោ វរញ្ញូ វរទោ វរាហរោ** ព្រះសម្មាសម្ពុទ្ធជាបុគ្គលដ៏ប្រសើរ ទ្រង់ជ្រាបនូវធម៌ដ៏ប្រសើរ ទ្រង់ប្រទាននូវធម៌ដ៏ប្រសើរ ទ្រង់នាំមកនូវធម៌ដ៏ប្រសើរ

**អនុត្តរោ ធម្មវរំ អទេសយិ** ព្រះអង្គប្រសើរឥតមានអ្នកណាមួយស្មើ ទ្រង់ត្រាស់សម្ដែងហើយនូវធម៌ដ៏ប្រសើរ

**ឥទម្បិ ពុទ្ធេ រតនំ បណីតំ** កែវគឺព្រះពុទ្ធនេះឯង ជាកែវដ៏ឧត្ដម

**ឯតេន សច្ចេន សុវត្ថិ ហោតុ** ដោយពាក្យសច្ចៈនេះ សូមសិរីសួស្ដីកើតមាន ។

**ខីណំ បុរាណំ នវំ នត្ថិ សម្ភវំ** កម្មចាស់ ( របស់អរិយបុគ្គលឯណា ) អស់ហើយ កម្មថ្មី រមែងមិនកើតប្រាកដ

**វិរត្តចិត្តាយតិកេ ភវស្មឹ** អរិយបុគ្គលទាំងឡាយឯណា មានចិត្តនឿយណាយហើយក្នុងភពតទៅ

**តេ ខីណពីជា អវិរុឡ្ហិឆន្ទា** អរិយបុគ្គលទាំងឡាយនោះ មានពូជអស់ហើយ មានឆន្ទៈគឺសេចក្តីប៉ុនប៉ងក្នុងចិត្តមិនដុះចម្រើនឡើយ

**និព្វន្តិ ធីរា យថាយម្បទីបោ** ជាអ្នកមានប្រាជ្ញា តែងរលត់ទៅ ដូចជាប្រទីបដែលរលត់ទៅនេះ

**ឥទម្បិ សង្ឃេ រតនំ បណីតំ** កែវគឺព្រះសង្ឃនេះឯងជាកែវដ៏ឧត្តម

**ឯតេន សច្ចេន សុវត្ថិ ហោតុ** ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។

**យានីធ ភូតានិ សមាគតានិ**

**ភុម្មានិ វា យានិ វ អន្តលិក្ខេ**

ពួកភូតឯណាជាទេវតាស្ថិតនៅលើផែនដីក្តី ពួកភូតឯណាជាទេវតាស្ថិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ

**តថាគតំ ទេវមនុស្សបូជិតំ**

**ពុទ្ធំ នមស្សាម សុវត្ថិ ហោតុ**

យើងទាំងឡាយ សូមនមស្ការនូវព្រះពុទ្ធជាម្ចាស់ ទ្រង់បានត្រាស់មកហើយដូចគ្នា ដែលទេវតានិងមនុស្សតែងបូជា សូមសិរីសួស្តី កើតមាន ។





**យានីធ ភូតានិ សមាគតានិ**

**ភុម្មានិ វា យានិ វ អន្តលិក្ខេ**

ពួកភូតឯណាជាទេវតាស្ថិតនៅលើផែនដីក្តី ពួកភូតឯណាជាទេវតាស្ថិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ

**តថាគតំ ទេវមនុស្សបូជិតំ**

**ធម្មំ នមស្សាម សុវត្ថិ ហោតុ**

យើងទាំងឡាយ សូមនមស្ការនូវព្រះធម៌មានមកហើយដូចគ្នា ដែលទេវតានិងមនុស្សតែងបូជា សូមសិរីសួស្តី កើតមាន ។

**យានីធ ភូតានិ សមាគតានិ**

**ភុម្មានិ វា យានិ វ អន្តលិក្ខេ**

ពួកភូតឯណាជាទេវតាស្ថិតនៅលើផែនដីក្តី ពួកភូតឯណាជាទេវតាស្ថិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ

**តថាគតំ ទេវមនុស្សបូជិតំ**

**សង្ឃំ នមស្សាម សុវត្ថិ ហោតុ**

យើងទាំងឡាយ សូមនមស្ការនូវព្រះសង្ឃមានមកហើយដូចគ្នា ដែលទេវតានិងមនុស្សតែងបូជា សូមសិរីសួស្តី កើតមាន ។

(លំនាំសូត្រតាមភាណវារៈ)

**(រតនសូត្រចប់)**

*-ព្រះស្តូបបញ្ចុះព្រះធាតុនៃព្រះសម្មាសម្ពុទ្ធ ២ នាក់ ឥឡូវនៅសល់តែគ្រឹះថ្ម ជាទីនឹករលឹក ។ ព្រះសម្មាសម្ពុទ្ធជាអច្ឆរិយមនុស្ស ទ្រង់ប្រសើរដោយគុណ ព្រះអង្គកើតក្នុងលោក តែលោកមិនប្រឡាក់ព្រះអង្គ ដូចផ្កាឈូក ដុះក្នុងទឹក ផុសចេញពីទឹក តែទឹកមិនជាប់សើមផ្កាឈូកឡើយ ។

*-ស្រះទឹកមង្គល តាមជំនឿនៃមនុស្សក្នុងសម័យនោះ ។ តាមពិត គុណធម៌ទើបជាមង្គលដ៏ឧត្តម ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងចំពោះសុព្រហ្មទេវបុត្រ ដូច្នេះថា :

**នាញ្ញត្រ ពោជ្ឈង្គតបសា នាញ្ញត្រ ឥន្ទ្រិយសំវរា**

**នាញ្ញត្រ សព្វនិស្សគ្គា សោត្ថឹ បស្សាមិ បាណិនន្តិ។**

តថាគតមិនឃើញសួស្តីរបស់ពួកសត្វ ក្រៅអំពីពោជ្ឈង្គ ការប្រព្រឹត្តដុតនូវកិលេស ការសង្រួមឥន្ទ្រិយ និងការលះបង់នូវកិលេសទាំងអស់ឡើយ ។

*-កូដាគារសាលា នាមមហាវន័ ព្រះបរមសាស្តាទ្រង់គង់ចាំវស្សាទី ៥ នៃព្រះអង្គ ។ ជាកន្លែងទទួលគរុធម៌ ៨ ប្រការ នៃព្រះនាងមហាបជាបតិគោតមី និងជាកន្លែងដែលព្រះអង្គទ្រង់ប្រទានឱ្យស្ត្រីបួសក្នុងព្រះពុទ្ធសាសនា ។ ព្រះនាងមហាបជាបតិ-





គោតមី ឧបសម្បទាមុនគេ ដោយការទទួលគរុធម៌ ៨ ប្រការ ចំណែកសាកិយានីទាំង ៥០០ អង្គ ឧបសម្បទាពីភិក្ខុសង្ឃ ។

ព្រះនាងមហាបជាបតិគោតមី ព្រមដោយព្រះនាងសាកិ-យានីទាំង ៥០០ អង្គ បានកោរសក់ ស្លៀកដណ្តប់សំពត់កាសាវៈ ប្រដាប់បាត្រ ហើយជាស្រេច ធ្វើដំណើរចេញពីក្រុងកបិលពស្តុ មកកាន់កូដាគារសាលា ក្នុងដំណើរផ្លូវ ៥១ យោជន៍ ។ ទោះជាព្រះកាយនឿយហត់យ៉ាងណា ក៏ផ្លូវចិត្តចេញចាកពីព្រះបរមរាជ-វាំង ដោយមិនអាឡោះអាល័យអ្វីឡើយ ហើយទីបំផុតក៏បានចូលកាន់ព្រះនិព្វាន ជាអវសាននៃសង្សារវដ្ត ប្រាកដក្នុងកូដាគារសាលា នេះឯងហោង ។

នៅពេលដែលព្រះបរមសាស្តា ព្រះអង្គទ្រង់ដាក់នូវព្រះ-ជន្មាយុសង្ខាររួចហើយ ព្រះអង្គត្រាស់នឹងព្រះអានន្ទថា :

ម្នាលអានន្ទ មកយើងនឹងទៅកាន់កូដាគារសាលា នាមមហាវន័ ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលនៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ព្រះអង្គក៏បានចូលទៅកាន់កូដាគារសាលា នាមមហាវន័ មួយអន្លើដោយព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទថា ម្នាលអានន្ទ អ្នកចូរទៅឱ្យពួកភិក្ខុទាំងប៉ុន្មានដែល

អាស្រ័យនៅ ក្នុងក្រុងវេសាលីទាំងអស់នោះ មកជួបជុំក្នុងឧបដ្ឋានសាលា ។ ព្រះអានន្ទដ៏មានអាយុ ទទួលព្រះបន្ទូលនៃព្រះ-ដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ឱ្យពួកភិក្ខុទាំងប៉ុន្មានដែលអាស្រ័យនៅ ក្នុងក្រុងវេសាលីទាំងអស់នោះ មកជួបជុំក្នុងឧបដ្ឋានសាលា ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ ឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបថ្វាយបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃប្រជុំគ្នាហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គ ទ្រង់ជ្រាបនូវកាលគួរ ក្នុងកាលឥឡូវនេះ ។

គ្រានោះ ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់យាងចូលទៅកាន់ឧបដ្ឋានសាលា លុះចូលទៅដល់ហើយ ក៏ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគទ្រង់គង់ស្រេចហើយ បានត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សាសន-ព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀត សាសនព្រហ្មចរិយៈនេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍





ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណា ដែលតថាគតសម្តែងហើយដោយបញ្ញាដ៏ឧត្តម ធម៌ទាំងឡាយនោះ អ្នកទាំងឡាយគប្បីរៀនដោយប្រពៃ ហើយសេព ចម្រើន ធ្វើឱ្យរឿយៗ ដោយប្រការដូច្នោះ ។ ធម៌ទាំងឡាយនោះ តើដូចម្តេច ។ អ្វីខ្លះ ។ គឺសតិប្បដ្ឋាន ៤ , សម្មប្បធាន ៤ , ឥទ្ធិបាទ ៤ , ឥន្ទ្រិយ ៥ , ពលៈ ៥ , ពោជ្ឈង្គ ៧ និងអរិយមគ្គប្រកបដោយអង្គ ៨ ។ ម្នាលភិក្ខុទាំងឡាយ ... ធម៌ទាំងឡាយនោះ យ៉ាងនេះឯង ។

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតនឹងដាស់តឿនអ្នកទាំងឡាយ សង្ខារទាំងឡាយមានសេចក្តីវិនាសទៅជាធម្មតា អ្នកទាំងឡាយចូរញ៉ាំងកិច្ចទាំងពួងឱ្យសម្រេចដោយសេចក្តីមិនប្រមាទចុះ បរិនិព្វាននឹងមានដល់តថាគតមិនយូរឡើយ កន្លង ៣ ខែ អំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ ។

(ក្នុងមហាបរិនិព្វានសូត្រ)

ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះបន្ទូលដូច្នេះហើយ ព្រះសុគតជាសាស្តា លុះទ្រង់មានព្រះបន្ទូលដូច្នេះហើយ ទើបទ្រង់

មានព្រះបន្ទូលដូច្នេះ តទៅទៀតថា :

**ទហរាបិ ច យេ វុឌ្ឍា យេ ពាលា យេ ច បណ្ឌិតា**
**អឌ្ឍា ចេវ ទលិទ្ទា ច សព្វេ មច្ចុបរាយនា ។**

ពួកជនណាៗ ទោះបីក្មេងក្តី ចាស់ក្តី ពាលក្តី បណ្ឌិតក្តី អ្នកមានក្តី អ្នកក្រក្តី ជនទាំងអស់នោះ តែងមានសេចក្តីស្លាប់នៅពីខាងមុខ ។

**យថាបិ កុម្ភការស្ស កតំ មត្តិកភាជនំ**
**ខុទ្ទកញ្ច មហន្តញ្ច យញ្ច បក្កំ យញ្ច អាមកំ**
**សព្វំ ភេទបរិយន្តំ ឯវំ មច្ចាន ជីវិតំ ។**

ភាជន៍ដី ដែលស្មូនឆ្នាំងធ្វើហើយ ទោះបីតូចក្តី ធំក្តី ឆ្អិនក្តី ឆៅក្តី ភាជន៍ទាំងអស់នោះ មានកិរិយាបែកធ្លាយជាទីបំផុត យ៉ាងណា ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។

ព្រះបរមសាស្តា ទ្រង់មានព្រះបន្ទូល ដូច្នេះតទៅទៀតថា :

**បរិបក្កោ វយោ មយ្ហំ បរិត្តំ មម ជីវិតំ**
**បហាយ វោ គមិស្សាមិ កតំ មេ សរណមត្តនោ ។**

វ័យរបស់តថាគត ចាស់ហើយ ជីវិតរបស់តថាគត មានប្រមាណតិច តថាគតនឹងលះបង់អ្នកទាំងឡាយ ហើយទៅ ឯទីពឹងរបស់ខ្លួន តថាគតបានធ្វើទុកហើយ ។





**អប្បមត្តា សតីមន្តោ សុសីលា ហោថ ភិក្ខវោ**
**សុសមាហិតសង្កប្បា សចិត្តមនុរក្ខថ ។**

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរកុំប្រមាទ ត្រូវមានស្មារតី មានសីលល្អ មានតម្រិះតម្កល់ស្មើល្អ ចូររក្សាចិត្តរបស់ខ្លួនឱ្យរឿយៗ ចុះ ។

**យោ ឥមស្មឹ ធម្មវិនយេ អប្បមត្តោ វិហរិស្សតិ**
**បហាយ ជាតិសំសារំ ទុក្ខស្សន្តំ ករិស្សតីតិ ។**

ភិក្ខុណា មិនប្រមាទ ហើយនៅក្នុងធម៌វិន័យនេះ (ភិក្ខុនោះ) នឹងលះបង់ជាតិសង្សារ ហើយធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃកងទុក្ខ បានមិនខានឡើយ ។

(បិដកលេខ ១៦ , ទំព័រ ២៥៦-២៥៧)

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ទ្រង់ពុទ្ធដំណើរចូលទៅបិណ្ឌបាត ក្នុងក្រុងវេសាលី លុះស្តេចយាងទៅបិណ្ឌបាត ក្នុងក្រុងវេសាលីហើយ ទ្រង់ត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្ត ទ្រង់ងាកក្រឡេកទតមើលនូវក្រុងវេសាលី ដូចជាដំរីដែលក្រឡេកបែរមើល (នូវទីខាងក្រោយ ) ហើយត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា :

ម្នាលអានន្ទ តថាគតឃើញក្រុងវេសាលីនេះ ជាបច្ឆិមទស្សនៈ (ការឃើញជាចុងក្រោយ ) ម្នាលអានន្ទ មក យើងនឹងទៅកាន់ភណ្ឌគ្រាម ។ ព្រះអានន្ទដ៏មានអាយុ ទទួលព្រះបន្ទូលនៃព្រះដ៏មានព្រះភាគថា : ព្រះករុណាព្រះអង្គ ។

អដ្ឋកថា : បញ្ជាក់អំពីព្រះតថាគតទតក្រុងវេសាលីម្តងនេះជាបច្ឆិមទស្សនៈ ។ តាមពិត ព្រះអង្គទ្រង់ជ្រាបអំពីក្រុងវេសាលីនឹងដល់នូវសេចក្តីវិនាសទៅក្នុងពេលបីឆ្នាំខាងមុខ ប៉ុន្តែកាលដែលពួកស្តេចលិច្ឆវីសាងចេតិយឈ្មោះថា **នាគាបលោកិតចេតិយ** (ចេតិយដែលព្រះដ៏មានព្រះភាគ ទ្រង់បែរព្រះកាយទតមើលក្រុងវេសាលី ដូចដំរីបែរខ្លួនមើលក្រោយ ) នៅជិតខ្លោងទ្វារនគរ ត្រង់ទីដែលព្រះអង្គទ្រង់បែរក្រោយទតព្រះនគរ ហើយបូជានូវចេតិយនោះដោយគ្រឿងសក្ការៈ មានផ្កាកម្រងនិងគ្រឿងក្រអូបជាដើម។ កិច្ចនោះក៏នឹងជាប្រយោជន៍ ទំនុកបម្រុងឱ្យសុខអស់កាលយូរ ។ ដូច្នេះ ទើបព្រះអង្គទ្រង់អនុគ្រោះដល់ពួកស្តេចលិច្ឆវី ។





# ឆាថា_កុសិនារា

*-ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងភណ្ឌគ្រាមនោះ ទ្រង់ធ្វើធម្មីកថាជាច្រើន ចំពោះភិក្ខុទាំងឡាយយ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ បញ្ញាដូច្នេះ ។ សមាធិដែលអប់រំដោយសីលហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ។ បញ្ញាដែលអប់រំដោយសមាធិហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ។ ចិត្តដែលអប់រំដោយបញ្ញាហើយ រមែងរួចស្រឡះដោយប្រពៃចាកអាសវៈទាំងឡាយ គឺកាមាសវៈ ភវាសវៈនិងអវិជ្ជាសវៈ។

**សីលំ សមាធិ បញ្ញា ច វិមុត្តិ ច អនុត្តរា**
**អនុពុទ្ធា ឥមេ ធម្មា គោតមេន យសស្សិនា ។**
**ឥតិ ពុទ្ធោ អភិញ្ញាយ ធម្មមក្ខាតិ ភិក្ខុនំ**
**ទុក្ខស្សន្តករោ សត្ថា ចក្ខុមា បរិនិព្វុតោតិ ។**

ធម៌ទាំងនេះ គឺសីល សមាធិ បញ្ញា និងវិមុត្តិដ៏ប្រសើរ ព្រះគោតម ព្រះអង្គមានយស បានត្រាស់ដឹងហើយ ។ ព្រះពុទ្ធទ្រង់ត្រាស់ដឹងយ៉ាងនេះហើយ ទើបសម្តែងធម៌ប្រាប់ចំពោះភិក្ខុទាំងឡាយ ព្រះសាស្តាមានចក្ខុ ទ្រង់ធ្វើនូវព្រះនិព្វានជាទីបំផុតនៃ

កងទុក្ខ ទ្រង់បរិនិព្វានហើយ ( ដោយកិលេសបរិនិព្វាន ) ។

( បិដកលេខ ១៦ , ទំព័រ ២៦០ )

✳-ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងភណ្ឌគ្រាមតាមសមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកថា : ម្នាលអានន្ទ មក យើងនឹងទៅកាន់ហត្ថិគ្រាម អម្ពគ្រាម ជម្ពុគ្រាម និងភោគនគរ ។ ព្រះអានន្ទដ៏មានអាយុទទួលព្រះបន្ទូលនៃព្រះដ៏មានព្រះភាគថា : ព្រះករុណាព្រះអង្គ ។

បានឮថា ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងអានន្ទចេតិយជិតភោគនគរនោះ ហើយទ្រង់សម្តែងនូវមហាបទេសទាំង ៤ ។

✳-ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងភោគនគរតាមសមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកថា : ម្នាលអានន្ទ មក យើងនឹងទៅកាន់ក្រុងបាវា ។

ព្រះអានន្ទដ៏មានអាយុ ទទួលព្រះបន្ទូលនៃព្រះដ៏មាន-ព្រះភាគថា : ព្រះករុណាព្រះអង្គ ។

បានឮថា ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងអម្ពវន៍របស់នាយចុន្ទកម្មារបុត្រ ( កូនជាងមាស ) ទៀបក្រុងបាវានោះ ។ នាយចុន្ទកម្មារបុត្របានអារាធនាព្រះអង្គព្រមដោយភិក្ខុសង្ឃ ទទួលភត្ត



ក្នុងថ្ងៃស្អែក ។

✳-នាយចុន្ទកម្មារបុត្រ ជាសោតាបន្នបុគ្គល តាំងតែពីបានជួបព្រះអង្គលើកទី១ ម៉្លេះ ហើយបានសាងវត្តក្នុងចម្ការស្វាយរបស់ខ្លួនថ្វាយសង្ឃ ។

✳-ព្រះសង្គីតិកាចារ្យទាំងឡាយ បានសម្តែងនូវគាថាក្នុងកាលធ្វើសង្គាយនា ដែលមានសេចក្តីថា :

ខ្ញុំបានឮថា ព្រះពុទ្ធជាអ្នកប្រាជ្ញ ទ្រង់សោយភត្តរបស់នាយចុន្ទកម្មារបុត្រ ហើយមានព្រះអាពាធជាទម្ងន់ ជិតនឹងបរិនិព្វាន ។ អាពាធដ៏ខ្លាំងក្លាកើតមានដល់ព្រះបរមសាស្តា ដែលសោយភត្តដោយសូករមទ្ទវៈ ។ ព្រះដ៏មានព្រះភាគ ទ្រង់មានអាពាធចុះព្រះលោហិតរឿយៗ ទើបមានព្រះពុទ្ធតម្រាស់ថា តថាគតនឹងទៅកាន់កុសិនារា ។

✍-អដ្ឋកថាបានសម្តែងថា : អាពាធដ៏ខ្លាំងក្លាបានកើតឡើងដល់ព្រះអង្គជាអ្នកសោយ តែមិនមែនកើតព្រោះសូករមទ្ទវៈដែលទ្រង់សោយជាបច្ច័យឡើយ ។ ព្រះអង្គទ្រង់មិនសោយក៏នឹងកើតអាពាធបាន ហើយជាអាពាធដ៏ខ្លាំងក្លាទៀតផង ។ ព្រោះព្រះអង្គ

ទ្រង់សោយនូវភោជនដ៏ល្អិតដែលទេវតាដាក់នូវឱជៈចូល ព្រះអង្គទើបមាននូវទុក្ខវេទនាស្រាលចុះ ដោយហេតុនោះឯង ព្រះអង្គទើបទ្រង់ពុទ្ធដំណើរទៅបាន ។

*-ព្រះពុទ្ធ ទ្រង់ស្តេចយាងទៅកាន់ស្ទឹងកកុធៈ ដែលមានទឹកថ្លា មានរសជាតិ និងជាទឹកស្អាត ។ ព្រះតថាគតជាព្រះបរម-សាស្តា ឥតមានបុគ្គលប្រៀបផ្ទឹមក្នុងលោក ទ្រង់ចុះកាន់ស្ទឹងស្រង់ផង សោយផងនូវទឹកនោះ ហើយទ្រង់គង់ក្នុងទីកណ្តាលនៃពួកភិក្ខុ ដែលគាល់ព្រះអង្គជាព្រះបរមសាស្តា ជាអ្នកស្វែងរកនូវគុណដ៏ធំ ព្រះអង្គញ៉ាំងធម៌ឱ្យប្រព្រឹត្តទៅក្នុងសាសនានេះ ទ្រង់ស្តេចចូលទៅកាន់អម្ពវ័ន ។

*-ចង្ហាន់បិណ្ឌបាតទាំងពីរនេះ មានផលស្មើគ្នា ហើយមានផលច្រើនផង និងមានអានិសង្សច្រើនផង ក្រៃលែងជាងចង្ហាន់បិណ្ឌបាតដទៃ ។ មួយគឺចង្ហាន់បិណ្ឌបាតដែលព្រះអង្គទ្រង់សោយហើយ ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ មួយទៀត គឺចង្ហាន់បិណ្ឌបាតដែលព្រះអង្គទ្រង់សោយហើយ ទ្រង់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។ ព្រះដ៏មានព្រះភាគទ្រង់បន្លឺនូវឧទានថា :





**ទទតោ បុញ្ញំ បវឌ្ឍតិ**
**សំយមតោ វេរំ ន ចីយតិ**
**កុសលោ ច ជហាតិ បាបកំ**
**រាគទោសមោហក្ខយា និព្វុតោតិ ។**

បុណ្យរមែងចម្រើនដល់អ្នកឱ្យទាន វេរាមិនចម្រើនដល់បុគ្គលអ្នកសង្រួម បុគ្គលអ្នកឈ្លាស ( បរិបូណ៌ដោយញាណ ) រមែងលះបង់នូវអំពើលាមកបាន បុគ្គលនោះក៏បរិនិព្វាន ព្រោះអស់រាគៈ ទោសៈ មោហៈ ។

(បិដកលេខ ១៦ , ទំព័រ ២៨៨)

*-ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកថា : ម្នាលអានន្ទ មកយើងនឹងទៅកាន់ខាងនាយនៃស្ទឹងហិរញ្ញវតី ហើយចូលទៅកាន់សាលវ័នរបស់ពួកមល្លក្សត្រ ដែលជាទីចូលទៅក្នុងក្រុងកុសិនារា ។ ព្រះអានន្ទដ៏មានអាយុ ទទួលព្រះបន្ទូលនៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។

ក្នុងទីបរិនិព្វានរបស់ព្រះតថាគត ព្រះអង្គទ្រង់ត្រាស់ប្រារព្ធចំពោះការបូជាដូច្នេះថា :

**យោ ខោ អានន្ទ ភិក្ខុ វា ភិក្ខុនី វា ឧបាសកោ**

**វា ឧបាសិកា វា ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ ។**

ម្នាលអានន្ទ បុគ្គលណាមួយ ទោះបីភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ជាប្រក្រតី បុគ្គលនោះឈ្មោះថា ធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត ដោយគ្រឿងបូជាដ៏ឧត្តម ។

**តស្មាតិហានន្ទ ធម្មានុធម្មប្បដិបន្នា វិហរិស្សាម សាមីចិប្បដិបន្នា អនុធម្មចារិនោតិ ឯវញ្ហិ វោ អានន្ទ សិក្ខិតព្វន្តិ ។**

ម្នាលអានន្ទ ព្រោះហេតុនោះ បរិស័ទក្នុងសាសនានេះ គប្បីសិក្សាថា យើងទាំងឡាយ នឹងប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ជាប្រក្រតី ម្នាលអានន្ទ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះឯង ។

( បិដកលេខ ១៦ , ទំព័រ ២៩១ )

ព្រះអង្គទ្រង់ត្រាស់ផ្តាំធ្វើជាចុងក្រោយ ដូច្នេះថា :





**យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ សោ វោ មមច្ចយេន សត្ថា ។**

ម្នាលអានន្ទ ធម៌ណាក្តី វិន័យណាក្តី ដែលតថាគតសម្តែងហើយ បញ្ញត្តហើយ ដល់អ្នកទាំងឡាយ លុះអំណើះតតអំពីតថាគតទៅ ធម៌និងវិន័យនោះ ជាគ្រូរបស់អ្នកទាំងឡាយ ។

( បិដកលេខ ១៦ , ទំព័រ ៣២១ )

**អថខោ ភគវា ភិក្ខូ អាមន្តេសិ ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថាតិ ។**

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា : ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះ ឥឡូវនេះ តថាគតប្រាប់អ្នកទាំងឡាយឱ្យបានដឹង សង្ខារទាំងឡាយ មានសេចក្តីសាបសូន្យជាធម្មតា អ្នកទាំងឡាយ ចូរញុំាងកិច្ចទាំងពួងឱ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ ។

( បិដកលេខ ១៦ , ទំព័រ ៣២៤ )

**អយំ តថាគតស្ស បច្ឆិមា វាចា** ។ នេះជាបច្ឆិមវាចារបស់ព្រះតថាគត ( ជាពាក្យព្រះសង្គីតិកាចារ្យទាំងឡាយ ) ។

*-កាលដែលព្រះដ៏មានព្រះភាគ បរិនិព្វាន សហម្បតិព្រហ្ម ក៏ពោលនូវគាថានេះ ព្រមនឹងការបរិនិព្វានរបស់ព្រះសាស្តាថា :

**សព្វេ វ និក្ខិបិស្សន្តិ ភូតា លោកេ សមុស្សយំ**
**យត្ថ ឯតាទិសោ សត្ថា លោកេ អប្បដិបុគ្គលោ**
**តថាគតោ ពលប្បត្តោ សម្ពុទ្ធោ បរិនិព្វុតោតិ ។**

ព្រះសាស្តា ដែលឥតបុគ្គលប្រៀបស្មើ ប្រាកដដូច្នេះ ព្រះ-តថាគតជាសម្ពុទ្ធបរិបូណ៌ហើយដោយកម្លាំង ទ្រង់បរិនិព្វានហើយក្នុងលោកណា ពួកសត្វទាំងអស់ មុខជានឹងដាក់ចុះនូវរាងកាយក្នុងលោកនោះ មិនខានឡើយ ។

(បិដកលេខ ១៦ , ទំព័រ ៣២៦)

ព្រះឥន្ទជាធំជាងទេវតា ក៏ពោលនូវគាថានេះ ព្រមនឹងការបរិនិព្វានរបស់ព្រះសម្មាសម្ពុទ្ធថា :

**អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ**
**ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោតិ ។**

សង្ខារទាំងឡាយមិនទៀងហ្ន៎ មានកិរិយាកើតឡើង និងសូន្យទៅជាធម្មតា លុះកើតឡើងហើយក៏រលត់ទៅវិញ កិរិយារម្ងាប់នូវសង្ខារទាំងនោះបាន ទើបនាំមកនូវសេចក្តីសុខ ។

(បិដកលេខ ១៦ , ទំព័រ ៣២៧)



ព្រះអនុរុទ្ធដ៏មានអាយុ ក៏ពោលនូវគាថាទាំងនេះ ព្រមនឹងការបរិនិព្វានរបស់ព្រះសម្មាសម្ពុទ្ធថា :

**នាហុ អស្សាសបស្សាសោ ឋិតចិត្តស្ស តាទិនោ**
**អនេជោ សន្តិមារព្ភ យំ កាលមករី មុនិ ។**
**អសល្លីនេន ចិត្តេន វេទនំ អជ្ឈវាសយិ**
**បជ្ជោតស្សេវ និព្វានំ វិមោក្ខោ ចេតសោ អហូតិ ។**

ព្រះមុនីនាថអង្គណា ដែលមិនមានតណ្ហា ទ្រង់ប្រារព្ធនូវអនុបាទិសេសនិព្វាន ទ្រង់ធ្វើនូវមរណកាល អស្សាសបស្សាសៈនៃព្រះមុនីនាថ ជាតាទិបុគ្គល ដែលមានព្រះហឫទ័យខ្ជាប់ខ្ជួននោះមិនមានហើយ ។ ព្រះមុនីនាថ ទ្រង់អត់សង្កត់នូវវេទនាបានដោយចិត្តមិនរួញរា សេចក្តីរលត់នៃចិត្តក៏កើតមាន បីដូចជាការរលត់នៃប្រទីប ។

(បិដកលេខ ១៦ , ទំព័រ ៣២៧)

ព្រះអានន្ទដ៏មានអាយុ ក៏ពោលនូវគាថានេះ ព្រមនឹងការបរិនិព្វានរបស់ព្រះសម្មាសម្ពុទ្ធថា :

**តទាសិ យំ ភឹសនកំ តទាសិ លោមហំសនំ**
**សព្វាការវរូបេតេ សម្ពុទ្ធេ បរិនិព្វុតេតិ ។**

កាលដែលព្រះសម្ពុទ្ធ ប្រកបដោយហេតុប្រសើរទាំងពួង ទ្រង់បរិនិព្វានហើយ សេចក្តីញាប់ញ័រក្តី សេចក្តីព្រឺរោមក្តី ក៏កើតមានប្រាកដ ។

(បិដកលេខ ១៦ , ទំព័រ ៣២៨)

## ដាក់អាយុសង្ខារ-បរិនិព្វាន

អង្គព្រះទ្រង់ញាណមានតេជះ សម្តែងប្រាប់ព្រះអានន្ទថា
រទេះដែលចាស់បរទៅណា ទៅបានដោយសារអបប្ញស្សី ។
តថាគតចាស់គ្រាំគ្រាហើយ ម្នាលអានន្ទអើយមានមាំអី
ដូចរទេះចាស់អបប្ញស្សី វស្សាឆ្នាំថ្មីប៉ែតសិបហើយ ។
ក្រោយព្រះអានន្ទទ្រង់ចេញផុត ពីព្រះសម្ពុទ្ធមិនយូរឡើយ
ក្រោយភត្តាហារថ្ងៃត្រង់ហើយ មារមិនកន្តើយគាល់សាស្តា ។
ឆ្នាំម្សាញ់ខែមាឃថ្ងៃអាទិត្យ ពេញបូណ៌មីពិតថ្ងៃនោះណា
ព្រះអង្គទ្រង់ដាក់អាយុសង្ខារ ចំពោះមុខមារគ្រានោះឯង ។
នៅនាបាវាលចេតិយ ក្បែរវេសាលីក្រៅកំផែង
កក្រើកធរណីគ្រប់កន្លែង ផ្គរលាន់ខ្ទាត់ខ្ទែងខ្ទរអាកាស ។





ក្រោយមកភិក្ខុជួបជុំគ្នា អង្គព្រះភគវាទ្រង់បានត្រាស់
សម្តែងគាថាអស្ចារ្យណាស់ រំលឹកយ៉ាងច្បាស់ត្រាស់ឱវាទ ។
*-ទ្រង់បានត្រាស់ថាសង្ខារទាំងឡាយ តែងតែអន្តរាយវិនាសខូចខាត
ចូរអ្នកទាំងឡាយកុំបីប្រមាទ ប្រឹងប្រែងសង្វាតឱ្យសម្រេចការ ។
ភាជន៍ដែលស្មូនឆ្នាំងដំដុតដោយដី តូចក្តីធំក្តីឆៅឆ្អិនយ៉ាងណា
ចុងក្រោយរមែងតែងមានកិរិយា បែកធ្លាយធម្មតានេះជាការពិត ។
យ៉ាងណាជីវិតសព្វសត្វនិករ ក្មេងចាស់មានក្រពាលឬបណ្ឌិត
ចុងក្រោយរមែងតែងតែស្លាប់ពិត បាត់បង់ជីវិតក៏យ៉ាងនោះដែរ ។
ជីវិតតថាគតមានប្រមាណតិច គោរពពាក្យពេចន៍ឥតគេចកែប្រែ
ពីថ្ងៃនេះទៅនៅត្រឹមបីខែ តថាគតត្រូវតែបរិនិព្វាន ។
*-បីខែកន្លងយ៉ាងរហ័ស សែនសោកស្តាយណាស់ព្រះទ្រង់ញាណ
វេលាជិតភ្លឺទ្រង់ចូលឈាន ហើយចូលនិព្វានកណ្តាលព្រៃ ។
ក្នុងខែពិសាខថ្ងៃអង្គារ ឆ្នាំម្សាញ់វេលាចុងរាត្រី
ថ្ងៃដប់ប្រាំកើតពេញបូណ៌មី បរិសទ្យប្រុសស្រីជុំត្រៀបត្រា ។
ទីទ្រង់និព្វាននោះតាំងនៅ ក្បែរផ្លូវទៅក្រុងកុសិនារា
រាំងភ្នំមួយគូសាលព្រឹក្សា មានផ្ទាំងសិលានៅចន្លោះ ។
កុំថាឡើយមនុស្សសោយសោកា សូម្បីទេវតាស្ថានទាំងអស់
យំសោកបោកប្រាណស្តាយស្រណោះ លាន់កក្រើកអស់ភពផែនដី ។

ទីទ្រង់និព្វាននោះឥឡូវ　　មានស្តូបតាំងនៅល្អប្រិមប្រិយ
សម្គាល់ទីដែលព្រះជិនស្រី　　និព្វានលើដីកុសិនារា ។
ក្នុងស្តូបមានព្រះបដិមាថ្ម　　កសាងយ៉ាងល្អគួរជ្រះថ្លា
តំណាងព្រះសពព្រះសាស្តា　　ស្តូកស្តឹងកាយាសែនអាសូរ ។
អ្នកទៅដល់ពិតចិត្តដិតជាប់　　ឃើញដូចព្រះសពនៅជ្រងោ
មានស្បង់ចីវរថ្វាយផ្លាស់ប្តូរ　　ទឹកនេត្រាហូរនឹកព្រះអង្គ ។
នឹកហាក់ដូចជានៅថ្មីៗ　　នឹកព្រះជិនស្រីប្រោសស្រោចស្រង់
នឹកដល់ព្រះធម៌ល្អផូរផង់　　នឹកទាំងព្រះសង្ឃអង្គសាវ័ក ។
ចាប់តាំងអំពីថ្ងៃនេះទៅ　　សូមដើរតាមផ្លូវព្រះអរិយៈ
ក្រោមម្លប់ព្រះធម៌ដ៏ត្រជាក់　　ផុតពីអន្ទាក់នៃពួកមារ ។
សូមឱ្យលោកអ្នកបានសូធ្យស្តាប់　　ប្រវត្តិសារសព្វព្រះភគវា
បានសុខចម្រើនគ្រប់ៗគ្នា　　កុំបីឃ្លាតឃ្លាគ្រាណាឡើយ ។

**សូមអនុមោទនា !!!**

ដោយឧបាសក **គុយ សុធន**

***_វត្តខ្មែរកុសិនារា** ជាទីរីករាយនៃពុទ្ធបរិស័ទ ។





## ព្រះគាថាក្នុងកន្លែងផ្សេងៗ

## ព្រះពុទ្ធដីកាជាសុភាសិត

( ក្នុងខុទ្ទកនិកាយ មហានិទ្ទេស បិ.៦៤ ,ទំ.៧៨_៧៩ )

**ជីវិតំ អត្តភាវោ ច　　សុខទុក្ខា ច កេវលា**
**ឯកចិត្តសមាយុត្តា　　លហុសោ វត្តតិក្ខណោ។**

ជីវិតក្តី អត្តភាពក្តី សុខឬទុក្ខក្តី គឺជាសភាវធម៌សុទ្ធៗ ប្រកបដោយខណៈចិត្តតែមួយ ខណៈនៃធម៌ទាំងនោះ ប្រព្រឹត្តទៅ គឺកន្លងទៅ យ៉ាងលឿនរហ័ស ។

**ចុល្លាសីតិសហស្សានិ　　កប្បា តិដ្ឋន្តិ យេ មរូ**
**ន ត្វេវ តេបិ ជីវន្តិ　　ទ្វីហិ ចិត្តេហិ សមាហិតា។**

ព្រហ្មទាំងឡាយណា ដែលតាំងនៅរហូត ៨ ម៉ឺន ៤ ពាន់មហាកប្បក៏ដោយ ក៏ព្រហ្មទាំងនោះ មិនបានរស់នៅដោយខណៈចិត្តពីរ ជាមួយគ្នាឡើយ ។

**យេ និរុទ្ធា មរន្តស្ស　　តិដ្ឋមានស្ស វា ឥធ**
**សព្វេវ សទិសា ខន្ធា　　គតា អប្បដិសន្ធិកា ។**

ខន្ធទាំងឡាយណា ដែលរលត់ទៅហើយ នៃអ្នកដែលដល់នូវសេចក្តីស្លាប់ ឬនៃអ្នកដែលកំពុងតាំងនៅក្នុងភពនេះ ខន្ធ

ទាំងឡាយនោះ មានសភាពរលត់ទៅដូចគ្នា កាលរលត់ទៅហើយ មិនកើតទៀតឡើយ ។

**អនិព្វត្តេន ន ជាតោ បច្ចុប្បន្នេន ជីវតិ**
**ចិត្តភង្គមតោ លោកោ បញ្ញត្តិ បរមត្ថិយា ។**

សត្វលោកឈ្មោះថានៅមិនទាន់កើត ដោយចិត្តនៅមិនទាន់កើត ឈ្មោះថាមានជីវិតរស់នៅ ដោយចិត្តដែលកំពុងកើតឡើង ឈ្មោះថាស្លាប់ហើយ ព្រោះចិត្តរលត់ទៅនេះជាបញ្ញត្តិអាស្រ័យបរមត្ថ ( សូម្បីដូច្នោះ ពាក្យបញ្ញត្តថាសត្វមានជីវិត ហាក់ដូចជាបរមត្ថមានពិត ) ។

**អនិធានគតា ភគ្គា បុញ្ជោ នត្ថិ អនាគតេ**
**និព្វត្តាយេវ តិដ្ឋន្តិ អារគ្គេ សាសបូបមា ។**

ខន្ធទាំងឡាយដែលបែកធ្លាយហើយ ក៏មិនដល់នូវកិរិយាតម្កល់ទុកឡើយ គំនរនៃខន្ធក្នុងអនាគតក៏មិនមាន ខន្ធទាំងឡាយដែលកើតឡើងហើយ រមែងតាំងនៅ ឧបមាដូចជាគ្រាប់ស្ពៃនៅនឹងចុងដែកស្រួច ។

**និព្វត្តានញ្ច ធម្មានំ ភង្គោ នេសំ បុរេក្ខតោ**
**បលោកធម្មា តិដ្ឋន្តិ បុរាណេហិ អមិស្សិតា ។**

កាលបើខន្ធទាំងឡាយកើតឡើងហើយ ការបែកធ្លាយនៃ



ខន្ធទាំងនោះ ក៏ស្ថិតនៅពីខាងមុខ ឯសភាវៈដែលត្រូវវិនាសទាំង-ឡាយ កំពុងតាំងនៅ មិនច្រឡូកច្រឡំដោយខន្ធចាស់ទេ ។

**អទស្សនតោ អាយន្តិ ភគ្គា គច្ឆន្តិ ទស្សនំ**
**វិជ្ជុប្បាទោវ អាកាសេ ឧប្បជ្ជន្តិ វយន្តិ ចាតិ។**

ខន្ធទាំងឡាយមកអំពីទីដែលមើលមិនឃើញ លុះបែកធ្លាយហើយ រមែងទៅកាន់ទីដែលមើលមិនឃើញវិញ តែងកើតឡើងហើយ វិនាសទៅវិញ ដូចផ្លេកបន្ទោរឰដ៏អាកាស ។

**ឯវំ ថិតិបរិត្តតាយ អប្បកំ ជីវិតំ ។**

ជីវិតតិច ព្រោះការតាំងនៅតិច យ៉ាងនេះឯង ។

**អប្បមាយុ មនុស្សានំ ហិឡេយ្យ នំ សុបោរិសោ**
**ចរេយ្យាទិត្តសីសោវ នត្ថិ មច្ចុស្ស នាគមោ ។**

អាយុរបស់ពួកមនុស្សតិច បុរសល្អគប្បីនឿយណាយនឹងអាយុនោះ គប្បីប្រព្រឹត្តដូចជាបុគ្គលដែលភ្លើងឆេះក្បាល ដំណើរមិនមកនៃមច្ចុមិនមានទេ ។

( បិដកលេខ ៦៤ , ទំព័រ ៨១ )

**អច្ចយន្តិ អហោរត្តា ជីវិតំ ឧបរុជ្ឈតិ**
**អាយុ ខីយតិ មច្ចានំ កុន្នទីនំវ ឧទកន្តិ ។**

ថ្ងៃនិងយប់តែងកន្លងទៅ ជីវិតក៏ស្រកស្រុតទៅដែរ អាយុរបស់ពួកសត្វ រមែងអស់ទៅ ដូចជាទឹកនៃស្ទឹងតូចទាំងឡាយដូច្នោះឯង ។

(បិដកលេខ ៦៤ , ទំព័រ ៨១)

**មមាយិតេ បស្សថ ផន្ទមានេ**
**មច្ឆេវ អប្បោទកេ ខីណសោតេ**
**ឯតម្បិ ទិស្វា អមមោ ចរេយ្យ**
**ភវេសុ អាសត្តិមកុព្វមានោ ។**

អ្នកទាំងឡាយ ចូរមើលពួកសត្វដែលកំពុងតែញាប់ញ័រ ក្នុងរបស់ដែលប្រកាន់ថាជារបស់យើង ដូចពួកត្រីក្នុងទីដែលមានទឹកតិច ទាំងដែលមានខ្សែទឹកអស់ហើយ ។ បុគ្គលលុះឃើញទោសនោះហើយ គប្បីប្រព្រឹត្តឱ្យជាអ្នកមិនប្រកាន់ថាជារបស់យើង មិនធ្វើនូវការជាប់ជំពាក់ក្នុងភពទាំងឡាយ ។

(បិដកលេខ ៦៤ , ទំព័រ ៨៩)

**សោចន្តិ ជនា មមាយិតេ**
**ន ហិ សន្តិ និច្ចា បរិគ្គហា**



**វិនាភាវសន្តមេវិទំ**
**ឥតិ ទិស្វា នាគារមាវសេ ។**

ពួកជនរមែងសោកស្តាយ ចំពោះវត្ថុដែលហួងហែង ការហួងហែងទាំងឡាយ ពុំមែនជាការទៀងទាត់ទេ វត្ថុនោះមានសភាពព្រាត់ប្រាសដោយពិត បុគ្គលកាលឃើញដូច្នេះហើយ មិនគួរនៅគ្រប់គ្រងផ្ទះឡើយ ។

(បិដកលេខ ៦៤ , ទំព័រ ២២៩)

**មរណេនបិ តំ បហីយតិ**
**យំ បុរិសោ មមយិទន្តិ មញ្ញតិ**
**ឯតម្បិ វិទិត្វា បណ្ឌិតោ**
**ន មមត្តាយ នមេថ មាមកោ ។**

បុគ្គលសម្គាល់នូវខន្ធបញ្ចកៈណាថា នេះរបស់អញ ខន្ធបញ្ចកៈនោះរមែងសាបសូន្យដោយមរណៈ បណ្ឌិតជាអ្នករាប់អាន (ព្រះរតនត្រ័យ) ដឹងច្បាស់ដំណើរនោះហើយ មិនគប្បីបង្អោនទៅក្នុងការហួងហែងថាជារបស់យើងឡើយ ។

(បិដកលេខ ៦៤ , ទំព័រ ២៣៣)

**សុបិនេន យថាបិ សង្គតំ**
**បដិពុទ្ធោ បុរិសោ ន បស្សតិ**
**ឯវម្បិ បិយាយិតំ ជនំ**
**បេតំ កាលកតំ ន បស្សតិ ។**

បុគ្គលភ្ញាក់ឡើងហើយ មិនឃើញអារម្មណ៍ដែលជួបប្រទះដោយការយល់សប្តិយ៉ាងណា បុគ្គលមិនឃើញជនជាទីស្រឡាញ់ដែលធ្វើមរណកាល ទៅកាន់បរលោកហើយ ក៏យ៉ាងនោះដែរ ។

( បិដកលេខ ៦៤ , ទំព័រ ២៣៧ )

**សព្វត្ថ មុនិ អនិស្សិតោ**
**ន បិយំ កុព្វតិ នោបិ អប្បិយំ**
**តស្មឹ បរិទេវមច្ឆរំ**
**បណ្ណេ វារិ យថា ន លិម្បតិ ។**

មុនីមិនអាស្រ័យនៅ ក្នុងវត្ថុទាំងពួង មិនធ្វើសេចក្តីស្រឡាញ់ ទាំងមិនធ្វើសេចក្តីស្អប់ចំពោះសត្វ និងសង្ខារ សេចក្តីខ្សឹកខ្សួល និងសេចក្តីកំណាញ់ មិនជាប់នៅក្នុងមុនីនោះ ដូចជាទឹកមិនជាប់នៅលើស្លឹកឈូក ។

( បិដកលេខ ៦៤ , ទំព័រ ២៥០ )



**ឧទកពិន្ទុ យថាបិ បោក្ខរេ**
**បទុមេ វារិ យថា ន លិម្បតិ**
**ឯវំ មុនិ នោ បលិម្បតិ**
**យទិទំ ទិដ្ឋ សុតំ មុតេសុ វា ។**

តំណក់ទឹកមិនជាប់នៅលើស្លឹកឈូកយ៉ាងណា ទឹកមិនជាប់នៅលើផ្កាឈូកយ៉ាងណា មុនីមិនជាប់នៅក្នុងអារម្មណ៍ ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ក៏យ៉ាងនោះដែរ ។

( បិដកលេខ ៥៤ , ទំព័រ ២៧៧ ឬ បិដកលេខ ៦៤ , ទំព័រ ២៥៥ )

***-មកុដពន្ធនចេតិយ** នៅខាងកើតក្រុងកុសិនារា ជាកន្លែងថ្វាយព្រះភ្លើង បូជាព្រះបរមសពនៃព្រះសម្មាសម្ពុទ្ធ ។ ទោណព្រាហ្មណ៍បានពោលនឹងពួកគណៈទូតទាំងឡាយដូច្នេះថា :

លោកទាំងឡាយដ៏ចម្រើន សូមស្តាប់ពាក្យរបស់ខ្ញុំមួយម៉ាត់សិន ព្រះពុទ្ធជាម្ចាស់នៃយើង ព្រះអង្គជាខន្តិវាទ ( អ្នកពោលសរសើរគុណនៃខន្តី ) មែនពិត ការប្រហារគ្នា (ច្បាំងគ្នា ) ព្រោះតែចំណែកនៃព្រះសារីរិកធាតុ របស់ឧត្តមបុគ្គលនេះ មិនប្រពៃឡើយ ។

បពិត្រលោកទាំងឡាយដ៏ចម្រើន យើងទាំងអស់គ្នា (គួរតែ)

ស្រុះស្រួលគ្នា ព្រមព្រៀងគ្នា រីករាយរកគ្នា ចែកព្រះសារីរិកធាតុ ឱ្យជា ៨ ចំណែក ព្រះស្តូបទាំងឡាយ សូមផ្សាយទៅក្នុងទិស ទាំងឡាយចុះ ពួកជនច្រើនគង់ជ្រះថ្លាចំពោះព្រះសម្ពុទ្ធដ៏មានចក្ខុ មិនលែងឡើយ ។

## ធាតុចេតិយនមស្ការគាថា

**មហាគោតមសម្ពុទ្ធោ　　កុសិនារាយ និព្វុតោ**
**ធាតុវិត្ថារកំ កត្វា　　តេសុ តេសុ វិសេសតោ**

ព្រះគោតមបរមសម្ពុទ្ធដ៏ប្រសើរ ព្រះអង្គបរិនិព្វានហើយ ជិតក្រុងកុសិនារា ធ្វើនូវកិរិយាផ្សាយនូវព្រះសារីរិកធាតុ ក្នុងទីទាំងឡាយនោះៗ ដោយផ្សេងៗ គ្នា

**ឧណ្ហីសំ ចតស្សោ ទាឋា អក្ខកា ទ្វេ ច សត្តមា**
**អសម្ភិន្នា វ តា សត្ត　　សេសា ភិន្នា វ ធាតុយោ**

ព្រះសារីរិកធាតុទាំងឡាយនោះ ដែលមិនបែកចេញមាន ៧អង្គគឺ ព្រះឧណ្ហីសធាតុ ១ ព្រះទាឋធាតុ ៤ ព្រះអក្ខកធាតុ ២ ព្រះសារីរិកធាតុដ៏សេសក្រៅពីនោះសុទ្ធតែបែកចេញ ( ជាចំណែកតូចៗ ) ។



**មហន្តា បញ្ច នាឡី ច　　មជ្ឈិមា ច ឆ នាឡិយោ**
**ខុទ្ទកា បញ្ច នាឡី ច　　សម្ភិន្នា តិវិធា មតា**

ព្រះបរមធាតុទាំងឡាយដែលបែកចេញ លោកពោលថា មាន ៣ យ៉ាងគឺ ព្រះធាតុខ្នាតធំវាល់បានចំនួន ៥ នាឡិ ព្រះធាតុខ្នាតកណ្តាលវាល់បានចំនួន ៦ នាឡិ ព្រះធាតុខ្នាតតូចវាល់បានចំនួន ៥ នាឡិ ។

**មហន្តា ភិន្នមុគ្គា ច　　មជ្ឈិមា ភិន្នតណ្ឌុលា**
**ខុទ្ទកា សាសបមត្តា　　ឯវំ ធាតុប្បមាណិកា**

ព្រះបរមធាតុទាំងឡាយ មានប្រមាណយ៉ាងនេះ គឺព្រះ-ធាតុខ្នាតធំ មានទំហំប៉ុនកំណាត់គ្រាប់សណ្តែកបាយ ព្រះធាតុខ្នាតកណ្តាល មានទំហំប៉ុនកំណាត់គ្រាប់អង្ករ ព្រះធាតុខ្នាតតូច មានទំហំប៉ុនគ្រាប់ស្ពៃ ។

**មហន្តា សុវណ្ណវណ្ណា　　មជ្ឈិមា ផលិកប្បភា**
**ខុទ្ទកា ពកុលវណ្ណា　　តាបិ វន្ទាមិ ធាតុយោ**

ព្រះបរមធាតុទាំងឡាយ ( មានពណ៌ផ្សេងគ្នាយ៉ាងនេះគឺ ) ព្រះធាតុខ្នាតធំ មានពណ៌ដូចមាស ព្រះធាតុខ្នាតកណ្តាល មានពណ៌ដូចកែវផលិក ព្រះធាតុខ្នាតតូច មានពណ៌ដូចផ្កាថ្កុល ខ្ញុំព្រះ-ករុណា សូមក្រាបថ្វាយបង្គំ នូវព្រះបរមធាតុទាំងឡាយនោះ ។

**ឯកោ ថូបោ រាជគហេ    ឯកោ វេសាលិយា អហុ**

**ឯកោ កបិលវត្ថុស្មឹ    ឯកោ ច អល្លកប្បកេ**

**ឯកោ ច រាមគាមស្មឹ    ឯកោ ច វេដ្ឋទីបកេ**

**ឯកោ បាវេយ្យកេ មល្លេ ឯកោ ច កុសិនារកេ**

ព្រះសថូប ១ ប្រតិស្ឋានទៅក្នុងក្រុងរាជគ្រឹះ ព្រះសថូប ១ ប្រតិស្ឋានទៅក្នុងក្រុងវេសាលី ព្រះសថូប ១ ប្រតិស្ឋានទៅក្នុងក្រុងកបិលពស្តុ ព្រះសថូប ១ ប្រតិស្ឋានទៅក្នុងក្រុងអល្លកប្បកៈ ព្រះសថូប ១ ប្រតិស្ឋានទៅក្នុងរាមគ្រាម ព្រះសថូប ១ ប្រតិស្ឋានទៅក្នុងក្រុងវេដ្ឋទីបកៈ ព្រះសថូប ១ ប្រតិស្ឋានទៅក្នុងក្រុងបាវេយ្យកៈ ក្នុងមល្លរដ្ឋជនបទ ព្រះសថូប ១ ប្រតិស្ឋានទៅក្នុងក្រុងកុសិនារា

**ឯតេ សារីរិកា ថូបា    ជម្ពូទីបេ បតិដ្ឋិតា**

**បូជិតា នរទេវេហិ    អហំ វន្ទាមិ ធាតុយោ**

ព្រះសថូប ( ទាំង ៨ ) នុ៎ះ ជាព្រះសថូបបញ្ចុះព្រះបរមសារីរិកធាតុ ប្រតិស្ឋានទៅក្នុងជម្ពូទ្វីប ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះបរមធាតុទាំងឡាយ ( ក្នុងព្រះសថូបទាំង ៨ នោះ ) ដែលទេវតានិងមនុស្សទាំងឡាយ តែងបូជា ។

**ឯកា ទាឋា តិទសបុរេ    ឯកា នាគបុរេ អហុ**





**ឯកា គន្ធារវិសយេ    ឯកា សីហឡទីបកេ**

ព្រះទាឋធាតុអង្គ ១ ប្រតិស្ឋានទៅក្នុងស្ថានត្រ័យត្រិង្ស ព្រះទាឋធាតុអង្គ ១ ប្រតិស្ឋានទៅក្នុងពិភពនាគ ព្រះទាឋធាតុអង្គ ១ ប្រតិស្ឋានទៅក្នុងគន្ធាររដ្ឋ ព្រះទាឋធាតុអង្គ ១ ប្រតិស្ឋានទៅក្នុងសីហឡទ្វីប

**ឥមា ចតូសុ ឋានេសុ    សត្ថុ ទាឋា បតិដ្ឋិតា**

**បូជិតា នរទេវេហិ    អហំ វន្ទាមិ ធាតុយោ**

ព្រះទាឋធាតុទាំងឡាយនេះ របស់ព្រះបរមសាស្ដា ប្រតិស្ឋានទៅក្នុងទីទាំងឡាយ ៤ កន្លែង ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយ ដែលទេវតានិងមនុស្សទាំងឡាយតែងបូជា ។

**ឧណ្ហិំ ទក្ខិណទាឋា ច    តាវតឹសេ បតិដ្ឋិតា**

**អធោ ទក្ខិណទាឋា ច    សីហឡទីបេ បតិដ្ឋិតា**

**វាមទាឋា ច ឧណ្ហម្បិ    គន្ធាររដ្ឋេ បតិដ្ឋិតា**

**វាមទាឋា ច អធោបិ    នាគលោកេ បតិដ្ឋិតា**

**បូជិតា នរទេវេហិ    អហំ វន្ទាមិ ធាតុយោ**

ព្រះទាឋធាតុស្កាំខាងលើ ប្រតិស្ឋានទៅក្នុងស្ថានតាវត្តិង្ស ព្រះទាឋធាតុស្កាំខាងក្រោម ប្រតិស្ឋានទៅក្នុងសីហឡទ្វីប ព្រះ-

ទាឋធាតុឆ្វេងខាងលើ ប្រតិស្ឋាននៅក្នុងដែនគន្ធារ ព្រះទាឋធាតុឆ្វេងខាងក្រោម ប្រតិស្ឋាននៅក្នុងពិភពនាគ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយ ដែលទេវតានិងមនុស្សទាំងឡាយតែងបូជា ។

**ព្រហ្មលោកេ ទុស្សធាតុ- វាមអក្ខកធាតុយោ**
**សព្វេ ព្រហ្មាភិបូជេន្តិ ថូបំ ទ្វាទសយោជនំ**

ព្រះទុស្សធាតុនិងព្រះអក្ខកធាតុខាងឆ្វេង ប្រតិស្ឋាននៅក្នុងព្រហ្មលោក ព្រហ្មទាំងឡាយទាំងអស់គ្នា តែងបូជានូវព្រះសថូបកម្ពស់ ១២ យោជន៍ (ដែលបញ្ចុះនូវធាតុទាំងនោះ)

**តាវតឹសម្ហិ ទេវានំ ចុឡាមណិម្ហិ កេសកំ**
**សព្វេ ទេវាភិបូជេន្តិ បសន្នា ពុទ្ធសាសនេ**
**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ**

ទេវតាទាំងឡាយទាំងពួង ដែលជាអ្នកជ្រះថ្លាក្នុងព្រះពុទ្ធសាសនា តែងបូជានូវព្រះកេសធាតុដែលប្រតិស្ឋាននៅក្នុងចូឡាមណីចេតិយ របស់ទេវតាទាំងឡាយក្នុងស្ថានត្រ័យត្រិង្ស ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយ ដែលទេវតានិងមនុស្សទាំងឡាយតែងបូជា ។

**ចត្តាឡីស សមាទន្តា កេសា លោមា នខាបិ ច**





**ទេវា ហរន្តិ ឯកេកំ ចក្កវាឡបរម្បរា**
**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ**

ព្រះទន្តធាតុទាំងឡាយ ៤០ គត់ផង ព្រះកេសធាតុទាំងឡាយផង ព្រះលោមធាតុទាំងឡាយផង ព្រះនខធាតុទាំងឡាយផង ទេវតាទាំងឡាយនាំទៅនូវព្រះធាតុមួយអង្គៗ កាន់ចក្កវាឡដទៃនិងដទៃ គឺព្រះធាតុមួយអង្គៗ ក្នុងចក្កវាឡមួយៗ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយ ដែលទេវតានិងមនុស្សទាំងឡាយតែងបូជា ។

**អដ្ឋារស ទ្វេ វស្សសតេ ធម្មាសោកោ តទា អហុ**
**ចតុរាសីតិសហស្សា ចេតិយា ច ការាបិតា**
**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ**

នាកាលព្រះពុទ្ធសករាជបាន ២១៨ ឆ្នាំ មានព្រះមហាក្សត្រ ១ អង្គទ្រង់ព្រះនាមធម្មាសោក ក្នុងកាលនោះព្រះអង្គបានកសាងព្រះចេតិយចំនួន ៨ ហ្មឺន ៤ ពាន់ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះធាតុទាំងឡាយ (ក្នុងព្រះចេតិយទាំងនោះ) ដែលទេវតានិងមនុស្សទាំងឡាយតែងបូជា ។ (ចាកភាណវរៈ សែម សូរ)

**(ចប់ ធាតុចេតិយនមស្ការគាថា)**

# កុសិនារា

ខ្ញុំសូមរៀបរាប់ហេតុបីប្រការ ដែលព្រះសាស្តាយាងមកនិព្វាន
នៅកុសិនារាសាស្តាទ្រង់ញាណ នូវហេតុដែលមានទាំងបីប្រការ ។
ទីមួយព្រោះមហាសុទស្សន- សូត្រមានស្តេចចក្ររុងរឿងអស្ចារ្យ
មានរាជធានីនៅកុសិនារា កាលនោះឈ្មោះថាកុសាវតី ។
ជនច្រើនបានស្តាប់ព្រះសូត្រនេះហើយ មិននៅកន្តើយហើយខំឃ្នាតខ្ចី
បំពេញកុសលនៅដោយស្មារតី ឃើញថាអ្វីៗសុទ្ធអនិច្ចា ។
ទីពីរព្រោះប្រោសនាយសុភទ្ទៈ ដែលជាសាវ័កអាស្រ័យសាស្តា
ព្រះអង្គទ្រង់ប្រោសប្រទានន័យថា ក្រៅព្រះសាសនាមិនមានសមណៈ ។
សុភទ្ទស្តាប់ហើយរកត្រើយនិព្វាន សាស្តានៅមានបួសជាសាវ័ក
ព្យាយាមសម្រេចអរហត្តមគ្គ បច្ឆិមសាវ័កនាមសុភទ្ទោ ។
ទីបីព្រោះហេតុចែកនូវព្រះធាតុ កុំឱ្យវិវាទដល់ថ្នាក់ឈាមហូរ
គឺបានទោណព្រាហ្មណ៍ដែលធ្លាប់ជាគ្រូ ខំប្រឹងតស៊ូពោលពីខន្តី ។
សូមអ្នកទាំងឡាយរីករាយរកគ្នា ធាតុព្រះភគវាចែកជាប្រាំបី
ព្រះពុទ្ធបរមគ្រូសរសើរខន្តី ឈ្លោះគ្នាធ្វើអ្វីចែកគ្នាទើបល្អ ។
ឱកុសិនារាសាលព្រឹក្សឧទ្យាន ឋានព្រះទ្រង់ញាណនិព្វានពិតប្រាកដ
នៅតែព្រះធម៌ឱ្យសត្តនិករ ដើរតាមផ្លូវល្អតាមស្នាមព្រះបាទ ។

ដោយ **ប.ស.ទ.**





# កបិលពស្ថុនិងរាមគ្រាម

*-**ធម្មនិយាម** គឺទំនៀមនៃព្រះបរមពោធិសត្វយាងចុះកាន់ព្រះគភ៌នៃព្រះវរមាតា :

១-គ្រានោះពន្លឺភ្លឺស្វាងច្បាស់រកប្រមាណមិនបាន បានកើតប្រាកដឡើងក្នុងលោក ។

២-មានទេវបុត្រ ៤ អង្គ តែងចូលទៅរក្សាក្នុងទិសទាំង ៤ ដោយគិតថា កុំឱ្យមនុស្ស និងអមនុស្សណានីមួយ បៀតបៀនព្រះបរមពោធិសត្វ និងព្រះមាតានៃព្រះពោធិសត្វនោះបានឡើយ។

៣-ព្រះមាតានៃព្រះបរមពោធិសត្វ ជាអ្នកមានសីល ៥ ជាប្រក្រតី ( ដោយខ្លួនឯង ) ។

៤-ព្រះមាតានៃព្រះបរមពោធិសត្វ មិនមានចិត្តប្រកបដោយកាមគុណក្នុងបុរសទាំងឡាយ (សូម្បីតែព្រះបិតានៃព្រះបរមពោធិសត្វ ) ទាំងដែលមិនមាននូវបុរសណាម្នាក់ មានចិត្តត្រេកអរប្រព្រឹត្តកន្លងបានឡើយ ។

៥-ព្រះមាតានៃព្រះបរមពោធិសត្វ តែងបាននូវកាមគុណទាំង ៥ ជាប្រក្រតី (ព្រះរាជានៃនគរជុំវិញបញ្ជូនបណ្ណាការមក

ថ្វាយ ) ទ្រង់ស្កប់ស្កល់ប្រកបព្រម ដោយមានអ្នកផ្គាប់បម្រើសព្វគ្រប់ ។

៦.ព្រះមាតានៃព្រះបរមពោធិសត្វ មិនមានអាពាធណាមួយកើតឡើងឡើយ មានតែសេចក្តីសុខជាប្រក្រតី មានកាយមិនលំបាក ម្យ៉ាងទៀត បានទតឃើញព្រះបរមពោធិសត្វ ហាក់ដូចជាឋិតនៅក្រៅផ្ទៃ សព្វអវយវៈ ទាំងធំទាំងតូច មានឥន្ទ្រិយមិនថោកថយ ។

៧.ព្រះមាតានៃព្រះបរមពោធិសត្វ តែងទ្រង់គភ៌ព្រះបរមពោធិសត្វអស់ ១០ ខែគត់ ទើបប្រសូត ។

*.**ពេលទ្រង់ប្រសូត** :

១.ព្រះមាតានៃព្រះបរមពោធិសត្វ តែងប្រសូតព្រះបរមពោធិសត្វ ក្នុងឥរិយាបថឈរ ។

២.ក្នុងកាលដែលព្រះបរមពោធិសត្វប្រសូតចាកផ្ទៃនៃព្រះវរមាតា ទេវតាទាំងឡាយតែងទទួលព្រះបរមពោធិសត្វមុន ទើបមនុស្សទាំងឡាយទទួលក្រោយ(កាលព្រះសិទ្ធត្ថទ្រង់ប្រសូតគឺព្រហ្មជាខីណាស្រពជាន់សុទ្ធាវាស ទទួលមុន រួចទើបមហារាជទាំង ៤ ទទួលពីព្រះព្រហ្មខីណាស្រពនោះ ទើបពួកមនុស្សទទួលបន្ត ) ។



៣.ក្នុងកាលដែលព្រះបរមពោធិសត្វប្រសូតចាកផ្ទៃនៃព្រះវរមាតា ព្រះបរមពោធិសត្វមិនទាន់ចុះដល់ផែនដី មានទេវបុត្រទាំង ៤ ទទួលព្រះអង្គតម្កល់ក្នុងខាងមុខនៃព្រះមាតា ហើយពោលថា : បពិត្រព្រះនាងទេវី សូមព្រះនាងមានព្រះហឫទ័យរីករាយចុះ បុត្ររបស់ព្រះនាង ជាអ្នកមានសក្តិធំ ទ្រង់កើតឡើងហើយ ។

៤.ក្នុងកាលដែលព្រះបរមពោធិសត្វប្រសូតចាកផ្ទៃនៃព្រះវរមាតា គឺល្អល្អះស្រស់បស់ មិនប្រឡាក់ដោយទឹក មិនប្រឡាក់ដោយស្លេស្ម មិនប្រឡាក់ដោយឈាម មិនប្រឡាក់ដោយគ្រឿងអសោចណានីមួយឡើយ ជាអ្នកស្អាតបរិសុទ្ធ ។

៥.ក្នុងកាលដែលព្រះបរមពោធិសត្វប្រសូតចាកផ្ទៃនៃព្រះវរមាតា មានធារទឹក ២ ហូរចុះមកអំពីអាកាស ធារទឹក ១ ត្រជាក់ ធារទឹក ១ ក្តៅ ធ្វើនូវការលាងជម្រះព្រះពោធិសត្វផង ព្រះមាតាផង ។

៦.ក្នុងកាលដែលព្រះបរមពោធិសត្វប្រសូតមកភ្លាម ទ្រង់ប្រតិស្ឋានឈរដោយព្រះបាទជាន់ស៊ប់លើផែនដី ឆ្ពោះព្រះភក្ត្រទៅកាន់ទិសឧត្តរ ទ្រង់យាងឈានទៅបាន ៧ ជំហាន កាលដែលមហាជនកំពុងបាំងស្វេតច្ឆត្រថ្វាយ ក៏រមិលមើលនូវទិសទាំងពួងផង ទ្រង់ពោលនូវអាសភិវាចា គឺវាចាដ៏ឧត្តមផងថា :

**អគ្គោហមស្មិ លោកស្ស**

**ជេដ្ឋោហមស្មិ លោកស្ស**

**សេដ្ឋោហមស្មិ លោកស្ស**

យើងជាបុគ្គលខ្ពង់ខ្ពស់របស់លោក យើងជាបុគ្គលធំបំផុតរបស់លោក យើងជាបុគ្គលប្រសើរបំផុតរបស់លោក ។

**អយមន្តិមា មេ ជាតិ នត្ថិទានិ បុនព្ភវោតិ** ។

នេះជាកំណើតចុងក្រោយបំផុតរបស់យើង ឥឡូវនេះភពថ្មីតពីនេះទៅទៀត មិនមានឡើយ ។

៧.ក្នុងកាលដែលព្រះបរមពោធិសត្វប្រសូតចាកផ្ទៃនៃព្រះវរមាតា គ្រានោះ ពន្លឺភ្លឺស្វាងច្បាស់ រកប្រមាណមិនបាន បានកើតប្រាកដឡើងក្នុងលោក ។

៨.ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលព្រះពោធិសត្វប្រសូតមកបាន ៧ ថ្ងៃ ព្រះមាតានៃព្រះពោធិសត្វ តែងធ្វើមរណកាលទៅកើតនៅស្ថានតុសិត ។

✍-អដ្ឋកថា ប្រាប់អំពីបុព្វនិមិត្តទាំងឡាយ :

១.ការប្រតិស្ឋានលើផែនដីដោយព្រះបាទស្មើគ្នា ជាបុព្វនិមិត្តនៃការបានឥទ្ធិបាទ ៤ ។





២.ការបែរព្រះភក្ត្រទៅទិសឧត្តរ ជាបុព្វនិមិត្តនៃដំណើរដែលទ្រង់យាងទៅទូន្មានមហាជន ។

៣.ព្រះអង្គទ្រង់យាង ៧ ជំហាន ជាបុព្វនិមិត្តនៃការបានរតនៈ គឺពោជ្ឈង្គ ៧ ។

៤.ការកាន់ស្វេតច្ឆត្រទិព្វ ជាបុព្វនិមិត្តនៃការបានឆត្រដ៏ប្រសើរ គឺវិមុត្តិ ។

៥.ការរមិលមើលនូវទិសទាំងពួង ជាបុព្វនិមិត្តនៃការបានអនាវរណញ្ញាណ ។

៦.ការបន្លឺនូវអាសភិវាចា ជាបុព្វនិមិត្តនៃការប្រព្រឹត្តទៅនៃព្រះធម្មចក្កប្បវត្តនសូត្រ ។

៧.ការបន្លឺសីហនាទថា នេះជាជាតិចុងក្រោយបំផុតរបស់យើង ជាបុព្វនិមិត្តនៃការបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។ ក្នុងពេលស្តេចយាងចុះកាន់ព្រះគភ៌ និងពេលប្រសូត មានបុព្វនិមិត្តច្រើនប្រការទៀត ។

✳.**សសរថ្មបញ្ឈរនៅទីដែលព្រះអង្គទ្រង់ប្រសូត** រហូតដល់សព្វថ្ងៃ ពុទ្ធបរិស័ទច្រើនក្រែបង្គំវន្ទា ។

## ទ្រង់ប្រសូត

កាលព្រះសិទ្ធត្ថអម្ចាស់ថ្លៃ ស្ដេចចុះចាប់ផ្ទៃនៃព្រះមហា
មាយាទេវីពុទ្ធមាតា នៅឆ្នាំរកាពេញបូណ៌មី ។
នាខែអាសាឍថ្ងៃព្រហស្បតិ៍ ជារាជឱរសនៃព្រះស្រី
សុទ្ធោទនៈរាជម្ចាស់ផែនដី កបិលពស្តុបុរីរាជសីមា ។
ស្ដេចទ្រង់ប្រសូតចេញចាកផ្ទៃ មាតានៅថ្ងៃសុក្រថ្លៃថ្លា
នាពេញបូណ៌មីវិសាខា ឆ្នាំច នោះណាមានសួស្ដី ។
នៅពេលដែលព្រះវរមាតា យាត្រាចេញពីរាជបុរី
កបិលពស្តុទៅដើម្បី បង្គំព្រះបិតាមាតា ។
នៅឯទេវទហៈរាជធានី ដល់លុម្ពិនីវន័ថ្លៃថ្លា
ទ្រង់ជ្រកក្រោមម្លប់សាលព្រឹក្សា ទិវាត្រង់ជាក់ទ្រង់ឈឺផ្ទៃ ។
ទ្រង់ឈរតោងមែកព្រឹក្សាសាល អយ្យបុត្តត្រកាលឆោមប្រពៃ
ប្រសូតចាកគភ៌រួសរាន់រៃ វិស័យអ្នកទេសន៍ចាកធម្មា ។
ប្រសូតភ្លាមឈរដើរឈោងឈាន ប្រាំពីរជំហានព្រះបាទា
ទ្រង់បានបន្លឺព្រះវាចា ថាយើងនេះណាជាចម្បង ។
លើលោកទាំងបីឥតនរណា ផ្ទឹមស្មើអាត្មាយើងជាម្ដង
ជាតិនេះជាជាតិបំផុតហោង យើងនឹងចម្លងសត្វទាំងឡាយ ។





ឱ្យឆ្លងដល់ទីដ៏ក្សេមក្សាន្ត ដោយធម្មយានអត្ថបរិយាយ
ឱ្យឆ្លងដល់ត្រើយនិព្វាននាយ សូន្យឆ្ងាយចាកទុក្ខសុខមហិមា ។
ទីទ្រង់ប្រសូតនោះព្រះបាទ អសោកនាថស្ដេចឥណ្ឌា
ទ្រង់សាងគោលថ្មល្អសោភា មួយជាអនុស្សាវរីយ៍ ។
ខ្ញុំសូមក្រាបថ្វាយបង្គំស្មោះ ចំពោះអង្គព្រះមហាមុនី
ស្ដេចទ្រង់ប្រសូតនៅត្រង់ទី សួនលុម្ពិនីដោយសទ្ធា ។
សូមសុខសួស្ដីជយមង្គល ចូលដល់ខ្ញុំនិងអ្នករាល់គ្នា
ដែលបានសូធ្យស្ដាប់សព្វពណ៌នា ពុទ្ធប្បវត្តិនេះកុំបីខានឡើយ ។

-កំណាព្យនេះខ្ញុំព្រះករុណា ខ្ញុំបាទ **គុយ សុធន** បានចេះចាំមាត់តាំងពី ព.ស.២៥២៣ (ពេលចេញពីសម័យប៉ុល ពត ឆ្នាំ ១៩៧៩ ) ។ មិនដឹងថាជាស្នាដៃរបស់អ្នកនិពន្ធណាទេ ក្រោយមកខ្ញុំភ្លេចខ្លះ ខ្ញុំខំព្យាយាមរកកំណាព្យនេះវិញ តែរកមិនជួបសោះ ខ្ញុំក៏បន្ថែមពាក្យដែលភ្លេចដោយពាក្យខ្លួនឯង ដូច្នេះបើមានខុសពីកំណាព្យដើម សូមលោកអ្នកនិពន្ធមេត្តាអភ័យទោសដល់ខ្ញុំព្រះករុណា ខ្ញុំបាទដោយអនុគ្រោះផងចុះ ។

***-ក្រុងកបិលពស្តុ** នមស្ការនៅខ្លោងទ្វារខាងកើត ទីដែលព្រះអង្គទ្រង់ស្រូត ចេញសាងព្រះផ្នួស ។

***-ព្រះស្តូបទាំងគូ** គឺជាព្រះចេតិយនៃព្រះពុទ្ធបិតា និងព្រះពុទ្ធមាតា នៅទិសឦសានក្រុងកបិលពស្តុ ពុទ្ធបរិស័ទដើរមួយសន្ទុះពីខ្លោងទ្វារខាងកើតក្រុង ។

**✳-សសរថ្មព្រះបាទធម្មាសោក** បញ្ជាក់ទីប្រសូតនៃព្រះសម្មាសម្ពុទ្ធកោនាគមនោ (ចេញពីក្រុងកបិលពស្តុឆ្ងាយដែរ) ។

**✳-និគ្រោធារាម** ទីដែលព្រះរាហុល និងព្រះនន្ទជាដើម សាងផ្នួស ។ ព្រះបរមសាស្តា មួយអន្លើដោយព្រះអរហន្ត ២ ហ្មឺន អង្គ គង់នៅជាដំបូង កាលដែលព្រះអង្គទ្រង់យាងពីរាជគ្រឹះទៅប្រោសព្រះញាតិ ។ ទ្រង់ត្រាស់សម្តែងវេស្សន្តរជាតកក្តី ត្រាស់សម្តែងនូវពុទ្ធវង្សក្តី សុទ្ធតែនៅនិគ្រោធារាមនេះឯង ។

**✳-សសរថ្មព្រះបាទធម្មាសោក** បញ្ជាក់ទីប្រសូតនៃព្រះសម្មាសម្ពុទ្ធកក្កុសន្ធោ នៅអំពីនិគ្រោធារាម ប្រមាណបីគីឡូម៉ែត្រ។

**✳-រាមគ្រាម នគរទេវទហៈ** មានស្តូប គឺព្រះចេតិយ ដែលក្នុងកាលមុនបានបញ្ចុះព្រះធាតុមួយចំណែក គឺ ២ នាឡិ នៅទិសខាងលិចនៃក្រុងកបិលពស្តុ ។ ព្រះធាតុរាមគ្រាមនេះ សព្វថ្ងៃបញ្ចុះនៅសុវណ្ណមាលិកចេតិយស្រីលង្កា ។

**✳-ស្ទឹងរោហិណី** នៅរវាងនគរកបិលពស្តុ និងនគរទេវទហៈ ។ តាមផ្លូវសព្វថ្ងៃទៅថ្វាយបង្គំព្រះស្តូបនៅរាមគ្រាម ក៏





បានឆ្លងកាត់ស្ទឹងរោហិណី។ ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងអត្តទណ្ឌសូត្រ និងព្រះជាតកយ៉ាងច្រើនផ្សះផ្សាពួកព្រះញាតិទាំងពីរនគរ ។ ព្រះអានន្ទត្ថេរក៏បានបរិនិព្វាននៅឰដ៏អាកាសលើស្ទឹងរោហិណីនេះ អធិដ្ឋានចែកព្រះធាតុរបស់លោកឱ្យដល់ព្រះញាតិទាំងពីរនគរ គឺទាំងខាងសក្យវង្សនគរកបិលពស្តុ និងទាំងខាងកោលិយវង្សនគរទេវទហៈ ។

**✳-ព្រះស្តូប** ដែលក្នុងកាលមុនបានបញ្ចុះព្រះធាតុមួយចំណែក គឺ ២ នាឡិ នៅនគរកបិលពស្តុ ។ សព្វថ្ងៃគឺជាចំណែកទឹកដីក្នុងប្រទេសឥណ្ឌា ជាប់គ្នានឹងប្រទេសនេប៉ាល់ ។ ព្រះស្តូបនេះឋិតក្នុងបូជនីយដ្ឋានធំទូលាយ គួរជាទីរីករាយ ។

**✳-ព្រៃហិមពាន្ត** ដែលសព្វថ្ងៃនេះមានផ្លូវទៅកាន់ក្រុងកដ្ឋមណ្ឌូ ប្រទេសនេប៉ាល់ ជាផ្លូវទៅតាមមាត់ជ្រោះចោតជ្រៅស្រឡូង ។

**✳-វត្តខ្មែរលុម្ពិនី** ជាទីរីករាយនៃពុទ្ធបរិស័ទ ។

# ក្រុងសាវត្ថី

***-វត្តជេតពនដ៏អស្ចារ្យ** ព្រះបរមសាស្តា គង់ចាំវស្សាអស់ ១៩ ព្រះវស្សា ។ ទីនេះ តែងកើតមានវត្តគ្រប់ពេលដែលព្រះសម្មាសម្ពុទ្ធត្រាស់ដឹង ព្រះគន្ធកុដិ និងជើងគ្រែរបស់ព្រះពុទ្ធគ្រប់អង្គ ឋិតនៅក្នុងទីតែមួយ ។ ក្នុងបរិវេណវត្ត ពេញទៅដោយទីដែលព្រះអរហន្តធ្លាប់គង់នៅ មានវិហារ មានឧបដ្ឋានសាលា មានកុដិដ៏ច្រើន និងព្រះពោធិព្រឹក្សអានន្ទពោធិ៍ ។ល។

សង្ខារធម៌ទាំងឡាយ មិនទៀងមែនពិត ព្រះអរហន្តទាំងឡាយបរិនិព្វានទៅអស់ហើយ ព្រះអរិយបុគ្គលដទៃក៏មិនឃើញមានដែរ សល់តែកន្លែងឱ្យជាទីនឹករលឹកប៉ុណ្ណោះ ព្រះអរិយបុគ្គលទាំងនោះ ទៅតាមព្រះដ៏មានព្រះភាគអស់ហើយ ។

# មង្គលសូត្រ

(បិដកលេខ ៥២ , ទំព័រ ៤-៥)

**ឯវម្មេ សុតំ** ( សូត្រនេះឈ្មោះមង្គលសូត្រ ) គឺខ្ញុំ (ឈ្មោះ អានន្ទ) បានស្តាប់មកហើយយ៉ាងនេះថា





**ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ** សម័យមួយព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី ។

**អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ** លំដាប់នោះឯង ទេវតាអង្គ ១ កាលដែលវេលារាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏ល្អ ញុំាងវត្តជេតពនជុំវិញទាំងអស់ឱ្យភ្លឺស្វាង ហើយព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងទីណា ក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំចំពោះអង្គព្រះដ៏មានព្រះភាគ ហើយឈរនៅក្នុងទីដ៏សមគួរ ។

**ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ** កាលទេវតានោះឈរក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគ ដោយពាក្យជាគាថា ( យ៉ាងនេះ ) ថា :

**ពហូ ទេវា មនុស្សា ច មង្គលានិ អចិន្តយុំ**
**អាកង្ខមានា សោត្ថានំ ព្រូហិ មង្គលមុត្តមំ**

ទេវតានិងមនុស្សទាំងឡាយជាច្រើន ប្រាថ្នានូវសិរីសួស្តី

បានគិតរកនូវមង្គលទាំងឡាយ សូមព្រះអង្គ ទ្រង់ព្រះមេត្តាសម្តែងប្រាប់ នូវមង្គលដ៏ឧត្តម ។

(ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងតបពាក្យទេវតានោះដោយពុទ្ធភាសិតជាគាថាយ៉ាងនេះថា)

**អសេវនា ច ពាលានំ　　បណ្ឌិតានញ្ច សេវនា**
**បូជា ច បូជនីយានំ　　ឯតម្មង្គលមុត្តមំ ។**

កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ ១ កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ ១ កិរិយាបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ ១ ទាំង ៣ នេះជាមង្គលដ៏ឧត្តម ។

**បដិរូបទេសវាសោ ច　　បុព្វេ ច កតបុញ្ញតា**
**អត្តសម្មាបណិធិ ច　　ឯតម្មង្គលមុត្តមំ ។**

កិរិយានៅក្នុងប្រទេសដ៏សមគួរ ១ ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន ១ កិរិយាតម្កល់ខ្លួនដោយប្រពៃ ១ ទាំង ៣ នេះជាមង្គលដ៏ឧត្តម ។

**ពាហុសច្ចញ្ច សិប្បញ្ច　　វិនយោ ច សុសិក្ខិតោ**
**សុភាសិតា ច យា វាចា　ឯតម្មង្គលមុត្តមំ ។**

ភាវៈនៃបុគ្គលបានស្តាប់ បានរៀនហើយដោយច្រើន ១ សិល្បសាស្ត្រ គឺសេចក្តីឆ្លៀវឆ្លាសក្នុងហត្ថកម្មរបស់អ្នកបួសនិង





គ្រហស្ថ ១ វិន័យដែលបុគ្គលសិក្សាដោយប្រពៃ១ វាចាដែលបុគ្គលពោលត្រឹមត្រូវ ១ ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។

**មាតាបិតុឧបដ្ឋានំ　　បុត្តទារស្ស សង្គហោ**
**អនាកុលា ច កម្មន្តា　　ឯតម្មង្គលមុត្តមំ ។**

កិរិយាបម្រើនូវមាតា ១ កិរិយាបម្រើនូវបិតា ១ សេចក្តីសង្គ្រោះដល់បុត្រនិងភរិយា ១ ការងារទាំងឡាយដែលមិនច្របូកច្របល់ ១ ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។

**ទានញ្ច ធម្មចរិយា ច　　ញាតកានញ្ច សង្គហោ**
**អនវជ្ជានិ កម្មានិ　　ឯតម្មង្គលមុត្តមំ ។**

កិរិយាបរិច្ចាគទាន ១ កិរិយាប្រព្រឹត្តនូវធម៌ ១ សេចក្តីសង្គ្រោះដល់ញាតិទាំងឡាយ ១ ការងារទាំងឡាយដែលមិនមានទោស ១ ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។

**អារតី វិរតី បាបា　　មជ្ជបានា ច សញ្ញមោ**
**អប្បមាទោ ច ធម្មេសុ　　ឯតម្មង្គលមុត្តមំ ។**

កិរិយាមិនត្រេកអរក្នុងបាបនិងកិរិយាវៀរចាកបាប ១ សេចក្តីសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង ១ សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ ១ ទាំង ៣ នេះជាមង្គលដ៏ឧត្តម ។

**គារវោ ច និវាតោ ច　　សន្តុដ្ឋី ច កតញ្ញុតា**

**កាលេន ធម្មស្សវនំ ឯតម្មង្គលមុត្តមំ ។**

សេចក្ដីគោរពចំពោះបុគ្គលដែលគួរគោរព ១ កិរិយាប្រព្រឹត្តបន្ទាបនូវខ្លួន ១ សេចក្ដីត្រេកអរចំពោះរបស់ដែលមាន ១ ភាវៈនៃបុគ្គលអ្នកដឹងនូវឧបការៈដែលអ្នកដទៃធ្វើហើយដល់ខ្លួន ១ កិរិយាស្ដាប់នូវធម៌តាមកាល ១ ទាំង ៥ នេះជាមង្គលដ៏ឧត្ដម ។

**ខន្តី ច សោវចស្សតា សមណានញ្ច ទស្សនំ**
**កាលេន ធម្មសាកច្ឆា ឯតម្មង្គលមុត្តមំ ។**

សេចក្ដីអត់ធន់ ១ ភាវៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ ១ កិរិយាបានឃើញបានជួបនូវសមណៈទាំងឡាយ ១ ធម្មសាកច្ឆា គឺកិរិយាសន្ទនាទៅវិញទៅមកនូវធម៌តាមកាល ១ ទាំង ៤ នេះជាមង្គលដ៏ឧត្ដម ។

**តបោ ច ព្រហ្មចរិយញ្ច អរិយសច្ចាន ទស្សនំ**
**និព្វានសច្ឆិកិរិយា ច ឯតម្មង្គលមុត្តមំ ។**

សេចក្ដីព្យាយាមដុតនូវបាបធម៌ ១ កិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ១ កិរិយាឃើញនូវអរិយសច្ចទាំងឡាយ ១ កិរិយាធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ១ ទាំង ៤ នេះជាមង្គលដ៏ឧត្ដម ។

**ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ**
**អសោកំ វិរជំ ខេមំ ឯតម្មង្គលមុត្តមំ ។**





ចិត្តនៃបុគ្គលឯណា ដែលលោកធម៌ទាំងឡាយពាល់ត្រូវហើយ មិនរំភើបញាប់ញ័រ ១ មិនមានសេចក្ដីសោក ១ មានធូលីគឺរាគៈទៅប្រាសហើយ ១ ជាចិត្តក្សេមក្សាន្ត ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្ដម ។

**ឯតាទិសានិ កត្វាន សព្វត្ថមបរាជិតា**
**សព្វត្ថ សោត្ថឹ គច្ឆន្តិ តន្តេសំ មង្គលមុត្តមន្តិ។**

ទេវតានិងមនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ ក្នុងទីទាំងពួង តែងដល់នូវសិរីសួស្ដី ក្នុងទីទាំងពួង ( ម្នាលទេវតា អ្នកចូរប្រកាន់ជឿថា ) មង្គលទាំង ៣៨ ប្រការ មានកិរិយាមិនសេពគប់នូវបុគ្គលពាលជាដើមនោះ របស់ទេវតានិងមនុស្សទាំងអម្បាលនោះ ជាមង្គលដ៏ឧត្ដម ។ (លំនាំសូត្រតាមភាណវារៈ)

**( មង្គលសូត្រចប់)**

*-ព្រះដ៏មានព្រះភាគ ទ្រង់ស្ដាបនាងតទគ្គបុគ្គលទាំងអស់នាវត្តជេតពនមហាវិហារ ។

## ឯតទគ្គបុគ្គល

(បិដកលេខ ៤០ ,ទំព័រ ៥៣-៥៨)

*-ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ៖

១-រត្តញ្ញូនំ យទិទំ អញ្ញាកោណ្ឌញ្ញោ ។

២-មហាបញ្ញានំ យទិទំ សារីបុត្តោ ។

៣-ឥទ្ធិមន្តានំ យទិទំ មហាមោគ្គល្លានោ ។

៤-ធុតវាទានំ យទិទំ មហាកស្សបោ ។

៥-ទិព្វចក្ខុកានំ យទិទំ អនុរុទ្ធោ ។

៦-ឧច្ចាកុលិកានំ យទិទំ ភទ្ទិយោ កាឡិគោធាយ-បុត្តោ ។

៧-មញ្ជុស្សរានំ យទិទំ លកុណ្ឌកភទ្ទិយោ ។

៨-សីហនាទិកានំ យទិទំ បិណ្ឌោលភារទ្វាជោ ។

៩-ធម្មកថិកានំ យទិទំ បុណ្ណោ មន្តានីបុត្តោ ។

១០-សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ វិភជន្តានំ យទិទំ មហាកច្ចានោតិ ៚

វគ្គោ បឋមោ ៚



*-ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ៖

១-មនោមយំ កាយំ អភិនិម្មិនន្តានំ យទិទំ ចុល្ល-បន្ថកោ ។ ចេតោវិវដ្ដកុសលានំ យទិទំ ចុល្លបន្ថកោ ។

២-បញ្ញាវិវដ្ដកុសលានំ យទិទំ មហាបន្ថកោ ។

៣-អរណវិហារីនំ យទិទំ សុភូតិ ។ ទក្ខិណេយ្យានំ យទិទំ សុភូតិ ។

៤-អារញ្ញកានំ យទិទំ រេវតោ ខទិរវនិយោ ។

៥-ឈាយីនំ យទិទំ កង្ខារេវតោ ។

៦-អារទ្ធវីរិយានំ យទិទំ សោណោ កោលិវិសោ ។

៧-កល្យាណវាក្ករណានំ យទិទំ សោណោ កុដិ-កណ្ណោ ។

៨-លាភីនំ យទិទំ សីវលី ។

៩-សទ្ធាធិមុត្តានំ យទិទំ វក្កលីតិ ។

វគ្គោ ទុតិយោ ៚

*-ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ៖

១-សិក្ខាកាមានំ យទិទំ រាហុលោ ។

២-សទ្ធាបព្វជិតានំ យទិទំ រដ្ឋបាលោ ។

៣~បឋមំ សលាកំ គណ្ហន្តានំ យទិទំ កុណ្ឌធានោ ។

៤~បដិភាណវន្តានំ យទិទំ វង្គីសោ ។

៥~សមន្តប្បាសាទិកានំ យទិទំ ឧបសេនោ វង្គន្តបុត្តោ ។

៦~សេនាសនប្បញ្ញាបកានំ យទិទំ ទព្វោ មល្លបុត្តោ ។

៧~ទេវតានំ បិយមនាបានំ យទិទំ បិលិន្ទវច្ឆោ ។

៨~ខិប្បាភិញ្ញានំ យទិទំ ពាហិយោ ទារុចីរិយោ ។

៩~ចិត្តកថិកានំ យទិទំ កុមារកស្សបោ ។

១០~បដិសម្ភិទប្បត្តានំ យទិទំ មហាកោដ្ឋិតោតិ ។

វគ្គោ តតិយោ ៚

*_ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ :

១~ពហុស្សុតានំ យទិទំ អានន្ទោ ។ សតិមន្តានំ យទិទំ អានន្ទោ ។ គតិមន្តានំ យទិទំ អានន្ទោ ។ ធិតិមន្តានំ យទិទំ អានន្ទោ ។ ឧបដ្ឋាកានំ យទិទំ អានន្ទោ ។

២~មហាបរិសានំ យទិទំ ឧរុវេលកស្សបោ ។





៣~កុលប្បសាទកានំ យទិទំ កាឡុទាយិ ។

៤~អប្បាពាធានំ យទិទំ ពក្កុលោ ។

៥~បុព្វេនិវាសំ អនុស្សរន្តានំ យទិទំ សោភិតោ ។

៦~វិនយធរានំ យទិទំ ឧបាលិ ។

៧~ភិក្ខុនោវាទកានំ យទិទំ នន្ទកោ ។

៨~ឥន្ទ្រិយេសុ គុត្តទ្វារានំ យទិទំ នន្ទោ ។

៩~ភិក្ខុឱវាទកានំ យទិទំ មហាកប្បិនោ ។

១០~តេជោធាតុកុសលានំ យទិទំ សាគតោ ។

១១~បដិភាណេយ្យកានំ យទិទំ រាធោ ។

១២~លូខចីវរធរានំ យទិទំ មោឃរាជាតិ ។

វគ្គោ ចតុត្ថោ ៚

*_ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ភិក្ខុនីនំ :

១~រត្តញ្ញូនំ យទិទំ មហាបជាបតី គោតមី ។

២~មហាបញ្ញានំ យទិទំ ខេមា ។

៣~ឥទ្ធិមន្តីនំ យទិទំ ឧប្បលវណ្ណា ។

៤~វិនយធរានំ យទិទំ បដាចារា ។

៥~ធម្មកថិកានំ យទិទំ ធម្មទិន្នា ។

៦. ឈាយិនីនំ យទិទំ នន្ទា ។

៧. អារទ្ធវីរិយានំ យទិទំ សោណា ។

៨. ទិព្វចក្ខុកានំ យទិទំ សកុលា ។

៩. ខិប្បាភិញ្ញានំ យទិទំ ភទ្ទា កុណ្ឌលកេសា ។

១០. បុព្វេនិវាសំ អនុស្សរន្តីនំ យទិទំ ភទ្ទា កបិលានី ។

១១. មហាភិញ្ញាបត្តានំ យទិទំ ភទ្ទា កច្ចានា ។

១២. លូខចីវរធរានំ យទិទំ កិសាគោតមី ។

១៣. សទ្ធាធិមុត្តានំ យទិទំ សិគាលមាតាតិ ។

វគ្គោ បញ្ចមោ ៚

* ឯតទគ្គំ ភិក្ខវេ មម សាវកានំ ឧបាសកានំ :

១. បឋមំ សរណំ គច្ឆន្តានំ យទិទំ តបុស្សភល្លិកា វាណិជា ។

២. ទាយកានំ យទិទំ សុទត្តោ គហបតិ អនាថបិណ្ឌិកោ ។

៣. ធម្មកថិកានំ យទិទំ ចិត្តោ គហបតិ មច្ឆិកសណ្ឌិកោ ។

៤. ចតូហិ សង្គហវត្ថូហិ បរិសំ សង្គណ្ហន្តានំ យទិទំ





ហត្ថកោ អាឡវកោ ។

៥. បណីតទាយកានំ យទិទំ មហានាមោ សក្កោ ។

៦. មនាបទាយកានំ យទិទំ ឧគ្គោ គហបតិ វេសាលិកោ ។

៧. សង្ឃុបដ្ឋាកានំ យទិទំ ឧគ្គតោ គហបតិ ។

៨. អវេច្ចប្បសន្នានំ យទិទំ សូរោ អម្ពដ្ឋោ ។

៩. បុគ្គលប្បសន្នានំ យទិទំ ជីវកោ កោមារភច្ចោ ។

១០. វិស្សាសកានំ យទិទំ នកុលបិតា គហបតីតិ ។

វគ្គោ ឆដ្ឋោ ៚

* ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ឧបាសិកានំ :

១. បឋមំ សរណំ គច្ឆន្តីនំ យទិទំ សុជាតា សេនានិធីតា ។

២. ទាយិកានំ យទិទំ វិសាខា មិគារមាតា ។

៣. ពហុស្សុតានំ យទិទំ ខុជ្ជុត្តរា ។

៤. មេត្តាវិហារីនំ យទិទំ សាមាវតី ។

៥. ឈាយិនីនំ យទិទំ ឧត្តរា នន្ទមាតា ។

៦.បណីតទាយិកានំ យទិទំ សុប្បវាសា កោ-លិយធីតា ។

៧.គិលានុបដ្ឋាកីនំ យទិទំ សុប្បិយា ឧបាសិកា ។

៨.អវេច្ចប្បសន្នានំ យទិទំ កាតិយានី ។

៩.វិស្សាសិកានំ យទិទំ នកុលមាតា គហបតានី ។

១០.អនុស្សវប្បសន្នានំ យទិទំ កាលី ឧបាសិកា កុររឃរិកា ។

វគ្គោ សត្តមោ ២

# ស្រុកកំណើតនៃឯតទគ្គបុគ្គល

## ភិក្ខុ ៤១ អង្គ

១.ព្រះអញ្ញាកោណ្ឌញ្ញៈ ឯតទគ្គៈលើភិក្ខុទាំងឡាយខាងរត្តញ្ញូ ។ លោកកើតក្នុងត្រកូលព្រាហ្មណមហាសាល ស្រុកទោណវត្ថុ មិនឆ្ងាយពីក្រុងកបិលពស្តុ ។

២.ព្រះសារីបុត្ត ឯតទគ្គៈខាងមានបញ្ញាច្រើន ។ លោកកើតក្នុងត្រកូលព្រាហ្មណមហាសាល ស្រុកនាលន្ទា មិនឆ្ងាយពី





ក្រុងរាជគ្រឹះ ។

៣.ព្រះមហាមោគ្គល្លាន ឯតទគ្គៈខាងមានឫទ្ធិ ។ លោកកើតក្នុងត្រកូលព្រាហ្មណមហាសាល ស្រុកនាលន្ទា មិនឆ្ងាយពីក្រុងរាជគ្រឹះ ។

៤.ព្រះមហាកស្សបៈ ឯតទគ្គៈខាងការទ្រទ្រង់ធុតង្គនិងការពោលសរសើរគុណនៃធុតង្គ ។ លោកកើតក្នុងត្រកូលព្រាហ្មណ-មហាសាល ស្រុកព្រាហ្មណ៍ឈ្មោះមហាតិត្ថៈ ក្នុងនគរមគធៈ ។

៥.ព្រះអនុរុទ្ធ ឯតទគ្គៈខាងមានទិព្វចក្ខុ ។ លោកកើតក្នុងសក្យត្រកូល នាក្រុងកបិលពស្តុ ។ បិតារបស់លោកព្រះនាម **អមិតោទនៈ**ត្រូវជាប្អូនបង្កើតរបស់ព្រះបាទ **ស្រីសុទ្ធោទនៈ** ពុទ្ធបិតា។

៦.ព្រះភទ្ទិយកាឡិគោធាបុត្ត ឯតទគ្គៈខាងកើតក្នុងត្រកូលខ្ពង់ខ្ពស់ ។ លោកកើតក្នុងខត្តិយត្រកូល នាក្រុងកបិលពស្តុ ។

៧.ព្រះលកុណ្ឌកភទ្ទិយៈ ឯតទគ្គៈខាងមានសំឡេងពីរោះ ។ លោកកើតក្នុងត្រកូលអ្នកមានទ្រព្យច្រើន ក្នុងក្រុងសាវត្ថី ។

៨.ព្រះបិណ្ឌោលភារទ្វាជៈ ឯតទគ្គៈខាងការបន្លឺសីហនាទ។ លោកកើតក្នុងត្រកូលព្រាហ្មណមហាសាល នៅក្រុងរាជគ្រឹះ ។

៩.ព្រះបុណ្ណមន្តានីបុត្ត ឯតទគ្គៈខាងការសម្តែងធម៌ ។ លោកកើតក្នុងត្រកូលព្រាហ្មណមហាសាល ស្រុកទោណវត្ថុ មិន

ឆ្ងាយពីក្រុងកបិលពស្តុ ។ មាតារបស់លោកមាននាមថា **មន្តានី** ជាប្អូនស្រីបង្កើតរបស់ព្រះអញ្ញាកោណ្ឌញ្ញៈ ។

១០-ព្រះមហាកច្ចាយនៈ ឯតទគ្គៈខាងការចែកអត្ថនៃភាសិតដោយសង្ខេបឱ្យពិស្តារ ។ លោកកើតក្នុងត្រកូលព្រាហ្មណ៍ បិតាជាបុរោហិតក្នុងនគរឧជ្ជេនី ។

១១-ព្រះចូឡបន្ថកៈ ឯតទគ្គៈខាងការនិម្មិតកាយឱ្យសម្រេចតាមចិត្តផង ខាងការឆ្លាតក្នុងចេតោវិវដ្តៈផង ។ លោកកើតក្នុងផ្ទៃម្តាយដែលជាធនសេដ្ឋីធីតាក្រុងរាជគ្រឹះ ឯឪពុករបស់លោកធ្លាប់ជាទាសៈក្នុងផ្ទះធនសេដ្ឋីនោះឯង ។

១២-ព្រះមហាបន្ថកៈ ឯតទគ្គៈខាងការឆ្លាតក្នុងបញ្ញាវិវដ្តៈ។ លោកជាបងបង្កើតរបស់ព្រះចូឡបន្ថកៈ មាតាបិតាជាមួយគ្នា ។

១៣-ព្រះសុភូតិ ឯតទគ្គៈខាងការនៅដោយឥតកិលេសផង ខាងការគួរដល់ទក្ខិណាទានផង ។ លោកកើតក្នុងត្រកូលសុមនសេដ្ឋី ក្នុងក្រុងសាវត្ថី ត្រូវជាប្អូនបង្កើតរបស់អនាថបិណ្ឌិកសេដ្ឋី ។

១៤-ព្រះរេវតខទិរវនិយៈ ឯតទគ្គៈខាងការនៅក្នុងព្រៃ ។ លោកកើតក្នុងត្រកូលព្រាហ្មណមហាសាល ជាប្អូនបង្កើតរបស់ព្រះសារីបុត្ត នៅស្រុកនាលន្ទា ជាប់ក្រុងរាជគ្រឹះ ។

១៥-ព្រះកង្ខារេវតៈ ឯតទគ្គៈខាងការបានឈាន ។ លោក





កើតក្នុងត្រកូលអ្នកមានទ្រព្យច្រើន ក្នុងក្រុងសាវត្ថី ។

១៦-ព្រះសោណកោឡិវិសៈ ឯតទគ្គៈខាងការប្រារព្ធព្យាយាម ។ លោកកើតក្នុងត្រកូលឧសភសេដ្ឋី ក្នុងនគរកាលចម្បាក ។

១៧-ព្រះសោណកុដិកណ្ណៈ ឯតទគ្គៈខាងមានវាចាពីរោះ ។ លោកកើតក្នុងផ្ទៃនៃស្ត្រីមេផ្ទះឈ្មោះកាឡី ក្នុងក្រុងរាជគ្រឹះ ។ លោកប្រសូតក្នុងរាត្រី ថ្ងៃដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ព្រះធម្មចក្កប្បវត្តនសូត្រ។ ពេលដែលលោកប្រសូត មាតារបស់លោកក៏បានសម្រេចសោតាបត្តិផលផងដែរ ព្រោះបានស្តាប់ព្រះធម៌ដែលសាតាគីរីយក្ខ សម្តែងឱ្យហេមវតយក្ខស្តាប់ នៅឰដ៏អាកាសចំពីលើដំបូលផ្ទះរបស់ខ្លួន នាក្រុងរាជគ្រឹះហ្នឹងឯង ។ ឧបាសិកាកាឡីមានប្តីទៅនៅឯកុលឃរនគរ តែមកប្រសូតបុត្រនៅស្រុករបស់ខ្លួន ។

១៨-ព្រះសីវលី ឯតទគ្គៈខាងមានលាភ ។ លោកកើតក្នុងខត្តិយត្រកូលនៃនគរកុណ្ឌិយា ។ ព្រះមាតារបស់លោកមានព្រះនាមថាសុប្បវាសាកោលិយធីតា ជាសោតាបន្នបុគ្គល ។

១៩-ព្រះវក្កលិ ឯតទគ្គៈខាងការបង្អោនចិត្តទៅដោយសទ្ធាជឿស៊ប់ ។ លោកកើតក្នុងត្រកូលព្រាហ្មណ៍ក្រុងសាវត្ថី ។

២០-ព្រះរាហុល ឯតទគ្គៈខាងមានបំណងប្រាថ្នាក្នុងការ

សិក្សា ។ លោកកើតក្នុងសក្យត្រកូល នគរកបិលពស្តុ ។

២១-ព្រះរដ្ឋបាល ឯតទគ្គៈខាងការសាងផ្នួសដោយសទ្ធា ។ លោកកើតក្នុងត្រកូលរដ្ឋបាលសេដ្ឋី ក្នុងនគរកុរុ ។

២២-ព្រះកុណ្ឌធាន ឯតទគ្គៈខាងការចាប់ស្លាកបានមុន ។ លោកកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី ។

២៣-ព្រះវង្គីសៈ ឯតទគ្គៈខាងមានបដិភាណ (បដិភាណក្នុងការពោលគាថាជាសុភាសិត ) ។ លោកកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី ។

២៤-ព្រះឧបសេនវង្គន្តបុត្ត ឯតទគ្គៈខាងការនាំសេចក្ដីជ្រះថ្លាមកដល់ជនទាំងពួង ។ លោកកើតក្នុងត្រកូលព្រាហ្មណ-មហាសាល ស្រុកនាលន្ទា នគរមគធៈ ត្រូវជាប្អូនប្រុសរបស់ព្រះ-សារីបុត្ត ។

២៥-ព្រះទព្វមល្លបុត្ត ឯតទគ្គៈខាងការចាត់ចែងសេនា-សនៈ ។ លោកកើតក្នុងត្រកូលមល្លក្សត្រ ក្នុងអនុបិយនគរ ។

២៦-ព្រះបិលិន្ទវច្ឆៈ ឯតទគ្គៈខាងជាទីស្រឡាញ់ពេញចិត្តនៃពួកទេវតា ។ លោកកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី ។

២៧-ព្រះពាហិយទារុចិរិយៈ ឯតទគ្គៈខាងការត្រាស់ដឹងដោយឆាប់រហ័ស ។ លោកកើតក្នុងត្រកូលអ្នកជំនួញក្នុងនគរ





ពាហិយៈ ។

២៨-ព្រះកុមារកស្សបៈ ឯតទគ្គៈខាងការសម្ដែងធម៌ដ៏វិចិត្រ ។ លោកបដិសន្ធិក្នុងផ្ទៃនៃស្រីម្នាក់ក្នុងក្រុងរាជគ្រឹះ ប៉ុន្តែនៅពេលលោកប្រសូត មាតារបស់លោក បានបួសជាភិក្ខុនីទៅហើយ ។ លោកប្រសូតក្នុងសំណាក់ភិក្ខុនីនានគរសាវត្ថី ព្រះបាទបសេនទិកោសល ទ្រង់ទទួលយកទារកនោះទៅចិញ្ចឹម ។

២៩-ព្រះមហាកោដ្ឋិតៈ ឯតទគ្គៈខាងការបានសម្រេចចាក់-ធ្លុះនូវបដិសម្ភិទា ៤ ។ លោកកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី ។

៣០-ព្រះអានន្ទ ឯតទគ្គៈ ៥ មុខគឺ

(១)-ពហុស្សូត (រៀនច្រើន ស្ដាប់ច្រើន )

(២)-ការមានសតិ (ស្មារតីក្នុងការងារគ្រប់យ៉ាង )

(៣)-ការមានគតិ (ញាណគតិ )

(៤)-ការមានធិតិ (ការអត់ធន់និងព្យាយាម )

(៥)-ការឧបដ្ឋាក (ការបម្រើព្រះពុទ្ធ )

លោកកើតក្នុងសក្យត្រកូល នាក្រុងកបិលពស្តុ។ បិតារបស់ព្រះអានន្ទព្រះនាម **សុក្កោទនៈ** ត្រូវជាប្អូនបង្កើតរបស់ព្រះបាទ **ស្រីសុទ្ធោទនៈ** ពុទ្ធបិតា ។

៣១.ព្រះឧរុវេលកស្សបៈ ឯតទគ្គៈខាងមានបរិស័ទច្រើន ។ លោកកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងនគរមគធៈ ។

៣២.ព្រះកាឡុទាយី ឯតទគ្គៈខាងការធ្វើឱ្យត្រកូលមានសេចក្ដីជ្រះថ្លា ។ លោកកើតក្នុងត្រកូលអាមាត្យ នាក្រុងកបិលពស្ដុ ។ លោកប្រសូតក្នុងថ្ងៃដែលព្រះសិទ្ធត្ថបរមពោធិសត្វទ្រង់បានប្រសូត ទាំងព្រះបរមពោធិព្រឹក្សក៏ដុះក្នុងថ្ងៃនោះដែរ...។

៣៣.ព្រះពក្កុលៈ ឯតទគ្គៈខាងមានអាពាធតិច ។ លោកកើតក្នុងត្រកូលសេដ្ឋី ក្រុងកោសម្ពី ។ កាលនៅពីទារក គេនាំយកទៅងូតទឹកទន្លេ **យមុនា** ត្រូវត្រីលេបនាំទៅដល់នគរពារាណសី បានលោកសេដ្ឋីមានទ្រព្យ ៨០ កោដិ ទទួលយកបានអំពីពោះត្រីនោះ ហើយចិញ្ចឹមប្រកបដោយសេចក្ដីស្រឡាញ់ ។ ក្រោយមកសេដ្ឋីបិតាបង្កើតក៏បានរកកូនឃើញ ។ ព្រះរាជាសម្រេចឱ្យជាមាតាបិតាទាំង ២ ត្រកូល ។

៣៤.ព្រះសោភិតៈ ឯតទគ្គៈខាងការរលឹកជាតិមុនបាន ។ លោកកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី ។

៣៥.ព្រះឧបាលី ឯតទគ្គៈខាងការទ្រទ្រង់នូវព្រះវិន័យ ។ លោកកើតក្នុងត្រកូលអ្នកកាត់សក់ នៅនគរកបិលពស្ដុ ។ លោកជាខ្ជាន់ព្រះកេសនៃសក្យត្រកូល ។



៣៦.ព្រះនន្ទកៈ ឯតទគ្គៈខាងការឱ្យឱវាទដល់ពួកភិក្ខុនី ។ លោកកើតក្នុងត្រកូលអ្នកក្រុងសាវត្ថី ។

៣៧.ព្រះនន្ទ ឯតទគ្គៈខាងការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ។ លោកកើតក្នុងព្រះគភ៌នៃព្រះនាងមហាបជាបតិ-គោតមី នាក្រុងកបិលពស្ដុ ។ ព្រះបិតារបស់លោកគឺព្រះបាទ**ស្រីសុទ្ធោទនៈ** ពុទ្ធបិតា ។

៣៨.ព្រះមហាកប្បិន ឯតទគ្គៈខាងការឱ្យឱវាទដល់ពួកភិក្ខុ ។ លោកកើតក្នុងខត្តិយត្រកូល នៃនគរកុក្កុដវតី បច្ចន្ត-ប្រទេស ។ ក្រោយមកលោកបានសោយរាជ្យ មានអគ្គមហេសី គឺព្រះនាងអនោជាទេវី ។ ពេលមួយបានដឹងដំណឹងតាមអ្នករទេះថា ព្រះពុទ្ធបរមគ្រូបានត្រាស់ ឥឡូវព្រះអង្គទ្រង់ប្រថាប់គង់នៅក្រុងសាវត្ថី ព្រះមហាកប្បិនក៏បានចេញបួសមួយអន្លើដោយពួកអាមាត្យ ១.០០០ នាក់ក្នុងគ្រានោះឯង ។

៣៩.ព្រះសាគតៈ ឯតទគ្គៈខាងការឆ្លាតក្នុងការចូលតេជោ-ធាតុ ។ លោកកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី ។

៤០.ព្រះរាធៈ ឯតទគ្គៈខាងការឈ្លាសវៃក្នុងបដិភាណ (អាចពោលធម៌តាមព្រះដ៏មានព្រះភាគបាន នៅពេលដែលព្រះអង្គ

សម្តែងចប់ហើយនោះ ព្រោះលោកបានយល់ច្បាស់ក្នុងព្រះធម៌ )។ លោកកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងរាជគ្រឹះ ។

៤១.ព្រះមោឃរាជ ឯតទគ្គៈខាងការទ្រទ្រង់ចីវរសៅហ្មង។ លោកកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី ។

## ភិក្ខុនី ១៣ អង្គ

១.ព្រះនាងមហាបជាបតិគោតមី ឯតទគ្គៈលើភិក្ខុនីទាំង-ឡាយខាងរត្តញ្ញូ ។ ព្រះនាងកើតក្នុងកោលិយវង្ស ក្នុងក្រុងទេវទហៈ ជាប្អូនស្រីបង្កើតរបស់ **ព្រះមហាមាយាទេវី** ពុទ្ធមាតា ។

២.ព្រះនាងខេមា ឯតទគ្គៈខាងមានបញ្ញា ។ ព្រះនាងកើតក្នុងព្រះរាជត្រកូល ក្នុងសាគលនគរ ។ លុះដល់ព្រះនាងពេញវ័យក៏បានមកជាព្រះអគ្គមហេសីនៃព្រះបាទពិម្ពិសារ នគរ មគធៈ ។

៣.ព្រះនាងឧប្បលវណ្ណា ឯតទគ្គៈខាងមានឫទ្ធិ ។ ព្រះនាងកើតក្នុងត្រកូលសេដ្ឋី ក្នុងក្រុងសាវត្ថី ។

៤.ព្រះនាងបដាចារា ឯតទគ្គៈខាងការទ្រទ្រង់ព្រះវិន័យ ។ ព្រះនាងកើតក្នុងត្រកូលសេដ្ឋី ក្រុងសាវត្ថី ។

៥.ព្រះនាងធម្មទិន្នា ឯតទគ្គៈខាងការសម្តែងធម៌ ។ ព្រះនាងកើតក្នុងត្រកូលសេដ្ឋី ក្រុងរាជគ្រឹះ ។



៦.ព្រះនាងនន្ទា ឯតទគ្គៈខាងការចូលឈាន ។ ព្រះនាងកើតក្នុងផ្ទៃនៃព្រះនាងមហាបជាបតិគោតមី នៅក្រុងកបិលពស្តុ។ ព្រះបាទ **ស្រីសុទ្ធោទនៈ** ជាព្រះបិតា ឯព្រះនន្ទជាបងប្រុសបង្កើត ។

៧.ព្រះនាងសោណា ឯតទគ្គៈខាងការប្រារព្ធសេចក្តីព្យាយាម ។ ព្រះនាងកើតក្នុងត្រកូលសេដ្ឋី ក្រុងសាវត្ថី ។

៨.ព្រះនាងសកុលា ឯតទគ្គៈខាងមានទិព្វចក្ខុ ។ ព្រះនាងកើតក្នុងត្រកូលព្រាហ្មណមហាសាល ក្រុងសាវត្ថី ។

៩.ព្រះនាងភទ្ទាកុណ្ឌលកេសា (ហៅព្រះនាងកុណ្ឌលកេសីក៏មានដែរ ) ឯតទគ្គៈខាងការត្រាស់ដឹងដោយឆាប់រហ័ស ។ ព្រះនាងកើតក្នុងត្រកូលសេដ្ឋី ក្រុងរាជគ្រឹះ ។

១០.ព្រះនាងភទ្ទាកបិលានី (ហៅព្រះនាងភទ្ទកាបិលានីក៏មានដែរ ) ឯតទគ្គៈខាងការដឹងជាតិមុន ។ ព្រះនាងកើតក្នុងត្រកូលព្រាហ្មណ៍កោសិយគោត្រ ក្នុងសាគលនគរ ដែនមទ្ទៈ ។ មុននឹងចេញបួសព្រះនាងជាភរិយា ដោយគ្រាន់តែរៀបការមកនៅជាមួយបិប្ផលិមាណព ក្នុងនគរមគធៈ ដោយអ្នកទាំងពីរមិនមានរាគៈជាមួយគ្នាឡើយ ។

១១.ព្រះនាងភទ្ទាកច្ចានា ឯតទគ្គៈខាងការបានសម្រេចនូវមហាភិញ្ញា គឺអភិញ្ញាដ៏ធំ ។ ព្រះនាងរលឹកជាតិក្នុងពេលតែមួយ

លើកបាន ១ អសង្ខេយ្យ កម្រៃ ១ សែនកប្ប ។ ព្រះនាងជាបុត្រីនៃព្រះបាទសុប្បពុទ្ធ នគរទេវទហៈ និងជាព្រះមាតានៃព្រះរាហុល ។

១២.ព្រះនាងកីសាគោតមី ឯតទគ្គៈខាងការទ្រទ្រង់ចីវរសៅហ្មង ។ ព្រះនាងកើតក្នុងត្រកូលអ្នកក្រសម្បត្តិ ក្រុងសាវត្ថី ប៉ុន្តែក្រោយមកនាងបានគ្រប់គ្រងសម្បត្តិ ៤០ កោដិកហាបណៈ ក្នុងត្រកូលខាងប្តី ។

១៣.ព្រះនាងសិគាលមាតា (ហៅព្រះនាងសិង្គាលមាតាក៏មាន ) ឯតទគ្គៈ ខាងការបង្អោនចិត្តទៅដោយសទ្ធាជឿស៊ប់ ។ ព្រះនាងកើតក្នុងត្រកូលសេដ្ឋី ក្រុងរាជគ្រឹះ ។

## ឧបាសក ១១ នាក់

១.តបុស្សៈ និងភល្លិកៈ បងប្អូនពាណិជទាំងពីរនាក់នេះ ឯតទគ្គៈលើឧបាសកទាំងឡាយខាងការដល់នូវសរណៈ(ព្រះពុទ្ធនិងព្រះធម៌ ) មុនគេ ។ គាត់កើតក្នុងត្រកូលកុដុម្ពិកៈ ក្នុងអសិតញ្ជននគរ (បានឮមកថា ជាប្រទេសភូមាសព្វថ្ងៃ ) ។ អ្នកទាំងពីរបានទទួលផ្ទាល់ពីព្រះដ៏មានព្រះភាគនូវព្រះកេសាធាតុ ៨ សរសៃដាក់ក្នុងប្រអប់មាស មកកសាងព្រះចេតិយឯនគររបស់ខ្លួន ។



២.សុទត្តអនាថបិណ្ឌិកសេដ្ឋី ឯតទគ្គៈខាងការថ្វាយទាន ។ គាត់កើតក្នុងត្រកូលសុមនសេដ្ឋី ក្រុងសាវត្ថី ។

៣.ចិត្តគហបតី ឯតទគ្គៈខាងការសម្តែងធម៌ ។ គាត់កើតក្នុងត្រកូលសេដ្ឋី ស្រុកមច្ឆិកសណ្ឌៈ (កន្លែងខ្លះថាមច្ឆិកាសណ្ឌៈ ) ក្នុងដែនដីនគរមគធៈ ។

៤.ហត្ថកអាឡវកៈ ឯតទគ្គៈខាងការសង្គ្រោះបរិស័ទដោយសង្គហវត្ថុ ៤ យ៉ាង។ ទ្រង់ប្រសូតក្នុងព្រះរាជត្រកូល ក្រុងអាឡវី។

៥.សក្យមហានាម ឯតទគ្គៈខាងការថ្វាយទានដ៏ប្រណីត (បានដល់ភោជនដែលមានរសប្រណីត ) ។ ទ្រង់កើតក្នុងសក្យត្រកូល ក្រុងកបិលពស្តុ ។

៦.ឧគ្គគហបតីអ្នកស្រុកវេសាលី ឯតទគ្គៈខាងការឱ្យរបស់ជាទីពេញចិត្ត (គឺតាមការពេញចិត្តរបស់គាត់ ) ។ គាត់កើតក្នុងត្រកូលសេដ្ឋី ក្រុងវេសាលី ។

៧.ឧគ្គតគហបតី ឯតទគ្គៈខាងការបម្រើសង្ឃ ។ គាត់កើតក្នុងត្រកូលសេដ្ឋី អ្នកស្រុកហត្ថិគ្រាម ។

៨.សូរអម្ពដ្ឋៈ ឯតទគ្គៈខាងការជ្រះថ្លាមិនកម្រើក ។ គាត់កើតក្នុងត្រកូលសេដ្ឋី (មិនប្រាកដនគរ ) ។

៩.ពេទ្យជីវកកោមារភច្ច ឯតទគ្គៈខាងមានសេចក្តីជ្រះថ្លា

ក្នុងបុគ្គល ។ គាត់កើតក្នុងផ្ទៃនៃស្ត្រីនគរសោភិនី ឈ្មោះសាលវតី នៅក្រុងរាជគ្រឹះ ។

១០.នកុលបិតា ឯតទគ្គៈខាងការស្និទ្ធស្នាល (ជាមួយនឹងព្រះសម្មាសម្ពុទ្ធ ) ។ គាត់កើតក្នុងត្រកូលសេដ្ឋី នគរសុំសុមារគិរីដែនភគ្គៈ ។

## ឧបាសិកា ១០ នាក់

១.នាងសុជាតាសេនិយធីតា ឯតទគ្គៈលើឧបាសិកាទាំងឡាយខាងការដល់ព្រះត្រៃសរណៈមុនគេ នាងកើតក្នុងត្រកូលកុដុម្ពិកៈឈ្មោះសេនីយៈ ក្នុងតំបន់ឧរុវេលាសេនានិគម នគរមគធៈ ។

២.នាងវិសាខាមិគារមាតា ឯតទគ្គៈខាងការថ្វាយទាន ។ នាងកើតក្នុងត្រកូលមហាសេដ្ឋី ក្នុងភទ្ទិយនគរ ដែនអង្គៈ ។ នាងអាស្រ័យផ្ទៃនាងសុមនទេវីភរិយារបស់ធនញ្ជ័យសេដ្ឋី ។ ក្រោយមកគ្រួសារនាងបានទទួលការអញ្ជើញពីព្រះបាទបសេនទិកោសល មករស់នៅស្រុកសាកេត ចម្ងាយ ៧ យោជន៍ពីក្រុងសាវត្ថី ។ លុះដល់នាងមានប្តី បានមកនៅនឹងត្រកូលខាងប្តីឯក្រុងសាវត្ថី ។



៣.នាងខុជ្ជុត្តរា ឯតទគ្គៈខាងពហុស្សូត ។ នាងកើតក្នុងផ្ទៃមេដោះក្នុងផ្ទះឃោសកសេដ្ឋី នគរកោសម្ពី ។ នាងជាអ្នកបម្រើនាងសាមាវតីបុត្រីធម៌របស់ឃោសកសេដ្ឋី រហូតមកកាន់ព្រះរាជវាំងនៃព្រះបាទឧទេន ។

៤.នាងសាមាវតី ឯតទគ្គៈខាងការនៅដោយមេត្តា ។ នាងកើតក្នុងត្រកូលភទ្ទវតិយសេដ្ឋី ក្នុងនគរភទ្ទវតីយ៍ ។ នាងមានពណ៌សម្បុរមាស ទើបឈ្មោះថា សាមាវតី ទាំងរូបរាងក៏ស្អាត ។ ក្រោយមកក៏បានជាអគ្គមហេសីនៃព្រះបាទឧទេន នគរកោសម្ពី ។

៥.នាងឧត្តរានន្ទមាតា ឯតទគ្គៈខាងការចូលឈាន ។ នាងកើតក្នុងផ្ទៃនៃភរិយារបស់នាយបុណ្ណៈ ក្រុងរាជគ្រឹះ ។ ក្រោយមកបានឡើងជាសេដ្ឋីក្នុងព្រះនគរមគធៈ អាស្រ័យបុណ្យឱ្យផលក្នុងបច្ចុប្បន្ន ។

៦.នាងសុប្បវាសាកោលិយធីតា ឯតទគ្គៈខាងការថ្វាយទានដ៏ប្រណីត (បានដល់ភោជនដែលមានរសប្រណីត ) ។ ព្រះនាងកើតក្នុងខត្តិយត្រកូលក្នុងកោលិយនគរ ។ ព្រះនាងជាព្រះមាតានៃព្រះសីវលី ដែលលោកជាឯតទគ្គៈលើភិក្ខុទាំងឡាយផ្នែកខាងមានលាភ ។

៧.សុប្បិយា ឯតទគ្គៈខាងការបម្រើព្រះសង្ឃមានអាពាធ។

នាងកើតក្នុងត្រកូលធម្មតាមួយនៃនគរពារាណសី ។

៨-នាងកាតិយានី ឯតទគ្គៈខាងការជ្រះថ្លាមិនកម្រើក ។ នាងកើតក្នុងត្រកូលធម្មតាមួយដែរ ក្នុងកុលឃរនគរ (កុររឃរ-នគរ) ក្នុងដែនអវន្តីជនបទ ។

៩-នាងនកុលមាតា ឯតទគ្គៈខាងការស្និទ្ធស្នាល (ជាមួយនឹងព្រះសម្មាសម្ពុទ្ធ )។ នាងកើតក្នុងត្រកូលសេដ្ឋី នគរសុំសុមារ-គិរី ដែនភគ្គៈ ។

១០-នាងកាឡីឧបាសិកានៅនគរកុររឃរិកា ឯតទគ្គៈខាងការជ្រះថ្លាក្នុងការស្ដាប់តាមគេ ។ នាងកើតក្នុងត្រកូលធម្មតានៃក្រុងរាជគ្រឹះ ។ កាលចម្រើនវ័យហើយ នាងមានស្វាមីទៅនៅឯកុររឃរនគរ (កុលឃរនគរ) ដែលជានគរខាងប្ដី ។

***-កន្លែងសម្ដែងយមកបាដិហារ្យ** ប្រមាណ ២.៥០០ ម៉ែត្រពីវត្តជេតពន នៅជិតខ្លោងទ្វារក្រុងសាវត្ថីសម័យពុទ្ធកាល ។ មនុស្ស និងទេវតា បានឃើញយមកបាដិហារ្យ ព្រមទាំងបានស្ដាប់ព្រះធម៌ដែលព្រះពុទ្ធនិម្មិត ទូលសួរហើយ ។ មនុស្ស និងទេវតា បានអមតធម៌ក្នុងគ្រានោះប្រមាណ ២០ កោដិ ។



***-ផ្ទះលោកសេដ្ឋីអនាថបិណ្ឌិក** នៅជិតផ្ទះបុរោហិតបិតាអង្គុលិមាល គួរឱ្យទស្សនា ។

***-ទីវត្តបុព្វារាម** នៅខាងកើតក្រុងសាវត្ថីសម័យពុទ្ធកាល គួរឱ្យជ្រះថ្លា ពេលដែលនឹកដល់ម្ចាស់អ្នកកសាង ។

***-ទីវត្តរាជិការាម** នៅជាប់វត្តជេតពន ជាទីគង់នៅនៃភិក្ខុនីសង្ឃសម័យពុទ្ធកាល សាងដោយព្រះបាទបសេនទិកោសល ព្រះរាជានៃនគរសាវត្ថី ។

***-ទីដែនដីស្រូបភិក្ខុទេវទត្តនិងនាងចិញ្ចា** នៅជិតវត្តជេតពន ។

***-ស្ទឹងអចិរវតី** ប្រមាណបួនគីឡូម៉ែត្រទៅទិសខាងជើងឆៀងខាងកើតនៃវត្តជេតពន គួរឱ្យគយគន់នឹកទៅដល់សម័យពុទ្ធ-កាល ។ នាងបដាចារឆ្លងស្ទឹងនេះឯង កូននាងពីរនាក់ត្រូវស្លាប់ ។ វិឌូឌភៈព្រមទាំងកងពល ត្រូវទឹកជំនន់នៃស្ទឹងអចិរវតីនេះកួចនាំយកទៅ ហើយត្រូវស្លាប់ទៅនរក ព្រោះបានលើកទ័ពទៅប្រហារអ្នកសក្យវង្សក្រុងកបិលពស្តុ ។

# ធម្មនិយាម ៣០ របស់ព្រះពុទ្ធ
# គ្រប់ព្រះអង្គ

សូមក្រាបបង្គំប្រណម្យវន្ទា ឆ្ពោះព្រះភគវាពុទ្ធាបានត្រាស់
ធម្មនិយាមទំនៀមល្អល្អះ សាមសិបមុខច្បាស់ខ្ញុំសូមពណ៌នា ។
មួយរញ្ជួយភពជាតិគ្រប់ចុងក្រោយ បារមីនាំឱ្យដឹងពេលវេលា
ទ្រង់យាងកាន់ផ្ទៃស្មារតីល្អជា ដឹងខ្លួនគ្រប់គ្រាក្នុងគភ៌មាតា ។
ពីរគឺព្រះភក្ត្រវរលក្ខណ៍ក្នុងគភ៌ ស្ថិតស្ងាធីក្នុងធមីបវរកាយា
ព្រះភក្ត្របែរផ្ទុយពីខ្នងមាតា ឆ្ពោះផ្ទៃភ្លឺថ្លាមាតារំពៃ ។
បីតរិយាបថនៃព្រះមាតា ពេលគ្រប់មាសាសាស្តាចាកផ្ទៃ
មាតាទ្រង់ឈរខុសស្រីដទៃ ប្រសូតបុត្រថ្លៃហឫទ័យជ្រះថ្លា ។
បួនសួនឧទ្យានទីឋានប្រសូត ក្នុងព្រៃរហូតឈើស្រួតចេញផ្កា
ទេវតានិងមនុស្សថ្វាយសាធុការ ចក្រវាលបព្វតាខ្ទរខ្ទារអ៊ូអរ ។
ប្រាំព្រះប្រសូតចុះស្រួតយាងឈាន ប្រាំពីរជំហានឆ្ពោះទិសឧត្តរ
ត្រួតគ្រប់ទិសឋានក្លាហានបវរ ទើបបានបន្លឺបន្លឺសីហនាទ ។
ប្រាំមួយប្រមើលទតមើលនិមិត្ត ទេវទូតបួនពិតចិត្តគិតលះញាតិ
បុត្រកើតថ្ងៃណាថ្ងៃនោះទ្រង់ឃ្លាត ចិត្តឥតរវាតយាត្រាសាងផ្នួស ។



ប្រាំពីរធីរោផ្ដាច់បួរព្យាយាម ឥតមានទាក់ទាមក្នុងនាមអ្នកបួស
កំណត់វេលាមិនអាចតិចហួស ប្រាំពីរថ្ងៃនោះនឹងបានត្រាស់ដឹង ។
ប្រាំបីមហេសីគង់សោយបាយាស ក្នុងថ្ងៃបានត្រាស់ទ្រង់ច្បាស់ទីពឹង
បាយាសថាសមាសថ្វាយព្រះថ្ងៃហ្នឹង ហៅបាយត្រាស់ដឹងបានបុណ្យមហិមា ។
ប្រាំបួនជូនភ័ព្វទ្រង់ទ្រាប់ស្បូវភ្លាំង ក្លាយជាបល្ល័ង្កគង់តាំងភាវនា
នៅគល់ពោធិព្រឹក្សនាទិសបូព៌ា បល្ល័ង្កភគវាផុសគ្រាសាយ័ណ្ហ ។
ដប់គាប់ហឫទ័យអានាបាណៈ បរិកម្មប្រចក្សសតិដឹងទាន់
ខ្យល់ចេញខ្យល់ចូលចិត្តមូលមិនភាន់ ដំណើរជវ័នជាន់ឆ្លងកាមា ។
ដប់មួយជំនួយពីព្រះបារមី ផ្ចាញ់មារអប្រិយ៍ព្រមទាំងសេនា
ពុទ្ធប្បវត្តិត្រង់នេះអស្ចារ្យ បរិស័ទជ្រះថ្លាបាចផ្កាអភិសេក ។
ដប់ពីរមុនីអង្គទ្រង់សម្រេចញាណ ត្រៃវិជ្ជាមានទ្រង់ញាណអនេក
ពិសាខបុណ្ណមីកើតញាណប្លែក១ ពោធិញ្ញាណខ្ពស់ឯកកក្រើកធរណី ។
ដប់បីក្សត្រថ្លៃគង់ក្នុងមហាឋាន វិមុត្តិក្សេមក្សាន្តអស់ឋានប្រាំពីរ
សប្ដាហ៍ឋានមួយលើកស្ទួយស្ថានទី ចេតិយព្រះមុនីប្រាំពីរកន្លែង ។
ដប់បួនជូនព្រហ្មជុំអារាធនា សូមព្រះភគវាយាងត្រាស់សម្ដែង
ព្រះធមីប្រពៃវិស័យសូរ្យសែង ទ្រង់ព្រមសម្ដែងដោយព្រហ្មវិហារ ។
ដប់ប្រាំចាំច្បាស់ទ្រង់ត្រាស់ធម្មចក្ក ឥសិបតនៈព្រៃមិគទាយា
ឋានត្រៃរតនៈអាសាឡ្ហបូជា ថ្ងៃព្រះភគវាស្ថាបនាព្រះសង្ឃ ។
ដប់ប្រាំមួយទ្រង់គង់ត្រាស់ឱវាទ បាដិមោក្ខស្អាងស្អាតឱវាទផ្លូវផង
បេះដូងព្រះធមីពន្លឺចតុរង្គ ថ្ងៃនោះត្រូវត្រង់មាឃបុណ្ណមី ។

ដប់ប្រាំពីរទ្រង់គង់វត្តជេតពន ប្រោសដល់មហាជននិរន្តរ៍ប្រក្រតី
ទ្រង់យកអរុណជេតពនសួស្តី ជេតពនជិនស្រីអាស្រ័យជានិច្ច ។
ដប់ប្រាំបីទ្រង់សម្តែងបាដិហារ្យ យមកៈអស្ចារ្យនិគ្រន្ថរត់គេច
នៅក្រុងសាវត្ថីប្រុសស្រីមិនតិច នេះគឺពុទ្ធកិច្ចសង្គ្រោះលោកា ។
ដប់ប្រាំបួនទ្រង់គង់ឋានត្រ័យត្រិង្ស ត្រិះរិះរំពឹងថ្លឹងគុណមាតា
សម្តែងអភិធម្មស័ក្តិសមអស្ចារ្យ ថ្វាយព្រះមាតាសុខាអមតៈ ។
ម្ភៃគឺព្រះអង្គទ្រង់ចាកទេវលោក ស្តេចយាងចុះមកដែនសង្កស្សៈ
មហាជនច្រើនពិតយកចិត្តទុកដាក់ បូជាគារវៈអចលចេតិយ ។
ម្ភៃមួយគឺទ្រង់គង់ក្នុងសមាបត្តិ ព្រះញាណស្ងប់ស្ងាត់លះកាត់លោកិយ៍
អរហត្តផលតម្កល់ប្រក្រតី ឆាប់ក្តីយូរក្តីវិស័យពុទ្ធញ្ញាណ ។
ម្ភៃពីរប្រមើលមើលគ្រប់វេនេយ្យ ឧបនិស្ស័យសព្វសត្វដែលមាន
ដោយព្រះករុណាសមាបត្តិញ្ញាណ ត្រួតសត្វកោដិលានមានពីរវារៈ ។
ម្ភៃបីទ្រង់លៃវិន័យអាជ្ញា បញ្ញត្តសិក្ខាតាមការជ្រាបជាក់
មានរឿងកើតមុនខូចគុណសាវ័ក មានហេតុជាក់លាក់ទើបដាក់វិន័យ ។
ម្ភៃបួនអង្រួនហឫទ័យករុណា ជាតកទេសនាសាស្តាលកលៃ
ដើមរឿងជាហេតុបង្កើតអត្ថន័យ ជាតកប្រពៃលៃតាមហេតុការណ៍ ។
ម្ភៃប្រាំទ្រង់ប្រោសដល់ពួកព្រះញាតិ អង្គព្រះលោកនាថសម្តែងបាដិហារ្យ
កម្ចាត់មានះព្រះញាតិវង្សា ទើបត្រាស់ទេសនាគម្ពីរពុទ្ធវង្ស ។
ម្ភៃប្រាំមួយទ្រង់គង់ធ្វន់ក្នុងធម៌ បរិស័ទណាល្អមានធម៌ទ្រទ្រង់
ស្តេចយាងទទួលស្រុះស្រួលដោយអង្គ គារវៈផូរផង់ឆ្ពោះត្រង់ព្រះធម៌ ។



ម្ភៃប្រាំពីរទ្រង់គង់ចាំវស្សា បើមាននរណានិមន្តដោយល្អ
ពេលចេញវស្សាមុនយាងចេញចរ ទ្រង់ចម្រើនពរត្រាស់លាអ្នកនោះ ។
ម្ភៃប្រាំបីទ្រង់គង់យ៉ាងហ្មត់ចត់ មុនភត្តក្រោយភត្តគ្មានភ្លាត់ភ្លេចសោះ
បំពេញពុទ្ធកិច្ចគ្រប់យាមទាំងអស់ ពុទ្ធកិច្ចសង្គ្រោះមនុស្សនិងទេវតា ។
ម្ភៃប្រាំបួនទ្រង់គង់សោយមំសៈ ក្នុងថ្ងៃទ្រង់ដាក់អនុដ្ឋានកាយា
បិណ្ឌបាតចុងក្រោយជាទានថ្លៃថ្លា សោយរសមំសាហឫទ័យបរិសុទ្ធ ។
សាមសិបអវសានទ្រង់បានចូលឈាន មុននឹងនិព្វានឈានច្រើនបំផុត
ម្ភៃបួនសែនកោដិសមាបត្តិបរិសុទ្ធ រួចហើយទ្រង់ផុតរលត់សង្ខារ ។
អហើរីខ្ញុំបង្គំវន្ទា ឆ្ពោះព្រះភគវាព្រះធម៌ថ្លៃថ្លា
ព្រមទាំងព្រះសង្ឃផូរផង់សីលា ចិន្តាលំអុតព្រះពុទ្ធនិយាម ។
សូមឱ្យសព្វសត្វបដិបត្តិតាមធម៌ សាសនាបវរល្អដូចព្រះនាម
អរហំសម្មាគ្មានការទាក់ទាម កិលេសរវាមរវាតសូន្យបង់ ។
សូមឱ្យសាសនាសម្មាសម្ពុទ្ធ បរិស័ទមោះមុតរួមចិត្តទ្រទ្រង់
ឋិតថេរចិរកាលអភិបាលដោយសង្ឃ ព្រមព្រៀងស្មោះត្រង់ផ្ចិតផ្ចង់សិក្ខា ។
សូមមនុស្សទេវតាមានការគោរព ទាំងថ្ងៃទាំងយប់ក្នុងព្រះសាសនា
សូមបានសម្រេចដូចក្តីប្រាថ្នា អស់នូវតណ្ហាទុក្ខាចប់ហោង ។

ដោយ **ប.ស.វ.**

## ស្ថានធំនារីទ ៤

ក្នុងព្រះវិហារ នៅពុទ្ធគយា ព្រះអង្គមេត្តា
ព្រះភក្ត្រផូរផង់ ស្មោះត្រង់ចិន្តា បរិស័ទជ្រះថ្លា
បង្គំវន្ទា ។

ប្រជាកុះករ មូលមីរឈូឆរ ហួសនឹងពណ៌នា
ច្រើនជាតិច្រើនសាសន៍ ចុះចម្រុះគ្នា ចូលមកបូជា
មិនថាយប់ថ្ងៃ ។

ព្រះអង្គមេត្តា មិនដឹងជាងណា អ្នករចនាច្នៃ
គន់មើលព្រះភក្ត្រ ជាក់យល់ព្រះទ័យ បរិស័ទថ្លាថ្លៃ
គ្មានអ្វីទើសទាក់ ។

ព្រះអង្គមេត្តា ទោះថ្មយ៉ាងណា ហាក់មានជីវៈ
បង្កប់ជីវិត ពិតប្រាកដជាក់ គន់មើលព្រះភក្ត្រ
អ្នកគង់បានដឹង ។

បើអ្នកឯណា នឹងចរយាត្រា សូមជ្រាបដំណឹង
បានទៅដល់ហើយ អ្នកអើយរំពឹង គយគន់សម្លឹង
វង់ភក្ត្រផូរផង់ ។

ទីពុទ្ធគយា យើងមកវន្ទា ចិត្តឆ្ពោះតម្រង់
ទីដែលព្រះពុទ្ធ គ្រប់ៗព្រះអង្គ រុងរឿងបញ្ចង់



គ្រប់អង្គបានត្រាស់ ។

តែកុំភ្លេចឡើយ បុណ្យបានណាស់ហើយ បុណ្យរឹតតែក្រាស់
បានឃើញព្រះភក្ត្រ ចិត្តជ្រះស្រឡះ មេត្តាពិតណាស់
ព្រះអង្គមេត្តា ។

មួយទៀតជាក់ស្តែង ទីគួរស្ញប់ស្ញែង កុសិនារា
រូបព្រះនិព្វាន មានមែនសិលា ស្ថិតនៅកណ្តាល
ព្រះវិហារឥដ្ឋ ។

សម្លឹងព្រះរូប ដែលផ្ទំស្តឹងស្តូក ហាក់ដូចបានស្ថិត
ហាក់បានចូលរួម ពេលព្រះវិជិត ទ្រង់និព្វានពិត
ចិត្តរឹតសង្វេគ ។

ឥសិបតនះ សម្តែងធម្មចក្ក ក៏ជាទីឯក
ញ៉ាំងចិត្តបរិស័ទ ជ្រះថ្លាពន់ពេក ឥតមានរារែក
បូជាគាថា ។

មួយទៀតគ្រប់បួន គឺស្ថិតនៅសួន លុម្ពិនីនោះណា
ទីទ្រង់ប្រសូត ឈើស្រូតចេញផ្កា ជនគ្រប់ទិសា
បានមកជួបជុំ ។

សូត្រធម៌វន្ទា ចម្រុះជាតិគ្នា លាន់ឮរងំ
មិនថាជាតិណា សាសន៍ណាតូចធំ អ្នកមកជួបជុំ

គឺពុទ្ធបរិស័ទ ។

អ្នកមកបូជា ពេលជួបមុខគ្នា ញញឹមស្មៀមស្ងាត់
ទីស្ថានទាំងបួន មាំមួនពេកក្កាត់ ដែលព្រះអង្គចាត់
ជាទីសង្វេគ ។

អ្នកបានទៅដល់ បង្គំបានផល ពុំរង់ចាំស្អែក
សន្ទុះនៃចិត្ត ឥតមានអល់អែក ជ្រះថ្លាអនេក
ពិតស្នានពុំដល់ ។

ដោយឧបាសិកា **ជូ ស៊ុំហៀង**

## បានមកស្រុកព្រះ

បានមកស្រុកព្រះសប្បាយណាស់ ទាំងក្មេងទាំងចាស់គួរជ្រះថ្លា
អ្នកដែលធ្លាប់កាចប្រែរាបសា ខឹងខុសយ៉ាងណាចេះអត់ទ្រាំ ។
ព្រោះតែព្រះគុណបុណ្យបារមី នៃព្រះជិនស្រីប្រោសរៀបចំ
សម្តែងព្រះធម៌ដ៏ឧត្តម ដឹកនាំសត្វលោកឱ្យផុតភ័យ ។
ទោះជាបាត់អង្គព្រះទ្រង់ញាណ ស្តេចទ្រង់និព្វានទៅហើយក្តី
សល់តែព្រះស្តូបព្រះចេតិយ យើងខ្ញុំប្រុសស្រីសូមវន្ទា ។
សូមថ្វាយបង្គំព្រះពុទ្ធស្ថាន ដែលមានប៉ុន្មានឋាននានា
លង្កានេប៉ាល់ទាំងឥណ្ឌា យកជាពំនឹងពឹងតទៅ ។

ដោយឧបាសក **គុយ សុធន**





## នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
## ក្នុងការខារធម្មទាន

| | |
|---|---|
| ១. លោកគ្រូ រស់ សូផាត | ២. ឧបាសក យន្ត សួន |
| ៣. ឧបាសក គួង លាងផេង | ៤. ឧបាសក មូង យេន |
| ៥. ឧបាសក ជឹម ជំនិត | ៦. ឧបាសក អ៊ិត ប្រាំង |
| ៧. ឧបាសិកា ជា សុណារី | ៨. ឧបាសិកា ប៊ុត ម៉ាលី |
| ៩. ឧបាសក គុយ សុធន | ១០. ឧបាសក វ៉ាន់ ខុនណា |
| ១១. ឧបាសក សោម រតនៈ | ១២. ឧបាសក ជឹង វ៉េងអ៊ាវ |
| ១៣. ឧបាសក ង៉ូវ គា | ១៤. ឧបាសក ហាយ ចំរើន |
| ១៥. ឧបាសិកា ហួនចាន់បូដា | ១៦. ឧបាសិកា ស្រី បូរ៉ាន់ |
| ១៧. ឧបាសក គឹម សោភ័ណ | ១៨. ឧបាសក ម៉ៅ ផុន |
| ១៩. ឧបាសិកា ហាយច័ន្ទធរី | ២០. ឧបាសក ទូច គីមស្រ៊ាង |

## រាយនាមពុទ្ធបរិស័ទក្នុងសហគមន៍ធម្មនាន
## ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយព្រះធម៌ប្រចាំឆ្នាំ

១- ឧ.ស. យូស៊ាង ងួនលី និង ឧ.សិ. លីម ឃីម ............. ស.រ.អ.
២- ឧ.ស. ឆាយ អ៊ីវស៊ាង និង ឧ.សិ.ហុង គឹមសែ ......... ស.រ.អ.
៣- ឧ.ស. ឆាយអ៊ីវ ស្រេងលីម និង ឧ.សិ.ហួត ឃីម....... ស.រ.អ.
៤- ឧ.ស. ហៃ ប៊ុនណារិន និង ឧ.សិ.អោង ស៊ីថាន់ ......... ស.រ.អ.
៥- ឧ.ស. វង់ ម៉ៅ និង ឧ.សិ.ឆាន់ កាន់ជួង ព្រមទាំងបុត្រ. ស.រ.អ.
៦- ឧ.សិ. ឆាន់ ហៃគីង ព្រមទាំងបុត្រ និង ចៅ ........... ស.រ.អ.
